ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ [illegible]

◆ [illegible] ការផ្សះផ្សាជាតិ

[illegible]

លេខ៤៨ ខែ ធ្នូ ឆ្នាំ២០០៣

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៤៨ ខែធ្នូ ឆ្នាំ២០០៣

# មាតិកា

◆ សំបុត្រៈ តួនាទីរបស់ជនរងគ្រោះនៅក្នុងដំណើរការតុលាការ........១

**ផ្នែកឯកសារ**

◆ ឈូក ម៉ឹងម៉ៅ អធិការបឋមសិក្សា.................................... ៣

◆ មតិណែនាំរបស់៨៧០ ..................................................... ៨

◆ បទឧទ្ទេសនាមរបស់សមមិត្តផល........................................ ៩

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១..........១២

◆ ព្រឹត្តិការណ៍ខែមិថុនា ឆ្នាំ១៩៧៨......................................១៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ បដិវត្តន៍របស់ កិត កឿន..................................................១៧

◆ ខ្ញុំមិនបានទទួលអ្វីសោះពីបដិវត្តន៍.........................................២០

◆ តើនេះគឺជាការឃ្លានពានរបស់ខ្មែរក្រហម? ...........................២២

◆ បរាជ័យដោយការធ្វេសប្រហែស.......................................២៥

**ផ្នែកច្បាប់**

◆ អំពើឃោរឃៅរបស់ខ្មែរក្រហមក្រោមច្បាប់កម្ពុជា.................៤២

**វេទិកាពិភាក្សាសាធារណៈ**

◆ អន្តរទំនាក់ទំនងរវាងយុត្តិធម៌និងការផ្សះផ្សាជាតិ....................៤៩

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ខ្ញុំមិនដែលស្គាល់ភាពអត់ឃ្លាន...........................................៦០





**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ:** យិន នាន, ដេង ពង្សរ៉ាស៊ី, ជួង សុភារិទ្ធ, សារិន វីរៈ, ឆេង វើង, ឡុង ដានី, ហ្សាល់ កាការីយ៉ា, ឆាលី បូវីរ, ចេសុន ប្រាហាម **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, ផាត រចនា **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងៈ** សួ ប៊ុនស៊ូ **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

*សំបុត្រៈ*

# តួនាទីរបស់ជនរងគ្រោះនៅក្នុងដំណើរការតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

ទោះបីជាកាសែត ទូរទស្សន៍ វិទ្យុ អ៊ិនធឺណែត និងប្រព័ន្ធផ្សព្វផ្សាយពត៌មានផ្សេងៗផ្តល់នូវភាពងាយស្រួលដល់ប្រជាជនក្នុងការតាមដានពត៌មាននៅក្នុងទីក្រុងភ្នំពេញនិងខេត្តក្រុងទាំងឡាយនៃប្រទេសកម្ពុជាយ៉ាងណាក្តី ចំពោះប្រជាជនមួយភាគធំដែលរស់នៅក្នុងឃុំទាំង១៦២១ គឺមិនទាន់មានមធ្យោបាយគ្រប់គ្រាន់ពិតប្រាកដក្នុងការតាមដានពត៌មានអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនឹងបង្កើតឡើងក្នុងពេលដ៏ខ្លីខាងមុខនៅឡើយទេ ។

ការដឹងឮនិងឃើញដោយផ្ទាល់ភ្នែកអំពីសកម្មភាពទាមទារយុត្តិធម៌គឺជាកត្តាដ៏សំខាន់បំផុតនៃដំណើរការព្យាបាលរបួសផ្លូវចិត្តរបស់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ជីវិតប្រជាជនប្រមាណពីរលាននាក់ដែលបានបាត់បង់នៅក្នុងសម័យខ្មែរក្រហមមិនអាចស្រោចស្រង់មកវិញបានទេ ហើយឱកាសនៃការរស់នៅដោយសុខសាន្តក្នុងសង្គមមួយដែលអាចនឹងមានវិបុលភាពក្នុងករណីដែលខ្មែរក្រហមមិនបានឡើងកាន់អំណាចនោះក៏មិនមានដែរ ។ តុលាការខ្មែរក្រហមនឹងផ្តល់ដល់ជនរងគ្រោះនូវឱកាសមួយដើម្បីដឹងឮថាពិភពលោកទាំងមូលទទួលស្គាល់ចំពោះការរងទុក្ខវេទនារបស់ខ្លួន ហើយអតីតមេដឹកនាំនៃរបបខ្មែរក្រហមត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួននៅចំពោះមុខច្បាប់ ។

ចំណុចសំខាន់មួយទៀតនោះ គឺថាការទទួលបានពត៌មានអំពីតុលាការខ្មែរក្រហមដោយផ្ទាល់ភ្នែកនឹងផ្តល់ជាមធ្យោបាយមួយដល់សាធារណជនដើម្បីចាប់ផ្តើមរួមចំណែកនៅក្នុងដំណើរការកសាងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាដែលជាគោលដៅក្នុងការឈានសម្រេចឲ្យបាន ។

ប៉ុន្តែឱកាសសម្រាប់ប្រជាជនកម្ពុជាចូលរួមសង្កេតមើលដំណើរការទាមទារយុត្តិធម៌ដោយផ្ទាល់ភ្នែកមិនទាន់មានការធានាឲ្យបាននៅឡើយ ។ ដំហររាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញឲ្យឃើញថាពុំមានផែនការផ្លូវការឬមិនផ្លូវការណាមួយដើម្បីប្រាប់ដំណឹងអំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមដល់សាធារណជនឲ្យបានដឹងជាសាធារណៈទេ ក្រៅអំពីសេចក្តីប្រកាសពត៌មានតាមទម្រង់បច្ចុប្បន្ន ។ ចំណែកអង្គការសហប្រជាជាតិអាចមិនមានមធ្យោបាយហិរញ្ញវត្ថុឬនយោបាយដើម្បីផ្តល់តួនាទីមួយដល់ជនរងគ្រោះនៅក្នុងដំណើរការកាត់ទោសដែរ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសរសេរលិខិតមួយច្បាប់ថ្វាយព្រះមហាក្សត្ររៀបរាប់ថ្វាយព្រះអង្គជ្រាបអំពីបញ្ហានេះ ។ (ដោយចេតនាគាំទ្រ) ព្រះមហាក្សត្របានបញ្ជូនលិខិតនេះទៅកាន់រាជរដ្ឋាភិបាល រដ្ឋសភាជាតិ និងព្រឹទ្ធសភាដើម្បីសុំការពិនិត្យពិចារណា “ស្តីអំពីតួនាទីរបស់ប្រជារាស្ត្រក្នុងការជួយបំពេញភាពខ្វះចន្លោះនៃច្បាប់នៅក្នុងពេលដំណើរការកាត់សេចក្តីអំពីឧក្រិដ្ឋកម្មដែលកើតមាននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យរបស់តុលាការដែលនឹងបាត់តាំងឡើង ។ ខ្ញុំសូមផ្ញើលិខិតខាងលើជូនសម្តេចទាំងបី សូមព្រះមេត្តាពិនិត្យចំពោះករណីដែលលោក ឆាំង យុ បានលើកឡើងនេះ” ។ ប៉ុន្តែការគាំទ្រនេះអាចមិនគ្រប់គ្រាន់ដើម្បីបង្កឲ្យមានប្រតិកម្មនៅក្នុងមជ្ឈដ្ឋានសាធារណៈឡើយ ជាពិសេសសម្រាប់សាធារណជនដែលត្រូវបានរើសអើង ។

យោងតាមមូលហេតុខាងលើ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងរៀបចំឲ្យមានការអនុវត្តគម្រោងការមួយដែលធានាឲ្យបាននូវការចូលរួមពីជនរងគ្រោះនៅក្នុងអង្គតុលាការ ដោយជម្រើសឲ្យសមាជិកមួយរូបមកពីឃុំនីមួយៗទូទាំងប្រទេសចូលរួមវគ្គមួយនៃការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ តំណាងរូបនេះនឹងត្រឡប់ទៅកាន់ឃុំរបស់ខ្លួនវិញ ហើយដឹកនាំការពិភាក្សាជាសាធារណៈជាមួយអ្នកស្រុកនៅតាមភូមិដ្ឋានអំពីដំណើរការកាត់ទោស ។

គម្រោងការនេះនឹងមានសារប្រយោជន៍សំខាន់ៗចំនួនបួនគឺៈ

១) ជួយកសាងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាដោយអនុញ្ញាតឲ្យអ្នកចូលរួមធ្វើជាសាក្សីនិងចៅក្រមក្រៅ

តុលាការបន្តឲ្យមានការពិភាក្សាជាចំហ និងមានការចូលរួមច្រើន ធ្វើឲ្យប្រជាជនយល់អំពី«សិទ្ធិដឹងឮ»របស់ខ្លួន និងចាប់ផ្តើមពង្រីកចលនាប្រជាជនប្រជាធិបតេយ្យមួយដើម្បីទាមទារបន្ថែមនូវសេរីភាពសារព័ត៌មាន ។

២) ផ្តល់ឱកាសឲ្យតំណាងឃុំក្នុងការបញ្ចេញយោបល់ដឹកនាំការពិភាក្សា និងឆ្លើយទៅនឹងការចោទសួរពីអ្នកស្រុកនៅតាមភូមិឃុំ ដែលជាចំណែកមួយក្នុងការស្តាបនាអនាគតមេដឹកនាំថ្មី សម្រាប់ចូលរួមនៅក្នុងការបោះឆ្នោតឃុំសង្កាត់នាពេលខាងមុខ ។

៣) រួមចំណែកក្នុងការចងក្រងប្រវត្តិសាស្ត្រផ្ទាល់មាត់ (ប្រវត្តិសាស្ត្រដែលចងក្រងដោយការនិយាយបន្តពីមាត់មួយទៅមាត់មួយ) នៃរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈការជំរុញឲ្យអ្នកចូលរួមមកពីឃុំទាំងអស់រៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួននិងបញ្ចេញមតិ ។ ដោយសារតែមជ្ឈមណ្ឌលឯកសារកម្ពុជាមានផែនការចែកចាយទស្សនាវដ្តីស្វែងរកការពិត ដែលនឹងផ្សព្វផ្សាយព័ត៌មានអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅពេលដែលតុលាការនេះចាប់ផ្តើម(និងចេញផ្សាយអត្ថបទពាក់ព័ន្ធផ្សេងទៀត) និងចងក្រងជាភាពយន្តនូវការពិភាក្សាគម្រោងការនេះនឹងអនុញ្ញាតឲ្យអ្នកចូលរួមដឹងថាមានមនុស្សជាច្រើនចាប់អារម្មណ៍ចំពោះអ្វីដែលជនរងគ្រោះបរិយាយ ហើយដឹងថាខ្លួនមានតួនាទីសំខាន់នៅក្នុងគម្រោងការនេះ ។

៤) វេទិកាពិភាក្សានៅតាមភូមិនឹងជួយអ្នកនៅរស់រានមានជីវិតមកពីរបបខ្មែរក្រហមចងចាំឡើងវិញនូវព្រឹត្តិការណ៍ទាំងឡាយនៅក្នុងរបបខ្មែរក្រហមនិងដើម្បីប្រាប់បទពិសោធន៍នេះទៅក្មេងជំនាន់ក្រោយឲ្យបានដឹងយ៉ាងមានប្រសិទ្ធភាពបំផុត ។ ជាលទ្ធផលគម្រោងការនេះនឹងជួយពង្រឹងទំនៀមទម្លាប់និយាយតៗគ្នាពីមាត់មួយទៅមាត់មួយ ពីជំនាន់មួយទៅជំនាន់មួយទៀតរបស់ប្រជាជនកម្ពុជា ។

## ផលប្រយោជន៍យូរអង្វែង

ក្រោយពេលដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានបញ្ចប់ គម្រោងការនេះនឹងទ្រទ្រង់ខ្លួនឯងបានតាមរយៈការលើកទឹកចិត្ត និងធ្វើឲ្យមានការជឿទុកចិត្តខ្លួនឯង តាមរយៈការពិភាក្សាសាធារណៈ និងការហ្វឹកហ្វឺនខាងការដឹកនាំៈ

១) ការពិភាក្សានឹងបង្ហាញពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះ និងជនដៃដល់នៅក្នុងរបបខ្មែរក្រហម ។ ដោយធ្វើឲ្យមានការយល់កាន់តែច្បាស់ គម្រោងការនេះនឹងជំរុញឲ្យមានការផ្សះផ្សាជាតិ ដែលនាំទៅរកការអត់ឱន សន្តិភាព និងបង្កលទ្ធភាពក្នុងការធ្វើដំណើរទៅមុខពីថ្នាក់មូលដ្ឋាន ។

២) គម្រោងការនេះនឹងអប់រំសាធារណៈជនអំពីវិធាននៃច្បាប់និងវិធីប្រើប្រាស់ច្បាប់ ដើម្បីទាមទារឲ្យមានការគោរពកាន់តែខ្លាំងនូវជីវិតមនុស្សនៅក្នុងភូមិឃុំ ។



៣) ការផ្លាស់ប្តូរដោយសេរីនូវគំនិតនិងទស្សនៈនយោបាយ នៅក្នុងវេទិកាពិភាក្សាសាធារណៈ នឹងជួយអ្នកបោះឆ្នោតក្នុងការសម្រេចចិត្តនាពេលបោះឆ្នោត ឃុំសង្កាត់អាណត្តិក្រោយ ហើយប្រើប្រាស់គោលដៅប្រជាធិបតេយ្យ តម្លាភាព និងយុត្តិធម៌ជាបង្អែកនៃការសម្រេចចិត្ត ។

ខ្ញុំសង្ឃឹមថាគម្រោងការនេះនឹងជំរុញអ្នកចូលរួមឲ្យឈានជើងចូលក្នុងជីវិតសាធារណៈ ហើយយើងនឹងចាត់ទុកថាគម្រោងការនេះជោគជ័យ ប្រសិនបើតំណាងឃុំទាំងនេះក្លាយជាបេក្ខជនប្រកួតប្រជែងនៅក្នុងការបោះឆ្នោតឃុំសង្កាត់ ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# ឈូក ម៉ឹងម៉ៅ អធិការបឋមសិក្សា


ឈូក ម៉ឹងម៉ៅ

ឈូក ម៉ឹងម៉ៅ ជាអតីតអធិការបឋមសិក្សានៅខេត្តតាកែវ កំពង់ស្ពឺ កំពត និងស្វាយរៀង ។ ក្រោយមកគាត់ត្រូវបានតែងតាំងធ្វើជាទូតប្រចាំប្រទេសស៊ីស ហើយបានត្រឡប់ចូលមកស្រុកខ្មែរវិញក្នុងពេលដែលប្រទេសកម្ពុជាស្ថិតក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ ។ ចំពោះអ្នកដែលមានចំណេះដឹងខ្ពង់ខ្ពស់មិនថានៅខាងក្នុងឬនៅក្រៅប្រទេសទេ ត្រូវខ្មែរក្រហមសម្លាប់ចោលស្ទើរតែទាំងអស់ពីបទសង្ស័យថាក្បត់ឬប្រព្រឹត្តបទល្មើសផ្សេងៗប្រឆាំងនឹងបដិវត្តន៍ខ្មែរក្រហម ។ សាស្ត្រាចារ្យនិងនិស្សិតដែលបានវិលត្រឡប់មកមាតុភូមិវិញកម្រមានវាសនាបានរួចផុតពីការសម្លាប់ណាស់ ។ ឈូក ម៉ឹងម៉ៅ ក៏មានវាសនាមិនខុសពីអ្នកទាំងនោះដែរ ។

## ប្រវត្តិគ្រួសារ

ឈូក ម៉ឹងម៉ៅ កើតនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩២០ នៅភូមិកន្ទោ(ឬតៀមកន្ទោ) ឃុំកន្ទោ ស្រុកកំពង់ត្រាច ខេត្តកំពត ។ ឪពុកឈ្មោះ ឈូក ម៉ឹង ម្តាយឈ្មោះ អ៊ុក ហ៊ិន (កសិករ) ។ ម៉ឹងម៉ៅ មានប្អូនស្រីម្នាក់ឈ្មោះ ឈូក ប៉ុម (ជាកសិករស្ត្រីមេម៉ាយ) និងប្អូនប្រុសម្នាក់ឈ្មោះ ឈូក មុត (អតីតជាគ្រូបង្រៀនដែលបានបោះបង់ចោលការងារគ្រូមកចូលរួមក្នុងចលនាតស៊ូបដិវត្តន៍ ហើយក៏បាត់ដំណឹងរហូត) ។ ប្រពន្ធរបស់ ម៉ឹងម៉ៅ ឈ្មោះ វង ហ៊ាន មានស្រុកកំណើតនៅព្រៃរបៀ ខេត្តកំពត ។ ម៉ឹងម៉ៅ មានកូនប្រុសពីរនាក់និងស្រីពីរនាក់ ។ កូនទី១ឈ្មោះ ឈូក ម៉ឹងឆាន់សន កូនទី២ឈ្មោះ ឈូកម៉ឹង បូណា កូនស្រីទី៣ឈ្មោះ ម៉ឹង សុភី និងកូនស្រីទី៤ឈ្មោះ ម៉ឹង សុភាព ។

នៅឆ្នាំ១៩៧២ ពេលដែល ម៉ឹងម៉ៅ ត្រូវទៅបំពេញការកិច្ចនៅក្រៅប្រទេស គាត់ក៏បាននាំប្រពន្ធនិងកូនៗទៅរស់នៅទីនោះដែរ ។ នៅឆ្នាំ១៩៧៥ គាត់បានត្រឡប់មកប្រទេសវិញដើម្បីរួមចំណែកកសាងជាតិជាមួយប្រជាជន ។ ចំណែកកូនៗរបស់គាត់រស់នៅប្រទេសបារាំងនៅឡើយ ។

## យុវភាពនិងការងារ

តាំងពីកុមារភាព ម៉ឹងម៉ៅ តែងមានគំនិតស្នេហាជាតិជាប់នឹងខ្លួនជានិច្ច ។ នៅពេលមានអាយុ១៨ឆ្នាំ គឺនៅឆ្នាំ១៩៣៦ ម៉ឹងម៉ៅ បានចូលរួមធ្វើកូដកម្មជាមួយសិស្សវិទ្យាល័យស៊ីសុវត្ថិក្នុងចលនាប្រឆាំងនឹងចក្រពត្តិបារាំង ។ ឆ្នាំ១៩៤៣ បន្ទាប់ពីធ្វើជាគ្រូបង្រៀនមួយឆ្នាំ គាត់បានចូលរួមក្នុងចលនាប្រឆាំងនឹងបារាំងម្តងទៀតជាមួយនឹងលោកគ្រូអាចារ្យ ហែម ចៀវ និងព្រះសង្ឃជាច្រើនអង្គ ។ ម៉ឹងម៉ៅ ថែមទាំងបានបញ្ចុះបញ្ចូលទាហានខ្មែរនៅខេត្តកំពតឲ្យចូលរួមក្នុងចលនាព្រមទាំងសម្លាប់ជនជាតិបារាំងនៅខេត្តកំពតទៀតផង ។ ឆ្នាំ១៩៤៧ ម៉ឹងម៉ៅ បានចូលរួមធ្វើសកម្មភាពក្នុងគណបក្សប្រជាធិបតេយ្យទទួលមុខតំណែងជាលេខាធិការនៅខេត្តកំពតនិងតាកែវ ។ ម៉ឹងម៉ៅ បំពេញកិច្ចការរបស់ខ្លួនដោយសុទ្ធចិត្តដោយមិនចង់បានមុខមាត់បុណ្យស័ក្តិអ្វីឡើយ ។ ក្រោយមក ម៉ឹងម៉ៅ បានបង្វិលចិត្តចូលរួមក្នុងអង្គការសង្គមរាស្ត្រនិយមវិញ ដែលនៅពេលនោះគាត់ត្រូវបានផ្លាស់ប្តូរតំណែងជាច្រើនដងពីខេត្តមួយទៅខេត្តមួយ ទម្រាំបានមកធ្វើការជាប់នៅភ្នំពេញ ។ ម៉ឹងម៉ៅ បានទទួលការគំរាមកំហែងជាញឹកញាប់ក្នុងរយៈពេលដែលគាត់កាន់មុខតំណែងជាប្រធានសមាគមបុគ្គលិកសិក្សា ។ បុគ្គលិកសិក្សា(គ្រូបង្រៀន) បានទទួលរងគ្រោះថ្នាក់គ្រប់បែបយ៉ាង ខ្លះជាប់គុក ខ្លះត្រូវសម្លាប់ដោយគ្មានការជំនុំជម្រះ ហើយខ្លះទៀតរត់ចោលការងារដើម្បីចូលរួមតស៊ូបដិវត្តន៍នៅក្នុងព្រៃ ។ ក្នុងនាមជាប្រធានសមាគមបុគ្គលិកសិក្សា ម៉ឹងម៉ៅ តែងតែជួយខបត្ថម្ភក្រុមគ្រួសារអ្នកទាំងនោះ បណ្តាលឲ្យមានការចោទប្រកាន់ថាគាត់ជា“ជនក្បត់” ។

ពីឆ្នាំ១៩៤៨-៥២ ម៉ឹងម៉ៅ បានធ្វើជាអធិការបឋមសិក្សាខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តកំពត និងខេត្តស្វាយរៀង ។

ឆ្នាំ១៩៥៦-៦៧ ម៉ឹងម៉ៅ បានធ្វើជាចាងហ្វាងកិច្ចការគរុកោសល្យនៅទីក្រុងភ្នំពេញ ។

ឆ្នាំ១៩៦៨-១៩៦៩ ម៉ឹងម៉ៅ ធ្វើជាអធិការអមទីស្ដីការក្រសួងអប់រំ ។

ឆ្នាំ១៩៧០-១៩៧១ ម៉ឹងម៉ៅ ធ្វើជាអគ្គស្នងការយុវជន ។

### ការតស៊ូរក្រៅក្របខ័ណ្ឌ

ក្រៅពីតួនាទីនៅក្នុងជួររដ្ឋការនៅពេលនោះ ឈូក ម៉ឹងម៉ៅ បានទាក់ទងជាមួយឈ្មោះ ផ្ទៃក គឿន ជាមេព្រៃនៅខេត្តកំពត និងអាចារ្យ ហែម ចៀវ នៅវត្តខណ្ឌលោមជាកន្លែងដែលខ្លួនធ្លាប់ស្នាក់អាស្រ័យជាមួយ ។ ម៉ឹងម៉ៅ ធ្លាប់បានចូលរួមអង្គប្រជុំមួយនៅកុដិរបស់អាចារ្យ ចៀវ អំពីផែនការចាប់ពួកបារាំងដោយមានជនជាតិជប៉ុនម្នាក់ចូលរួមដែរ ។ ក្រោយមក ម៉ឹងម៉ៅ បានជួបនិងស្គាល់ឈ្មោះ យ៉ង សង្គ្រែង ជាប៉ូលិសសន្តិសុខជាតិ និងជាសមាជិកម្នាក់របស់ចលនាហៃហ្វ ដែលដឹកនាំដោយ ស៊ឹង ង៉ុកថាញ់ ។ ចលនាហ្វហៃបង្កើតឡើងក្នុងគោលបំណងប្រឆាំងនឹងបារាំង ។ បារាំងបានហៅចលនានេះថា "ចលនានាគក្រហម" ក្នុងគោលបំណងភ្ជាប់ទៅនឹងចលនាយួនដែលបង្កើតឡើងនៅពេលជាមួយគ្នានិងដែលមាននិន្នាការដូចគ្នា ។ អ្នកដែលគាំទ្រចលនាហៃហ្វមានឈ្មោះ ស៊ឹម វ៉ា, ស្វាយ សូរ, សម ថាំង, ស្វាយ វ៉ា, សុខ នួង, ហង់ ធុនហាក់, ស៊ីចូវ, អ៊ុំ ស៊ឹម, ឃី តាំងលឹម រហូតដល់ស្ម័គ្រចិត្តរត់ចូលព្រៃជាមួយ ស៊ឹង ង៉ុកថាញ់ បង្កើតជាចលនាខ្មែរឥស្សរៈមួយប្រឆាំងនឹងបារាំង ។ ក្រៅពីនេះនៅមានកម្លាំងគាំទ្រពីព្រះសង្ឃជាច្រើនអង្គទៀតដែលគង់នៅវត្តនៅទីក្រុងភ្នំពេញ ដូចជាអាចារ្យ ប៉ាង ខាត់ សាស្ត្រាចារ្យនៅវត្តខណ្ឌលោម, អាចារ្យ សូ ហៃ សាស្ត្រាចារ្យនៅវត្តខណ្ឌលោម និងអាចារ្យ ខៀវ ជុំ សាស្ត្រាចារ្យនៅវត្តលង្កា ។ ម៉ឹងម៉ៅ ក៏ជាសមាជិកសំខាន់ម្នាក់នៅក្នុងចលនានេះដែរ ។ ម៉ឹងម៉ៅ ធ្លាប់បានអញ្ជើញអាចារ្យ ប៉ាង ខាត់ ទៅទេសនានៅខេត្តកំពតចំនួនពីរដង និងធ្លាប់បានតាមដានអនុគណនិងចៅអធិការវត្តនៅតាមវត្តជាច្រើន ហើយដឹងថាព្រះសង្ឃភាគច្រើនសុទ្ធតែគាំទ្រចលនារបស់ ស៊ឹង ង៉ុកថាញ់ ។

នៅក្នុងខេត្តកំពតទាហានជប៉ុនបានមកបោះមូលដ្ឋានទ័ពអាកាសនៅពងទឹក ។ ម៉ឹងម៉ៅ បានទទួលភារកិច្ចពីទាហានជប៉ុនស័ក្តិពីរម្នាក់ឈ្មោះ ស៊ិប៉ិយ៉ា ដើរប្រមូលសិស្សសាលាចំនួន២០នាក់ដើម្បីបើកបង្រៀនភាសាជប៉ុន ។ ម៉ឹងម៉ៅ ក៏មានចំណែកក្នុងការបង្រៀននេះដែរ ។

ឆ្នាំ១៩៤៤ ម៉ឹងម៉ៅ បានមកភ្នំពេញដើម្បីផ្ដល់ព័ត៌មានអំពីស្ថានការណ៍របស់ចលនានៅខេត្តកំពតឲ្យ សាវ៉ាង វង្ស, ស៊ឹម វ៉ា, អាចារ្យ ខាត់ និងអាចារ្យ សូ ហៃ និងបានសំណូមពរឲ្យអាចារ្យទាំងពីរបន្តបញ្ចុះបញ្ចូលប្រជាជននៅតាមខេត្តថែមទៀត ។

ចុងឆ្នាំ១៩៤៤និងដើមឆ្នាំ១៩៤៥ ម៉ឹងម៉ៅ បានទទួលភារកិច្ចពី ស៊ឹង ង៉ុកថាញ់ តាមរយៈ សាវ៉ាង វង្ស ឲ្យបន្តទាក់ទងមជ្ឈដ្ឋានពីរ ទី១) មជ្ឈដ្ឋានសិស្សនៅវិទ្យាល័យស៊ីសុវត្ថិ ដើម្បីរក្សាជំហរគាំទ្រឲ្យនៅដដែល និងទី២) មជ្ឈដ្ឋានសង្ឃដើម្បីពង្រីកការគាំទ្រឲ្យបានគ្រប់ទីកន្លែង ។ ម៉ឹងម៉ៅ បានទាក់ទង ស៊ីចូវ និង ហង់ ធុនហាក់, អាចារ្យ ប៉ាង ខាត់ និងអាចារ្យ សូ ហៃ ។ ចំណែកខ្លួនគាត់បានដើរឃោសនានៅតាមខេត្តនានាជាមួយព្រះសង្ឃបួនអង្គ គឺអាចារ្យ សែត សែស, អាចារ្យថែម, អាចារ្យគូ និងអាចារ្យឈិត ។ ចំណែកនៅក្នុងគណកម្មការកណ្ដាលវិញ ភាគច្រើន ម៉ឹងម៉ៅ តែងតែជួបឈ្មោះមួយចំនួនដូចជា ម៉េង ណាគ្រី, សម ថាំង, សេង សន, ង៉ែត ហ៊ាន, អ៊ីវ យ៉ាំង, តាត ហេង, អ៊ុំ ស៊ឹម និង សាវ៉ាង វង្ស ដែលអ្នកទាំងអស់នេះគឺជាអ្នកជិតដិតជាមួយ ស៊ឹង ង៉ុកថាញ់ ។

ឆ្នាំ១៩៤៥ ម៉ឹងម៉ៅ និង ម៉េង ណាគ្រី ត្រូវបានចាត់តាំងឲ្យទៅស្ទាបស្ទង់មតិអ្នករាជការនៅតាមបណ្ដាខេត្តនានា ។

ឆ្នាំ១៩៤៥ ម៉ឹងម៉ៅ បានរៀបចំកម្លាំងរបស់ខ្លួននៅស្រុកចំនួនប្រាំគឺ ស្រុកកំពង់ត្រាច ស្រុកទូកមាស ស្រុកឈូក ស្រុកព្រៃនប់ និងស្រុកកំពត ក្នុងការត្រៀមវាយបដិវត្តន៍ ។ ក្រោយមក ម៉ឹងម៉ៅ បានទទួលបញ្ជាឲ្យដុតលិខិតនិងកំណត់ហេតុសំខាន់ៗចោល ដោយសារថាស្ថានការណ៍ប្រទេសកម្ពុជានៅពេលនោះមានការប្រែប្រួល ជប៉ុនបានបណ្ដេញបារាំងចេញពីប្រទេសកម្ពុជា ហើយអាមេរិកាំងបានជ្រៀតចូលមកទៀត ។ ម៉ឹងម៉ៅ បានជួបជនជាតិអាមេរិកម្នាក់ឈ្មោះ វីលសុន ជាអ្នកប្រដៅ

សាសនាប្រូតេស្តង់ ដែលដើរផ្សព្វផ្សាយឥទ្ធិពលរបស់អាមេរិក តាំងពីនៅអឺរ៉ុប ឆ្លងមហាសមុទ្រប៉ាស៊ីហ្វិក និងមកដល់ប្រទេសកម្ពុជាទៀត ។

ឆ្នាំ១៩៤៦ ម៉ឹងម៉ៅ បានផ្អាកសកម្មភាពគាំទ្រចលនារបស់ សឺង ង៉ុកថាញ់ ហើយងាកមកទាក់ទងនឹង វីលសុនវិញ ។ មួយឆ្នាំក្រោយមកទើប ម៉ឹងម៉ៅ ភ្ជាប់ខ្លួនជាមួយនឹងចលនា ស៊ឺង ង៉ុកថាញ់ ជាថ្មី ។ ម៉ឹងម៉ៅ ទទួលសំណើពី ហ៊ុយ កន្ថុល ឲ្យត្រឡប់ទៅរៀបចំគណៈកម្មការនៅឯខេត្តកំពតឡើងវិញ ដែលមាន ផ្លែក ភឿន ជាប្រធាន ។ នៅតាមស្រុក ម៉ឹងម៉ៅ បានចាត់តាំងឲ្យបក្ខពួករបស់ខ្លួនកាន់តំណែងជាប្រធានៗ មាន ទិត ស៊ុន, ចេង ឆ្តុក, សុះ ម៉ាត់, ញាណ គ្រឿន, កើត, ស៊ីសុវត្ថិ យុត្តិវង្ស, ឈាន រឹម និង ចុន អ៊ុក ដែលសុទ្ធតែជាអ្នកគាំទ្រចលនា សឺង ង៉ុកថាញ់ ទាំងអស់ ។

នៅក្នុងខែសីហា ឆ្នាំ១៩៤៨ ម៉ឹងម៉ៅ បានទៅជួប វីលសុន និងជនជាតិស្បែកសពីរនាក់ទៀតឈ្មោះ ឡឺវីត និង ក្រាមែ ។ បន្ទាប់ពីការបញ្ចុះបញ្ចូលរបស់អ្នកទាំងពីរ ម៉ឹងម៉ៅ បានសម្រេចចិត្តចូលធ្វើជាភ្នាក់ងារសេ.អ៊ី.អា អាមេរិកាំង ។ ក្នុងនាមជាសមាជិកសេ.អ៊ី.អា ម៉ឹងម៉ៅ មានភារកិច្ចយកពត៌មានពីគណបក្សនយោបាយខ្មែរនិងពីកងទ័ពបារាំងនៅស្រុកខ្មែរ ។ រៀងរាល់ខែ ម៉ឹងម៉ៅ ត្រូវមកភ្នំពេញដើម្បីរាយការណ៍ឲ្យ ឡឺវីត អំពីពត៌មានដែលខ្លួនប្រមូលបានពីខេត្តកំពតនិងខេត្តកំពង់ស្ពឺ ។

ឆ្នាំ១៩៤៩ ម៉ឹងម៉ៅ បានចាត់តាំងកម្លាំងរបស់ខ្លួនឲ្យជួយស្វែងរកពត៌មានថែមទៀត ។ ចំណែក ម៉ឹងម៉ៅ បានទៅទាក់ទងព្រះសង្ឃពីរអង្គនាម សុន និងឈ្មោះ ស៊ុំ គង់ នៅវត្តខណ្ឌលោម ដើម្បីសួរដំណឹងព្រះសង្ឃមួយចំនួនដែលធ្លាប់មានឈ្មោះក្នុងចលនា ហែម ចៀវ និង ស៊ឺង ង៉ុកថាញ់ ក្នុងគោលបំណងភ្ជាប់ខ្សែបន្តទៀត ។ ក្រោយមកទើបដឹងថាព្រះសង្ឃទាំងនោះកំពុងលាក់ព្រះកាយនៅស្រុកស្រែចម្ការនៅឡើយ ។

ឆ្នាំ១៩៥០ ម៉ឹងម៉ៅ បាននាំ ហង់ ធុនហាក់ (ធ្វើការនៅក្រសួងឃោនាការ) ទៅជួបនឹង អ៊ុំស៊ឹម ដើម្បីឆ្លៀតឱកាសសុំភ្ជាប់ខ្សែរបស់ខ្លួននៅតាមខេត្តជាមួយនឹងខ្សែគណៈកម្មការកណ្តាលគណបក្សប្រជាធិបតេយ្យនៅភ្នំពេញ ។

ឆ្នាំ១៩៥១-៥៣ ម៉ឹងម៉ៅ បាននាំ ស៊ីចូវ មកផ្សព្វផ្សាយអារ្យធម៌អឺរ៉ុបតាមបណ្តាញព្រះសង្ឃទាំងអស់ដែលធ្លាប់ស្គាល់ពីមុន ឲ្យភ្លើតភ្លើននឹងវប្បធម៌បរទេស ចំណែក ម៉ឹងម៉ៅ ខ្លួនឯងត្រៀមចេញដំណើរទៅក្រៅប្រទេសដែរ ។

ឆ្នាំ១៩៥៤ ម៉ឹងម៉ៅ បានទៅប្រទេសបារាំងមួយឆ្នាំតាមរយៈ ឡឺវីត ដើម្បីទៅសិក្សាពីបច្ចេកទេសយកពត៌មាន វិធីវិភាគពត៌មាន និងវិធីរាយការណ៍ពត៌មានទៅថ្នាក់លើ ។ ក្រោយពីវិលត្រឡប់មកប្រទេសកម្ពុជាវិញរយៈពេល៦ខែ ម៉ឹងម៉ៅ បានទៅធ្វើការនៅខេត្តស្វាយរៀង ។ នៅពេលនេះ ម៉ឹងម៉ៅ នៅតែមានគំនិតបម្រើការឲ្យអាមេរិកដដែល ។

ឆ្នាំ១៩៥៧-៥៨ ម៉ឹងម៉ៅ បានទទួលតំណែងថ្មី ដោយគ្រប់គ្រងលើសមាជិកភ្នាក់ងារ៨នាក់ទៀត ដែលអ្នកទាំងនោះមានតួនាទីយកពត៌មានពីចលនាតស៊ូខ្មែរទៅឲ្យសេ.អ៊ី.អា ។

ឆ្នាំ១៩៥៩ ម៉ឹងម៉ៅ បានចូលរួមការប្រជុំសម្ងាត់មួយជាមួយខ្សែរយៈនានានៅក្រសួងសេដ្ឋកិច្ចក្រោមការដឹកនាំរបស់ ផ្លែក ភឿន ដើម្បីជ្រើសរើសយុវជនចំនួន២០នាក់យកទៅអប់រំរៀនសូត្រអំពីបច្ចេកទេសផ្សេងៗសម្រាប់បម្រើការឲ្យភ្នាក់ងារអាមេរិកាំង ។ នៅឆ្នាំ១៩៦៣ ម៉ឹងម៉ៅ បានដឹកនាំការប្រជុំម្តងទៀត ជាមួយអ្នកដែលធ្លាប់មានទំនាក់ទំនងនឹងគ្នានៅទីចាត់ការគរុកោសល្យ ។ ការប្រជុំនេះ ម៉ឹងម៉ៅ បានលើកតែពីភារកិច្ចដែលត្រូវបន្តធ្វើ បន្ទាប់ពីកម្ពុជាទាត់ចោលជំនួយនិងការផ្តាច់ទូតជាមួយអាមេរិកាំង ។

ឆ្នាំ១៩៦៥ ម៉ឹងម៉ៅ បានទៅពិនិត្យមើលសកម្មភាពបង្រៀនរបស់សាស្ត្រាចារ្យជនជាតិបារាំងពីរនាក់នៅក្នុងសាលាបច្ចេកទេសជាន់ខ្ពស់ ក្រោយមកក៏បានរាយការណ៍និងស្នើសុំឲ្យអគ្គទូតបារាំងព្រមានដល់ឈ្មោះទាំងពីរនេះ ពីបទបានឃោសនានយោបាយនៅក្នុងពេលបង្រៀន ។ នៅក្នុងរយៈពេលបួនប្រាំឆ្នាំ ម៉ឹងម៉ៅ កសាងកម្លាំងបានយ៉ាងច្រើនតាំងពីថ្នាក់អធិការខេត្ត រហូតដល់សាស្ត្រាចារ្យគ្រូបង្រៀននៅតាមសាលាមធ្យមសិក្សាបឋមសិក្សា និងកម្លាំងយុវជននៅតាមវិទ្យាល័យ ។

ឆ្នាំ១៩៦៨-៦៩ ម៉ឹងម៉ៅ បានបន្តធ្វើការងារជាមួយ ផ្លែក ភឿន, អ៊ឹង ក្រពុំផ្កា, ភូ ស៊ីអ៊ុយ, កែវ ចែម និង កៅ លន់

ដដែល ។ ដើមឆ្នាំ១៩៦៩ សម្តេច សីហនុ បានផ្ទេរតំណែងរដ្ឋមន្ត្រីទីមួយឲ្យទៅ លន់ ណុល និង សិរិមតៈ ។ នៅពេលនោះ ម៉ឺងម៉ៅ មានអំណាចក្នុងការចាត់តាំងសាស្ត្រាចារ្យមួយចំនួនឲ្យទទួលខុសត្រូវនៅតាមវិទ្យាល័យនីមួយៗ ពិសេសនៅក្នុងពេលមានបាតុកម្មទម្លាក់សម្តេច សីហនុ ។

ថ្ងៃ១៨មីនា ឆ្នាំ១៩៧០ ជាថ្ងៃដែល លន់ ណុល ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ។ កិច្ចការជាបន្តបន្ទាប់ទៀតរបស់ភ្នាក់ងារសេ.អ៊ី.អា គឺទប់ទល់កុំឲ្យលទ្ធិកុម្មុយនិស្តជ្រៀតចូលតាមសាលារៀន។ ម៉ឺងម៉ៅ មានតួនាទីជាអ្នកចាត់តាំងគ្រូៗដែលជាខ្សែបណ្តាញរបស់ខ្លួននៅតាមសាលានានាឲ្យតាមដានសភាព-ការណ៍នៅតាមវិទ្យាល័យនានា ក្រែងមានការផ្សព្វផ្សាយលទ្ធិកុម្មុយនិស្តដល់សិស្សនិងនិស្សិត ។ ដើមឆ្នាំ១៩៧២ ម៉ឺងម៉ៅ ត្រូវបាន លន់ ណុល និងសិរិមតៈ តែងតាំងឲ្យទៅធ្វើជាទូតប្រចាំនៅប្រទេសស្វ៊ីសតាមការស្នើសុំរបស់ជនជាតិអាមេរិកកាំងឈ្មោះ ហ្វូឡាប៉ែរ ។ មុនចេញដំណើរទៅក្រៅប្រទេស ម៉ឺងម៉ៅ បានទាក់ទងព្រះសង្ឃនៅភ្នំពេញនិងគ្រូៗនៅតាមសាលារៀន ហើយបញ្ចុះបញ្ចូលបានកម្លាំងបីនាក់ឈ្មោះ គាន់ ប៊ុនសរ, ជួង ម៉ានឡា និង សុខ ធឿងឌឿង ។ ម៉ឺងម៉ៅ បានផ្តើមធ្វើការនៅស្ថានទូតខ្មែរប្រចាំក្រុងប៉ែរន៍នៃប្រទេសស្វ៊ីស ចាប់ពីថ្ងៃទី២០ឧសភា ឆ្នាំ១៩៧២ រហូតដល់ថ្ងៃ១៥ កក្កដា ឆ្នាំ១៩៧៥ ។ នៅពេលនោះ ការងារផ្នែកខាងក្រៅរបស់គាត់គឺផ្សព្វផ្សាយតែវប្បធម៌អារ្យធម៌ខ្មែរឲ្យមជ្ឈដ្ឋានស្វ៊ីសនិងមជ្ឈដ្ឋានអឺរ៉ុបជ្រួតជ្រាបប៉ុណ្ណោះ ។ នៅខែតុលា ម៉ឺងម៉ៅ បានជួបទំនាក់ទំនងស្គាល់ជនជាតិអាមេរិកាំងម្នាក់ឈ្មោះ ហ្វង់វីប៉ែរ ធ្វើការនៅស្ថានកុងស៊ុលអាមេរិកប្រចាំប្រទេសស្វ៊ីស ហើយឈ្មោះនេះតែងតែនាំ ម៉ឺងម៉ៅ ឲ្យស្គាល់សមាគមស្វ៊ីសតូចៗនិងណែនាំអំពីការងារផ្សេងៗដែលពាក់ព័ន្ធនឹងសេ.អ៊ី.អា ។

ឆ្នាំ១៩៧៣ ម៉ឺងម៉ៅ បានចាប់ផ្តើមប្រមូលជនជាតិខ្មែរចំនួន៨នាក់ដែលរស់នៅប្រទេសស្វ៊ីស ដើម្បីធ្វើកម្លាំងប្រឆាំងនឹងបដិវត្តន៍ ។

ឆ្នាំ១៩៧៤ ម៉ឺងម៉ៅ បានទទួលផែនការពី ហ្វង់វីប៉ែរ ក្នុងការបញ្ចូលសេ.អ៊ី.អាមកស្រុកខ្មែរ ដើម្បីភ្ជាប់ខ្សែបណ្តាញសេ.អ៊ី.អារបស់អាមេរិកឲ្យរស់ឡើងវិញ ក្នុងគោលបំណងវាយបដិវត្តន៍នៅខែមិថុនា ឆ្នាំ១៩៧៧និងឆ្នាំ១៩៧៨ ។ បន្ទាប់ពីទទួលផែនការរួច ម៉ឺងម៉ៅ បានចេញពីប្រទេសស្វ៊ីសទៅស្នាក់នៅប្រទេសបារាំងអស់រយៈពេលប្រាំខែដើម្បីប្រមូលកម្លាំងសេ.អ៊ី.អាចាស់ៗចូលស្រុកវិញ ។ មុនចេញដំណើរដប់ថ្ងៃ ម៉ឺងម៉ៅ បានទទួលផែនការបន្ថែមពី ហ៊ីង អុន ឲ្យរៀបចំកម្លាំងនៅក្នុងស្រុកឲ្យរួចរាល់មុនពេលដែលគាត់ត្រឡប់ចូលស្រុកវិញក្នុងគោលបំណងតែមួយគឺវាយអង្គការបដិវត្តន៍ ។ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៥ ម៉ឺងម៉ៅ បានធ្វើដំណើរចេញពីប្រទេសបារាំង ហើយមកដល់ប្រទេសកម្ពុជានៅថ្ងៃទី២៦ដោយស្នាក់នៅមន្ទីរ ក-១៥ (មន្ទីរបឹងត្របែក) ជាកន្លែងសម្រាប់ដាក់អ្នកដែលត្រឡប់មកពីបរទេស ។ ខែកុម្ភៈ ឆ្នាំ១៩៧៦ ម៉ឺងម៉ៅ បានចាប់ផ្តើមទាក់ទងខ្សែបណ្តាញធ្វើសកម្មភាពតាមផែនការរបស់ ហ៊ីង អុន ភ្លាម ។ ខែកញ្ញា ឆ្នាំ១៩៧៦ ម៉ឺងម៉ៅ និងបក្ខពួករបស់គាត់បានផ្លាស់ទីកន្លែងទៅនៅភូមិតាឡី និងបានប្រជុំជាមួយសមាជិករបស់ខ្លួន ដើម្បីផ្តើមគំនិតប្រឆាំងនឹងបដិវត្តន៍កម្ពុជា និងដើម្បីឲ្យបក្ខពួករបស់ខ្លួនបានទទួលតំណែងល្អៗក្នុងអង្គការបដិវត្តន៍ ។ «ខ្ញុំបានព្យាយាមប្រជុំនិងបក្ខពួកខ្ញុំ ដើម្បីដាក់ផែនការឲ្យអ្នកទាំងអស់នោះសម្រេចដោយបង្កើតគំនិតប្រឆាំងនឹងបដិវត្តន៍កម្ពុជា និងទាមទារយកតំណែងសំខាន់ៗពីរដ្ឋអំណាចនៃបដិវត្តន៍កម្ពុជាជាប្រយោជន៍បក្ខពួកយើងខ្ញុំ» ។

នៅខែវិច្ឆិកា ម៉ឺងម៉ៅ និងមិត្ត២០នាក់បានចេញពីតាឡីមករស់នៅមន្ទីរបឹងត្របែក(មន្ទីរក-១៥) នៅពេលនោះ គាត់នៅតែទាក់ទងជាមួយភ្នាក់ងារសេ.អ៊ី.អាដដែល ដោយបានព្យាយាមណាត់ជួបបក្ខពួកម្តងម្នាក់ៗនិយាយគ្នាស្ងាត់ៗអំពីផែនការប្រឆាំងបដិវត្តន៍កម្ពុជា ។ ម៉ឺងម៉ៅ បានលើកយកតែបញ្ហាកង្វះខាតអាហារនិងសុខភាពមកធ្វើជាចំណុចសំខាន់ក្នុងការប្រឆាំងនឹងបដិវត្តន៍កម្ពុជាប៉ុណ្ណោះ ។ បន្ទាប់ពីនោះ ម៉ឺងម៉ៅ ក៏បានបន្តទៅជួប អ៊ិន សូកាន, តូច ភឿន ដើម្បីឲ្យដឹងអំពីសភាពការណ៍ក្នុងស្រុក ។

នៅក្នុងចម្លើយសារភាពរបស់ ម៉ឺងម៉ៅ ក៏បាននិយាយដែរថា នៅខែមិថុនា ឆ្នាំ១៩៧៧ អាមេរិកបានត្រៀមដាក់កម្លាំងទ័ពចំនួន៦ម៉ឺននាក់មកប្រទេសកម្ពុជា ។ បីម៉ឺននាក់ចូលតាមផ្លូវ

គោក ពីរម៉ឺននាក់ឡើងតាមច្រកកំពង់សោម និងមួយម៉ឺននាក់ឡើងតាមច្រកទន្លេមេគង្គ ។ ផែនការនេះបានទទួលការគាំទ្រពីប្រទេសចំនួនដប់ដូចជាប្រទេសថៃ, ម៉ាឡេស៊ី, សិង្ហបុរី, ឥណ្ឌូនេស៊ី, ហ្វីលីពីន, តៃវ៉ាន់, ជប៉ុន, ស្វីស, កាណាដា,អូស្ត្រាលី និងប្រទេសកូរ៉េខាងត្បូង ។ ម៉ឹងម៉ៅ មានតួនាទីជាអ្នករៀបចំអ្នកនាំសារមួយក្រុមសម្រាប់ទាក់ទងជាមួយបណ្ដាញនៅទីក្រុងបាងកក ។

ម៉ឹងម៉ៅ, ផ្លែកភឿន និង អ៊ិន សុកាន(ប្អូន អ៊ិន សុភាព) នៅតែបន្តសហការជាមួយគ្នាត្រៀមផែនការវាយលុករបស់អាមេរិកាំង ចូលទឹកដីកម្ពុជា ។ នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ១៩៧៦ ម៉ឹងម៉ៅ ត្រូវបានចាប់ខ្លួនជាមួយមិត្តប្អូននាក់ទៀត ។ ក្នុងចំណោមអ្នកទាំងប្អូនដែលត្រូវចាប់ខ្លួនទៅជាមួយនោះ ពីរនាក់មានគ្រួសារ ហើយទើបនឹងទទួលតំណែងទូតនៅប្រទេសគុយបា និងយុវជនពីរនាក់ទៀត ជាអតីតនិស្សិតមកពីជប៉ុន ។

យោងតាមសេចក្ដីសារភាពរបស់ ម៉ឹងម៉ៅ បង្ហាញថាគាត់សោកស្ដាយនឹងកំហុសរបស់ខ្លួនដែលមិនបានធ្វើការជូនអង្គការបដិវត្តន៍ ហើយបានសុំឲ្យអង្គការបដិវត្តន៍ទុកជីវិតដើម្បីឲ្យគាត់មានឱកាសបម្រើជាតិតទៅទៀត ។ «ជាមួយនឹងមុខតំណែងរបស់ខ្ញុំ ខ្ញុំខំបញ្ចេញគំនិតប្លែកៗឲ្យបានគំរូថ្លៃថ្នូរ ប៉ុន្តែសម្រេចសម្រួចទៅជាលទ្ធផលខ្ញុំពុំបានធ្វើអ្វីឲ្យពេញចិត្តខ្លួនឯងសោះ ខាតអស់ជាង៣០ ឆ្នាំហើយក្នុងជីវិតរបស់ខ្ញុំ ព្រោះខ្ញុំគ្មានសេចក្ដីក្លាហានរួមផ្ទាល់ក្នុងអង្គការបដិវត្តរបស់បងប្អូនពីដើមដៃ ថ្វីដ្បិតតែយូរៗម្ដងខ្ញុំធ្លាយសម្ដីថា មានតែបដិវត្តន៍ទេទើបដោះស្រាយបញ្ហាខ្មែរបាន ។ ឥឡូវជីវិតខ្ញុំជ្រេបន្តិចទៅហើយ តែខ្ញុំនៅចិញ្ចឹមគំនិតថា ខ្ញុំអាចរួមចំណែកខ្លះក្នុងការកសាងជាតិ ។ សូមអង្គការបដិវត្តន៍ណែនាំខ្ញុំដើម្បីឲ្យជីវិតខ្ញុំមានន័យច្បាស់ជាងមុនទៅទៀតចំពោះជាតិ» ។

នៅក្នុងចម្លើយសារភាពរបស់ ម៉ឹងម៉ៅ មានឈ្មោះមនុស្ស១៥៧ដែលជាប់ពាក់ព័ន្ធ ។ ភាគច្រើនអ្នកទាំងនោះសុទ្ធតែជាមន្ត្រីរដ្ឋការដែលមានបុណ្យស័ក្តិធំៗ ។ **លី សុផល**

# សេចក្ដីជូនដំណឹងរបស់សមាគមអ្នកនិពន្ធខ្មែរ

សមាគមអ្នកនិពន្ធខ្មែរសូមជម្រាបដល់ប្រជាជនកម្ពុជាគ្រប់រូបថា សមាគមបានរៀបចំ «**វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ**» ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ វេទិកានេះមានគោលបំណងសំខាន់ៗដូចជា÷

◆ រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំសាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្ដីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្ដងទៀតនៅក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

សមាគមអ្នកនិពន្ធខ្មែរសូមអំពាវនាវដល់ប្រជាជនកម្ពុជាចូលរួមសរសេរអត្ថបទទាំងឡាយអំពី÷ ១) រឿងរ៉ាវផ្ទាល់ខ្លួន ២) ព្រឹត្តិការណ៍ដែលលោកអ្នកធ្លាប់បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ៣) ផ្ដល់ដំណោះស្រាយចំពោះបញ្ហាប្រវត្តិសាស្ត្រនេះ ។ ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។

សមាគមអ្នកនិពន្ធខ្មែរនិងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងមានកិត្តិយសដោយចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្ដី «ស្វែងរកការពិត» ព្រមទាំងផ្ដល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ ការចូលរួមរបស់លោកអ្នកគឺជាការរួមចំណែកលើកស្ទួយតម្លៃនៃការសរសេរនិងចំណេះដឹង ។

សូមផ្ញើអត្ថបទរបស់លោកអ្នកមកសមាគមអ្នកនិពន្ធខ្មែរទីស្នាក់ការៈ វត្តបទុមវតី ភ្នំពេញ ឬទាក់ទងតាមទូរស័ព្ទលេខ ០១២ ៨៨៣ ០៧២ ចាប់ពីពេលផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ។

សូមអរគុណ ។

ឯកសារខ្មែរក្រហម

# មតិណែនាំរបស់៨៧០

**កម្មវត្ថុ:** អំពីការទម្លាក់គ្រាប់បែករបស់ចក្រពត្តិអាមេរិក លើក្រុងសៀមរាបថ្ងៃទី២៥-២-៧៦

កាលពីថ្ងៃទី២៥-២-៧៦ នៅម៉ោង៨កន្លះព្រឹក មានយន្តហោះមួយគ្រឿងទម្លាក់គ្រាប់បែក៣គ្រាប់លើក្រុងសៀមរាប ហើយម៉ោង២រសៀលយន្តហោះ២គ្រឿងទៀតមកទម្លាក់គ្រាប់បែក១គ្រាប់នៅកន្លែងដដែល បណ្តាលឲ្យខូចខាតអាយុជីវិត ទ្រព្យសម្បត្តិ និងផ្ទះសម្បែងមួយចំនួន។

ព្រឹត្តិការណ៍ទម្លាក់គ្រាប់បែកលើក្រុងសៀមរាបថ្ងៃទី២៥-២នេះជាព្រឹត្តិការណ៍មួយធំ ក្រោយពីយើងរំដោះទូទាំងប្រទេសមក។ រឿងនាវាម៉ាយ៉ាហ្គេសក៏មិនធំដុំដល់ព្រឹត្តិការណ៍នេះដែរ ពីព្រោះការទម្លាក់គ្រាប់បែកនេះចូលមកជ្រៅក្នុងដីយើង។

តើយន្តហោះនេះជារបស់នរណា?

អចិន្ត្រៃយ៍សន្និដ្ឋានថាជារបស់ចក្រពត្តិអាមេរិក។ យន្តហោះនេះហ៊ានមកទម្លាក់គ្រាប់បែកបែបនេះទាល់តែមានការសម្រេចពីរដ្ឋាភិបាលអាមេរិក។ ដូច្នេះការណ៍នេះទាក់ទងដល់នយោបាយ។ ចក្រពត្តិអាមេរិកវាធ្វើសកម្មភាពវាយយើងជាបន្តបន្ទាប់ខាងជើងគោក។ តែវាវាយមិនបាន។ ជាហេតុនាំឲ្យចក្រពត្តិអាមេរិកទាល់ច្រក បែរមកវាយយើងតាមជើងអាកាស។

តើមូលហេតុអីបានជាវាយយើង?

អាមេរិកវាចាញ់សង្គ្រាមយើង វាឈឺចាប់ណាស់រហូតដល់ទៅយំ។ វាខឹងនឹងជាប់ជាមួយយើង ហើយវាខំរកវិធីដើម្បីវាយយើងវិញ តែត្រូវបរាជ័យយ៉ាងជូរចត់ជាបន្តបន្ទាប់ទៀត។

ពេលមហាសន្និបាតជាតិលើកទី២របស់យើងប្រកាសគោលជំហរមហាសាមគ្គីជាតិ ហើយផ្តន្ទាទោសតែពួកអាក្បត់៧នាក់ ចក្រពត្តិអាមេរិកវាសង្ឃឹមថាជាឱកាសឲ្យវាអនុវត្តផែនការវាយយើងក្រោយពេលវាចាញ់ ដោយវារក្សាកម្លាំងរបស់វាបានតទៅទៀតនៅក្នុងក្រុងភ្នំពេញនិងទីរួមខេត្ត។ តែក្រោយពីយើងឈ្នះយើងជកប្រជាជនចេញពីក្រុងភ្នំពេញនិងទីរួមខេត្ត ផែនការចក្រពត្តិអាមេរិកដែលត្រៀមវាយយើង ក្រោយពេលវាចាញ់ត្រូវខាតខ្ទាយ នាំឲ្យចក្រពត្តិអាមេរិកក្តៅក្រហាយនឹងបដិវត្តន៍កម្ពុជាកាន់តែខ្លាំងទៀត។ វាចាញ់ខាងនយោបាយរួចហើយ។

ខាងចាត់តាំងត្រូវមានវិធានការរក្សាការសម្ងាត់ ឃ្លាំងគ្រាប់ ឃ្លាំងអាវុធ ឃ្លាំងអង្ករ អំបិល ស្រូវ ក្រណាត់...ទីតាំងស្រុក តំបន់ ភូមិភាគ ក្រសួងផ្សេងៗត្រូវស្ងាត់និងចល័ត។

ខាងយោធា ណែនាំឲ្យគ្រប់អង្គភាពជើងទឹក ជើងគោកតាមព្រំដែនធ្វើសកម្មភាពវាយយើងនៅតាមព្រំដែន តាមសមុទ្រ និងតាមកន្លែងផ្សេងទៀត។

អចិន្ត្រៃយ៍ស្នើយកព្រឹត្តិការណ៍នេះអប់រំផ្ទៃក្នុងបក្សអង្គភាព ស្នូល កងទ័ព និងមហាជន សំដៅបំផុសកំហឹងជាមួយខ្មាំងឲ្យក្តៅគគុកនិងស្រួចជាប់ជានិច្ច សំដៅកសាងគោលជំហរ ប្រុងប្រយ័ត្នបដិវត្តជាប់ជានិច្ច កសាងគោលជំហរ សតិអារម្មណ៍នយោបាយ និងចាត់តាំងធ្វើបដិវត្តសង្គមនិយមនិងកសាងសង្គមនិយមឲ្យខ្លាំងក្លា ការពារទឹកដីឲ្យបានជាដាច់ខាត ការពារលទ្ធផលបដិវត្តឲ្យជាប់ដាច់ខាត ហើយរួមជាមួយប្រជាជន សាច់មួយឈាមមួយ ជាធ្លុងមួយ សម្រុកធ្វើប្រព័ន្ធភ្លឺស្រែ ដើម្បីសម្រេចឲ្យបាន៣តោនក្នុង១ហិកតា និងកែប្រែជីវភាពប្រជាជនឲ្យបានតាមសំណូមពររបស់បក្ស។

### វិធីដំណើរការ:

- អប់រំផ្ទៃក្នុងបក្ស អង្គការស្នូល កងទ័ព
- ធ្វើមិទ្ទីងបំផុសកំហឹងប្រជាជន

**សម្គាល់:** ក្នុងការអប់រំផ្ទៃក្នុងនិងក្នុងមិទ្ទីងមហាជន ត្រូវលើកឲ្យឃើញថា ខ្មាំងវាវាយយើងតាមយន្តហោះយ៉ាងនេះមកពីបដិវត្តយើងខ្លាំងហើយណែនគ្រប់ផ្នែក ខ្មាំងវាទាល់ច្រក អស់លទ្ធផលវាយយើងតាមវិធីផ្សេងទៀត។ នេះមិនមែនមកពីវាខ្លាំងទេ។

ថ្ងៃទី២៧ ខែ២-៧៦

គណៈ៨៧០

**ឯកសារលេខ១៦៨៨**

ឯកសារខ្មែរក្រហម

## ឧទ្ទេសនាមរបស់សមមិត្ត ផល:

# ទស្សនៈសភាពការណ៍បច្ចុប្បន្ននៃប្រទេសកម្ពុជា

១) សភាពការណ៍នៃបដិវត្តប្រជាជាតិ

រំឭកអំពីរដ្ឋប្រហារនិងសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក និងការបរាជ័យរបស់វា ចាប់តាំងពីថ្ងៃ១៨ ខែ៣ ឆ្នាំ១៩៧០ ចក្រពត្តិអាមេរិកមានគោលបំណងយកប្រទេសកម្ពុជាធ្វើជាមូលដ្ឋានសឹករបស់វា គឺតាំងមូលដ្ឋានសឹកមិនវាយបេ.៥២មកទម្លាក់លើប្រជាជនកម្ពុជា បន្ទាប់មកទៀតយកវៀតណាមកូបនីយកម្មមកវាយកម្ទេចបដិវត្តន៍យើងតែត្រូវបរាជ័យ ប្រើខ្មែររូបនីយកម្មសង្គ្រាមត្រូវចាញ់ទៀត ចាប់ពីខែមករា ឆ្នាំ១៩៧៥ យើងកាត់ផ្តាច់ផ្លូវទន្លេមេគង្គបានធ្វើឲ្យខ្មាំងទ្រុឌទ្រោមខាងសេដ្ឋកិច្ច ខាងយោធាក៏វារឹតតែចាញ់យើងខ្លាំងមែនទែន ឈានទៅរំដោះភ្នំពេញទាំងស្រុង ។

គោលបំណងរបស់ចក្រពត្តិដាក់មូលដ្ឋានសឹកក៏ត្រូវបរាជ័យទាំងស្រុង ថែមទាំងដេញចក្រពត្តិអាមេរិកឲ្យអាម៉ាស់ជាទីបំផុត ខាងសេដ្ឋកិច្ច ខ្មាំងចាញ់កាន់តែខ្លាំងថែមទៀតធ្វើឲ្យចុះដល់កម្រិត ។

ដើម្បីដាក់ផែនការរំដោះក្រុងភ្នំពេញ ត្រូវលើកសមរភូមិបីជាសំខាន់ ទី១) សមរភូមិផ្តាច់គមនាគមន៍ ទី២) សមរភូមិទីរួមខេត្ត ទី៣) សមរភូមិភ្នំពេញ ។

តើខ្មាំងរៀបចំចាញ់យ៉ាងដូម្តេច?

ក្រោយពេលខ្មាំងឃើញបដិវត្តន៍យើងវាយសម្រុកខ្លាំង វារៀបចំចាញ់យើង គឺវាមានវិធានការសាជាថ្មីមុនយើងចូលដល់ក្រុងខាងផ្នែកយោធាវារៀបចំដើម្បីធ្វើសកម្មភាពតបនឹងយើងមានគប់គ្រាប់បែកលើយើងពីលើផ្ទះថ្ម ចំពោះការរៀបចំចាញ់នេះខ្មាំងវានៅត្រដរខ្យល់ខាងផ្នែកយោធាទៀត វារៀបចំបញ្ចូលក្នុងកងទ័ពយើងក្នុងរយៈមួយខែឲ្យយើងចុះខ្សោយម្តងបន្តិចៗ គឺវាវាយយើងនេះខាងយោធា ខាងផ្នែកនយោបាយវាទៅទាក់ទងសម្តេច សីហនុ ឲ្យកម្ទេចកម្លាំងបដិវត្តយើងទោះវាថោកទាបយ៉ាងណាក៏ដោយ ចក្រពត្តិវាប្រើឧបាយកលយ៉ាងនេះក៏ដោយ ប្រជាជនយើងអាចដឹងទាំងអស់នូវផែនការកខ្វក់នេះ ក្រោយមកវាបានរៀបចំកម្លាំងរណសិរ្សកណ្តាលមានប្រាំរយនាក់ទទួលយើង និងបញ្ចូលក្នុងកងទ័ពយើងនេះ ចក្រពត្តិអាមេរិកាំងវាដឹកនាំ វាបានចក្រពត្តិកុម្ម៉ង់ដូឲ្យមកទាក់ទងកងទ័ពយើងចក្រពត្តិនិងបរិវារក្បត់វាចាញ់ខាងយោធាចាញ់ខាងនយោបាយ ចាញ់ខាងសតិអារម្មណ៍ ចាញ់ខាងសេដ្ឋកិច្ច ចាញ់ខាងទូត ។

### វិធានការរបស់យើងត្រៀមលក្ខណៈនិងក្រោយឈ្នះ

ក្រោយពីខ្មាំងរៀបចំចាញ់យើងក៏ដើម្បីឈ្នះយើងវិញពេលនោះបើទោះបីយើងវាយឈ្នះទីក្រុងភ្នំពេញយើងហើយមិនជម្លៀសប្រជាជនចេញ ខ្មាំងពិតជាវាយលើយើងវិញមិនខានដូច្នេះផែនការរបស់អង្គការត្រូវជម្លៀសប្រជាជនក្រុងភ្នំពេញឲ្យទៅជនបទ ខាងផ្នែកយោធាត្រៀមរៀបចំស្លៀកពាក់ខោអាវខ្មៅថាវាគស៊ូខាងក្នុងឲ្យកងទ័ពយើងទទួលស្គាល់វា នេះជាឧបាយ-កលរបស់ខ្មាំងវារៀបចំបញ្ចូលក្នុងជួរបដិវត្តន៍យើងដើម្បីវាយយើងបន្តទៅមុខធ្វើឲ្យយើងមានការស្មុគស្មាញពិបាកដោះស្រាយផ្ទៃក្នុងកងទ័ពយើងតែពេលនោះបក្សយើងវាងវៃមានវិធាការទប់ទល់បាន ។

### ឧបាយកលថ្មីរបស់ចក្រពត្តិអាមេរិកនិងបរិវារ

ក្រោយពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដែលរំដោះបានទូទាំងប្រទេសចក្រពត្តិអាមេរិកនៅបន្តការជិះជាន់មកលើប្រទេសកម្ពុជា គឺវាចូលតាមផ្លូវទូត វាប្រើគ្រប់ឧបាយកល ខាងយោធាខាងទូត ខាងនយោបាយ វាប្រើម៉ាស៊ីនឃោសនា ដោយឃោសនាថាប្រជាជនស្លាប់រាប់សែននាក់ព្រោះអត់បាយ ឲ្យពិភពលោកជឿតែពិភពលោកគេមិនជឿ គេទទួលស្គាល់យើងទៅវិញខាងយោធាមានចូលកប៉ាល់តាមសមុទ្រមានកោះសេះជាដើម មិនតែប៉ុណ្ណោះវាយកយន្តហោះមកទម្លាក់កម្ទេចកំពង់ផែសីហនុ

រោងចក្រប្រេងកាតរបស់យើង នេះជាផែនការឈ្លានពានរបស់ចក្រពត្តិអាមេរិកមិនឲ្យយើងកសាងប្រទេសបានរីកចំរើន គឺវាប្រមូលកម្លាំងលាក់ខ្លួនក្នុងក្រុងនិងបញ្ចូលតាមរយៈអ្នកធ្វើដំណើរទៅមក គឺដើម្បីគាស់អាវុធវាលាក់ទុកយកមកវាយយើងវិញ តែដោយបក្សយើងមានវិធានការទប់ស្កាត់ទាន់ខ្លាំងត្រូវបរាជ័យ ។

### វិធានការរបស់យើងទៅថ្ងៃមុខ

១) ទស្សនៈខាងគោលជំហររបស់យើងត្រូវប្រុងប្រយ័ត្នឯករាជ្យម្ចាស់ការដើម្បីទប់ទល់ខ្សែបាយកលរបស់ខ្មាំងដែលវាប្រើខ្សែបាយកលបំផ្លិចបំផ្លាញ យើងត្រូវមានទស្សនៈនេះលើគោលជំហរកសាងនិងការពារប្រទេស ។

២) ត្រូវមានវិធានការខាងចារកម្មយោធា គឺត្រូវមានការផែកឆេរតាមជនបទ ព្រោះវាបញ្ចូលចារកម្មរបស់វាមកក្នុងប្រទេសយើងដើម្បីបន្តអុកឡុកយើង ធ្វើឲ្យស្ទះដំណើរការកសាងប្រទេសនិងការពារប្រទេស គិញសន្តិសម្ព័ន្ធ វាបញ្ចូលក្នុងផ្ទៃប្រជាជន ព្រោះប្រជាជនមានសហករណ៍ ហើយយើងត្រូវទប់ទល់កុម្មុំផងដូ ។

៣) ត្រូវមានវិធានការការពារកម្លាំងយោធាយើងទាំងកម្លាំងមនុស្សនិងសម្ភារៈ ជាគោលជំហររបស់យើងគឺធ្វើសង្គ្រាមប្រជាជនយើងប្រើសង្គ្រាមឈ្លបគឺសង្គ្រាមប្រជាជន ត្រូវអនុវត្តសង្គ្រាមឈ្លប សង្គ្រាមប្រជាជនទាំងមូលដ្ឋានបន្តទៅមុខទៀត ។

៤) វិធានការនយោបាយនិងទូតៈ ក្នុងប្រទេសកម្ពុជាយើងក្រោយពេលរំដោះក្រុងហើយ ចក្រពត្តិអាមេរិកសុំដាក់ទូតប្រទេសដទៃទៀតដែលមិនអើពើពីមុនក៏សុំដាក់ទូតដែរ គឺគោលបំណងរបស់អាមេរិកគឺបញ្ចូលសេ.អ៊ី.អាតាមរយៈទូត ដូចនេះបក្សយើងមានវិធានការការពារ ទូតណាមិនបញ្ចូលសេ.អ៊ី.អាគឺទទួល ទូតណាបញ្ចូលសេ.អ៊ី.អាមិនទទួល ហើយប្រទេសកម្ពុជាយើងប្រកាន់យកអព្យាក្រឹត មិនចូលបក្សសម្ព័ន្ធនិងមិនឈ្លានពានគេ ។

៥) វិធានការខាងសេដ្ឋកិច្ចៈ ខាងសេដ្ឋកិច្ចខ្មាំងមានគោលបំណងកម្ទេចផ្លូវទឹកយើងនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៧៥ ដើម្បីកុំឲ្យយើងដឹកជញ្ជូនបាន ដូចជា ពោត ស្រូវ សណ្តែកយកទៅបរទេស នេះជាគោលបំណងរបស់ចក្រពត្តិអាមេរិកាំងដោយវាឃើញយើងមានធាតុម្ចាស់ការក្នុងការការពារប្រទេសនិងកសាងប្រទេស បានជាអាមេរិកាំងប្រើខ្សែបាយកលគ្រប់បែបយ៉ាងក៏ចូលមិនបានព្រោះប្រជាជនយើងដឹង ។

### សភាពការណ៍ខាងផ្នែកបដិវត្តន៍

សភាពការណ៍បដិវត្តប្រជាធិបតេយ្យមុនពេលរំដោះទូទាំងប្រទេស

ពេលមុនរំដោះទូទាំងប្រទេសនៅក្នុងតំបន់រំដោះគឺយើងធ្វើនយោបាយមួយកម្រិតនៅក្នុងសហករណ៍៩០-៩៩ ភាគរយ ខាងផ្នែកនយោបាយគឺក្តាប់បានគ្រប់ប្រជាជនទាំងខាងសេដ្ឋកិច្ច យើងចាត់តាំងបានមួយចំនួន កម្មសិទ្ធិឯកជនត្រូវរណបសហករណ៍ ឯសហករណ៍នេះឋិតនៅក្រោមការដឹកនាំការដឹកនាំរបស់អង្គការផ្ទាល់ ឯប្រជាជនចេញពីក្រុងភ្នំពេញទៅនៅក្រោមរបស់អង្គការយើងទាំងអស់ កម្មសិទ្ធិឯកជនត្រូវរលាយអស់តែបុគ្គលនៅមាននៅក្នុងបដិវត្តន៍ប្រជាធិបតេយ្យយើងវាយកម្ទេចអស់របបអស់វណ្ណៈនៅបុគ្គល ។

១) ទិដ្ឋភាពនៃបដិវត្តប្រជាធិបតេយ្យរដ្ឋកាន់សេដ្ឋកិច្ចពាណិជ្ជកម្ម ឧស្សាហកម្ម និងហិរញ្ញវត្ថុ ។

អ្នកឯកជននៅទីក្រុងភ្នំពេញយកកម្មសិទ្ធិទៅក៏គ្មានទាក់និងឯកជនជនបទទេ ឯកជនក្រុងយកទៅក៏នៅក្រោមការដឹកនាំរបស់សហករណ៍យើងដែរ ប្រជាធិបតេយ្យគឺរដ្ឋកាន់កាប់សេដ្ឋកិច្ចពាណិជ្ជកម្ម ឧស្សាហកម្ម ហិរញ្ញវត្ថុទាំងអស់ ។

២) សភាពការណ៍បដិវត្តប្រជាធិបតេយ្យ ក្រោយពេលរំដោះទូទាំងប្រទេសៈ យើងរំដោះទូទាំងប្រទេស យើងមានលក្ខណៈសម្បត្តិនិងមានទិដ្ឋភាពទី២ គឺទីក្រុងនិងជនបទបង្កបង្កើតផលនិងបោសសម្អាតសក្តិភូមិ នាយទុន នាម៉ឺន អនុធន ឲ្យងើបក្បាលលែងរួច ព្រោះជនបទគ្មានកម្មសិទ្ធិឯកជន ។

របបសក្តិភូមិ នាយទុន អនុធន វាត្រូវរលំរលាយហើយ បែបបុគ្គល នៅជេរបដិវត្តយើង នៅមានជំហរសតិអារម្មណ៍ប្រឆាំងបដិវត្តន៍យើង បើមានចារកម្មសន្តិសម័ន្ធចូលមកវារួមផ្សំឡើងនេះសតិអារម្មណ៍របស់វា ។ល ។

**ឯកសារ D២១៩០៥**

# ជនរងគ្រោះ



# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១០៧៣ | លឹម ឡុន ហៅ ឡុង | វរសេនាតូច | កងពល៣១០ | ១០-៧-៧៦ | ៧-១០-៧៦ ឈឺស្លាប់ |
| ១០៧៤ | ផង់ លី | មេពួក | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៧៥ | ម៉ម យ៉ែម | មេក្រុម | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៧៦ | ម៉ី ភាវ | មេក្រុម | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៧៧ | ជុំ ធន | មេក្រុម | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៧៨ | គង់ វ៉ាន | មេពួក | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៧៩ | ឡាយ សឿន | នីរសា | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៨០ | យ៉ុង សាវុធ | អនុក្រុម | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៨១ | គ្រួច ឃួន | យុទ្ធជន | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៨២ | យូ វ៉ា | យុទ្ធជន | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៨៣ | ណោ ស៊ីណា | យុទ្ធជន | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៨៤ | រិន ជួន | យុទ្ធជន | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៨៥ | រ៉ូ រុន | យុទ្ធជន | កងពល៨០១ | ៣-៨-៧៦ | ៩-១០-៧៦ ឈឺស្លាប់ |
| ១០៨៦ | ឆួន សារ៉ាត ហៅ កួយ | កម្មករ | អគ្គិសនីចាក់អង្រែ | ៤-៨-៧៦ | ៩-១០-៧៦ ឈឺស្លាប់ |
| ១០៨៧ | បាន ឡុង | កម្មករ | រដ្ឋករទឹក | ៤-៨-៧៦ | ៩-១០-៧៦ ឈឺស្លាប់ |
| ១០៨៨ | តាំង អ៊ុល | កងហា | កងពល៣១០ | ១០-៧-៧៦ | ១០-១០-៧៦ |
| ១០៨៩ | តាយ រី ហៅ រេន | កងរយ | ពាណិជ្ជកម្មកំពត | ២៥-៦-៧៦ | ១០-១០-៧៦ |
| ១០៩០ | ឃឹម អ៊ិន | នីរសា | វរសេនាធំ១៥២ | ៥-៩-៧៦ | ១០-១០-៧៦ |
| ១០៩១ | ឈឹម ឌុន | មេពួក | កង៤៥០ | ២៩-៧-៧៦ | ១០-១០-៧៦ |
| ១០៩២ | ឡុង ប៊ុនណា ហៅ កួយ | កម្មករ | កំពង់សោម | ៧-៩-៧៦ | ១០-១០-៧៦ |
| ១០៩៣ | ព្រុំ ភាគ | មេពួក | កង៤៨៨ | ២៩-៧-៧៦ | ១០-១០-៧៦ |
| ១០៩៤ | គឹម ប៊ុនធូ | ពលកម្ម | រដ្ឋករទឹក | ៤-៨-៧៦ | ១០-១០-៧៦ |
| ១០៩៥ | ឈឿង ហ៊ឹន | យុទ្ធជន | ថាមពល | ១៥-៩-៧៦ | ១០-១០-៧៦ |
| ១០៩៦ | ស៊ីន សាមឿន | យុទ្ធជន | រោងចក្រ ក-២ | ១២-៩-៧៦ | ១០-១០-៧៦ |
| ១០៩៧ | ឃឹម យុទ្ធ ហៅ ស៊ីម | ក្រឡឹង | រោងចក្រ ជ-២ | ១២-៩-៧៦ | ១០-១០-៧៦ |
| ១០៩៨ | អ៊ុន អឿន ហៅ សៀន | យុទ្ធជន | ផែកំពង់សោម | ៨-៨-៧៦ | ១២-១០-៧៦ ឈឺស្លាប់ |

| | | | | | |
|---|---|---|---|---|---|
| ១០៩៩ | អ៊ុក យិន | កម្មករ | អគ្គិសនី | ៤-៨-៧៦ | ១៤-១០-៧៦ ឈឺស្លាប់ |
| ១១០០ | ម៉ម សំបូរ | កម្មករ | អគ្គិសនី | ៤-៨-៧៦ | ១៤-១០-៧៦ ឈឺស្លាប់ |
| ១១០១ | ស៊ីន អ៊ាង ហៅ សំអាន | អាត់សាជង់ | តាឡី | ៣១-៨-៧៦ | ១៤-១០-៧៦ ឈឺស្លាប់ |
| ១១០២ | អ៊ុង សាន | អនុវរសេនាតូច | កងពល៣១០ | ២២-៩-៧៦ | ១៤-១០-៧៦ ឈឺស្លាប់ |
| ១១០៣ | ស៊ិន សាឌី | មេក្រុមបើកឡាន | កសិកម្មរដ្ឋទឹកថ្លា | ២៣-៩-៧៦ | ១៤-១០-៧៦ ឈឺស្លាប់ |
| ១១០៤ | យ៉ាវ ញ៉ុច | ប្រជាជន | ពោធិសាត់ | ៤-១០-៧៦ | ១៤-១០-៧៦ |
| ១១០៥ | ទ្រី មួយ (ស្រី) | កម្មករ | រោងចក្រគ-១០ | ៤-១០-៧៦ | ១៤-១០-៧៦ |
| ១១០៦ | គុយ ឈុន (ស្រី) | កម្មករ | រោងចក្រប្រេងកន្ទក់ | ៤-១០-៧៦ | ១៤-១០-៧៦ |
| ១១០៧ | អៀម ម៉ារីយ៉ា ហៅ ម៉ារី (ស្រី) | | កូនស្តេចស-២១យ | ១០-១០-៧៦ | ១៤-១០-៧៦ |
| ១១០៨ | ភោគ វណ្ណារី (ស្រី) | កូនកម្មករ | ស-២១យ | ១០-១០-៧៦ | ១៤-១០-៧៦ |
| ១១០៩ | ហាក់ ហៀនហៅហៀង(ស្រី) | នយោបាយកងធំ | កងពល៣១០ | ២២-៩-៧៦ | ១៤-១០-៧៦ |
| ១១១០ | តឹក ហ៊ាង | ប្រធានបើកបរ | កសិកម្មរដ្ឋទឹកថ្លា | ៩-១០-៧៦ | ១៧-១០-៧៦ ឈឺស្លាប់ |
| ១១១១ | ហួត ប៉េងឡេង | យុទ្ធជន | កងពល១៧០ | ១៩-៩-៧៦ | ១៩-១០-៧៦ ឈឺស្លាប់ |
| ១១១២ | កែវ មុត | រដ្ឋការ | ស៊ីងប្រាល | ៧-៩-៧៦ | ២០-១០-៧៦ ឈឺស្លាប់ |
| ១១១៣ | តូច សុភាព ហៅ សុគុណ | យុទ្ធជន | កងពល១៦៤ | ១៥-៦-៧៦ | ២០-១០-៧៦ ឈឺស្លាប់ |
| ១១១៤ | នួន នឹម ហៅ រី | នីរសាស្រុក | តំបន់១៥ | ១-៩-៧៦ | ២១-១០-៧៦ ឈឺស្លាប់ |
| ១១១៥ | ឡុង ដាន ហៅ សុវណ្ណ | នីរសា | វរសេនាធំ១៥២ | ៥-៩-៧៦ | ២១-១០-៧៦ ឈឺស្លាប់ |
| ១១១៦ | យស់ សំបុក | កម្មករ | រទេះភ្លើងរមាស | ១៣-៩-៧៦ | ២១-១០-៧៦ ឈឺស្លាប់ |
| ១១១៧ | ម៉ា សួស ហៅ ឡៃ | កម្មករ | អគ្គិសនី | ៤-៨-៧៦ | ២៣-១០-៧៦ ឈឺស្លាប់ |
| ១១១៨ | សៅ ច្រិច ហៅ រុន | មេក្រុម | រោងចក្រសុរាគារ | ២៧-៨-៧៦ | ២៣-១០-៧៦ ឈឺស្លាប់ |
| ១១១៩ | សៅ ឈន ហៅ ឌន | មេពួក | ថាមពល | ៣-៨-៧៦ | ២៣-១០-៧៦ ឈឺស្លាប់ |
| ១១២០ | ញ៉ឹក អឿន | មេក្រុមទូរស័ព្ទ | កងពល១៧០ | ៦-៩-៧៦ | ២៤-១០-៧៦ ឈឺស្លាប់ |
| ១១២១ | គង់ សុផាត ហៅ សុន | វរសេនាតូច | ពាណិជ្ជកម្មកំពង់សោម | ២០-៦-៧៦ | ២៤-១០-៧៦ ឈឺស្លាប់ |
| ១១២២ | សួន ស៊ីន | គណៈសាលា | កងពល៥០២ | ១-៩-៧៦ | ២៥-១០-៧៦ ឈឺស្លាប់ |
| ១១២៣ | ស៊ឹម ស៊ីឡេណា | សក្តិ១ | តំបន់២៥ | ២១-៨-៧៦ | ២៦-១០-៧៦ ឈឺស្លាប់ |
| ១១២៤ | គិត តិប | យុទ្ធជន | កងពល៥០២ | ៥-៩-៧៦ | ២៦-១០-៧៦ ឈឺស្លាប់ |
| ១១២៥ | វ៉ាល់ សប៊ុន ហៅ ម៉ៅ | កម្មករ | អគ្គិសនី | ៤-៨-៧៦ | ២៧-១០-៧៦ ឈឺស្លាប់ |
| ១១២៦ | ម៉ៅ ហង់ ហៅ សុភី | យុទ្ធជន | កង ៤៨៨ | ៤-៨-៧៦ | ២៧-១០-៧៦ ឈឺស្លាប់ |
| ១១២៧ | ទន់ ទិត | យុទ្ធជន | ២១យ | ២៦-១០-៧៦ | ២៧-១០-៧៦ |
| ១១២៨ | អ៊ួច គិន | យុទ្ធជន | ២១យ | ២៦-១០-៧៦ | ២៧-១០-៧៦ |
| ១១២៩ | នៅ ហឿន ហៅ ហៃ | យុទ្ធជន | ២១យ | ២៦-១០-៧៦ | ២៧-១០-៧៦ |
| ១១៣០ | ដាន់ លឿម ហៅ ដាន | យុទ្ធជន | ២១យ | ២៦-១០-៧៦ | ២៧-១០-៧៦ |

**(នៅមានត)**

# ព្រឹត្តិការណ៍ខែមិថុនា ឆ្នាំ១៩៧៨ នៅស្រុកពញាក្រែក

ការចង្អុលបង្ហាញរណ្តៅសាកសពចំនួនបីកន្លែងនៅក្នុងបរិវេណព្រៃស្ទឹងតូច តាមរយៈសាក្សីនៅឃុំកក់ ស្រុកពញាក្រែក ពីរនាក់គឺ យ៉ែម យុទ្ធ និង ង៉ែត សំអឿន បានឈានទៅដល់ការបង្ហើបឲ្យដឹងពីការសម្លាប់រង្គាលជីវិតមនុស្សចំនួនមួយភូមិក្នុងរយៈពេលជិតមួយសប្តាហ៍ កាលពីអំឡុងខែមិថុនា ឆ្នាំ១៩៧៨ នៅភូមិបុស្ស ឃុំដូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម ។ យុទ្ធ និង សំអឿនបានអះអាងដូចគ្នាថា សោកនាដកម្មដ៏សាហាវឃោរឃៅនេះគឺជាការព្រមានខ្លាំងបំផុតមួយសម្រាប់កម្មាភិបាលភូមិភាគបូព៌ានិងកម្មាភិបាលជាច្រើនទៀតនៅទូទាំងប្រទេសដែលមានបំណងក្បត់បដិវត្តន៍ ។

ព្រៃស្ទឹងតូចមានចម្ងាយប្រមាណ២០គីឡូម៉ែត្រពីភូមិបុស្ស ឃុំដូនតី ។ មុនរបបខ្មែរក្រហមព្រៃស្ទឹងតូច គឺជាតំបន់ព្រៃក្រាស់ សម្បូរសត្វព្រៃនិងគ្មានមនុស្សរស់នៅ ។ នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានយកតំបន់នោះធ្វើជាកន្លែងសម្លាប់មនុស្ស ។ បច្ចុប្បន្ន ព្រៃស្ទឹងតូចគឺជា«ភូមិស្ទឹងតូច» ដែលមានប្រជាជនជាច្រើនគ្រួសាររស់នៅប្រមូលផ្តុំគ្នានិងប្រកបរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត ។

រហូតមកដល់បច្ចុប្បន្ន រណ្តៅក្រហេងក្រហូងជ្រៅៗ នៅព្រៃស្ទឹងតូចបានប្រែក្លាយជារណ្តៅរាក់ៗ ស្ទើរតែកត់សម្គាល់មិនបាន ម្យ៉ាងដោយសាររុក្ខជាតិតូចធំជាច្រើនបានដុះគ្របដណ្តប់លើរណ្តៅសាកសពទាំងនោះ ។ សាក្សីមួយចំនួនគឺជាអតីតជនរងគ្រោះដែលរួចផុតពីការសម្លាប់នៅព្រៃស្ទឹងតូចនេះ ។ សុខ គន់, យក់ អៀម, អ៊ឹម ញ៉ែម, អ៊ឹម អួន និង អ៊ឹម ពៅ ព្រមទាំងជនរងគ្រោះចំនួន១៣នាក់ផ្សេងទៀតបានដឹងអំពីរណ្តៅសាកសពជាច្រើននៅតំបន់នោះ ។

សុខ គន់ ជាគ្រូបង្រៀននៅសាលាបឋមសិក្សាឃុំដូនតីជាជនរងគ្រោះផ្ទាល់ដែលត្រូវខ្មែរក្រហមវាយពីរដំបងទម្លាក់ចូលក្នុងរណ្តៅតែមិនទាន់ស្លាប់ ។ គន់ បានអធិប្បាយប្រាប់ហេតុការណ៍នៅទីតាំងសម្លាប់ព្រៃស្ទឹងតូចថា៖

«នៅខែមិថុនា ឆ្នាំ១៩៧៨ បន្ទាប់ពីការចាប់ខ្លួន សោភឹម ប្រធានភូមិភាគបូព៌ា មនុស្សរាប់ពាន់នាក់ដែលស្ថិតនៅក្រោមការដឹកនាំរបស់គាត់ត្រូវបានសម្លាប់ក្នុងនោះមានទាំងប្រជាជនជាច្រើនរយនាក់នៅភូមិបុស្ស ឃុំដូនតី ស្រុកពញាក្រែកផង ។ ជនរងគ្រោះទាំងក្មេងទាំងចាស់មួយភូមិត្រូវខ្មែរក្រហមដឹកតាមរថយន្តធំៗជាច្រើនគ្រឿងយកទៅសម្លាប់នៅទីនោះ ។ សោកនាដកម្មដ៏គួរឲ្យព្រឺក្បាលនេះបានប្រព្រឹត្តទៅនៅ ក្រោយមួយថ្ងៃបន្ទាប់ពីមានការកោះហៅប្រជាជនក្នុងភូមិទាំងអស់ឲ្យចូលរួមប្រជុំ ។ ចំណុចសំខាន់នៃការប្រជុំនេះគឺផ្តោតទៅលើការផ្លាស់ប្តូរទីលំនៅនិងទម្លាក់កំហុសទៅលើប្រធានភូមិភាគបូព៌ាថាបានក្បត់នឹងបដិវត្តន៍ ។ កម្មាភិបាលក្មេងៗដែលទើបតែផ្លាស់មកពីភូមិភាគនិរតី បានតាំងខ្លួនជាឪពុកម្តាយនិងជាអ្នកត្រួតត្រាលើភូមិភាគបូព៌ាទាំងស្រុង» ។

រណ្តៅជាច្រើនត្រូវខ្មែរក្រហមជីកទុកជាស្រេចនៅបរិវេណព្រៃស្ទឹងតូច បន្ទាប់ពីបានកាប់ឆ្ការព្រៃក្រាស់ៗចេញ ព្រមទាំងបានជ្រើសរើសទីតាំងមួយកន្លែងទៀតដែលស្ថិតនៅក្នុងបរិវេណនោះធ្វើជាកន្លែងឃុំឃាំងបណ្តោះអាសន្នរង់ចាំការសម្លាប់ចោល ។ អ្នកទោសត្រូវចងស្លាបសេកនិងរុំមុខនឹងក្រមា ឬក្រណាត់ ហើយដឹកតាមរថយន្ត ដោយមានកងឈ្លបការពារផង ។ គន់ និយាយពីកងឈ្លបថា «អាកងឈ្លបម្នាក់ជិះ នៅកាប៊ីនមុខជាមួយតៃកុងឡាន និងអាពីរនាក់ទៀត នៅយាមខាងក្រោយឡាន ។» ខ្ញុំត្រូវខ្មែរក្រហមចងក្រមាឃ្លុំមុខជិត ហើយដៃទាំងពីរត្រូវចងនឹងខ្សែអង្រឹង ។ ប្រពន្ធកូនខ្ញុំទាំងអស់ក៏ជិះឡានជាមួយនឹងខ្ញុំដែរ ប៉ុន្តែមិនដឹងនៅត្រង់ណា ព្រោះសុទ្ធតែរុំមុខទាំងអស់» ។ កុំថាឡើយតែមនុស្សចាស់ដែលត្រូវចោទប្រកាន់ថាបានចូលរួមក្បត់បដិវត្តន៍ជាមួយប្រធានភូមិភាគរបស់ខ្លួន សូម្បីតែក្មេងតូចៗក៏ត្រូវចោទប្រកាន់និងយកទៅសម្លាប់ចោលដែរ ។ រថយន្តមួយគ្រឿងអាចដាក់

មនុស្សបានលើសពី៥០នាក់ ហើយបើកតាមផ្លូវក្រវេចក្រវៀន បត់ចុះបត់ឡើងធ្វើឲ្យជនរងគ្រោះទាំងអស់មិនដឹងពីគោលដៅដែលត្រូវទៅឡើយ ។

ពេលទៅដល់ទីលានសម្លាប់នៅព្រៃស្ទឹងតូច គន់ និងអ្នក៦ទៀតៗបានត្រូវកងឈ្លបបណ្តេញឲ្យចុះពីលើរថយន្តទាំងក្រមារុំមុខនិងដៃជាប់ចំណង ។ គន់ ដឹងថាមានមនុស្សច្រើននាក់ណាស់នៅក្បែរៗគាត់ ក្រោមដើមឈើមួយដើម ។ ជនរងគ្រោះជាបុរសត្រូវខ្មែរក្រហមបណ្តើរយកទៅសម្លាប់មុន បន្ទាប់មកទៀតគឺស្ត្រីនិងកុមារ ។

ខ្មែរក្រហមបានយកខ្សែចំណងមួយទៀត ទៅចងភ្ជាប់អ្នកទោសពីម្នាក់ទៅម្នាក់រួចបណ្តើរទៅកាន់រណ្តៅសម្លាប់ជាបណ្តើរៗតាមម៉ោងពេលដែលថ្នាក់លើបានកំណត់ ។ គន់ ត្រូវកងឈ្លបចងជាមួយនឹងជនរងគ្រោះ៧នាក់ផ្សេងទៀត ហើយបណ្តើរចេញទៅ ។ កងឈ្លបខ្មែរក្រហមបានស្រាយចំណងរុំមុខគាត់ចេញ ហើយស្រែកគំហកឲ្យគាត់លុតជង្គង់នៅមាត់រណ្តៅ ។ «ខ្ញុំមិនដែលធ្លាប់ស្គាល់ទីនោះពីមុនមកទេ ។ ខ្ញុំឃើញមានសាកសពប្រហែល១០នាក់ដេកស្តូកស្តឹងប្រគងប្រគាក់គ្នានៅក្នុងរណ្តៅ ។ ខ្ញុំដឹងខ្លួនថាពិតជាស្លាប់មិនខាន ព្រោះកងឈ្លបពីរនាក់ដែលឈរនៅមាត់រណ្តៅមានកាន់ដំបងមួយម្នាក់បម្រុងវាយសម្លាប់ខ្ញុំ» ។

នៅកន្លែងផ្សេងទៀត នៃបរិវេណព្រៃស្ទឹងតូចខ្មែរក្រហមបានធ្វើសកម្មភាពដូចគ្នានឹងហេតុការណ៍ដែលកើតឡើងលើរូប គន់ ដែរ ។ នៅបរិវេណនោះមានរណ្តៅច្រើនណាស់ស្ថិតនៅជាប់ៗគ្នាខណ្ឌដោយព្រៃរបោះ ។ «ខ្ញុំមិនបានចាំរណ្តៅដែលវា(ខ្មែរក្រហម) វាយខ្ញុំទម្លាក់ទេ ព្រោះកាលនោះមានរណ្តៅច្រើនពេក ហើយចម្ងាយពីរណ្តៅមួយទៅរណ្តៅមួយខណ្ឌគឺដោយព្រៃរបោះ» ។ គន់ ត្រូវកងឈ្លបខ្មែរក្រហមវាយផ្ទប់គ្នាពីរដំបង រួចធាក់ទម្លាក់ចូលក្នុងរណ្តៅដែលមានទំហំបណ្តោយប្រហែល៣ម៉ែត្រ ទទឹង២ម៉ែត្រនិងជម្រៅ២ម៉ែត្រ ។ គន់ នៅចាំបានថាជុំវិញមាត់រណ្តៅមានសុទ្ធតែក្រមានិងខ្សែអង្រឹងដែលខ្មែរក្រហមប្រើប្រាស់សម្រាប់ចងអ្នកទោស ។


វិចិត្រករៈ វ៉ាន់ ណាត អតីតអ្នកទោសមន្ទីរស-២១


សុខ គន់

គន់ ប្រាប់ថា «ខ្ញុំត្រូវពួកវាចាប់ខ្លួននៅវេលាម៉ោងប្រហែល៥ល្ងាចហើយ នៅម៉ោងប្រហែល៦ ល្ងាចថ្ងៃដដែល ខ្ញុំបានទៅលុតជង្គង់នៅមាត់រណ្តៅ និងត្រូវខ្មែរក្រហមវាយទម្លាក់រណ្តៅតែម្តង» ។ គន់ ជាមនុស្សតែម្នាក់គត់ដែលបានរួចជីវិតពីការវាយសម្លាប់របស់ខ្មែរក្រហម ដោយសារគាត់ធ្វើពុតជាស្លាប់ក្នុងគំនរសាកសពជាច្រើននាក់ទៀតដែលនៅពីលើគាត់ ។ «ខ្ញុំត្រូវសាកសពជាច្រើនគ្របពីលើ ខ្ញុំរាប់ទៅឃើញមានចំនួន២៧នាក់ ។ អស់រយៈពេលប្រហែលពីរម៉ោងក្រោយមកខ្ញុំបានវារចេញពីរណ្តៅឡើងមកពួនសម្ងំនៅក្បែរគុម្ពោតព្រៃមួយដែលមានចម្ងាយប្រហែល៣០ម៉ែត្រពីរណ្តៅ» ។ គន់ បន្តថា គាត់និងសាកសពឯទៀតត្រូវកងឈ្លបចុះរៀបនិងស្រាយចំណងចេញពីដៃទើបគាត់មានឱកាសលួចរត់ចេញពីរណ្តៅបាន ។ «ខ្ញុំប្រវេប្រវាចេញពីរណ្តៅទាំងក្បាលហូរឈាមសស្រាក់» ។

ក្នុងអំឡុងពេលពេញមួយយប់នាខែមិថុនា ឆ្នាំ១៩៧៨ គន់ បានពួនសម្ងំមើលឃើញសកម្មភាពសម្លាប់ទាំងអស់របស់កងឈ្លបខ្មែរក្រហមដែលធ្វើមកលើជនរងគ្រោះ ។ ខ្មែរក្រហមក្មេងៗដែលមានអាយុមិនដល់២០ឆ្នាំផង បានសម្លាប់មនុស្សអស់រាប់រយនាក់នៅក្នុងបរិវេណព្រៃស្ទឹងតូច ។ គ្រាន់តែនៅក្នុងរង្វង់ដីប្រហែល៣០ម៉ែត្រ គន់ ឃើញមានរណ្តៅចំនួន៥និងសាកសពប្រហែល២០០នាក់ ។ គន់ និយាយថា «មានរណ្តៅច្រើនណាស់ ប៉ុន្តែខ្ញុំមិនអាចរាប់បានទេ ព្រោះមានព្រៃរបោះជារនាំង ។ ខ្ញុំឮសម្រែកមនុស្សចេញមកពីគ្រប់ទិសនៃព្រៃស្ទឹងតូច ប៉ុន្តែគ្មាននរណាជួយអ្នកណាទេ» ។

មួយយប់បានកន្លងផុតទៅ នៅវេលាម៉ោង៤ទៀបភ្លឺ ការសម្លាប់មនុស្សនៅព្រៃស្ទឹងតូចត្រូវបានបញ្ចប់ទាំងរដាក់រដុប ហើយមានរណ្តៅខ្លះមិនទាន់លុបជិតស្រួលបួលផង ។ ខ្លះទៀតបានត្រឹមយកមែកឈើនិងកូនឈើមកគ្របពីលើប៉ុណ្ណោះ ។ ចំហាយក្លិនអសោចបានធ្វើឲ្យប្រជាជនដែលដើរ កាត់ចុះឡើងទៅធ្វើការនៅការដ្ឋានក្បែរៗនោះនឹកភ្នកទៅដល់ការសម្លាប់មនុស្សរបស់ខ្មែរក្រហមភ្លាម ។

យ៉ែម យុទ្ធ ជាអ្នកជួយព្យាបាលរបួសឲ្យ គន់ ពេលដែលគាត់ឃើញ គន់ វារចេញពីកន្លែងសម្លាប់ព្រៃស្ទឹងតូច ។ យុទ្ធ និយាយដូច្នេះថា «នៅពេលខ្ញុំចេញពីធ្វើការនៅការដ្ឋានវិញ ខ្ញុំបានប្រទះឃើញគាត់ (គន់) ហើយខ្ញុំក៏ជួយគាត់តែម្តងទៅ» ។

អ្នកមីង យក់ អៀម និងកូនរបស់គាត់គឺ អ៊ឹម ញ៉ែម, អ៊ឹម អួន និង អ៊ឹម ពៅ បានរួចខ្លួនពីការសម្លាប់របស់កងឈ្លបខ្មែរក្រហមនៅព្រៃស្ទឹងតូចដែរ ដោយសារ អៀម មានកូនប្រុសច្បងឈ្មោះ ភឿក បម្រើការជាកងទ័ពនៅមជ្ឈិម ។

អៀម និងកូនៗរបស់គាត់ត្រូវកងឈ្លបបញ្ជាឲ្យឡើងឡានជាមួយនឹងអ្នកឯទៀត រួចបញ្ជូនទៅកាន់ទីតាំងសម្លាប់ព្រៃស្ទឹងតូច ។ ញ៉ែម ត្រូវខ្មែរក្រហមបណ្តើរជាមួយអ្នកឯទៀតយកទៅកាន់រណ្តៅដើម្បីសម្លាប់ ។ ញ៉ែម និយាយថា «ខ្ញុំត្រូវពួកវារុំក្រមាមុខយ៉ាងតឹង ហើយឲ្យដិះឡានផ្សេងពីម៉ែនិងប្អូនៗ» ។ ប៉ុន្តែក្រោយមកគាត់ត្រូវហៅឲ្យត្រឡប់មកវិញដើម្បីទទួលបញ្ជាឲ្យទៅរស់នៅសហករណ៍ថ្មីមួយទៀត តាមការកំណត់របស់កងឈ្លប ។ ញ៉ែម ដឹងច្បាស់ថា ខ្មែរក្រហមមិនសម្លាប់គាត់ដោយសារតែគាត់មានបងប្រុសម្នាក់ធ្វើកងទ័ពនៅមជ្ឈិម ។ ចំណែកឪពុករបស់ ញ៉ែម មិនមានសំណាងដូចកូននិងប្រពន្ធឡើយ ខ្មែរក្រហមយកគាត់ទៅសម្លាប់មុនប្រពន្ធកូនមួយថ្ងៃ ។ ញ៉ែម បានបន្តទៀតថា គាត់បានដើរកាត់រណ្តៅសាកសពជាច្រើនទម្រាំទៅដល់រណ្តៅដែលខ្មែរក្រហមប្រុងសម្លាប់គាត់ ។ «ខ្ញុំមិនដឹងរណ្តៅមួយណាជារណ្តៅដែលកងឈ្លបសម្លាប់ឪពុករបស់ខ្ញុំឡើយ ព្រោះរណ្តៅដែលមានសាកសពពេញត្រូវលុបដីពីលើអស់ហើយ» ។ មីង អៀម និយាយថា «កងឈ្លបនោះមិនបានដឹងថាគាត់ មានកូនប្រុសធ្វើការនៅមជ្ឈិមទេ ។ ប្រសិនបើវាដឹងថាគាត់មានកូននៅធ្វើការឯមជ្ឈិម ប្តីខ្ញុំពិតជាមិនស្លាប់ឡើយ» ។ មីងអៀម និងកូនទាំងបីរបស់គាត់ត្រូវកងឈ្លបខ្មែរក្រហមដោះលែងនិងបញ្ជាឲ្យចាកចេញពីទីតាំងសម្លាប់ជាបន្ទាន់ ។ អៀម និងកូនរបស់គាត់បានមករស់នៅក្នុងមន្ទីរសន្តិសុខមួយឈ្មោះថា «ម៉ែសាក់» បន្ទាប់មកគាត់បានភៀសខ្លួន មករស់នៅជាមួយប្រជាជននៅឃុំកណ្តាលជ្រុំ រហូតទាល់តែដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

**ផេង ពង្សរ៉ាស៊ី**

# បដិវត្តន៍របស់ កិត ភឿន




កិត ភឿន ភេទស្រី អាយុ៤៣ឆ្នាំ កើតនៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល ។ ភឿន ចូលបម្រើបដិវត្តនៅឆ្នាំ១៩៧៤ ដោយសារជឿតាមពាក្យឃោសនារបស់យុវជន យុវនារីដែលចូលបម្រើបដិវត្តមុនថា "ចូលបម្រើបដិវត្តន៍ ទៅវែកបាយស្នូក មានពេលលេងសើចប្រដេញប្រលែងគ្នាសប្បាយណាស់" ។ កាលណោះ ភឿន មានអាយុ១៥ឆ្នាំ បាននឹកឃើញដល់ការសប្បាយនោះក៏បបួលមិត្តភក្តិអាយុស្របាល។គ្នាលួចរត់ចេញពីផ្ទះទៅបម្រើកងទ័ពរំដោះ ដោយមានតែខោអាវមួយកំប្លេជាប់នៅនឹងខ្លួនប៉ុណ្ណោះ ។ នៅពេល ភឿន ទៅដល់មន្ទីរស្រុកកោះធំ កម្មាភិបាលដែលធ្វើការនៅទីនោះធ្លាប់បានស្គាល់និងរាប់អានជាមួយបងស្រីរបស់ ភឿន បានប្រាប់ឲ្យត្រឡប់ទៅផ្ទះវិញ ។ ភឿន បានបដិសេធ ហើយនៅតែជម្នះទៅមុខបន្តទៀត ។

ភឿន ត្រូវបានអង្គការខ្មែរក្រហមបញ្ជូនទៅរៀនវគ្គនយោបាយ នៅវត្តកំពតពុលអស់រយៈពេល២ខែ ទើបបញ្ជូនបន្តទៅហាត់បច្ចេកទេសកងទ័ពនៅព្រែកតាទែនអស់រយៈពេល៣ខែទៀត ។ បន្ទាប់មក ភឿន ត្រូវបានអង្គការខ្មែរក្រហមបញ្ជូនឲ្យទៅនៅក្នុងកងពល១១ ដែលមានឈ្មោះ សោម ជាគណៈកងពល ។ ភឿន ស្ថិតនៅក្នុងកងនារីដែលមានឈ្មោះ ម៉ៅ ជាគណៈវរសេនាធំ ។ នៅក្នុងកងពល១១ គណៈវរបានរៀបចំឲ្យយុទ្ធនារីទាំងអស់ធ្វើដំណើរដោយថ្មើរជើងពីព្រែកតាទែនទៅហាត់បាញ់ស៊ីបនៅភ្នំតាម៉ៅក្នុងរយៈពេលកន្លះខែ ។ ក្រោយពេលបញ្ចប់ការហាត់បាញ់កាំភ្លើងយុទ្ធនារីទាំងអស់ត្រឡប់មកអង្គភាពនៅព្រែកតាទែនវិញ ដើម្បីទទួលការបែងចែកទៅតាមមុខព្រួញប្រយុទ្ធ ។ យុទ្ធនារីណាដែលបាញ់កាំភ្លើងបានល្អ មានរាងកាយធំមាំមួននិងមានកាយសម្បទាល្អ ត្រូវបានចាត់តាំងឲ្យឡើងប្រយុទ្ធនៅលើសមរភូមិមុខ ។ ចំណែក ភឿន បាញ់កាំភ្លើងមិនបានល្អ ហើយមានអាយុតិចផងនោះ ត្រូវបានគណៈវរៈចាត់តាំងឲ្យនៅក្នុងកងវែកបាយស្នូកដែលមានមុខព្រួញប្រយុទ្ធនៅសមរភូមិសិត្បូ សមរភូមិព្រេញច្រុំ ទួលក្រសាំង ជ្រុងលាបស្ថិតនៅភាគខាងត្បូងក្រុងភ្នំពេញ ។ ចំពោះកងវែកបាយ គឺកងនារី។ត្រូវវែកបាយស្នូកយកទៅឲ្យខាងកងនារី។ដែលកំពុងត្រៀមប្រយុទ្ធនៅលើសមរភូមិ ។ ចំណែកបុរសត្រូវវែកបាយយកទៅឲ្យកងបុរស ។ នៅអំឡុងពេលធ្វើសង្គ្រាមនារីនិងបុរសអាចប្រាស្រ័យទាក់ទងគ្នាដូចធម្មតា ។ ប្រសិនបើមានយុទ្ធនារីណាមួយមានជំងឺឬត្រូវរបួសដែលនាំឲ្យសមរភូមិខ្វះកម្លាំង គណៈវរៈនឹងដកកងវែកបាយស្នូកឲ្យឡើងទៅជំនួសនៅលើសមរភូមិ ។ ភឿន ធ្លាប់ឡើងទៅជំនួសនៅលើសមរភូមិម្តងម្កាលដែរ ។

កងវែកបាយស្នូកនិងកងសែងរបួសត្រូវធ្វើការតែនៅពេលមានការប្រយុទ្ធគ្នាប៉ុណ្ណោះ ក្រៅពីនេះត្រូវមានភារកិច្ចដើររកម្ហូបដូចជាទៅរកត្រីជាដើមដើម្បីធ្វើប្រហុកទុក ។

នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ភឿន បានឡើងទៅទីក្រុងភ្នំពេញជាមួយកងពល១១ ។ នៅពេលដែលកងរបស់ ភឿន ចូលមកដល់ទីក្រុងភ្នំពេញ ខ្មែរក្រហមបានបញ្ជាឲ្យជម្លៀសប្រជាជនចេញទៅជនបទបណ្តើរ។ហើយ ។ អង្គភាពរបស់ ភឿន បានស្នាក់នៅក្នុងបន្ទាយស្លឹកមួយក្បែរមន្ទីរពេទ្យរបេងម៉ុំទួលទំពូង ។ រយៈពេលដែលស្នាក់នៅទីក្រុងភ្នំពេញ ភឿន ត្រូវបានចាត់តាំងឲ្យរៀបចំសម្អាតផ្ទះសម្បែង គណៈបញ្ជាការបានប្រាប់ ភឿន ថា រៀបចំផ្ទះដើម្បីចាប់ខ្មាំងដែលពួនសម្ងំនៅក្នុងផ្ទះថ្ម ។ បន្ទាប់ពីបោសសម្អាត រៀបចំផ្ទះសម្បែងបានរយៈពេល២សប្តាហ៍ ភឿន ត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែនៅស្ទឹងកន្ទួត ស្ទឹងបាគូព្រែស ។ នៅពេលនោះកងពល១១ត្រូវបានរំលាយចោល ហើយបំបែកកម្លាំងខ្លះបញ្ចូលទៅក្នុងកងពល៧០៣ ខ្លះបញ្ចូលទៅក្នុងកងពល១៦៨នៅកំពង់សោមនិងខ្លះទៀតកងពល៥០២ ។

កងវរសេនាធំរបស់ ភឿន ត្រូវបញ្ចូលទៅក្នុងកងពល៥០២ ដែលមានទីតាំងនៅព្រលានយន្តហោះពោធិ៍ចិនតុង ហើយ ភឿន ត្រូវបញ្ជូនមកធ្វើស្រែនៅអូរបែកក្អមនិងទួលលោភី ។

នៅអំឡុងឆ្នាំ១៩៧៦ ភឿន មានជំងឺត្រូវប្រធានកងពលបញ្ជូនមកសម្រាកនៅមន្ទីរពេទ្យរបស់អង្គភាព ។ ភឿន បានឃើញអតីតទាហាន លន់ ណុល ម្នាក់ដើរឱនត្រុនៗទៅបើកឆ្នាំងបាយនៅផ្ទះបាយរបស់មន្ទីរពេទ្យ ភឿន ក៏ស្រែកឆោឡោឡើងធ្វើឲ្យកម្មាភិបាលពេទ្យដែលយាមប្រចាំការចាប់អតីតទាហាននោះបាន ប៉ុន្តែ ភឿន មិនដឹងថាខ្មែរក្រហមនាំយកអតីតទាហាន លន់ ណុល នោះទៅទីកន្លែងណាឡើយ ។

នៅដើមឆ្នាំ១៩៧៧ ភឿន ធ្លាប់បានឃើញកងទ័ពខ្មែរក្រហមចាប់អតីតទាហាន លន់ ណុល ម្នាក់ទៀតដែលមានរូបរាងស្គមស្គាំង សក់ក្បាលវែង ហៀរទឹកមាត់កក្អាក់វារចេញពីក្នុងលូមក ទំនងដូចជាដើរលែងរួចទៅហើយ ។

នៅចុងឆ្នាំ១៩៧៧ អង្គការខ្មែរក្រហមមានផែនការបញ្ជូនយុទ្ធជនមួយចំនួននៅក្នុងកងពល៥០២ឲ្យទៅកសាងព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង ប៉ុន្តែបញ្ជូនទៅជាវគ្គៗ គឺរយៈពេល ២ខែម្តងនឹងមានការផ្លាស់ប្តូរកម្លាំងឲ្យត្រឡប់មកកន្លែងដើមវិញ ហើយអ្នកថ្មីនឹងត្រូវទៅជំនួសម្តង ។ ភឿន ធ្លាប់បានទៅធ្វើការនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំងរយៈពេល២ខែ ទើបអង្គការខ្មែរក្រហមបញ្ជូនមកធ្វើស្រែនៅអូរបែកក្អមវិញ ។ ក្នុងរយៈពេលធ្វើស្រែនៅអូរបែកក្អម កងនារីរបស់ ភឿន ត្រូវទៅធ្វើស្រែជាមួយកងបុរសៗដែរ ។ ភឿន បានឲ្យដឹងថា “អង្គការមិនហាមឃាត់នារីមិនឲ្យនិយាយស្តីជាមួយបុរសឡើយ លើកលែងតែមានទំនាក់ទំនងស្នេហា” ។ ប្រសិនបើយុវជនណាម្នាក់ចង់បានគូស្រករត្រូវប្រាប់ឲ្យគណៈគ្រប់គ្រងអង្គភាពរបស់ខ្លួនសរសេរសំបុត្រដោយមានភ្ជាប់ប្រវត្តិរូបសាមីខ្លួនខាងបុរសនិងឈ្មោះនារី ដែលខ្លួនពេញចិត្តផ្ញើទៅឲ្យគណៈគ្រប់គ្រងនារី ។ ចំណែកពិធីរៀបការគឺរៀបចំម្តងៗចំនួន១០,២០ ឬ ៣០គូ ដោយគ្រាន់តែឲ្យគូស្វាមីភរិយាឡើងចាប់ដៃប្តេជ្ញានិងហូបបាយតែមួយពេលប៉ុណ្ណោះគឺចប់សព្វគ្រប់ ។ ភឿន ធ្លាប់មានយុទ្ធជនខ្មែរក្រហមស្នើចំនួនពីរលើក ។ លើកទី១ កាលពីនៅធ្វើស្រែនៅអូរបែកក្អមប៉ុន្តែ ភឿន បានប្រកែកមិនព្រមរៀបការ ។ នៅចុងឆ្នាំ១៩៧៨ ភឿន ត្រូវបានស្នើឲ្យរៀបការម្តងទៀត ។ ដោយសារខ្លាចអង្គការដាក់ទោស ភឿន ក៏យល់ព្រមរៀបការ ។ ភឿន បានរៀបការនៅអរិយក្សត្រ ជាមួយយុទ្ធជនម្នាក់ដែលមានស្រុកកំណើតនៅស្រុកកោះធំដូចគ្នា ។

នៅពាក់កណ្តាលឆ្នាំ១៩៧៨ អង្គការខ្មែរក្រហមបានដកកម្លាំងមួយចំនួននៅក្នុងកងពល៥០២ឲ្យចុះទៅគ្រប់គ្រងប្រជាជននៅតាមមូលដ្ឋានជុំវិញទីក្រុងភ្នំពេញ ។ ភឿន និងមិត្តភក្តិ៣នាក់ទៀតត្រូវបានចាត់តាំងឲ្យធ្វើគណៈឃុំសារិកាកែវ(អរិយក្សត្រ) ។ ភឿន បានឲ្យដឹងថា “របនាសម្ព័ន្ធគ្រប់គ្រងប្រជាជនអត់មានផ្លាស់ប្តូរទេអ្នកនៅកន្លែងណាគឺនៅកន្លែងនោះដដែល ដោយគ្រាន់តែផ្លាស់ប្តូរការហូបចុកប៉ុណ្ណោះ ដូចជាពេលមុនប្រជាជនបង្កបង្កើនផលបានប៉ុន្មានត្រូវបញ្ជូនទៅមជ្ឈិមនៅភ្នំពេញទាំងអស់ ទើបបែងចែករបបមកតាមមូលដ្ឋានវិញ ។ ប៉ុន្តែពេលនោះយើងបង្កបង្កើនផលបានប៉ុន្មានគឺយើងទុកផ្គត់ផ្គង់ប្រជាជនទាំងអស់ ។ ក្នុងរយៈពេលគ្រប់គ្រង់នៅឃុំសារិកាកែវប្រជាជនបានហូបចុកគ្រប់គ្រាន់ ។ ក្រុមរបស់ខ្ញុំមិនបង្ខិតបង្ខំប្រជាជនឲ្យធ្វើការហួសកម្លាំងទេ ដោយឲ្យធ្វើការងារតាមធម្មតា ។ ចំពោះប្រជាជនណាដែលមានជំងឺយើងអាចឲ្យក្មេងៗឡើងបេះដូងឲ្យគាត់ហូបបានគឺប្រជាជនបានឆ្ងាញ់និងមិនខ្វះហូបទេ ។ ខ្ញុំបើកចំហឲ្យប្រជាជនធ្វើការងារឲ្យតែពួកគាត់បានស្រួល បានឆ្ងាញ់ ។ ចំណែកឯការងារប្រជុំខាងគណៈឃុំយើងខ្ញុំបានដាក់ទិសដៅឲ្យថាឥឡូវភូមិ(ខ) ត្រូវទៅជួយដកស្ទូងនៅភូមិ(ក) គឺយើងគ្រាន់តែផ្លាស់ប្តូរក្នុងភូមិ យើងគ្មានជំរុញឲ្យប្រជាជនធ្វើអ្វីទៀតទេ និងគ្រាន់តែបែងចែកទៅតាមផ្នែកទៅតាមកងដូចជាកងចល័តដែលមានកម្លាំងមាំមួន កងចាស់ៗមួយក្រុមនៅដាំបន្លែជូនរដ្ឋ ចាស់ៗមួយក្រុមជំទង់មួយក្រុមនៅដាំបន្លែ ឧបត្ថម្ភសហករណ៍គឺចែកតាមផ្នែកអ៊ីចឹងមិនបាច់ចាត់តាំងអីច្រើនទេ ។ ពេលបើកសម្ភារសម្រាប់ប្រជាជនក្នុងឃុំ មិនបាច់ឆ្លងកាត់ស្រុកតំបន់ទេ គឺខ្ញុំឡើងមកបើកនៅភ្នំពេញនៅកងពល៥០២ផ្ទាល់តែម្តង” ។

ភឿន គ្រប់គ្រងប្រជាជននៅឃុំសារិកាកែវ(អរិយក្សត្រ) បានរយៈពេល៧ខែ ទើបកងទ័ពវៀតណាមវាយចូលមកប្រទេស

កម្ពុជា ។ ខណៈពេលនោះដោយមានការភ័យខ្លាចកងទ័ពវៀតណាម ចាប់ ភឿន ក៏បានរត់ភៀសខ្លួនជាមួយកម្មាភិបាលខ្មែរក្រហមជាច្រើននាក់ទៀតទៅភាគខាងលិចប្រទេសកម្ពុជា ។ មកដល់ខេត្តកំពង់ស្ពឺ ភឿន ក៏ស្នាក់នៅទីនោះមួយរយៈ ។

នៅពេលកងទ័ពវៀតណាមវាយកាន់តែ ជិត ភឿន បានភៀសខ្លួនទៅមុខរហូតដល់ភ្នំក្បាលគោ ។ នៅពេលនោះខ្មែរក្រហមបានកៀរប្រជាជនជាច្រើនឡើងភ្នំ ។ នៅពេលកំពុងរត់ ភឿន បានជួបយាយ គុន ដែលធ្លាប់ធ្វើជាប្រធានភូមិនៅស្រុកកំណើតរបស់ខ្លួន ហើយបាននិយាយប្រាប់ ភឿន ថា «ឪពុករបស់ឯងមកតាមក្រោយ» ។ ភឿន នៅចាំរកមើលឪពុករហូតដល់ផុតហ្វូងមនុស្សនៅតែមិនឃើញ ក៏សម្រេចចិត្តធ្វើដំណើរបន្តទៅទៀត ។ ភឿន និយាយថា «ពេលធ្វើដំណើរយើងលែងគិតថាអ្នកណាមេ អ្នកណាកើយទៀតហើយ គិតតែយករួចខ្លួនឯងប៉ុណ្ណោះ ។ សម្ភារផ្សេងៗត្រូវបោះបោលទាំងអស់ ទុកតែខែអង្ករនិងអំបិលប៉ុណ្ណោះ» ។ ពេលនោះកងទ័ពវៀតណាមបានដេញរហូតធ្លាក់ទៅដល់ព្រំដែនថៃ ។ ទាហានថៃបានបញ្ជូនអ្នកទាំងនោះទៅជំរំខៅអ៊ីដាង ។ នៅក្នុងជំរុំខៅអ៊ីដាង មានជនភៀសខ្លួនរាប់ពាន់នាក់ដែលស្ថិតនៅក្រោមការជួយផ្គត់ផ្គង់របស់កាកបាទក្រហមអន្តរជាតិ ។ ភឿន បានរត់ឡើងភ្នំចូលមកទឹកដីកម្ពុជាជាមួយមនុស្សប្រមាណ១០នាក់ផ្សេងទៀត ប៉ុន្តែត្រូវទាហានថៃចាប់បានបញ្ជូនទៅវិញ ។ ពេលនោះទាហានថៃបានសួរថា ចង់នៅជំរំខៅអ៊ីដាង ឬជំរំព្រះពុទ្ធ? ។ ភឿន បានស្នាក់នៅជំរំព្រះពុទ្ធអស់រយៈពេល៤ខែ ក៏សុំខ្មែរក្រហមឡើងភ្នំម្តងទៀត ។ ការរស់នៅជាមួយកងទ័ពខ្មែរក្រហមយូរៗទៅក៏កកើតជាគ្រួសារកាន់តែច្រើនទៅៗ ទើបនាំគ្នាសុំអនុញ្ញាតបង្កើតជំរំមួយដែលមានឈ្មោះថាអង់ជីសាយដេ ។ នៅក្នុងជំរំភាគច្រើនជាក្រុមគ្រួសារកូនចៅរបស់ខ្មែរក្រហម ដែលជីវភាពរស់នៅប្រចាំថ្ងៃ គឺដាំបន្លែបង្ការបន្តិចបន្តួចនិងទទួលរបបអង្ករ ត្រីខកំប៉ុង ប្រហុក អំបិលពីកាកបាទក្រហមអន្តរជាតិ ។ ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះកាកបាទក្រហមអន្តរជាតិបើកស្បៀងអាហារឲ្យមិនទៀងទាត់ទើបបងប្អូននៅក្នុងជំរំអង់ជីសាយដេ បានរំសាយមករស់នៅជំរំសាយយេវិញ ។ ភឿន បានស្នាក់នៅជំរំសាយយេ រហូតដល់ពេលធ្វើមាតុភូមិនិវត្តន៍មកស្រុកកំណើតនៅឆ្នាំ១៩៩៣ ។

សព្វថ្ងៃនេះ ភឿន ជាស្ត្រីមេម៉ាយរស់នៅជាមួយកូន៥នាក់ប្រកបរបរធ្វើស្រែចម្ការ ។ ភឿន បានឲ្យដឹង ថា«គ្រួសារខ្ញុំមានជីវភាពយ៉ាប់យ៉ឺន ពីព្រោះខ្ញុំមានដីធ្វើស្រែចម្ការបន្តិចបន្តួចមិនអាចហូបចុកគ្រប់គ្រាន់ឡើយ» ។

**ឡុង ដានី**

## ពន្យល់ពាក្យខ្មែរក្រហម

◆***រាបសា:*** *ជឿជាក់លើកម្លាំងប្រជាជនមូលដ្ឋាន ពឹងផ្អែកលើប្រជាជនមូលដ្ឋាន ហើយដាក់កាយចិត្តឃោសនាអប់រំ និងកសាងកម្លាំងសម្ព័ន្ធភាពកម្មករ-កសិករ ។ គឺរាបសាជាមួយប្រជាជនមូលដ្ឋាន រាបសាជំហរជាសំខាន់មិនមែនត្រឹមតែជារូបភាព ។*

◆***ម៉ត់ចត់:*** *គឺខ្លួនឯងត្រូវម៉ត់ចត់ តឹងរ៉ឹង តែអធ្យាស្រ័យឲ្យអ្នកដទៃ ។ ម្យ៉ាងទៀតត្រូវគិតគូរដោះស្រាយគ្រប់បញ្ហាតាមសមូហភាពតាមខ្សែចាត់តាំងនឹងដោយថ្លឹងថ្លែងក្នុងស្មារតីទទួលខុសត្រូវចំពោះប្រជាជនមូលដ្ឋាន ។*

*(ដកស្រង់ចេញពីសៀវភៅ: ការងារពង្រឹងនឹងកែលម្អគោលជំហរនិងអាកប្បកិរិយាដឹកនាំនិងធ្វើការងាររបស់បក្ស)*

## សេចក្តីជូនដំណឹង

សមាគមអ្នកនិពន្ធខ្មែរ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមជម្រាបជូនដំណឹងដល់ម្ចាស់អត្ថបទដែលបានផ្ញើអត្ថបទមកកាន់សមាគមអ្នកនិពន្ធខ្មែរ ដើម្បីចូលរួមក្នុង «វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ» ឲ្យបានជ្រាបថា គណៈកម្មការកំណែកំពុងពិនិត្យវាយតម្លៃស្នាដៃនីមួយៗ ។ ចំពោះលទ្ធផលសម្រេច សមាគមអ្នកនិពន្ធខ្មែរនឹងជូនដំណឹងនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ ។ សូមអរគុណ ។

**យូ បូ**

**ប្រធានសមាគមអ្នកនិពន្ធខ្មែរ**

# ខ្ញុំមិនបានទទួលអ្វីសោះពីបដិវត្តន៍

ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ស្រុកកោះធំស្ទើរតែទាំងមូល បានក្លាយទៅជាតំបន់រំដោះ ។ ការវាយប្រហាររវាងទាហាន ធីវគីនិងទាហាន លន់ ណុល កើតឡើងមិនចេះដាច់ ។ ជីវិតមនុស្ស សត្វពាហនៈ ផ្ទះសម្បែង និងទ្រព្យសម្បត្តិត្រូវសម្លាប់និងបំផ្លាញ ដោយសារភ្លើងសង្គ្រាម ។ ចលនាតស៊ូបដិវត្តន៍ដើម្បីរំដោះជាតិ រំដោះប្រជាជនក៏កើតមានឡើង ។ ចាប់ពីឆ្នាំ១៩៧១ យុវជន យុវនារីមួយចំនួននៅក្នុងស្រុកកោះធំបានស្ម័គ្រចិត្តចូលបម្រើក្នុង ជួរកងទ័ពបដិវត្តន៍ និងមួយចំនួនទៀតត្រូវប្រធានភូមិ-ឃុំ កៀងគរ លួងលោមបុ្របង្ខំឲ្យចូលឲ្យតែម្តង ។

មាស ប៉េងគ្រី និងមិត្តភក្តិ៣នាក់មានឈ្មោះ ថន, វ៉ា និង ថេន ដែលមានអាយុស្រករគ្នា ត្រូវបានប្រធានភូមិកំពង់ស្វាយ កណ្តាលឈ្មោះ សុខ សេង ចុច ឈ្មោះយកទៅបម្រើក្នុងជួរកង ទ័ពដោយមិនប្រាប់ឪពុកម្តាយឲ្យ បានដឹងជាមុនឡើយ ។ នៅពេល នោះ ប៉េងគ្រី មានអាយុប្រហែល ១៥ឆ្នាំ ។ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ប៉េងគ្រី ជា មនុស្សតែម្នាក់ដែលមានសំណាងបានរួចផុតពីស្លាប់ក្នុងចំណោម យុវជនទាំង៤នាក់ដែលចាកចេញពីភូមិក្នុងពេលជាមួយគ្នា ។


មាស ប៉េងគ្រី អតីតយុទ្ធជន

ចូលជួរបដិវត្តន៍មុនដំបូង គ្រី ត្រូវបានប្រធានភូមិយកទៅ ដាក់នៅមន្ទីរឃុំព្រែកថ្មីរយៈពេលមួយសប្តាហ៍ ។ បន្ទាប់មកប្រធាន ឃុំឈ្មោះ ឃុត បានបញ្ជូន ប៉េងគ្រី និងយុទ្ធជនជាង១០នាក់ ទៅអង្គភាពយោធាស្រុកកងពលលេខ១៨ មានទីតាំងនៅក្នុងឃុំ ឈើខ្មៅ ក្រោមការទទួលខុសត្រូវរបស់ឈ្មោះកាត ។ នៅទីនោះ គ្រី និងយុទ្ធជនដទៃទៀតបានហាត់រៀនក្បួនយុទ្ធសាស្ត្រកងទ័ព អស់រយៈពេលជិតមួយឆ្នាំ ។ សេង លី ហៅ ទិន ជាគ្រូបង្ហាត់និងជា អ្នកគ្រប់គ្រងអង្គភាព ។ ក្រោយពេលហាត់រៀនក្បួនយោធា ហើយ គ្រី និងយុទ្ធជន២កងរយបានផ្លាស់មកត្រៀមនៅភូមិសាស្ត្រ ឃុំព្រែកតូច ស្រុកស្អាង ។

ឆ្នាំ១៩៧៤ គ្រី ផ្លាស់មកនៅអង្គភាពកងហាផ្នែកកាំភ្លើងធំ ចំណុះឲ្យកងពលលេខ១២ ហើយឈ្មោះ ណាត និង ពីន ជាអ្នក គ្រប់គ្រង ។ ចន្លោះឆ្នាំ១៩៧៤-១៩៧៥ គ្រី បានចូលរួមប្រយុទ្ធ នៅសមរភូមិភ្នំសណ្ត គោកតាគាវ និងពារាំង ក្នុងខេត្តព្រៃវែង ដើម្បីពួនស្ទាក់វាយកម្ទេចម៉ារីនដឹកស្បៀងរបស់សត្រូវ ។ នៅ ក្នុងផែនការវាយយកទីក្រុងភ្នំពេញរបស់បដិវត្តន៍ កងរបស់ គ្រី ទទួលមុខព្រួញវាយសម្រុកតាមបណ្តោយផ្លូវជាតិលេខ១ ឆ្លងកាត់ ទន្លេមេគង្គត្រង់ឆ្ពោះទៅតាខ្មៅ ។

បន្ទាប់ពីបដិវត្តន៍ដណ្តើមយកបានអំណាចបានទាំងស្រុង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រី និងមិត្តរួមអាវុធមួយ ចំនួនមិនបានវិលទៅរស់នៅឯស្រុកកំណើតជួបជុំគ្រួសារទេ ថ្នាក់លើ បានបញ្ជូនឲ្យទៅនៅក្នុងអង្គភាពទ័ពនៅស្រុកតាខ្មៅ ហើយបាន បង្វែរពីកាន់អាវុធមកកាន់ចបកាប់ ធ្វើស្រែចម្ការវិញ ។ កងពល លេខ១២ បានប្តូរមកជាកងពលលេខ៧០៣វិញ ក្រោមការ គ្រប់គ្រងរបស់ តាពីន ។ ធ្វើស្រែអស់រយៈពេលប្រហែល១ឆ្នាំ គ្រី និងយុទ្ធជន១០នាក់ត្រូវបានអង្គការជ្រើសរើសឲ្យទៅរៀន បើកបររយៈពេល២ខែនៅសេនាធិការកងទ័ព ។ រៀន បើកបរចប់ គ្រី ផ្លាស់មកនៅក្នុងក្រុមនីរសាក្រុងដោយមាននាទីជាអ្នកចិញ្ចឹម សត្វនិងធ្វើជានីរសានាំសំបុត្រពី តាណាត និងសេនាធិការទៅ កងពលនិងអង្គភាពផ្សេងៗម្តងម្កាល ។

ចុងឆ្នាំ១៩៧៦ គ្រី ផ្លាស់ពីសេនាធិការមកនៅអង្គភាព ស-២១ស្ថិតនៅក្រោមការដឹកនាំរបស់ ហ៊ុយ ។ គ្រី បានឲ្យដឹងថា «នៅមន្ទីរស-២១ អ្នកបើកឡានប្រចាំនៅអង្គភាពនេះមានចំនួន ហាសិបនាក់និងបែកចេញជាបីក្រុម» ។ គ្រី ជាអ្នកបើកឡានដឹក បន្លែសម្រាប់ឲ្យអ្នកទោសនិងចិញ្ចឹមសត្វ ។ គ្រី បានប្រាប់ថា

យុទ្ធជនពីក្រុមមួយទៅក្រុមមួយមិនអាចទាក់ទងគ្នាបានទេ ការងារបែកដាច់ស្រឡះពីគ្នា ។ អ្នកបើកឡានដឹកភ្ញៀវ ដឹងតែពីដឹកភ្ញៀវ ខ្ញុំដឹកស្មៅចិញ្ចឹមសត្វ ដឹងតែដឹកស្មៅចិញ្ចឹមសត្វ ដែលជាការងាររបស់ខ្ញុំទៅ ។ យុទ្ធជនគ្មានសិទ្ធិដឹងពីរឿងផ្សេងៗក្រៅពីការងាររបស់ខ្លួនទេ ។...នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំធ្លាប់ដឹកអ្នកទោសម្តងពីរដងដែរ កាលនោះមានអ្នកទោសពីរបីនាក់ជាកងទ័ពដូចគ្នាត្រូវចាប់ខ្លួននៅមុំពោធិ៍ចិន ។ រថយន្តសម្រាប់ដឹកអ្នកទោសនោះមានគ្របក្រណាត់ពីខាងលើនិងផ្នែកខាងក្រោយជិតឈឹងហើយមានយុទ្ធជន២នាក់ជិះនៅខាងក្រោយដើម្បីយាមអ្នកទោស ។ ខ្ញុំដឹកអ្នកទោសមកឈប់ត្រឹមកន្លែងរបស់ខ្ញុំ បន្ទាប់មកមានយុទ្ធជនមកបណ្តើរយកអ្នកទោសបន្ត ។ ខ្ញុំមិនដែលបានដឹកអ្នកទោសចូលទៅដល់កន្លែងទេ" ។ ក្រៅពីការងារបើកបរ គ្រី ធ្លាប់បានចូលរួមប្រជុំរៀនសូត្រនយោបាយពី ឌុច ម្តងនៅផ្លូវធំក្បែរផ្ទះរបស់ ឌុច ។ ឌុចបានបំពាក់បំប៉នគោលជំហរឲ្យយុទ្ធជនខិតខំប្រឹងប្រែងធ្វើការងារហើយត្រូវមានចិត្តស្មោះត្រង់ចំពោះបដិវត្តន៍ ។ គ្រី បញ្ជាក់ថា "ប្រធានមន្ទីរស-២១ឈ្មោះ ឌុច ក្បាលធំ និយាយញាប់ មុខរាងជ្រងសម្បុរស ។ ចំណែកម្នាក់ទៀតឈ្មោះ ហ៊ មាត់វៀច មាឌធំសម្បុរស" ។

ចុងឆ្នាំ១៩៧៦ គ្រី បានទទួលភារកិច្ចដឹកជញ្ជូនស្បៀងទៅឲ្យភ្ញៀវចិននិងកូរ៉េនៅខេត្តបាត់ដំបង ។ ពេលត្រឡប់មកវិញ គ្រី ត្រូវធ្វើដំណើរហួសទៅខេត្តតាកែវបន្តទៀត ។ នៅក្នុងរថយន្តមាន ហ៊ុយ និងយុទ្ធជន២នាក់ទៀតជិះជាមួយដែរ ដោយសារការធ្វេសប្រហែសក្នុងពេលបើកបរ(ងងុយដេក) គ្រី បានបើករថយន្តធ្លាក់ប្រឡាយ នៅតាមបណ្តោយផ្លូវជាតិលេខ៣ ត្រង់ចំណុចភូមិស្វែងបណ្តាលឲ្យរថយន្តក្រឡាប់ ប៉ុន្តែមិនបណ្តាលឲ្យនរណាម្នាក់រងរបួសទេ ។


មាស ប៉េងគ្រី (បច្ចុប្បន្ន)

បន្ទាប់ពីហេតុការណ៍ក្រឡាប់រថយន្តកន្លងផុតទៅ គ្រី ត្រូវបានអង្គការផ្លាស់ឲ្យទៅធ្វើការនៅព្រៃស ដែលមានឈ្មោះ ហ៊ុយស្រែ ជាអ្នកដឹកនាំ ។ គ្រី និយាយថា "ខ្ញុំដឹងមូលហេតុដែលអង្គការផ្លាស់ខ្ញុំទៅព្រៃស គឺដោយសាររឿងក្រឡាប់ឡាន ប៉ុន្តែវាជាសំណាងរបស់ខ្ញុំហើយដែលអង្គការមិនយកខ្ញុំទៅសម្លាប់ចោល ។ ព្រៃសគឺជាកន្លែងសម្រាប់លត់ដំយុទ្ធជនឬកម្មាភិបាលដែលមានកំហុស ។ ក្រោយមកដោយខ្វះខាតអ្នកបើកបរ ហ៊ុយស្រែ ក៏បានជ្រើសរើស គ្រី ឲ្យបើករថយន្តរួមជាមួយយុទ្ធជន៣នាក់ដឹកដីនិងអួសកំប្លោកមកចិញ្ច្រាំយកទៅធ្វើជី ។ ក្រៅពីនេះ គ្រី បំពេញភារកិច្ចជាអ្នកជួសជុលម៉ាស៊ីនបូមទឹកធុនតូចៗនៅតាមកងនារីទៀត ។ គ្រី ត្រូវក្រោកធ្វើការតាំងពីម៉ោង៤ទៀបភ្លឺ ចំណែករបបអាហារទទួលបានបបរមួយចានក្នុងមួយពេល ។

គ្រី បម្រើការងារនៅព្រៃសរហូតដល់ថ្ងៃរបបខ្មែរក្រហមដួលរលំ ។ គ្រី បានរត់ភៀសខ្លួនទៅភ្នំឱរ៉ាល់និងបន្តការតស៊ូប្រយុទ្ធរួមជាមួយកងទ័ពខ្មែរក្រហមដែលនៅសេសសល់ ។ ឆ្នាំ១៩៨០ ដោយយល់ឃើញថាការតស៊ូនៅក្នុងព្រៃគ្មានប្រយោជន៍ ម្យ៉ាងទៀតដោយសារនឹករឭកក្រុមគ្រួសារនៅឯស្រុកកំណើតផង គ្រី បានសម្រេចចិត្តចូលសារភាពជាមួយរដ្ឋាភិបាលវិញ និងបានរៀបការជាមួយនារីម្នាក់ឈ្មោះ ចាន់ ម៉ាលីន ។

ឆ្នាំនេះ គ្រី មានអាយុ៤៧ឆ្នាំ មានកូនប្រុស៣នាក់ និងកូនស្រីម្នាក់ ។ គ្រី គិតតែពីធ្វើស្រែចម្ការលែងខ្វល់ខ្វាយពីរឿងស្រុកទេសទៀតហើយ ព្រោះថាការលះបង់តស៊ូរបស់គាត់កន្លងមកមិនមានផ្តល់ផលប្រយោជន៍អ្វីដល់គាត់សូម្បីតែបន្តិចក៏គ្មានដែរ ។

**ឆេង ឌឹង**

# តើនេះគឺជាការឈ្លានពានរបស់ខ្មែរក្រហម នៅក្នុងប្រទេសវៀតណាម ឆ្នាំ១៩៧៧-៧៨?

**ថាន ឡាប**

នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៧៧ កងទ័ពខ្មែរក្រហមជាច្រើនកងវរសេនាធំបានសម្រុកចូលឃុំថានឡាប ខេត្តតាយនិញ ។ កងទ័ពខ្មែរក្រហមបានសម្លាប់ប្រជាជនវៀតណាមអស់ចំនួនប្រាំរយនាក់ដែលលាក់ខ្លួននៅក្នុងលេណដ្ឋានព្រមទាំងបានកម្ទេចភូមិករចំនួន៥ នៅក្នុងឃុំដដែលនេះ ។ នៅក្នុងភូមិតូចមួយនៅក្នុងឃុំនេះ កងទ័ពខ្មែរក្រហមបានដុតផ្ទះសម្បែងអ្នកស្រុកភូមិអស់ប្រមាណ១០០ខ្នង ។ គ្រួសារជាច្រើនត្រូវបានសម្លាប់គ្មានសល់ម្នាក់ សូម្បីតែស្ត្រីឬកូនក្មេងក៏មិនទុកជីវិតឲ្យដែរ ។ ក្រុមកងទ័ពទាំងនេះបានបាញ់សម្លាប់មនុស្សពេញវ័យហើយវាយសម្លាប់កូនក្មេងនឹងស្នូកកាំភ្លើង ។ មានករណីមួយគឺកងទ័ពខ្មែរក្រហមយកខ្សែចងក្មេងតូចៗមួយខ្សែ រួចហើយយកទៅទម្លាក់ចូលក្នុងអណ្តូងទឹក ។

យើងបានសម្ភាសន៍ជាមួយស្ត្រីមេម៉ាយម្នាក់ឈ្មោះ



កងទ័ពខ្មែរក្រហម

(រូបថតឯកសារ៖ ចូសេហ្វ កូហ្វម៉ាន់)

ង្វៀន ធីជូ អាយុ៤៨ឆ្នាំ ដែលបានរួចផុតពីការសម្លាប់រង្គាលនេះ ។ នៅយប់ដែលមានអំពើឃោរឃៅកើតឡើង គ្រួសាររបស់នាង ធីជូ បានចូលពួនសម្ងំនៅក្នុងលេណដ្ឋានដែលគាត់បានជីកកាលពីពីរបីខែមុន ។ កងទ័ពខ្មែរក្រហមបានបាញ់រះចូលទៅក្នុងលេណដ្ឋានពីមាត់លេណដ្ឋានទាំងសងខាង បន្ទាប់មកក៏បានគប់គ្រាប់បែកចូលបន្ថែមទៀត ។ បងប្រុសម្នាក់របស់ ជូ ត្រូវបាញ់សម្លាប់នៅពេលដែលគាត់ព្យាយាមរត់គេចពីលេណដ្ឋាន ។ សំណាងល្អស្ត្រីវ័យក្មេងរូបនេះនៅរស់រានមានជីវិត ។ នាងធ្វើពុតជាដេកស្លាប់ត្រាំឈាមរបស់បងប្អូនដែលនៅពួនសម្ងំនៅក្នុងលេណដ្ឋានជាមួយគ្នាអស់រយៈពេលពេញមួយយប់ ។

នៅពេលដែលអ្នកស្រុកភូមិថានឡាបកំពុងលង់លក់ក្នុងដំណេកគ្រាប់ផ្លោងបានធ្លាក់ចំឃុំ ។ ដោយគិតថាបញ្ហានេះជាទម្លាប់នៃការបង្ករឿងហេតុ អ្នកភូមិក៏នាំគ្នាសម្រុកចូលទៅក្នុងលេណដ្ឋានរៀងៗខ្លួន ។ ពីក្នុងលេណដ្ឋានអ្នកភូមិបានឮសូរសម្រែករបស់កងទ័ពខ្មែរក្រហមដែលរត់ចូលពីគ្រប់ទិសថា "សម្លាប់វាចោល! សម្លាប់វាចោលឲ្យអស់!" ។ ភូមិថានត្រូវភ្លើងឆេះសន្ធោសន្ធៅ ។ នៅក្រោមពន្លឺអណ្តាតភ្លើងដែលមានពន្លឺភ្លឺរន្ទាល អ្នកវាយប្រហារក៏ចាប់ផ្តើមសម្លាប់រង្គាល ។ មុខសញ្ញាទីមួយគឺអ្នកដែលកំពុងព្យាយាមគេចខ្លួន បន្ទាប់មកទៀតគឺអ្នកដែលពួនសម្ងំនៅក្នុងលេណដ្ឋាន ។ ម្ភៃប្រាំគ្រួសារត្រូវបានកម្ទាត់ចោលនៅក្នុងរាត្រីនោះ ។ ចំណែកនៅក្នុងសាលារៀន ដែលត្រូវភ្លើងឆេះ ហើយដែលប្រែក្លាយឲ្យទៅជាផ្ទះមរណនោះមានលោកគ្រូអ្នកគ្រូចំនួន១១រូបក្នុងចំណោមគ្រូ១៣រូបដែលស្នាក់នៅក្នុងសាលានោះត្រូវបានបាញ់សម្លាប់ចោល ។



កាន់តែព្រឺព្រួចជាងនេះ នៅពេលឮសូរថាខ្មែរក្រហមបានប្រព្រឹត្តមកលើជនរងគ្រោះតាមរបៀបផ្សេងទៀត ។ កុមារអាយុ១០ឆ្នាំម្នាក់ឈ្មោះ ង៉ុក អាញ់ កំពុងតែអង្គុយសុខៗនៅក្នុងសួនច្បារក្នុងបរិវេណលំនៅឋានរបស់ខ្លួន ស្រាប់តែកងទ័ពខ្មែរក្រហមចូលមកចាក់សម្លាប់នឹងចំពុះទុង ។ ត្រឹង ធី ទុយ ត្រូវបានបាញ់ ហើយស្រែកទ្រហោយំទាំងក្តីឈឺចាប់នៅក្បែរកូនតូចរបស់នាង ។ ពេលនោះខ្មែរក្រហមក៏កញ្ឆក់កូនតូចពីដៃនាងហើយចាប់ជើងកូនរបស់នាងហែកដាច់ជាពីរចំណែក ។

នាងដុង មានផ្ទៃពោះប្រាំខែ ។ នាងកំពុងអង្គុយមើលសាកសពប្តីរបស់នាងស្រាប់តែរំពេចនោះខ្មែរក្រហមបានមកដល់នាងក៏សំពះអង្វរសុំក្តីមេត្តា ប៉ុន្តែខ្មែរក្រហមបែរជាចាប់នាងវះពោះយកកូនក្នុងផ្ទៃគ្រវែងចោលនៅចំពោះមុខនាង ។

បីថ្ងៃក្រោយមកកងទ័ពខ្មែរក្រហមបានដកថយចូលខាងទឹកដីកម្ពុជាវិញ ដោយបន្សល់ទុកនូវសាកសពជាច្រើន ខ្លះបាក់ដៃ ខ្លះបាក់ជើង ខ្លះទៀតត្រូវកាប់ដាច់ជាចំណែកៗ ខ្លះត្រូវកាត់ក្បាលចោល ហើយមានសាកសពខ្លះទៀតត្រូវវះយកថ្លើមអស់ ។

**បាជុក**

នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៨ កងទ័ពខ្មែរក្រហមជាច្រើននាក់បានវាយកាន់កាប់ ឃុំបាជុក ក្នុងខេត្តអាន់យ៉ាង

ស្ថិតនៅជាប់ព្រំដែនវៀតណាម-កម្ពុជា ។ នៅឃុំបាជុកមានជនជាតិវៀតណាមដើមកំណើតខ្មែររស់នៅជាច្រើន ។ កងទ័ពខ្មែរក្រហមបានប្រមូលជនរងគ្រោះជាក្រុមៗដែលក្នុងមួយក្រុមមានមនុស្សពី៣០ទៅ៤០នាក់ រួចយកទៅបាញ់សម្លាប់ចោល ។ អ្នកភូមិមួយចំនួនរត់ចូលមកជ្រកកោនក្នុងវត្តអារាម ដោយគិតថានឹងមានសុវត្ថិភាព ។ ប៉ុន្តែវត្តអារាមទាំងពីរ គឺវត្តភីឡៃ និង តាំប៉ូ ត្រូវបានកម្ទេចចោល ហើយប្រជាជនត្រូវបានសម្លាប់រង្គាល ។ មន្ត្រីមូលដ្ឋានអះអាងថា មានជនរងគ្រោះចំនួន២០២២នាក់ ត្រូវបានកាប់សម្លាប់នៅអំឡុងពេលវាយប្រហារនេះ ។

កងទ័ពកម្ពុជាបានបាញ់សម្លាប់អ្នកទាំងឡាយដែលមកជ្រកកោននៅក្នុងវត្តនេះ ហើយបានបន្សល់ទុកសាកសពក្នុងថ្លុកឈាមពីរកន្លែងនៅលើកម្រាលឥដ្ឋ ហើយសាច់របស់ជនរងគ្រោះខ្ទាតទៅជាប់នឹងជញ្ជាំង ។ វត្តអារាមទាំងពីរនេះត្រូវបានអ្នកស្រុកភូមិដែលនៅសល់ពីស្លាប់ដាក់ឈ្មោះថា «វត្ត៥០០» និង «វត្ត៦០០» ទៅតាមចំនួនប្រជាជនដែលស្លាប់នៅទីនោះ ។

លលាដ៍ក្បាលសពចំនួន៨៥០ក្បាលមាននៅបូជនីយដ្ឋានបាជុក ស្ថិតនៅជាប់នឹងវត្ត ភីឡៃ ដែលមានការកាប់សម្លាប់ជាច្រើននៅក្នុងឆ្នាំ១៩៧៨ ។ យើងបានជួបសម្ភាសជាមួយសាក្សីបីរូបដែលបានដឹងពីការសម្លាប់ធំៗដែលហាក់ដូចជាកើតឡើងនៅកន្លែងបីផ្សេងគ្នាក្នុងឆ្នាំ១៩៧៨ ពោលគឺនៅថ្ងៃទី១៧ ខែមីនា, ថ្ងៃទី២៤ ខែមីនា និងថ្ងៃទី២២ ខែមេសា ។

## ថ្ងៃទី១៧ ខែមីនា

ការសម្លាប់នៅថ្ងៃនេះគឺកសិករ(ស្រី)ម្នាក់បានឃើញផ្ទាល់នឹងភ្នែក ។ កសិកររូបនេះឈ្មោះ ហា ធីង៉ា អាយុ៥៦ឆ្នាំ រស់នៅបាជុក ។ នៅថ្ងៃនោះនាងបានឃើញកងទ័ព ។ ខ្មែរក្រហមបណ្តេញអ្នកស្រុកភូមិរាប់ពាន់នាក់ឲ្យចេញទៅទីវាល ឡេ គួយ ហើយបានបាញ់សម្លាប់ចោលទាំងអស់ ។ កូនក្មេងខ្លះត្រូវខ្មែរក្រហមបោកក្បាលនឹងគល់ឈើស្លាប់តែម្តង ។ បច្ចុប្បន្នលលាដ៍ក្បាលកូនក្មេងតូចៗនៅតម្កល់ទុកនៅបូជនីយដ្ឋាន ។ ធីង៉ា មានរបួសយ៉ាងធ្ងន់ធ្ងរ ហើយដេកសន្លប់មិនដឹងខ្លួននៅជាមួយគំនរសាកសព ។ នៅពេលនាងដឹងខ្លួនឡើងវិញទើបដឹងថាអ្នកដេកជុំវិញខ្លួនសុទ្ធតែបាត់បង់ជីវិត មានតែរូបគាត់ម្នាក់ប៉ុណ្ណោះដែលនៅរស់ ។ ក្រុមគ្រួសារទាំងមូលត្រូវបានសម្លាប់សរុបទាំងអ្នកដែលមានអាយុពេញវ័យផងគឺ៣៥នាក់ ។

## ថ្ងៃទី២៤ ខែមីនា

បួយ វ៉ាន់ឡឺ កសិករអាយុ៥៧ឆ្នាំ ជាកសិករមកពីបាជុកជាអ្នកបានឃើញខ្មែរក្រហមសម្លាប់ប្រជាជនជាច្រើននាក់នៅក្បែរវត្តឡុងចាន់ ។ គាត់និយាយថា មនុស្សចំនួនពីរពាន់នាក់ត្រូវបានកងទ័ពខ្មែរក្រហមបង្ខំឲ្យដើរទៅកាន់ស្ពានមួយដើម្បីសម្លាប់ចោលគ្មានសល់ ។ វ៉ាន់ឡឺ និងក្រុមគ្រួសារបានភៀសខ្លួនទៅពួនសម្ងំនៅក្នុងរូងភ្នំ ប៉ុន្តែកងទ័ពខ្មែរក្រហមបានរកឃើញ ហើយសម្លាប់ចោលទាំងអស់នៅសល់តែរូបគាត់ម្នាក់ប៉ុណ្ណោះដែលត្រូវរបួស ហើយគេចខ្លួនរួច ។ ឡឺ បានបាត់បង់សមាជិកគ្រួសារចំនួន១០០នាក់នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៨ ។

## ថ្ងៃទី២២ ខែមេសា

ឃាតកម្មនៅថ្ងៃនេះត្រូវបានកសិករមួយរូបឈ្មោះ បួយ វ៉ាន់ឆ អាយុ៧១ឆ្នាំ រស់នៅបាជុកបានឃើញផ្ទាល់ភ្នែក ។ អ្នកភូមិត្រូវបានប្រមូលផ្តុំនៅវត្តភីឡៃទុយ រួចបាញ់សម្លាប់ចោលទាំងអស់ ។ មនុស្សមួយក្រុមដែលមានគ្នាចំនួន៣០នាក់បានព្យាយាមរត់គេចចូលទៅពួនសម្ងំនៅក្រោយខ្នងព្រះពុទ្ធរូប ប៉ុន្តែអ្នកទាំងនោះត្រូវស្លាប់អស់ដោយសារគ្រាប់បែកមួយគ្រាប់ដែលគប់ពីច្រកចូលទៅ ។ បុរសរូបនេះបាត់បង់គ្រួសារទាំងមូល មានប្រពន្ធនិងកូនបួននាក់ រួមជាមួយសាច់ញាតិចំនួន៤៤នាក់ទៀត ។ មនុស្សចំនួន៣០០នាក់ បានស្លាប់នៅក្នុងវត្តនេះនៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៨ ប៉ុន្តែសាក្សីរូបនេះបានចាកចេញដោយសុវត្ថិភាព ។

ហេឡែន អេសទើ ដាក់កាលបរិច្ឆេទ «ថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៨» ហើយនាងផ្តល់ថាបានតួលេខ២០២២ ពីណាមក បើនៅបូជនីយដ្ឋានមានលលាដ៍ក្បាលតែ៨២០នោះ ។ យើងមិនបានរាប់ចំនួនលលាដ៍ក្បាលនៅបូជនីយដ្ឋានថ្មីដែលសង់នៅឆ្នាំ១៩៨៩នោះទេ ប៉ុន្តែជាក់ស្តែងមានលលាដ៍ក្បាលលើសពី៨២០ទៅទៀត ។ លលាដ៍ក្បាលសាកសពជាច្រើនបានបាត់បង់ឬសត្វស៊ីអស់មុនពេលសាងសង់ជាបូជនីយដ្ឋានឲ្យមានលក្ខណៈសមរម្យ ។

**ឆាលី ឬ៉័រ**

# បរាជ័យដោយការធ្វេសប្រហែសៈ នយោបាយរបស់ខ្មែរក្រហមចំពោះស្ត្រី

*(តបប់)*

### *ជំពូកទីបី*

### *ការធ្វេសប្រហែស ការបង្ខិតបង្ខំ និង បរាជ័យៈ គោលនយោបាយរបស់ខ្មែរក្រហមចំពោះស្ត្រី*

«យើងបានលុបបំបាត់ចោលរួចទៅហើយនូវទម្លាប់នៃការគិតដែលនៅសេសសល់តាំងតែពីមុនសម័យបដិវត្តន៍ ។ យើងបានកាត់ផ្តាច់មនោសញ្ចេតនារវាងកូននិងឪពុកម្តាយរវាងបុរសនិងបុរស និង រវាងបុរសនិងស្ត្រី» ។ អូ ប្រាយអិន ឆ្នាំ១៩៨៤ «អង្គការគឺជាឪពុកនិងជាម្តាយនៃយុវជនខ្មែរ!» ពាក្យស្លោកខ្មែរក្រហម ។

នៅក្រោមរបបខ្មែរក្រហម បញ្ហាទាក់ទិនទៅនឹងស្ត្រីនៅប្រទេសកម្ពុជាមិនត្រូវបានដោះស្រាយតាមរយៈការប្រើប្រាស់មធ្យោបាយតឹងរ៉ឹងនិងផែនការដាក់លាក់ដូចនៅប្រទេសចិននិងវៀតណាមក្នុងដំណាក់កាលតស៊ូបដិវត្តន៍របស់ប្រទេសទាំងពីរនេះទេ ។ ការយកលទ្ធិម៉ាក្សលេនីនមកប្រើប្រាស់ទាំងស្រុង បានជំនួសឲ្យចលនាចម្រើនពិតប្រាកដមួយក្នុងខណៈដែលប្រពៃណីគ្រួសាររបស់កសិករស្ត្រី ដែលប្រជាជនស្រលាញ់ពេញចិត្តត្រូវបានបន្ទាបសក្តិយស ឬមិនបានទទួលការយកចិត្តទុកដាក់ ។ ការចាប់ទាហានបានបង្កឲ្យមានការមិនពេញចិត្តចំពោះរបបដឹកនាំ ហើយការបញ្ចូលមនោគមវិជ្ជាក៏ពុំបានធ្វើដោយការយកចិត្តទុកដាក់ខ្ពស់ ។ លើសពីនេះចលនាតស៊ូរបស់ស្ត្រីកម្ពុជាក៏ពុំមានលេចជារូបរាងឬគ្មានមេដឹកនាំត្រឹមត្រូវដែរ ។

ជំពូកនេះបានពឹងផ្អែកទៅលើសម្ភាសន៍របស់ខ្ញុំជាមួយស្ត្រីកសិករកម្ពុជាដែលត្រូវជ្រើសរើសឲ្យចូលបម្រើបដិវត្តន៍ដោយខ្មែរក្រហមនៅក្នុងអំឡុងសង្គ្រាមស៊ីវិលដូចជានៅឆ្នាំ១៩៧៤ជាដើម ។ ស្ត្រីភាគច្រើនត្រូវបានបង្ខំឲ្យចូលបម្រើបដិវត្តន៍ ។ នៅអំឡុងពេលមុនសម័យកម្ពុជាប្រជាធិបតេយ្យ ស្ត្រីដែលជាកសិករទាំងអស់នេះត្រូវបានជ្រើសរើសចេញពីឃុំព្រែកស្តីមានចម្ងាយប្រមាណ៩០គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ។ បទពិសោធន៍របស់ស្ត្រីទាំងនេះមានទម្រង់ស្រដៀងគ្នា ។ ក្រោយពីការជ្រើសរើសស្ត្រីទាំងនេះត្រូវឆ្លងកាត់ការហ្វឹកហ្វឺនសង្ខេបដែលមានរយៈពេលពីពីរទៅប្រាំមួយសប្តាហ៍មុនពេលត្រូវបញ្ជូនទៅសមរភូមិមុខដើម្បីបម្រើការងារដូចជាអ្នកដឹកជញ្ជូនអាវុធនិងស្បៀងនិងសែងអ្នករបួស ។ ស្ត្រីខ្លះពុំបានទទួលការហ្វឹកហ្វឺនទាល់តែសោះ ។ ស្ត្រីភាគតិចប៉ុណ្ណោះដែលនិយាយថាបានកាន់កាំភ្លើង ។ ភាពភ័យរន្ធត់នៅសមរភូមិមុខនិងការបែកបាក់គ្រួសារបានបង្ខំឲ្យស្ត្រីលួចរត់ចេញពីកងទ័ពត្រឡប់មកផ្ទះ ដោយពុំមានការអនុញ្ញាតពីមេកង ប៉ុន្តែក្រោយមកត្រូវបានចាប់បញ្ជូនទៅសមរភូមិវិញ ។ ស្ត្រីខ្លះរត់គេចហើយត្រូវចាប់ត្រឡប់មកវិញជាច្រើនលើកជាច្រើនសា ។ ក្រោយជ័យជម្នះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការបានបញ្ជូនស្ត្រីដែលធ្លាប់រត់ចោលជួរទៅគុកព្រៃសជាសាខាមួយរបស់គុក ស-២១ ។ ស្ត្រីទាំងនេះត្រូវឃុំខ្លួនរហូតពេញមួយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ។ បទឧក្រិដ្ឋរបស់ស្ត្រីទាំងនេះគឺការរត់ចោលជួរដោយគ្មានការអនុញ្ញាត ។ នៅក្នុងដំណាក់កាលនៃភាពចលាចលបន្ទាប់ពីការឈ្នះសង្គ្រាមរបស់វៀតណាមលើខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ ស្ត្រីខ្លះរត់ភៀសខ្លួនទៅព្រំដែនថៃជាមួយប្រជាជនខ្មែររាប់ពាន់នាក់ទៀត ។ នៅទីបញ្ចប់ស្ត្រីបានវិលត្រឡប់មកកាន់ភូមិកំណើតរបស់ខ្លួនវិញ ក្រោយពីរស់នៅបានពីរ ឬបីខែហើយខ្លះទៀតក្រោយពីរស់នៅជាច្រើនឆ្នាំនៅក្នុងជំរំ ។ ការចាប់អារម្មណ៍របស់ជំពូកនេះគឺការជួបជាមួយខ្មែរក្រហមជាលើកដំបូងរបស់ស្ត្រីមុនខែមេសា ឆ្នាំ១៩៧៥ ការជ្រើសរើសនិងការហ្វឹកហ្វឺនស្ត្រី និងបទពិសោធន៍របស់ស្ត្រីនៅក្នុងសមរភូមិ ។

រឿងរ៉ាវរបស់ស្ត្រីទាំងនេះបញ្ជាក់អំពីមូលហេតុដែលខ្មែរក្រហមទទួលបរាជ័យនៅក្នុងការទាក់ទាញកសិករស្ត្រីក្នុងចំនួន

ច្រើនឲ្យចូលបម្រើបដិវត្តន៍ ។ មានកត្តាទាក់ទងគ្នាបួនដែលបង្កឲ្យមានការបរាជ័យនេះគឺ ១) ការប្រើប្រាស់វិធីសាស្ត្រជ្រើសរើសមិនមានប្រសិទ្ធភាព ២) ការបង្ខិតបង្ខំស្ត្រីឲ្យចាកចេញពីគ្រួសារ ៣) ការអប់រំនយោបាយមិនត្រឹមត្រូវដល់កងនារីទើបចូលថ្មី និង៤) ការបរាជ័យទាំងស្រុងក្នុងការបង្កើតតួនាទីសំខាន់សម្រាប់ស្ត្រីនៅក្នុងបដិវត្តន៍ ។

### ការជ្រើសរើស

វិធីសាស្ត្រជ្រើសរើសស្ត្រីរបស់ខ្មែរក្រហមមានចំណុចខ្វះខាតជាច្រើន ។ ទីមួយៈ ជនកុម្មុយនិស្តតែងតែពឹងផ្អែកទៅលើការបង្ខិតបង្ខំនិងការបំភិតបំភ័យដើម្បីស្វែងរកការគាំទ្រ ។ ឡូ ស៊ីម ជាកសិករបាននិយាយថា គាត់មានអាយុ១៩ឆ្នាំនៅពេលដែលខ្មែរក្រហមចូលមកដល់ភូមិរបស់គាត់ក្នុងឆ្នាំ១៩៧៤ ហើយបានបង្ខំគាត់ឲ្យចាកចេញពីភូមិជាមួយនឹងកងទ័ពបដិវត្តន៍ ។ “ប្រសិនបើយើងមិនចូលរួមយើងមិនអាចរស់បានសុខទេ ។ វាបង្ខំអ្នកភូមិ ។ បើយើងបដិសេធ ពួកវានឹងមកធ្វើបាបយើង ។ ពួកខ្មែរក្រហមថា ម៉េចបានជាមិនចូលរួមបើគេឯងចូលរួមអស់ហើយនោះ? ...ប្រសិនបើយើងទៅមិនរួចពួកវាសែង ។ យើងនឹងត្រូវពួកវាសម្លាប់ បើចេះតែរឹងរូស ។ អ៊ីម ចាន់ថា បានរៀបរាប់អំពីស្ថានការណ៍ក្នុងន័យដូចគ្នាថា “ប្រសិនបើខ្មែរក្រហមមិនបានបង្ខំក៏យើងត្រូវតែចូលរួមដែរ បើមិនអីចឹងទេពួកវានឹងធ្វើបាបយើងហើយ” ។ ការប្រព្រឹត្តរបស់ជនកុម្មុយនិស្តខ្មែរបែបនេះបានធ្វើឲ្យ ឡូ ស៊ីម និង អ៊ីម ចាន់ថា យល់ថាចលនាបដិវត្តន៍ជារឿងជួរចត់ហើយជាសញ្ញាបញ្ជាក់អំពីបរាជ័យរបស់ខ្មែរក្រហមក្នុងការកែប្រែស្ត្រីឲ្យក្លាយទៅជាជនកុម្មុយនិស្តថ្មីមានការលះបង់ខ្ពស់ដើម្បីបុព្វហេតុបដិវត្តន៍ ។ បទពិសោធន៍របស់ស្ត្រីទាំងនេះស្របជាមួយនឹងការអះអាងរបស់ ខេត ហ្វ្រីសុន ថាការគាំទ្ររបស់កសិករចំពោះបដិវត្តន៍ “គឺមិនចេញពីបេះដូងទេគឺចេញពីការចង់រក្សាជីវិតនៅក្នុងពេលមានសង្គ្រាម” ។

ប្រព្រឹត្តិកម្មដែល ឡូ ស៊ីម និង អ៊ីម ចាន់ថា បានទទួលហាក់បីដូចជារាលដាលនៅក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៤ ។ តាមការអះអាងរបស់ ខេនេតឃ្វីន ចាប់ពីឆ្នាំ១៩៧៣ ខ្មែរក្រហមបានបង្កើនការអនុវត្តន៍នូវផែនការថ្មីរបស់ខ្លួនដោយប្រើប្រាស់ការបំភិតបំភ័យ ហើយបានធ្វើកំណែទម្រង់សង្គមកម្ពុជាដ៏គំហុក ។ បានសេចក្តីថាសម្តេចព្រះ នរោត្តម សីហនុ ដែលជាឧបករណ៍ដ៏មានប្រសិទ្ធភាពបំផុតរបស់ជនកុម្មុយនិស្តសម្រាប់កេណ្ឌទ័ពនារីដល់ដំណាក់កាលនេះត្រូវបានកៀសចេញឆ្ងាយ ។ សម្តេចព្រះ នរោត្តម សីហនុ គឺជាមេដឹកនាំនយោបាយនិងមានអំណាចខាងសាសនានៅតាមជនបទនៃប្រទេសកម្ពុជា ហើយពីមុនមកវត្តមានរបស់ព្រះអង្គជាមួយខ្មែរក្រហមមានសារសំខាន់ណាស់ក្នុងការទាក់ទាញកសិករភាគច្រើនឲ្យធ្វើការដើម្បីបុព្វហេតុរបស់ខ្មែរក្រហមនិងព្រះមហាក្សត្រ ។ វត្តមានរបស់ព្រះមហាក្សត្រជាមួយពួកកុម្មុយនិស្តខ្មែរក្រហមគឺមិនស័ក្តិសមទៅហើយ ប៉ុន្តែខ្មែរក្រហមក៏មិនស័ក្តិសមនឹងជំនួសព្រះអង្គដែរ ពីព្រោះថានយោបាយកុម្មុយនិស្តរបស់ខ្មែរក្រហមផ្តល់ចំណង់ចំណូលចិត្តតិចបំផុតដល់ប្រជាកសិករ ។ លើសពីនេះ ការប្រើប្រាស់ឈ្មោះរបស់ ប៉ុល ពត ជាជនកុម្មុយនិស្ត ប្រកបដោយគតិបណ្ឌិតគួរឲ្យគោរពនិងជាអ្នកមិនកាន់សាសនា ដែលប្រជាជនអាចធ្លាប់ស្គាល់ដូចករណី ម៉ៅ សេទុង និង ហូជីមិញ នោះហាក់បីដូចជាពុំសូវបានពិចារណាឲ្យបានដិតដល់ដោយជនកុម្មុយនិស្តកម្ពុជាទេ ។ លទ្ធផលគឺការកេណ្ឌដោយបង្ខិតបង្ខំនិងដោយកម្រោល ។

ប៉ុន្តែក៏មិនមែនស្ត្រីទាំងអស់នៅព្រែកស្តីចូលរួមបដិវត្តន៍ដោយសារការគំរាមគំហែងដែរ ។ ណាំ សុខា ដែលមានអាយុប្រហែល១៨ឆ្នាំនៅពេលនោះ ទទួលស្គាល់ថាគាត់ចូលបម្រើបដិវត្តន៍ដោយស្ម័គ្រចិត្តនៅពេលដែលខ្មែរក្រហមចូលមកដល់ភូមិរបស់គាត់ក្នុងឆ្នាំ១៩៧៤ ។ “ខ្ញុំបានស្ម័គ្រចិត្តចូលរួមបដិវត្តន៍ព្រោះខ្ញុំគិតថាវាសប្បាយ ហេតុអ្វីបានមានអ្នកខ្លះមិនចូល?” ។ ស៊ឹម ស្រេង មានវ័យក្មេងបំផុតនៅក្នុងក្រុមរបស់គាត់ក៏បានរៀបរាប់អំពីមូលហេតុនៃការចូលបម្រើបដិវត្តន៍របស់គាត់ថា “ចង់សប្បាយ”ដែរ ។ សុខា និង ស្រេង មានអាកប្បកិរិយាបែបនេះក៏ប្រហែលដោយសារតែអ្នកទាំងពីរទើបតែមានអាយុប្រហែល១៨ឆ្នាំប៉ុណ្ណោះនៅឆ្នាំ១៩៧៤ ។ ចំណែកឯ ទុយ សុន គាត់ចូលបម្រើបដិវត្តន៍ដោយសារតែគាត់គេចចេញពីការបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ ។

ភាពត្រេកត្រអាលនាពេលដំបូងទីរបស់អ្នកទើបនឹងកេណ្ឌ

ទោះជាយ៉ាងណាមិនត្រូវបានយកទៅប្រើប្រាស់ដោយខ្មែរក្រហមទេ ពីព្រោះខ្មែរក្រហមបានបរាជ័យក្នុងការពង្រីកភាពត្រេកត្រអាលនេះតាមរយៈការអប់រំនយោបាយមួយដ៏មានប្រសិទ្ធភាព ។ រាល់ស្ត្រីទាំងអស់សុទ្ធតែបាននិយាយថា ការហ៊ឹកហ៊ឺនខ្លីហើយសង្ខេបទៀត ដែលមិនគ្រប់គ្រាន់សម្រាប់បណ្តុះឲ្យមានឧត្តមគតិបដិវត្តន៍ទេ ។ តាមការពិត ដេវីដ ឆេនល័រ បានកត់សម្គាល់ថា ប្រជាជនកម្ពុជាភាគច្រើនមានឆន្ទៈក្នុងការប្រថុយប្រថានធ្វើបដិវត្តន៍មួយរយៈពេលខ្លីបដកខ្លួនចេញ ។ គាត់សរសេរថា "ប្រជាជនភាគច្រើនពុំបានចូលរួមឲ្យពេញដៃពេញជើងទេ" ។ នេះជាលទ្ធផលនៃការបែកបាក់គ្រួសាររបស់ប្រជាជនកម្ពុជាដែលជាមូលហេតុសំខាន់ទីពីរនៃបរាជ័យរបស់ខ្មែរក្រហមក្នុងការស្វែងរកការគាំទ្រពីកសិករ ។

## ការបែកបាក់គ្រួសារ

"ក្នុងដំណាក់កាលដំបូងនៃការតស៊ូរបស់យើង ទោះនៅក្នុងការតស៊ូនយោបាយ ការតស៊ូអាវុធ ឬនៅក្នុងសង្គ្រាមក្តី កម្មសិទ្ធិឯកជនបានធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់បដិវត្តន៍ ។ ជាក់ស្តែង អ្នកដែលគិតអំពីផលប្រយោជន៍គ្រួសារតែងតែមិនស្មោះត្រង់ចំពោះបដិវត្តន៍ ។ ជនបែបនេះបានបោះបង់ចោលការតស៊ូ ហើយទៅរស់នៅដាច់ដោយឡែកតែឯង ស្វែងរកសុភមង្គលសម្រាប់តែគ្រួសារឯងជាជាងសម្រាប់សមូហភាព" ។ (ស្រង់ចេញពីសៀវភៅ "ទង់បដិវត្តន៍" លេខពិសេស ខែកញ្ញា-តុលា ឆ្នាំ១៩៧៦) ។

មេដឹកនាំបដិវត្តន៍ខ្មែរក្រហមមិនចាត់ទុកភាពស្មោះស្ម័គ្រចំពោះគ្រួសារជាចំណុចល្អនោះទេ ។ មេដឹកនាំទាំងនេះចង់ឲ្យបដិវត្តន៍ជ្រៀតចូលទៅក្នុងគ្រប់ស្រទាប់វណ្ណៈនៃសង្គម រួមទាំងគ្រួសារកម្ពុជាដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងសមាជិក ។ មេដឹកនាំខ្មែរក្រហមមួយរូបបានសរសេរថា "បដិវត្តន៍សង្គមនិយមក្តោបលើអ្វីៗទាំងអស់" ។ ប្រជាជនកម្ពុជាត្រូវបានបង្ខំឲ្យរស់នៅហូបចុកនិងថែទាំកូនចៅរួមគ្នានៅក្នុងសហករណ៍ ។ នេះជានយោបាយដែលត្រូវបានស្អប់ខ្ពើមជំនួសឲ្យការស្រលាញ់គ្រួសារ ។ រស់នៅដាច់ឆ្ងាយពីក្រុមគ្រួសារធ្វើឲ្យប្រជាជនកម្ពុជាបាត់បង់ភាពស្មោះស្ម័គ្រចំពោះបដិវត្តន៍ ។ ណាយ អ៊ិត បានរៀបរាប់ថា "ក្រោយពេលចូលបម្រើបដិវត្តន៍ ខ្មែរក្រហមមិនអនុញ្ញាតឲ្យខ្ញុំត្រឡប់មកលេងផ្ទះវិញទេ ។ ធ្វើអីចឹងខ្ញុំអស់ទឹកចិត្តរលីង" ។ កូនត្រូវបានបំបែកចេញពីឪពុកម្តាយរយៈពេលជាច្រើនសប្តាហ៍ទើបបានជួបមុខគ្នាម្តង ។ ម៉ម កល្យានី បានសរសេរថា ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកដែលខ្លួនមិនដែលស្គាល់ ។ ការព្យាយាមលុបបំបាត់ចោលការរស់នៅជាគ្រួសារបានចាប់ផ្តើមនៅក្នុងសម័យសង្គ្រាមស៊ីវិល ។

ទោះជាយ៉ាងណាក៏ដោយ ការវាយប្រហារទៅលើចំណងគ្រួសារគឺជាការគិតខុសដ៏ធំមួយរបស់ខ្មែរក្រហម ហើយជាកត្តាដ៏សំខាន់មួយនៅក្នុងការបរាជ័យរបស់បដិវត្តន៍ខ្មែរក្រហម ។ តាមរយៈ ប៉ែន យៀរនិន ទង្វើនេះជាចំណុចដែលពុំអាចទ្រាំទ្របានបំផុតរបស់របបខ្មែរក្រហម ។ ការសង្កេតមើលជីវភាពជនបទកម្ពុជារបស់ ម៉េ អេប៊ីហ៊ារ៉ា បញ្ជាក់ពីមូលហេតុពិត ។ គ្រួសារជាធាតុសង្គមជាមូលដ្ឋានសម្រាប់សង្គមកសិករខ្មែរ ។ នៅតាមភូមិឃុំកម្រមានក្លឹបសមាគមឬគណបក្សនយោបាយណាស់ ។ ជាលទ្ធផល "ចំណងគ្រួសាររវាងប្តីនិងប្រពន្ធកូននិងកូន ពិសេសកូននិងឪពុកម្តាយស្អិតល្មួតនិងស៊ិតស្មាញជាងអ្វីៗទាំងអស់នៅតាមជនបទ" ។ ចំណងរវាងម្តាយនិងកូនស្រីក៏ស្អិតល្មួតណាស់ដែរ ។ នារីជំទង់អាស្រ័យលើឪពុកម្តាយជាច្រើនចំណុច ហើយឪពុកម្តាយការពារកូនស្រីខ្លាំងណាស់ ។ គូស្វាមីភរិយាថ្មីតែងតែរស់នៅជាមួយឪពុកម្តាយខាងស្រីក្រោយពេលរៀបអាពាហ៍-ពិពាហ៍ រហូតដល់ពេលបុរសជាប្តីមានលទ្ធភាពគ្រប់គ្រាន់ដើម្បីសាងសង់ផ្ទះមួយដោយខ្លួនឯង ។

ការផ្សារភ្ជាប់ទៅនឹងគ្រួសារជាផ្នែកមួយនៃទស្សនវិស័យអភិរក្សនិយមទូទៅរបស់កសិករខ្មែរ ។ នេះចំណុចដែលមិនមែនបដិវត្តន៍ ។ ប្រជាកសិករបានគាំទ្របដិវត្តន៍ខ្មែរក្រហមដើម្បីស្តាបនាសណ្តាប់ធ្នាប់សង្គមមុនសង្គ្រាមឡើងវិញ ។ ប្រជាជនចង់បញ្ចប់សង្គ្រាមឲ្យបានឆាប់ៗ ដើម្បីវិលត្រឡប់ទៅរកការរស់នៅតាមធម្មតាវិញ ពិសេសការរស់នៅជាគ្រួសារ ។

ចម្លើយរបស់ស្ត្រីដែលបានសម្ភាសនៅទីនេះ ឆ្លុះបញ្ចាំងពីទស្សនវិស័យអភិរក្សទាក់ទងនឹងគ្រួសារ ។ ក្រោយពីបានបញ្ជូនទៅសមរភូមិមុខធ្វើជាអ្នកដឹកជញ្ជូនគ្រាប់ ស៊ុម ស្រេង អាយុ១៨ឆ្នាំ

ក៏ដូចនារីដទៃ តែឥមានការភ័យខ្លាចចំពោះការស្លាប់ ហើយទង្វើរបស់គាត់ក្រោយមកទៀតដូចទៅនឹងអ្វីដែលស្ត្រីផ្សេងបានធ្វើៈ "ព្រោះតែនឹកផ្ទះពេក ខ្ញុំរត់ទៅជួបឪពុកម្តាយខ្ញុំជាញឹកញយ ។ ខ្ញុំនឹកផ្ទះមែនទែន ខ្ញុំចង់តែរត់គេចទេ" ។ រាល់ពេលដែលគាត់លួចរត់មកផ្ទះ គាត់តែងតែត្រូវខ្មែរក្រហមចាប់បញ្ជូនទៅវិញជានិច្ច ទោះជាគាត់ឈឺធ្ងន់យ៉ាងណាក៏ដោយ ។ គាត់ពោលថា "ខ្ញុំលួចរត់មកដល់ផ្ទះ៥ដង ។ ពេលមួយ នោះខ្ញុំឈឺរលាកខ្នង ហើយក្តៅខ្លួនយ៉ាងខ្លាំង ។ គេនៅសែងខ្ញុំនឹងអង្រឹងយកទៅវិញ" ។ ណាំ សុខា បានទទួលរងនូវការធ្វើបាបស្រដៀងគ្នា គាត់ពោលថា "ខ្ញុំនឹកពុកនិងម៉ែណាស់ ។ ខ្ញុំបានលួចរត់មកផ្ទះ ឈឺគ្រុនញាក់ ស្គមស្បែកដណ្តប់ឆ្អឹង ។ ពោះខ្ញុំតូចជាងជង្គង់ ។ ពេលមកដល់ផ្ទះខ្មែរក្រហមបានចាប់ខ្ញុំត្រឡប់ទៅវិញ" ។ នារីទាំងពីរសុទ្ធតែត្រូវបានពិន័យដោយសារការរត់ចោលជួរ ។ មេកងរបស់ ណាយ អ៊ិត បានប្រាប់គាត់ថា ឈប់រត់ទៅផ្ទះទៀតទៅ ពីព្រោះយួនបានសម្លាប់ឪពុកម្តាយគាត់អស់ហើយ ។ ក្រោយមកគាត់បានដឹងថា សម្តីនេះមិនពិតទេ គាត់រៀបរាប់ថា "មេកងខ្ញុំកុហកខ្ញុំ ។ គាត់កុហកខ្ញុំកុំឲ្យខ្ញុំលួចរត់ត្រឡប់មកផ្ទះវិញទៀត" ។ ណាយ អ៊ិត បានពោលបន្តថា ដោយសារខ្មែរក្រហមតឹងរ៉ឹងពេកមិនឲ្យគាត់មកលេងផ្ទះសោះ ទើបគាត់អស់ទឹកចិត្តនឹងបម្រើបដិវត្តន៍ទៀត ។ រាល់ស្ត្រីដែលផ្តល់បទសម្ភាសន៍បានព្យាយាមលួចរត់ត្រឡប់មកផ្ទះវិញ ដោយមូលហេតុនឹកផ្ទះ ។

សុខា និង ស្រេង បានបញ្ជាក់អំពីភាពរឹងរូសរបស់កសិករដែលមិនព្រមផ្តាច់ចំណងនៃក្តីស្រលាញ់គ្រួសារ ទោះបីជារងទុក្ខវេទនានៅក្នុងសង្គ្រាមយ៉ាងណាក៏ដោយ ។ ការព្យាយាមជាច្រើនលើកច្រើនសា លួចរត់ចោលសមរភូមិមកផ្ទះ គឺជាករណីផ្ទុយទាំងស្រុងទៅនឹងការពិពណ៌នារបស់ អេប៊ីហាវ៉ា អំពីយុវជនកម្ពុជាដែលត្រូវបានបញ្ចុះបញ្ចូលមនោគមវិជ្ជាយ៉ាងជិតដល់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យឲ្យឈប់នឹកនាអំពីគ្រួសារ ហើយលះបង់ទាំងស្រុងដើម្បីបដិវត្តន៍ៈ

"យុវជនគឺជាគោលដៅពិសេសនៃការបញ្ចុះបញ្ចូលមនោគមវិជ្ជារបស់បដិវត្តន៍...ការបញ្ចុះបញ្ចូលមនោគមវិជ្ជារួមទាំងការដាក់ឲ្យរស់នៅជាក្រុមនិងការបំបែកចេញពីគ្រួសារ នឹងបង្កឲ្យមានការរសាយចិត្តលែងនឹកនាអំពីគ្រួសារនិងធ្វើឲ្យមានភាពស្មោះស្ម័គ្រចំពោះសហករណ៍កងទ័ព បក្ស និងប្រទេសទាំងមូល" ។

ទោះបីជាមានយុវជនបែបនោះច្បាស់ក៏ដោយ ក៏មានភស្តុតាងជាក់ស្តែងបញ្ជាក់ថាករណីនេះមិនទូទៅទេ ពីព្រោះទំនៀមទម្លាប់ប្រពៃណីមិនងាយសាបរលាបនៅក្នុងអារម្មណ៍របស់ប្រជាជនកម្ពុជាទេ ។ កល្យាទី បានចងក្រងជាឯកសារនូវសេចក្តីក្លាហានរបស់ឪពុកម្តាយ ដែលបញ្ជាក់អំពីសេចក្តីស្រលាញ់ដ៏ជ្រាលជ្រៅរបស់ឪពុកម្តាយចំពោះកូន ។ កល្យាទី បានសម្ភាសស្ត្រីដែលជាម្តាយដែលក្នុងសម័យខ្មែរក្រហមបានលួចអាហារទុកឲ្យកូន ។ នេះជាទង្វើដ៏ក្លាហានមួយដែលបញ្ជាក់ថាអង្គការពុំបានផ្តល់ម្ហូបអាហារគ្រប់គ្រាន់ ហើយបានបរាជ័យក្នុងការបំពេញកាតព្វកិច្ចជាឪពុកម្តាយរបស់កុមារនិងយុវជន ។

ខ្មែរក្រហមបានទាមទារនូវការគាំទ្រពេញទំហឹងនិងភាពស្មោះស្ម័គ្រពីប្រជាជនកម្ពុជា ។ បដិវត្តន៍ត្រូវការការលះបង់បែបនេះ ដូចដែល ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋបានរៀបរាប់នៅក្នុងសុន្ទរកថាមួយនៅក្នុងឆ្នាំ១៩៧៨ក្នុងទិវាខួបលើកទីបីនៃជ័យជម្នះខ្មែរក្រហមថាៈ

*"យើងទាំងអស់គ្នាប្តេជ្ញាចិត្តខិតខំរៀនសូត្រយកគំរូតាមភាពអង់អាចក្លាហានបដិវត្តន៍របស់កងទ័ពបដិវត្តន៍ ដោយពង្រឹងភាពស្មោះស្ម័គ្រចំពោះបដិវត្តន៍ឲ្យរឹងដូចដែកថែមទៀត និងបង្កើនមោទនភាពបដិវត្តន៍ឆ្ពោះទៅរកជាតិ ប្រជាជន កងទ័ពបដិវត្តន៍ បដិវត្តន៍និងបក្ស តាមរយៈការដាក់ប្រយោជន៍ជាតិ ប្រជាជនវណ្ណៈសង្គមនិងបដិវត្តន៍ឲ្យខ្ពស់ជាងប្រយោជន៍បុគ្គលនិងគ្រួសារ..."* ។

អតីតកម្មាភិបាលខ្មែរក្រហម អ៊ិត សារិន បានបកស្រាយសេចក្តីព្យាយាមជំរុញឲ្យប្រជាជនគាំទ្រជា "លក្ខខណ្ឌផ្តាច់ការមួយរបស់បក្សលើបុគ្គល ជាអាជ្ញាធរមិនមានដែនកំណត់របស់បក្សលើអ្វីៗគ្រប់យ៉ាង" ។ រដ្ឋចង់បានការគ្រប់គ្រងលើការសម្រេចចិត្តដែលពីមុនមកត្រូវបានធ្វើទៅលើបុគ្គលនិងគ្រួសារ ដូច្នេះអាជ្ញាធរត្រូវតែកម្ចាត់ចោល ។ តាមរយៈអង្គការ អ៊ិត សារិន បានសរសេរថា "បុគ្គលតែឯង មិនគ្រប់គ្រាន់មិនពូកែ" ។ តាមការពិតស្ត្រីកសិករដែលបានសម្ភាស បានផ្តល់ហេតុផលអំពីចំណុចខ្វះខាតនេះតែទៅលើការរត់ចោលជួរប៉ុណ្ណោះ ។ ចំពោះអង្គការ

នេះជាកំហុសមួយដែលប្រព្រឹត្តឡើងដោយសារស្ត្រីទាំងនេះប្រឡាក់ទៅដោយគំនិតបុគ្គលនិយម ។ អ៊ឹម ចាន់ បានដឹងច្បាស់អំពីគ្រោះថ្នាក់នៃការលាតត្រដាងជំនឿក្នុងចិត្តរបស់គាត់ចំពោះអង្គការ ។ ក្រោយពីចូលបម្រើបដិវត្តន៍គាត់ពោលថា "ខ្ញុំខឹងជានិច្ច តែខ្ញុំលាក់ទុកនៅក្នុងចិត្ត ។ បើខ្ញុំនិយាយចេញ គេនឹងសម្លាប់ខ្ញុំ ។ នៅក្នុងសម័យនោះ មួយម៉ាត់រស់ មួយម៉ាត់ស្លាប់" ។ នួន ជា ឬ បងទីពីរ (បន្ទាប់ពី ប៉ុល ពត) ហើយក្នុងរយៈពេលមួយជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ បានទទួលស្គាល់អំពីវត្តមាននៃជំងឺ"គ្រួសារនិយម"នៅក្នុងសម័យសង្គ្រាមស៊ីវិល ។ នៅក្នុងសេចក្តីថ្លែងការណ៍ទៅកាន់ "បក្សកម្មករកុម្មុយនិស្តដាណឺម៉ាក" នៅឆ្នាំ១៩៧៨ នួន ជា បានកត់សម្គាល់ថា"នៅក្នុងការតស៊ូយើងបានជួបប្រទះឧបសគ្គជាច្រើន ដូចជាកម្មាភិបាលខ្លះដែលត្រូវបានបំបែកចេញពីគ្រួសារហើយមិនរឹងមាំផ្នែកសតិអារម្មណ៍បានលួចរត់ត្រឡប់មកផ្ទះវិញ" ។ នួន ជា បានបន្តថា "មនោគមវិជ្ជាជាកត្តាពិសេស" នៅក្នុងការព្យាយាមបំពេញការខ្វះខាតខាងគោលជំហរបដិវត្តន៍" ។ ការយកចិត្តទុកដាក់អំពីមនោគមវិជ្ជាបានបន្តក្រោយ "ថ្ងៃរំដោះ" ឆ្នាំ១៩៧៥ ។ នៅក្នុងសេចក្តីថ្លែងការណ៍ដដែល នួន ជា បានពន្យល់ថា "នៅក្នុងការងារអប់រំកម្មាភិបាល យើងសង្កត់ធ្ងន់ទៅលើការកម្ទេចចោលនូវគោលជំហរសតិអារម្មណ៍ដែលនៅសេសសល់ពីសង្គមចាស់" ។ ក្នុងន័យនេះគឺរួមទាំងការកម្ទេចចោលនូវការរស់នៅជាគ្រួសារផង ។

អេលីហ្សាប៊ែត ប៊ែកឃ័រ បានកត់សម្គាល់ថា ខ្មែរក្រហមមិនដែលបានហាមប្រាមជាផ្លូវការមិនឲ្យមានគ្រួសារប្រភេទនេះទេ ។ សឹងតែរាល់បទបញ្ជារបស់ខ្មែរក្រហម និយាយអំពីការបំបែកបំបាក់គ្រួសារ ។ ខ្មែរក្រហមថែមទាំងបានហាមឃាត់មិនឲ្យប្រើពាក្យដែលធ្លាប់បានប្រើប្រាស់នៅក្នុងគ្រួសារពីមុន ដែលសុទ្ធតែជាពាក្យបញ្ជាក់ពីការគោរពចំពោះចាស់ទុំ ។ ការរិះគន់ដោយផ្ទាល់មួយបានលើកឡើងអំពីគុណវិបត្តិរបស់បក្សកុម្មុយ-និស្តកម្ពុជា និយាយអំពីគោលជំហររបស់កម្មាភិបាលដែលនៅតែគាំទ្រ "គ្រួសារនិយម ទ្រព្យសម្បត្តិឯកជន អំណាច កេរ្តិ៍ឈ្មោះនិងការប្រណែនឈ្នានីស" ។

ការពង្រត់យុវនារីនៅក្នុងស្រុកព្រែកស្តីចេញពីគ្រួសារហើយការហាមប្រាមនារីទាំងនេះមិនឲ្យមកជួបឪពុកម្តាយ គឺជាផ្នែកមួយនៃគម្រោងរបស់ខ្មែរក្រហមក្នុងការបំបាត់ចោលប្រភពអំណាចដែលប្រកួតប្រជែងជាមួយអង្គការ ។ គោលនយោបាយដ៏តឹងរ៉ឹងរបស់ខ្មែរក្រហមចំពោះស្ត្រីគឺជាឧទាហរណ៍នៃការប្រើប្រាស់ទ្រឹស្តីម៉ាក្ស-លេនីនរបស់ខ្មែរក្រហម ជា"ឧបករណ៍ដ៏រេចរឹលនិងជាអាវុធបង្កឲ្យមានវិនាសកម្ម" នៅពេលដែលខ្មែរក្រហមអនុវត្តគំនិតរបស់ អ៊ែងដែល អំពីពលកម្មទិន្នផលខ្ពស់របស់ស្ត្រីជាមួយភាពមិនបត់បែន ។ ទោះជាយ៉ាងណា ការរិះគន់ខ្លួនឯងខាងលើនេះបានបង្ហាញអំពីភាពស៊ិតស្វាញនៃចំណងក្តីស្រលាញ់របស់គ្រួសារ ទោះជានៅក្នុងរដ្ឋមួយដែលមានភាពទន់ខ្សោយយ៉ាងណាក៏ដោយ ។

ផ្ទុយទៅវិញ បក្សកុម្មុយនិស្តចិននិងវៀតណាមបានផ្តល់ដល់ស្ត្រីនូវតួនាទីបដិវត្តន៍មួយនៅក្នុងគ្រួសារ គឺស្ត្រីមានកាតព្វកិច្ចថែទាំផ្ទះនៅពេលដែលប្តីរបស់ខ្លួនទៅធ្វើសង្គ្រាម ។ ក្នុងពេលជាមួយគ្នា នៅប្រទេសកូរ៉េខាងជើងមេដឹកនាំ គីម អ៊ីលស៊ុង បានប្រកាសអំពីសារប្រយោជន៍នៃគ្រួសារចំពោះការពង្រឹងបដិវត្តន៍ ។ នៅពេលដែលនិន្នាការកំណែទម្រង់នៅក្នុងចលនាទាំងនេះត្រូវបានហាមឃាត់ ទំនៀមទម្លាប់របស់កសិករត្រូវបានគោរព ។ ឧត្តមគតិនៃការធ្វើដូច្នេះត្រូវបានសង្កេតឃើញយ៉ាងច្បាស់ដោយមេដឹកនាំខ្មែរក្រហម ។

ចំពោះខ្មែរក្រហម កុម្មុយនិស្តនិយមជ្រុលការលះបង់បែបនោះគឺជាការផ្ទុយទៅនឹងគោលជំហរ ហើយខ្មែរក្រហមបានតាំងចិត្តបង្កើតរបបសង្គមនិយមដ៏បរិសុទ្ធមួយតាមដែលអាចធ្វើទៅបាន ។ តាមការពិត ដូចបានបង្ហាញនៅក្នុងជំពូកមុន ខ្មែរក្រហមបានជឿជាក់ថាខ្លួនបានធ្វើឲ្យសម្រេចដូច្នោះរួចហើយ ។ ខ្មែរក្រហមបានបង់ការខូតខាតចំពោះលទ្ធិរ៉ាឌីកាល់និយមរបស់ខ្លួនពីព្រោះខ្មែរក្រហមមិនទទួលបានភាពស្មោះស្ម័គ្រចំពោះរបបខ្លួន ។ ចំពោះខ្មែរក្រហមភាពមិនបត់បែនរបស់ខ្លួនគឺធ្វើឲ្យមានការខាតបង់ច្រើន ។ នៅក្នុងទស្សនៈរបស់ស្ត្រីកម្ពុជាគោលនយោបាយទាំងនេះគឺជាការប៉ុនប៉ងដ៏ឃោរឃៅពុំអាចយល់បានក្នុងការបំផ្លាញទំនាក់ទំនងជាទីពេញចិត្តរបស់ប្រជាជន និងបំបាំងភាពក្តៅក្រហាយរបស់ប្រជាជនចំពោះរបបខ្មែរក្រហម ។ ការឈឺចាប់

របស់ ណាំ សុខា ចំពោះឪពុកម្តាយគាត់និងក្រុមគ្រួសារគាត់នៅតែមិនទាន់សាបរលាប ។ គាត់ពោលថា «ឪពុកម្តាយ និងបងប្អូនខ្ញុំបានស្លាប់បាត់បង់ជីវិត ។ ១៨នាក់ស្លាប់ទាំងអស់ ខ្លោចផ្សាណាស់ ។ ខ្ញុំចង់សម្លាប់ខ្មែរក្រហមទាំងអស់ ដែលបានសម្លាប់ឪពុកម្តាយខ្ញុំ ។ បើសម្លាប់ទៅធ្វើឲ្យបងប្អូនខ្ញុំរស់ឡើងវិញ ខ្ញុំនឹងតាមសម្លាប់ខ្មែរក្រហមភ្លាម» ។

## មនោគមវិជ្ជា និង ការអប់រំ

«យើងត្រូវបន្តពង្រីកនិងពង្រឹងសតិអារម្មណ៍សង្គមនិយម ដើម្បីឲ្យវាក្លាយទៅជាសរសៃពួរដ៏សុិតរបស់សហករណ៍» ។ ស្រង់ចេញពីឯកសារទង់បដិវត្តឆ្នាំ១៩៧៦ ។

ទោះបីជាមានការអះអាងបន្តបន្ទាប់ដូចជាឃ្លាខាងលើ ខ្មែរក្រហមពុំអាចធ្វើឲ្យប្រជាកសិករស្ត្រីបំភ្លេចគ្រួសារ ហើយតស៊ូលះបង់ដើម្បីបដិវត្តន៍ឡើយ ។ ការអប់រំបដិវត្តន៍ដែលខ្មែរក្រហមបានផ្តល់ឲ្យ មានភាពច្របូកច្របល់និងសង្ខេបពេក ហើយជួនកាលមិនមាននៅក្នុងភាពជាក់ស្តែងទៀតផង ។ ហេតុដូច្នេះ ខ្មែរក្រហមបរាជ័យក្នុងការសម្រេចគោលដៅដាស់សតិអារម្មណ៍នយោបាយមហាជន ។ ការប្រជុំនយោបាយនិយាយតែអំពីការបង្គាប់បញ្ជាឲ្យកសិករ «ខំប្រឹងធ្វើការងារ» ដោយពុំបានផ្តល់ហេតុផលច្បាស់លាស់ លើកលែងតែការគំរាមដាក់ទណ្ឌកម្មអាចដល់ស្លាប់ ។ បក្សកុម្មុយនិស្តកម្ពុជាពុំអាចផ្សារភ្ជាប់នយោបាយកុម្មុយនិស្តខ្លួនទីពឹងខ្លួនទៅនឹងជីវិតរបស់កសិករ ហើយថែមទាំងខ្វះខាតកម្មាភិបាលជាអ្នកអប់រំដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការពន្យល់អំពីគោលគំនិតរបស់បក្សឲ្យមានប្រសិទ្ធភាពទៀតផង ។

បញ្ហាទីមួយជាមួយការបញ្ចូលមនោគមវិជ្ជារបស់ខ្មែរក្រហមគឺការធ្វើឲ្យតែបានរបស់ខ្មែរក្រហម ។ បញ្ហានេះមានលក្ខណៈធ្ងន់ធ្ងរនៅក្នុងដំណាក់កាលចុងក្រោយនៃសង្គ្រាមស៊ីវិល នៅពេលដែលអ្នកអប់រំនយោបាយត្រូវបានជ្រើសចូលដោយជនកុម្មុយនិស្តកម្ពុជា ។ ខ្មែរក្រហមបានសម្លាប់ចោល ឬ បញ្ជូនកម្មាភិបាលចេះដឹងមួយចំនួនរបស់ខ្លួនទៅសមរភូមិឲ្យស្លាប់ ដែលសុទ្ធតែបានទទួលការអប់រំពីទីក្រុងហាណូយ ។ សម្រាប់មេដឹកនាំខ្មែរក្រហមដែលប្រឆាំងនឹងឥទ្ធិពលបរទេស ពិសេសវៀតណាម ទំនាក់ទំនងដ៏យូរយង់របស់កម្មាភិបាលទាំងនេះជាមួយវៀតណាមមានន័យថា កម្មាភិបាលទាំងនេះគឺជាជនក្បត់រួមដៃជាមួយយួន ។ បញ្ញវន្តដែលបានចូលបម្រើបដិវត្តន៍ក៏ត្រូវបានសង្ស័យដែរ ។ ទីម៉ូធី ម៉ៃឃើលខានី បានពិពណ៌នាអំពីស្ថានភាពជាលទ្ធផលថា «ដុយពីនៅប្រទេសវៀតណាម ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនគោរពតាមតម្លៃថ្មីរបស់ខ្លួន ប្រហែលមកពីមូលហេតុថា សូម្បីតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមក៏មិនមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបង្កឲ្យមានការជឿជាក់ក្នុងចិត្តចំពោះបដិវត្តន៍ ដែលចាំបាច់សម្រាប់ការអនុវត្តន៍ទ្រឹស្តីប្រកបដោយការបត់បែនទៅតាមកាលៈទេសៈបានផងទេ» ។ គ្រួសាររបស់ ណាំ អុិត បានរងគ្រោះដោយសារកង្វះបទពិសោធន៍បែបនោះ រួមនិងមហិច្ឆតានិងអំពើឃោរឃៅរបស់ខ្មែរក្រហម ។ គាត់បានរំឭកថា «មេដឹកនាំ ដែលទើបតែឡើងកាន់អំណាចនិងចង់ធ្វើធំ បានចោទថាឪពុកម្តាយរបស់ខ្ញុំជាចិនឬយួន ហើយក៏យកពួកគាត់ទៅសម្លាប់ចោល ។ ពួកវាថែមទាំងចង់សម្លាប់ប្អូនខ្ញុំទៀត ប៉ុន្តែប្អូនខ្ញុំនៅតូចពេកមិនយល់ពីអ្វីទាំងអស់» ។

ការដាក់បញ្ញារបស់ជនកុម្មុយនិស្តវៀតណាមត្រូវបានធ្វើឡើងយ៉ាងប្រុងប្រយ័ត្នដើម្បីចៀសវាងសកម្មភាពបែបនោះ ។ វៀតណាមមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការជ្រើសរើសកងទ័ពដើម្បីធានាថាគោលដៅធំរបស់បដិវត្តន៍មិនឋិតនៅក្រោមមហិច្ឆតារបស់ជនដែលមានមនោគមវិជ្ជាខ្សោយទេ ។ សាន់ជ្រា ថាយលើរ បានពន្យល់ថា «បក្សបានហាមប្រាមមិនឲ្យជ្រើសរើសសមាជិកចូលច្រើនពេកទេ ដែលនាំឲ្យបាត់បង់ការគ្រប់គ្រង ។ «ឱកាសនិយម» ឬ «ស្ម័គ្រចិត្តនិយម» ដែលអនុញ្ញាតឲ្យសមាជិកបក្សខ្លះអាចធ្វើតាមសេចក្តីត្រូវការផ្ទាល់ខ្លួន មិនមែនជាការណែនាំរបស់បក្ស គឺត្រូវចៀសវាង» ។ សំណាងអាក្រក់សម្រាប់ស្ត្រីនៅក្នុងឃុំព្រែកស្តី មេដឹកនាំដែលស្រីទាំងនោះត្រូវបង្ខំឲ្យគោរពតាមបានបង្ហាញភាពមិនចេះគោរពតាមហេតុផល ភាពមិនបត់បែន និងការដឹកនាំអន់ខ្សោយដែល ម៉ៃឃើល ខានី បានសង្កេតឃើញពីព្រោះខ្មែរក្រហមមិនយល់ពីអារម្មណ៍របស់កម្មាភិបាលរួមអាវុធនិងមិនរកមធ្យោបាយដើម្បីជាថ្នូរចំពោះភាពឯកោនិងការភ័យខ្លាចរបស់ប្រជាជន ។

ស្ថានភាពដ៏ក្រៀមក្រំរបស់ស្ត្រីទាំងនេះមួយផ្នែកគឺជា

លទ្ធផលនៃការបញ្ចូលមនោគមវិជ្ជាទាន់ហន់ដែលបង្កើតបាន ត្រឹមតែការប្តេជ្ញាចិត្តសើៗចំពោះបុព្វហេតុបដិវត្តន៍ ។ ការណ៍នេះ បង្កឲ្យស្ត្រីមិនអាចទ្រាំទ្រនឹងភាពលំបាកវេទនានិងកណ្តោចកណ្តែង នៅក្នុងសមរភូមិឡើយ ។ ស៊ុម មានអាយុ១៨ឆ្នាំប៉ុណ្ណោះនៅ ពេលចូលបម្រើបដិវត្តន៍ដំបូង ដែលនៅមានភាពទន់ខ្សោយ ។ ក្រោយពីបានចាកចេញពីភូមិ គាត់ត្រូវទទួលការហ្វឹកហ្វឺនយោធា រយៈពេលមួយខែកន្លះ ប៉ុន្តែពុំចាំថាគាត់បានទទួលការអប់រំអំពី គំនិតជាមូលដ្ឋានគ្រឹះរបស់បដិវត្តន៍ និងផលប្រយោជន៍របស់ បដិវត្តន៍ចំពោះគាត់និងគ្រួសារគាត់ទេ ។ ឆ្លងកាត់ការងារដញ្ជូន គ្រាប់នៅក្នុងសមរភូមិ គាត់ក៏ដឹងថាគាត់បានសម្រេចចិត្តខុស គឺថា ការចូលរួមបដិវត្តន៍មិនមែនជា "ការសប្បាយ" ដូចដែល គាត់បានគិតទុកនោះទេ ។ គាត់ប្រាប់ថា "ខ្ញុំបានដឹងភ្លាមៗថាខ្ញុំ បានធ្វើខុសមិនអាចកែបាន ។ ខ្ញុំចង់លួចរត់ ។ ខ្ញុំត្រូវខ្មែរក្រហម បោកបញ្ឆោតឲ្យចូលបម្រើកងទ័ព នៅពេលខ្ញុំមិនទាន់ដឹងអ្វីប៉ុន្មាន" ។ ដឹងខ្លួនខុសនិងមានអារម្មណ៍ច្របូកច្របល់ នារីជំទង់នៅសមរភូមិ បានបដិសេធរាល់ការអប់រំដែលខ្មែរក្រហមបានផ្តល់ឲ្យ ។ ស៊ុម និយាយថា "យើងមិនចង់រៀនអីទាំងអស់ ចង់តែរត់មកផ្ទះ ។ យើងលួចរត់ តែត្រូវគេចាប់យកទៅវិញ" ។ បច្ចុប្បន្ននេះ នៅ ពេលត្រូវគេសួរពីមូលហេតុ ដែលគាត់ចូលបម្រើខ្មែរក្រហម ស៊ុមឆ្លើយថា "ខ្ញុំមិនដឹង គ្រាន់តែដឹងថាធ្វើតាមគេ វាយប្រយុទ្ធ រហូតដល់ឈ្នះជាមួយគេទៅ" ។

បទពិសោធន៍របស់ ណាំ ស្រដៀងគ្នានឹង ស៊ុម "ខ្ញុំមិនដែល បានហាត់រៀនទេ ។ ខ្ញុំជាអ្នកដញ្ជូនស្បៀងនៅក្នុងសមរភូមិ ។ គេឲ្យខ្ញុំចូលសមរភូមិតែខ្ញុំមិនដែលបានហាត់រៀនទេ" ។ នៅពេល ដែលទៅដល់សមរភូមិ ណាំ ត្រូវបានអប់រំឲ្យគិតតែអំពីបដិវត្តន៍ មួយមុខប៉ុណ្ណោះ ។ "នៅក្នុងជួរកងទ័ព គេឲ្យយើងតស៊ូ គេមិន ឲ្យនិយាយពីឪពុកម្តាយមិនឲ្យត្រឡប់មកផ្ទះវិញទេ" ។

ឡូ ស៊ីម បានពោលថា គាត់ក៏ពុំបានហ្វឹកហាត់ដែរ ។ ទោះបីជាយ៉ាងណាក៏ដោយពីដំបូងគាត់ជឿជាក់ចំពោះមូលហេតុ នៃការប្រយុទ្ធដែលខ្មែរក្រហមប្រាប់គឺ "ដើម្បីប្រជាជន និងទឹកដី ខ្មែរ" ហើយនេះគឺ "គួរឲ្យជឿមែន" ។ គាត់បានបន្តគិតអំពី "ការរំដោះ" ហើយ "កាលពីដំបូងខ្ញុំជឿគេ ខ្ញុំជឿលើគោលជំហរ នយោបាយរបស់គេ" ។ គំនិតនេះបានផ្លាស់ប្តូរយ៉ាងឆាប់រហ័ស គាត់ថា "ដំបូងខ្ញុំជឿ តែក្រោយមកឈប់ជឿហើយ ព្រោះវា មិនដែលធ្វើតាមពាក្យសម្តីសោះ" ។

កាសែតរបស់ទីក្រុងឡុងដ៍ឈ្មោះ "ទូរសារប្រចាំថ្ងៃ" បានសម្ភាសជាមួយនារីម្នាក់នៅឆ្នាំ១៩៧៨ ដែលបានពិពណ៌នា អំពីបទពិសោធន៍ស្រដៀងគ្នាទៅនឹងអ្វីដែលបានរៀបរាប់ខាងលើ ។ គាត់ថា "ខ្ញុំត្រូវគេនាំចេញពីភូមិកាលពីឆ្នាំមុន ។ អ្នកដែលមក យកខ្ញុំទៅនោះថានឹងសម្លាប់បងប្អូនខ្ញុំបើខ្ញុំមិនទៅតាម ។ ខ្ញុំទទួល ការហាត់រៀនប្រើប្រាស់កាំភ្លើងវែងពីរបីថ្ងៃ ក្រៅពីនេះខ្ញុំដឹក លេណដ្ឋាននិងដញ្ជូនគ្រាប់... ។ ខ្ញុំនៅទីនោះ ពីព្រោះខ្ញុំអាចត្រឹម តែស្តាប់បញ្ជាប៉ុណ្ណោះ" ។ នេះបញ្ជាក់ឲ្យឃើញថា ការអប់រំ នយោបាយសម្រាប់នារីជាច្រើនគឺមិនគ្រប់គ្រាន់នោះទេ ។ នារី ខ្មែរក្រហមអាចត្រូវបានបង្រៀនអំពីពាក្យស្លោក និងចម្រៀង មូលដ្ឋានគ្រឹះនៃនយោបាយខ្មែរក្រហម និងរបៀបបាញ់កាំភ្លើង ប៉ុណ្ណោះ ។

លើសពីនេះ ខ្មែរក្រហមបានបង្ហាញពីការមិនយកចិត្តទុក ដាក់អំពីសុខុមាលភាពអ្នកតស៊ូរបស់ខ្លួន ។ តាមរយៈជនប្រឆាំង មួយរូបដែលទទួលការហាត់រៀនពីហាណូយ"មេដឹកនាំខ្មែរក្រហម តែងតែនិយាយថា យើងនឹងប្រយុទ្ធភ្លាមៗ ទោះជាមានអ្នកស្លាប់ ប៉ុន្មានក៏ដោយ ។ ឲ្យតែឈ្នះ ងាប់ប៉ុន្មាន ក៏ងាប់ទៅមិនបញ្ហាទេ" ។ គាត់បន្ថែមថា "នៅពេលមានចំណុចខ្សោយត្រូវវាយប្រហារ ច្បាស់ជាវាយហើយ វាយតែអាហ្នឹង" ។ នេះជាគំនិតផប់ផល់ របស់ខ្មែរក្រហមចំពោះការវាយសម្រុកឲ្យបានលទ្ធផលខ្ពស់ ។ តាមការពិត បក្សកុម្មុយនិស្តកម្ពុជាបានកត់សម្គាល់ថា រយៈពេល ក្រោយជ័យជម្នះទៅលើសត្រូវ "បក្សមានកាតព្វកិច្ចដឹកនាំ ប្រទេស ។ បើបក្សខ្លាំងបក្សអាចឆក់យកជ័យជម្នះឆាប់រហ័ស ។ បក្សបានសន្យាបែបនេះមុនពេលផ្ទុះសង្គ្រាម" ។ បក្សរបស់ខ្មែរ ក្រហមប្រហែលអាចទទួលបានជ័យជម្នះលឿនមែនពិត ប៉ុន្តែបុរស និងស្ត្រី ដែលប្រយុទ្ធនៅសមរភូមិទទួលបានលទ្ធផលខ្លោចផ្សា ។

ទោះជាមានភ័ស្តុតាងបញ្ជាក់អំពីការបញ្ចូលមនោគមវិជ្ជា អន់ខ្សោយនិងលក្ខខណ្ឌសមរភូមិដ៏សែនវេទនាក៏ដោយក៏អក្សរសិល្ប៍ ខ្មែរក្រហមជាច្រើនបានឆ្លុះបញ្ចាំងអំពីភក្តីភាពរបស់យុវជន

កសិករកម្ពុជាចំពោះអង្គការ មុននិងក្រោយជ័យជម្នះរបស់ខ្មែរក្រហម ។ តាមការពិត បក្សកុម្មុយនិស្តកម្ពុជាខ្លួនឯងទទួលស្គាល់ការពិតថា យុវជនជាសសរទ្រូងរបស់បដិវត្តន៍ ហើយអួតអាងថាខ្លួនជ្រើសរើសតែក្មេងៗនិងពលរដ្ឋជំទង់ប៉ុណ្ណោះ ដើម្បីយកមកអប់រំឲ្យចេះស្រលាញ់បដិវត្តន៍ ។ ខេណេត យ៉ឹន បានបកស្រាយអំពីដំណើរការដែលយុវជននៅតាមជនបទត្រូវបានប្រែក្លាយជាកម្មាភិបាលខ្មែរក្រហម ។ ការបកស្រាយនេះ មានសារប្រយោជន៍សម្រាប់លើកជាឧទាហរណ៍ពីព្រោះវាផ្ទុយទៅនឹងអ្វីដែលត្រូវលើកយកមកពិភាក្សានៅក្នុងនិក្ខេបបទនេះ

"ខ្មែរក្រហមបានចាប់ផ្ដើមកម្មវិធីអប់រំនយោបាយសម្រាប់យុវជននិងយុវនារី ដែលរួមមានការនាំចេញពីភូមិកំណើតទៅកាន់តំបន់ជនបទដាច់ស្រយាលក្នុងអំឡុងពេលពីពីរទៅបីសប្ដាហ៍ ។ គ្មានភ័ស្តុតាងបញ្ជាក់ពីប្រធានបទនិងវិធីសាស្ត្រនៃការអប់រំទេ ប៉ុន្តែការអប់រំហាក់បីដូចជាទទួលបានលទ្ធផលក្នុងកម្រិតមួយ ។ អាស្រ័យទៅលើប្រភពផ្សេងៗ យុវជននិងយុវនារី (អាយុពី១៦ទៅ១៨ឆ្នាំ) ពេលត្រឡប់មកពីទទួលការបង្ហាត់បង្រៀនវិញ... មានភាពមោះមុតក្នុងការរិះគន់សាសនា និង"របៀបរបបចាស់" មិនខ្លាចឪពុកម្ដាយ មានមនោសញ្ចេតនាខ្ពស់ចំពោះបក្សនិងរដ្ឋ មានការរិះគន់ខ្ពស់ចំពោះទំនៀមទម្លាប់ចាស់ និងមានគោលជំហរប្រយុទ្ធខ្ពស់ដែលបញ្ជាក់តាមរយៈការប្រើប្រាស់អាវុធស្ទាត់ជំនាញ...។ យុវជនទាំងនេះបានឈប់ធ្វើការងារសម្រាប់គ្រួសាររបស់ខ្លួនទៀត ហើយមកបម្រើការងារឲ្យសមាគមយុវជនវិញ ។ សមាគមនេះបានក្លាយទៅជាឪពុកម្ដាយថ្មីរបស់យុវជន" ។

យុវជនដែល ខេណេត យ៉ឹន បកស្រាយ ហាក់ដូចជាបានឆ្លងកាត់ការហ្វឹកហាត់ផ្នែកមនោគមវិជ្ជាច្រើនជាងស្ត្រីនៅក្នុងស្រុកព្រែកស្ដីដែលបានសម្ភាសទៅទៀត ។ វាត្រូវតែអីចឹង ប្រសិនបើខ្មែរក្រហមចង់សម្រេចបាននូវការលុបបំបាត់ចោលទាំងស្រុងនូវទំនៀមទម្លាប់ប្រពៃណីយូរយារមកហើយក្នុងរយៈពេលពីពីរទៅបីសប្ដាហ៍នៃការហាត់រៀន ។ តាមការបកស្រាយរបស់ ខេណេត យ៉ឹន កម្មវិធីអប់រំនយោបាយរបស់ខ្មែរក្រហមហាក់បីដូចជាមានប្រសិទ្ធភាពខ្លាំងណាស់ ។

ការបកស្រាយរបស់ ខេណេត យ៉ឹន ស្ទើរតែត្រឹមត្រូវទាំងស្រុងទេ ហើយបានផ្អែកទៅតាមការសម្ភាសន៍របស់មន្ត្រីបរិចារកិច្ចអាមេរិក ។ ទោះជាយ៉ាងនេះក្ដី មានកត្តាពីរដែល ខេណេត យ៉ឹន បានមើលរំលង៖ ទីមួយ ដូច ម៉ៃឃើល វីកឃ័រី បានកត់សម្គាល់ថា វាមានភាពខុសគ្នាខាងផ្នែកភូមិសាស្ត្រនិងពេលវេលានៃព្រឹត្តិការណ៍ផ្សេងៗក្នុងសម័យសង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជានាដើមទសវត្សរ៍ឆ្នាំ១៩៧០ ។ ដូច្នេះអ្វីដែលពិតនៅកន្លែងមួយ ឬក្នុងពេលមួយមិនមែនប្រាកដថា ពិតនៅកន្លែងផ្សេងទេ ។ បទសម្ភាសន៍របស់ ខេណេត យ៉ឹន បានធ្វើឡើងនៅរវាងខែកក្កដា ឆ្នាំ១៩៧២ និងខែមករា ឆ្នាំ១៩៧៤ មុនពេលដែលស្ត្រីភាគច្រើនដែលខ្ញុំបានសម្ភាសចូលបម្រើបដិវត្តន៍ ។ ខ្ញុំសន្និដ្ឋានថានៅពេលដែល ខេណេត យ៉ឹន ចុះស្រាវជ្រាវកម្ពុជា នៅពេលនោះមានកម្មាភិបាលមានចំណេះដឹងខ្ពស់ច្រើនជាងនៅអំឡុងពេលក្រោយៗមកទៀត ពីព្រោះសមាសធាតុជ្រុលនិយមរបស់ខ្មែរក្រហម(ដឹកនាំដោយខ្មែរក្រហម)ពុំទាន់មានឱកាសដើម្បីផ្ដួលរំលំរាល់គូប្រជែងរបស់ខ្លួននៅឡើយ ។ ក្នុងពេលជាមួយគ្នានេះដែរ សាក្សីរបស់ ខេណេត យ៉ឹន រស់នៅក្នុងតំបន់ផ្សេងៗរបស់ប្រទេសកម្ពុជាប៉ុន្តែមិនច្បាស់ថាតើសាក្សីទាំងនោះលើកយកតំបន់មួយណាមករៀបរាប់ទេ ។ ទីពីរ ខេណេត យ៉ឹន បានបកស្រាយថា យុវជនដែលបានត្រឡប់មកពីមជ្ឈមណ្ឌលបណ្ដុះបណ្ដាលមនោគមវិជ្ជាមានគោលជំហរបដិវត្តខ្ពស់ ប៉ុន្តែគោលជំហរនេះ មិនទាន់ត្រូវបានយកទៅសាកល្បងនឹងភាពតក់ស្លុតនៅក្នុងសមរភូមិនៅឡើយទេ ។ សមរភូមិជាកន្លែងសម្រាប់សាកល្បងអំពីភាពប្ដូរផ្ដាច់ពិតប្រាកដចំពោះបដិវត្តន៍របស់យុវជន ។

ក្រេក អេចឆេសាន់ បានវិភាគអំពីជម្រៅនៃការគាំទ្ររបស់កសិករចំពោះមនោគមវិជ្ជារបស់ខ្មែរក្រហម ហើយបានសន្និដ្ឋានថា មានកម្មាភិបាលមួយចំនួនតូចប៉ុណ្ណោះដែលអាចយល់និងព្រមបម្រើបដិវត្តន៍ដោយស្ម័គ្រស្មោះ ដោយតម្រូវទស្សនៈរបស់ខ្លួនទៅតាមបដិវត្តន៍ ដើម្បីឲ្យ"បុគ្គលម្នាក់ៗជឿទៅលើភាពត្រឹមត្រូវខាងសីលធម៌របស់បដិវត្តន៍" ។ ប្រជាកសិករមិនយល់អំពីគោលនយោបាយកុម្មុយនិស្ត ហើយមិនបានប្ដូរផ្ដាច់ក្នុងការសម្រេចគោលដៅរបស់ខ្មែរក្រហមទេ ។ ស្ត្រីភាគច្រើនដែល

បានផ្តល់បទសម្ភាសន៍មានការភ័ន្តច្រឡំអំពីមូលហេតុដែលខ្លួនប្រយុទ្ធ ។ ស្ត្រីទាំងនេះមានគំនិតស្នេហាជាតិ ប៉ុន្តែមិនយល់អំពីទស្សនៈបដិវត្តន៍កុម្មុយនិស្តទេ ។ ណាំ បានបកស្រាយថាគាត់ត្រូវបានបង្រៀន«ឲ្យមានចិត្តរឹងមាំក្នុងការប្រយុទ្ធប្រឆាំងនឹងសត្រូវ» ។ គាត់ថាគេមិនបានជម្រាបគាត់ឲ្យច្បាស់អំពីមូលហេតុនៃសង្គ្រាមទេ ។ នៅពេលត្រូវចោទសួរអំពីមូលហេតុគាត់ឆ្លើយថា «ខ្ញុំមិនដឹងទេ ។ គេបានប្រាប់ឲ្យខ្ញុំទៅខ្ញុំក៏ទៅតែម្តង ។ ខ្ញុំមិនយល់អស់ពេលជាយូរមកហើយ ។ ខ្ញុំភ័យណាស់ហើយស្តាប់តាមបញ្ជាគេជានិច្ច» ។ នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានទទួលទាហានជាចាំបាច់ដើម្បីប្រយុទ្ធក្នុងសង្គ្រាមស៊ីវិលដ៏ឃោរឃៅ ប៉ុន្តែមិនមានពេលវេលាឬធនធានគ្រប់គ្រាន់ដើម្បីអប់រំនយោបាយដល់ប្រជាកសិករឲ្យមានប្រសិទ្ធភាពដូចករណី ណាំ ឡើយ ។ ការបង្កិតបង្កំលាយជាមួយភាពឃោរឃៅតែងតែត្រូវបានប្រើប្រាស់ដើម្បីឲ្យមានការរណបខ្លាច ។

តាមការពិត ការសម្រេចគោលដៅឲ្យបានក្នុងមួយប៉ប្រិចភ្នែកដែលខ្មែរក្រហមបានគ្រោងសម្រាប់បដិវត្តន៍កម្ពុជាទាំងនៅក្នុងសម័យសង្គ្រាមស៊ីវិលនិងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានផលអាក្រក់ដល់សកម្មភាពអប់រំបដិវត្តន៍ ។ ប៉ុល ពត ខ្លួនឯងបានថ្លែងនៅក្នុងសុន្ទរកថាមួយថា «យើងចង់កសាងសង្គមនិយមបានឆាប់រហ័ស យើងចង់ឲ្យប្រទេសជាតិយើងផ្លាស់ប្តូរមុខមាត់ឆាប់រហ័ស ហើយយើងចង់ឲ្យប្រជាជនកម្ពុជារស់នៅបានសុខសាន្តឆាប់រហ័ស» ។ ដើម្បីរក្សាគោលជំហរនេះ ខ្មែរក្រហមបានកុហកខ្លួនឯងថាខ្លួនត្រូវបានគាំទ្រយ៉ាងពេញទំហឹងពីយុវជនខ្មែរដែលទទួលបានការអប់រំនយោបាយយ៉ាងជ្រួតជ្រាបរួមផ្សំនឹងការស្រលាញ់បដិវត្តន៍ ។ ពេញមួយអំឡុងពេលនៃការដឹកនាំខ្មែរក្រហមបានរំពុកម្តងហើយម្តងទៀត អំពីមូលដ្ឋានមនោគមវិជ្ជា«ដ៏ត្រឹមត្រូវ»នៃជោគជ័យរបស់បក្ស ។ ការរៀបរាប់អំពីប្រវត្តិយុវជននៅក្នុងបក្សដែលបានបោះពុម្ពនៅក្នុងព្រឹត្តិបត្រយុវជនខ្មែរក្រហមគឺសាមញ្ញៈ

*«ដោយសារទទួលបានការអប់រំមនោគមវិជ្ជាបដិវត្តន៍ថ្មីពីបក្សចលនាតស៊ូបដិវត្តន៍របស់យុវជនកើនឡើងកាន់តែខ្លាំងក្លាទាំងនៅក្នុងទីក្រុង និងនៅតាមជនបទ ហើយបានរួបរួមជាមួយចលនារបស់មហាជនទាំងមូលនៅក្រោមការដឹកនាំរបស់បក្ស ។ ជាក់ស្តែង ចលនាតស៊ូប្រយុទ្ធរបស់យុវជនដែលបក្សបានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៦២...នៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់បក្ស»* ។

នៅក្នុងឧទាហរណ៍មួយផ្សេងទៀត អៀង សារី រដ្ឋមន្ត្រីការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យបានពោលទៅកាន់កាសែត «ឡឺម៉ុងដ៏» នៅក្នុងឆ្នាំ១៩៧២ អំពីសារប្រយោជន៍នៃមនោគមវិជ្ជានិងនយោបាយត្រឹមត្រូវសម្រាប់ចលនារបស់បដិវត្តន៍ថាៈ

*«...ដើម្បីសម្រេចបានជោគជ័យនៅក្នុងបដិវត្តន៍ ត្រូវមានថ្នាក់ដឹកនាំមុឹងម៉ាត់ គោរពតាមគោលការណ៍បក្ស មានគំនិតច្នៃប្រឌិតទៅតាមលក្ខខណ្ឌជាតិជាក់ស្តែង ដើរតាមមាគ៌ានយោបាយនិងមានគោលដៅច្បាស់លាស់... ។ កត្តាកំណត់ជ័យជម្នះគឺមនុស្សនិងប្រជាជនដែលមានសន្ទុះនយោបាយប្រយុទ្ធខ្ពស់»* ។

នៅពេលដែលមេដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាបានអួតអាងអំពី«ជោគជ័យ»របស់ខ្លួន និងរៀបរាប់អំពីកម្ពុជាថ្មីដែលមិនទាន់កើត មានកម្មាភិបាលខ្វះការអប់រំរបស់ខ្មែរក្រហមនៅតាមមូលដ្ឋានបានចាប់ផ្តើមសង្ស័យចំពោះមហាជន រួមទាំងយុវជនដែរ ដោយបង្ខំឲ្យអ្នកទាំងនោះធ្វើការដើម្បីតែបដិវត្តន៍មួយមុខគត់ ហើយយកភាពឃោរឃៅមកជំនួសឲ្យការអប់រំនយោបាយជាក់ស្តែង ។ បទពិសោធន៍ស្រដៀងគ្នារបស់ ណាំ សុខា, ស៊ុម ស្រេង និងស្ត្រីដទៃទៀត ជាភស្តុតាងបញ្ជាក់អំពីស្ថានភាពនេះ ។ ជំនួសឲ្យការរំដោះប្រជាកសិករឲ្យចាកផុតពី«គ្រួសារនិយម» តាមរយៈដំណើរការនៃការអប់រំដែលមានបែបផែនត្រឹមត្រូវប្រជាកសិករត្រូវបានគេដាក់ពិន័យ ។ ស្ត្រីទាំងអស់នេះត្រូវជាប់ឃុំឃាំងក្រោយពីជ័យជម្នះខ្មែរក្រហមនៅឆ្នាំ១៩៧៥ ហើយប្រវត្តិរូបសង្ខេបនៅក្នុងគុកបានរៀបរាប់អំពីបទឧក្រិដ្ឋរបស់គាត់ថា «រត់ចោលជួរ» ។ តាមរយៈបទឧក្រិដ្ឋនេះ ស្ត្រីទាំងអស់ត្រូវបានស្តីបន្ទោសឬដាក់ទោសចំពោះការស្រលាញ់គ្រួសារ ។ រហូតដល់ឆ្នាំ១៩៧៩ ក្រោយពេលដែលត្រូវប្រានចេញពីអំណាចដោយកងទ័ពវៀតណាម ខ្មែរក្រហមទទួលស្គាល់ថា កម្មាភិបាលរបស់ខ្លួននៅតាមមូលដ្ឋានពុំមានចំណេះដឹងបដិវត្តន៍គ្រប់គ្រាន់ដូចការគិតរបស់មេដឹកនាំទេ ។ នៅឆ្នាំដដែល

*នៅអង្គការសហប្រជាជាតិ អៀង សារី បានទទួលស្គាល់ថា "ប្រហែលជាកម្មាភិបាលមួយចំនួនបានប្រព្រឹត្តកំហុសហើយ" ។ ចំពោះអំពើឃោរឃៅដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម អៀង សារី បានបន្ថែមថា "សកម្មភាពមួយចំនួនបានកើតឡើងដោយយើងខ្ញុំពុំបានដឹង" ។*

*ភាពអស់សង្ឃឹមនឹងជីវិតនៅក្រោមរបបខ្មែរក្រហមត្រូវបានកត់ត្រាទុកដោយចៃដន្យនៅក្នុងព្រឹត្តិបត្រមួយរបស់បក្ស ។ ឃ្លាខាងក្រោមដែលត្រូវបានសរសេរចេញដោយអចេតនាគឺត្រូវបានសរសេរក្នុងគោលបំណងពិពណ៌នាអំពីជីវិតនៅក្រោមរបបមូលធននិយម ប៉ុន្តែការសរសេរនេះបែរជារៀបរាប់អំពីភាពក្រៀមក្រំនៅក្នុងរបបខ្មែរក្រហមទៅវិញៈ*

*"យុវជនរបស់យើងប្រៀបបានទៅនឹងដើមផ្កាដែលកំពុងចេញត្រួយនិងផ្ការីកស្គុះស្គាយ ប៉ុន្តែនៅក្នុងសង្គមរបស់ពួកជិះជាន់យុវជនយើងនៅគ្រប់ស្រទាប់វណ្ណៈត្រូវបានធ្វើឲ្យក្រៀមស្វិតសង្កត់សង្កិន បំបិទមាត់ និងរងទុក្ខវេទនា ដោយសារតែអំពើពិសពុលរបស់ពួកអ្នកគាបសង្កត់ និងការគំរាមកំហែង និងបំភិតបំភ័យរបស់របបហ្វាស៊ីសផ្តាច់ការនៃពួកអ្នកគាបសង្កត់ ។ អនាគតរបស់យុវជនយើងគឺខ្មៅងងឹតនិងគ្មានន័យខ្វឹមសារអ្វីទាំងអស់" ។*

### តួនាទីរបស់ស្ត្រីនៅក្រោមរបបខ្មែរក្រហម
### "បុរស និង នារីស្មើភាពគ្នាពេញទីលើវិស័យទាំងអស់"
### មាត្រាទី១៣នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ។

*នៅក្នុងពេលមានសង្គ្រាមស៊ីវិល ខ្មែរក្រហមបានខំប្រឹងតស៊ូប្រយុទ្ធស្វែងរកការគាំទ្រពីប្រជាកសិករកម្ពុជា ។ ដូចយើងបានឃើញរួចមកហើយតាមរយៈគោលនយោបាយមិនច្បាស់លាស់ ការបង្ខិតបង្ខំ និងអំពើឃោរឃៅគ្រប់ទិសទី ខ្មែរក្រហមទទួលបានការគាំទ្រតែមួយកម្រិតដ៏តូចប៉ុណ្ណោះពីប្រជាជនកម្ពុជាភាគច្រើន ។*

*ស្ត្រីនៅតាមជនបទក៏ទទួលរងនូវការជិះជាន់និងការមិនយកចិត្តទុកដាក់ដែរ ។ ខ្មែរក្រហមមិនបានបង្កើតគោលនយោបាយរួមចំពោះស្ត្រី មិនបានបង្កើតវិធីសាស្ត្រដើម្បីបង្កើនការគាំទ្រពីស្ត្រីទេ ។ ខ្មែរក្រហមមិនបានវិភាគអំពីស្ថានភាពមុនបដិវត្តន៍ និងស្នើជាដំណោះស្រាយឲ្យស្របទៅតាមនយោបាយផ្អែកតាមលទ្ធិម៉ាក្ស-លេនីនរបស់ខ្លួនឡើយ ។ ខ្មែរក្រហមគាំទ្រសិទ្ធិស្ត្រីផ្អែកតាមការបកស្រាយត្រង់ៗនៃទ្រឹស្តីអំពីពលកម្មស្ត្រីរបស់អែងដែល ។ ខ្មែរក្រហមចាត់ទុកការកេងប្រវ័ញ្ចពលកម្មស្ត្រីជាការរំដោះស្ត្រី ។ លើសពីនេះ ខ្មែរក្រហមមិនដែលដាក់បញ្ហាស្ត្រីជាអាទិភាពរបស់បក្សទេ ដែលមានន័យថាជាការបដិសេធចោលការគាំទ្រពីប្រជាជនពាក់កណ្តាលប្រទេស ។ ការខ្វះខាតគោលនយោបាយរួមមួយដើម្បីបង្កើនការគាំទ្រពីស្ត្រីជាកត្តាមួយនាំទៅរកបរាជ័យរបស់បដិវត្តន៍ទាំងមូល ។*

*នរវិទូ ម៉េ អេប៊ីហ៊ារ៉ា បានចំណាយពេលវេលាយ៉ាងយូរនៅតាមជនបទប្រទេសកម្ពុជា ហើយការសង្កេតរបស់គាត់ គឺជាបន្ទួចដ៏សំខាន់របស់យើងសម្រាប់សម្លឹងមើលទៅជីវិតរបស់កសិករស្ត្រីមុនឆ្នាំ១៩៧០ ។ គាត់គាំទ្រការអះអាងដែលថា "ស្ត្រីកម្ពុជា... មានអំណាចមួយកម្រិតជាក់លាក់ ឯករាជ្យ និងសេរីភាព" ។ ជាក់ស្តែងនៅក្នុងកិច្ចការសេដ្ឋកិច្ចគ្រួសារ ស្ត្រីបានជួយបង្កើនទ្រព្យធនគ្រួសារតាមរយៈការធ្វើស្រែចម្ការ និងការបំពេញការងារក្រៅម៉ោងផ្សេងៗ ។ ដូចបានរៀបរាប់ខាងលើស្ត្រីបានគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារក៏ដូចជាកិច្ចការជួញដូរ ។ អេប៊ីហ៊ារ៉ា បានកត់សម្គាល់ថាការទទួលខុសត្រូវទាំងនេះបានដឹកនាំស្ត្រីឲ្យមានទំនាក់ទំនងជាមួយពិភពខាងក្រៅ ។ នារីជំទង់ក៏មានសេរីភាពបែបនេះដែរ ។ អេប៊ីហ៊ារ៉ា បានសង្កេតឃើញថានារីក្មេងៗធ្វើការនៅក្នុងស្រែចម្ការខំប្រឹងស្វែងរកប្រាក់តាមរយៈការធ្វើការងារបន្ទាប់បន្សំផ្សេងៗនៅតាមភូមិជិតខាង ហើយនារីជំទង់ទាំងនេះថែមទាំងអាចកាន់កាប់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនទៀតផង ប៉ុន្តែជីវិតរបស់នារីជំទង់នៅតែមិនមមាញឹក ។ គាត់បានកត់ចំណាំថា វាមានសារសំខាន់ដែលនារីជំទង់ត្រូវមានភាពនឹងធឹង ហើយបានលើកឡើងពីគ្រួសារមួយដែលហាមប្រាមមិនឲ្យកូនស្រីដើរចេញក្រៅផ្ទះនៅពេលយប់ ។ អេប៊ីហ៊ារ៉ា បានពណ៌នាថា គ្រួសារជាកត្តាចម្បងនៃសង្គមជនបទកម្ពុជាហើយបានលើកអំពីសេចក្តីស្រលាញ់ដ៏ជ្រាលជ្រៅរវាងឪពុកម្តាយនិងកូន ។*

*ជាក់ស្តែង ជីវិតមួយភាគធំរបស់ស្ត្រីជនបទមិនស្របតាមការអនុវត្តន៍របស់ខ្មែរក្រហមទេ ហើយនៅពេលដែលគ្មានការបង្ហាញឲ្យបានត្រឹមត្រូវអំពីភាពខុសគ្នានេះ វាមិនមានអ្វីប្លែកទេដែលខ្មែរ*

ក្រហមមិនអាចទទួលបានការគាំទ្រពីស្ត្រី ។ មានចំណុចមិនស្របគ្នាជាច្រើន ។ ទីមួយ ឯករាជ្យភាព និងសេរីភាពរបស់ស្ត្រីមិនបានធ្វើឲ្យស្ត្រីក្លាយជាកម្មាភិបាលល្អឥតខ្ចោះរបស់របបខ្មែរក្រហមដែលប្រឆាំងនឹងបុគ្គលនិយម ហើយទាមទារឲ្យមានភក្តីភាពពិតប្រាកដ ។ ទីពីរ តួនាទីផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីក្នុងគ្រួសារមិនមានអ្វីចំណោញសម្រាប់គោលនយោបាយសេដ្ឋកិច្ចកុម្មុយនិស្តក្រោមរបបខ្មែរក្រហមឡើយ ។ ខ្មែរក្រហមបានលុបបំបាត់ចោលការប្រើប្រាស់លុយនិងសេដ្ឋកិច្ចទីផ្សារ ហើយបានប្រើប្រាស់បែបផែនផលិតកម្មជាសហករណ៍វិញ ។ ជាលទ្ធផល នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ស្ត្រីត្រូវដកហូតអំណាច និងឥទ្ធិពល ។ នេះជាការដកហូតដែលពិតជានឹងបង្កឲ្យមានភាពក្តៅក្រហាយ ។ ប៉ុល ពត បានបង្ហាញអំពីភាពមិនសមស្របទាំងពីរនេះនៅក្នុងសុន្ទរកថាមួយនៅឆ្នាំ១៩៧៦ ។ គាត់បានរិះគន់ស្ត្រីនៅក្នុងប្រទេសសង្គមនិយមផ្សេងទៀតដែលមាន "លក្ខណៈបុគ្គលនិយម" បន្តស្វែងរកលុយកាក់ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ។ ផ្ទុយទៅវិញ ផែនការរបស់បក្សកុម្មុយនិស្តកម្ពុជា "មិនដើរតាមផ្លូវនេះទេ ។ យើងនឹងដើរតាមវិថីសហករណ៍ ទៅកាន់សង្គមនិយម" ។

ចំណុចមិនស្របគ្នាទីបីគឺចំណងគ្រួសារដ៏ស្អិតល្មួតរវាងឪពុកម្តាយនិងកូន ពិសេសម្តាយនិងកូនដែលត្រូវបានកាត់ផ្តាច់យ៉ាងខ្លោចផ្សាដោយខ្មែរក្រហម ។ ស្ត្រីភាគច្រើននៅក្នុងស្រុកព្រែកស្តីដែលបានផ្តល់បទសម្ភាសន៍ បានរំឭកអំពីទុក្ខព្រួយរបស់ឪពុកម្តាយនៅពេលដែលពួកគាត់ចាកចេញពីភូមិជាមួយខ្មែរ-ក្រហម ។ ណាំ ដែលស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍បានពោលអំពីអារម្មណ៍របស់គាត់និងឪពុកម្តាយរបស់គាត់នៅពេលដែលគាត់ចាកចេញថា "ម៉ែឪខ្ញុំយំព្រោះយើងនៅក្មេង ហើយធ្វើអ្វីតាមតែគេ ។ មិនដឹងអីទេ មិនចេះគិតអំពីទុក្ខព្រួយរបស់ម៉ែឪទេ ។ ពេលឃើញគេលើកដៃ ក៏លើកតាមគេទៅ" ។ ដូចជាករណី ណុប លៃ ឪពុកម្តាយរបស់ ស៊ុំ ក៏បានយំដែរ នៅពេលដែលកូនស្រីរបស់គាត់ចាកចេញទៅ ។

ផ្ទុយទៅវិញ ប៉ុល ពត មិនរវល់ចំពោះទុក្ខសោកទាំងនេះទេ ។ ប៉ុល ពត បានចេញក្រឹត្យថា "ម្តាយមិនត្រូវជំពាក់ជំពិនជាមួយកូនពេកទេ" ។ សេចក្តីស្រលាញ់លើសលប់រវាងសមាជិកគ្រួសារត្រូវបានបានក្លាយជាការគំរាមកំហែង ។ កំណត់ហេតុអង្គប្រជុំបក្សកុម្មុយនិស្តកម្ពុជាមួយនៅក្នុងឆ្នាំ១៩៧៦បានរិះគន់មនោសញ្ចេតនានិយមបែបនោះនៅក្នុងបក្សផ្ទាល់ "រហូតមកដល់បច្ចុប្បន្ននេះ នៅក្នុងថ្នាក់ដឹកនាំបក្សយើងសង្កេតឃើញថា នៅតែមានទស្សនៈគ្រួសារនិយម បងប្អូននិយម និងញាតិសន្តាននិយម ។ បញ្ហានេះជាគ្រោះថ្នាក់មួយពីព្រោះវាផ្ទុយទៅនឹងលក្ខន្តិកៈបក្ស" ។ ការមិនគិតគូរចំពោះចំណងគ្រួសារបែបនោះបានបង្ហាញពីការមិនយល់របស់ខ្មែរក្រហមអំពីការពិតជាក់ស្តែងនៃជីវិតពិតរបស់កសិករ ។ ខ្មែរក្រហមពុំបានសិក្សាឲ្យបានគ្រប់គ្រាន់អំពីភាពខុសគ្នារវាងកម្មវិធីកុម្មុយនិស្តរបស់ខ្លួន និងជីវិតបែបប្រពៃណីរបស់ស្ត្រី ហើយពុំបានបង្កើតនយោបាយមួយដើម្បីដោះស្រាយបញ្ហារបស់ស្ត្រីទេ ។ លទ្ធផល គឺការគាំទ្រមិនគ្រប់គ្រាន់របស់ស្ត្រីចំពោះបដិវត្តន៍ ។

បទសម្ភាសន៍ដែលបានធ្វើឡើងនៅស្រុកព្រែកស្តីបង្ហាញថានយោបាយរបស់ខ្មែរក្រហមចំពោះស្ត្រីគឺសាមញ្ញនិងសង្ខេប ។ ខ្មែរក្រហមបានពោលថា ដោយសារស្ត្រីធ្វើការងារដូចបុរស ស្ត្រីនិងបុរសមានសិទ្ធិស្មើគ្នា ។ ម៉ម កល្យានី បានសន្និដ្ឋានដូចគ្នាក្រោយពីបានសិក្សាទៅលើស្ត្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គំនិតនេះត្រូវបានគាំទ្រតាមរយៈសម្ភាសន៍មួយចំនួន ប៉ុន្តែអ្នកខ្លះថាខ្មែរក្រហមគ្រាន់តែបានប្រកាសពីភាពស្មើសិទ្ធិគ្នាតែក្នុងករណីស្ត្រីធ្វើការធ្ងន់និងទៅធ្វើសង្គ្រាមនៅសមរភូមិតែប៉ុណ្ណោះ ។ ណយ អ៊ុត ដែលខ្មែរក្រហមកុហកថាឪពុកម្តាយគាត់ស្លាប់ ហើយបានជឿជាក់ថាខ្មែរក្រហមមានបំណងលុបបំបាត់ការរស់នៅជាគ្រួសារ ទោះជាគាត់មិនយល់ពីមូលហេតុក៏ដោយ ។ គាត់បានពោលថាខ្មែរក្រហមប្រព្រឹត្តមិនល្អចំពោះស្ត្រី ដោយបានបញ្ជូនស្ត្រីទៅសមរភូមិ ។ គាត់បានបន្ថែមថា មុនពេលចូលបដិវត្តន៍ "យើងមានសិទ្ធិ ប៉ុន្តែនៅពេលក្លាយជាកងទ័ពយើងអត់មានសិទ្ធិអ្វីទាំងអស់" ។ ស៊ុម នៅចាំថា គាត់ទទួលបានការអប់រំតិចតួចណាស់អំពីសិទ្ធិស្ត្រី ។ នៅក្នុងគុកជាអ្នកទោស គាត់បានចូលរួមប្រជុំប៉ុន្តែ "ពួសូរតែអំពីការខិតខំប្រឹងប្រែងធ្វើការងារ" ហើយគាត់ជឿជាក់ថាការប្រជុំបែបនេះគឺ"គ្រាន់តែចង់ឲ្យយើងខំប្រឹងធ្វើការងារតែប៉ុណ្ណោះ" ។

ទោះជាបានទទួលរងទុក្ខវេទនា និងការបាត់បង់គ្រួសារ

ដោយសារខ្មែរក្រហមក៏ដោយ ក៏ ណាំ សុខា បានបកស្រាយជាវិជ្ជមានអំពីការផ្តល់អំណាចឲ្យស្ត្រីដោយសារស្ត្រីបានធ្វើការនៅសមរភូមិមុខៈ«និយាយពីសិទ្ធិស្មើគ្នា បុរសអាចលីកាំភ្លើង យើងក៏អាចលីកាំភ្លើងបានដែរ ។ ដូច្នេះយើងតស៊ូទាំងអស់គ្នា» ។ គាត់បានបកស្រាយយ៉ាងច្បាស់ថា «ស្ត្រីបានសុំឲ្យមានសិទ្ធិស្មើគ្នា ។ យើងតស៊ូជាមួយបុរស ទោះជាបុរសមានកម្លាំងខ្លាំងជាងស្ត្រីក៏ដោយ ។ បុរសអាចដឹកនាំបាន ស្ត្រីក៏អាចដឹកនាំបានដែរ» ។

ខិត្តប័ណ្ណឃោសនានយោបាយមួយបោះពុម្ពនៅឆ្នាំ១៩៧៣ ដោយស្ថានទូត«រណសិរ្សរួបរួមជាតិកម្ពុជា» នៅទីក្រុងប៉េកាំង ដែលហាក់ដូចជាបញ្ជាក់អំពីគំនិតរបស់សមាសធាតុ សីហនុនិយម នៅក្នុងសម្ព័ន្ធភាពរណសិរ្សរួបរួមរវាងកងទ័ពខ្មែរក្រហម និងសម្តេច សីហនុ បានបង្ហាញអំពីរបៀបដែលខ្មែរក្រហមអាចបញ្ចុះបញ្ចូលស្ត្រីបាន ។ ខិត្តប័ណ្ណនេះបានពណ៌នាអំពីប្រភពនៃមោទកភាពមួយចំនួនសម្រាប់ស្ត្រី ដែល ណាំ សុខា បានជួបប្រទះ ។ នេះជាឯកសារដ៏កម្រមួយដែលពិភាក្សាអំពីតួនាទីបដិវត្តន៍របស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា ។ មួយផ្នែកនៃឯកសារនេះ និយាយស្របនឹងការបកស្រាយរបស់ ណាំ សុខា ទាក់ទិនទៅនឹងសិទ្ធិស្ត្រី ពីព្រោះការសរសើររបស់អត្ថបទនេះចំពោះការប្រឹងប្រែងរបស់ស្ត្រីនៅក្នុងបដិវត្តន៍បានលើកអំពីជោគជ័យផ្នែកយោធា ។ ឯកសារនេះយកគំរូតាមការឃោសនារបស់វៀតណាមដើម្បីកេណ្ឌស្រីចូលបដិវត្តន៍និងបានឆ្លុះបញ្ចាំងអំពីការតស៊ូរបស់ប្រទេសកម្ពុជាទល់នឹងសត្រូវដែលគ្មានសីលធម៌ ។ ត្រូវបានរៀបចំឡើងដើម្បីជាស់តឿនគុណធម៌របស់ស្ត្រីជនបទ ហើយបានណែនាំអ្នកអានឲ្យដឹងអំពីការគំរាមកំហែងលើស្ត្រីខ្មែរៈ «នៅក្នុងតំបន់កាន់កាប់ដោយសត្រូវ ក្រៅអំពីការគាបសង្កត់បែបហ្វាស៊ីស ស្ត្រីមានកាតព្វកិច្ចដោះស្រាយជីវភាពប្រចាំថ្ងៃនិងឆ្លងកាត់ការលំបាកដើម្បីចិញ្ចឹមជីវិត ។ លើសពីនេះមានការព្រួយបារម្ភជាច្រើនទៀត ។ ប្តីនិងកូនប្រុសៗអាចត្រូវគេចាប់ឲ្យចូលបម្រើកងទ័ពគ្រប់ពេលវេលា ។ កូនស្រីអាចត្រូវចាប់ជិះត់ ហើយរំលោភដោយទាហានមកពីទីក្រុងភ្នំពេញនិងព្រៃនគរ ។ ការរស់នៅបែបលោកខាងលិចរបស់ពួកអាមេរិកសង្គមពុករលួយ និងពេស្យាចារ បានបំពុលអារម្មណ៍របស់នារីនិងស្ត្រីអស់ជាច្រើននាក់» ។

ទោះជាយ៉ាងណាក៏ដោយក៏នៅមានក្តីសង្ឃឹមខ្លះៈ«លើសពីពេលណាៗទាំងអស់ ស្ត្រីកម្ពុជាដឹងថាមធ្យោបាយតែមួយគត់ដើម្បីរំដោះខ្លួនឲ្យរួចចាកផុតពីទាសភាព គឺចូលរួមការតស៊ូជាមួយបុរសដោយគ្មានការស្ទាក់ស្ទើរឬសម្រុះសម្រួលប្រឆាំងទល់នឹងពួកឈ្លានពានអាមេរិកនិងឆ្កែបម្រើវាដើម្បីរំដោះជាតិ» ។

ឯកសារនេះបានរៀបរាប់អំពីករណីយកិច្ចបដិវត្តន៍ជាច្រើនរបស់ស្ត្រី រួមទាំងការប្រយុទ្ធ ការងារពេទ្យ ការធ្វើអន្ទាក់ ការការពារភូមិ និងការងារកសិកម្ម ។ ឯកសារនេះបានលើកសរសើរចំពោះការខំប្រឹងប្រែងរបស់ស្ត្រីដែរ «ដូចបុរស ស្ត្រីកម្ពុជាម៉ឺរលមិញនិងថ្ងៃនេះបានរួមវិភាគទានយ៉ាងច្រើនចំពោះការតស៊ូប្រឆាំងការឈ្លានពានបរទេសដើម្បីការពារមាតុប្រទេស» ។ អ្នកសរសេរឯកសារនេះបានផ្តល់ដល់ស្ត្រីនូវការយល់ឃើញមួយថាស្ត្រីជាផ្នែកមួយនៃការតស៊ូហើយពណ៌នាស្ត្រីដោយវោហារស័ព្ទវីរភាពនិងគុណធម៌ៈ «ដើម្បីបំពាក់បំប៉នខ្លួនឯង ដោយសីលធម៌បដិវត្តន៍និងដើម្បីបង្ហាញវីរភាពបដិវត្តន៍ខ្ពស់ ស្ត្រីបានសម្រេចជ័យជម្នះដ៏មានអំនួត ។ ដូច្នេះស្ត្រីកំពុងតែចូលរួមនៅក្នុងការលុបបំបាត់ទស្សនៈអន់ថយចំពោះភេទរបស់ខ្លួនដែលនៅតែកើតមាននៅក្នុងពិភពលោក» ។ នៅចុងបញ្ចប់ឯកសារនេះបានលើកអំពីឧទាហរណ៍មួយនៃភាពវៃឆ្លាតរបស់ស្ត្រីបដិវត្តន៍ ក្នុងការបញ្ឆោតឲ្យទាហាន លន់ ណុល ចូលអន្ទាក់ ហើយរំដោះបានប្រជាជនមួយភូមិ ។ រឿងនេះប្រហែលជាមានប្រភពមកពីប្រទេសវៀតណាម ពីព្រោះវាមានសាច់រឿងស្រដៀងគ្នាទៅនឹងរឿងមួយដែលបានប្រើប្រាស់ដោយអ្នកឃោសនាកុម្មុយនិស្តវៀតណាម ដែលរៀបរាប់អំពីជោគជ័យរបស់ស្ត្រីវៀតណាមម្នាក់ឈ្មោះ អ្ហួត ទិច ជាវីរនារីបដិវត្តន៍វៀតណាម នៅក្នុងសម័យសង្គ្រាមប្រឆាំងនឹងអាណានិគមនិយមបារាំង ។

ឯកសារនេះក៏ជាផ្នែកមួយនៃការឃោសនារបស់ស្ត្រីដ៏ទំនើប (បើគិតតាមបទដ្ឋានខ្មែរក្រហម) ដោយបានបកស្រាយអំពីបញ្ហាផ្សេងៗដែលមានសារសំខាន់ចំពោះស្ត្រីតាមជនបទនិងអំពីឥទ្ធិពលរបស់សង្គ្រាមមកលើស្ត្រី ។ ឯកសារនេះបានទទួលស្គាល់ការគំរាមកំហែងដែលសង្គ្រាមបានធ្វើទៅលើគ្រួសារ និង

គុណធម៌ ដែលមានសារប្រយោជន៍យ៉ាងខ្លាំងសម្រាប់កសិករស្ត្រី រួច ហើយផ្សារភ្ជាប់ការប្រយុទ្ធប្រឆាំងនឹងការគំរាមកំហែងនេះ ជាមួយបុព្វហេតុបដិវត្តន៍ ។ គួរឲ្យកត់សម្គាល់ថា វាមិនបានរៀបរាប់អំពីកុម្មុយនិស្តនិយមទេ ហើយសម្តេច សីហនុ នៅតែត្រូវបានចាត់ទុកថាជាមេដឹកនាំរណសិរ្សដដែល ។ អត្ថបទឃោសនានេះក៏បានលើកឧទាហរណ៍អំពីកត្តាកំណត់មួយដែលមាននៅក្នុងប្រទេសចិន វៀតណាម និង កម្ពុជាៈ កំណែទម្រង់ទៅលើស្ត្រីត្រូវបានផ្សារភ្ជាប់យ៉ាងស្អិតល្មួតទៅនឹងសេវាកម្មក្នុងសម័យសង្គ្រាមរបស់ស្ត្រី ហើយមិនត្រូវបានចាត់ទុកថាមានប្រយោជន៍នៅពេលចប់សង្គ្រាមឡើយ ។ ចិត្តប័ណ្ណនេះត្រូវបានបោះពុម្ពនៅពេលចាប់ផ្តើមដំបូងនៃចលនាតស៊ូ ជាពេលដែលវត្តមានរបស់សម្តេច សីហនុ ជាមួយខ្មែរក្រហមបានទាក់ទាញប្រជាកសិករក្នុងចំនួនច្រើនឲ្យចូលរួមបម្រើបដិវត្តន៍ ។

នៅពេលដែលការឃោសនាបែបនោះអាចទាក់ទាញស្ត្រីឲ្យចូលបម្រើបដិវត្តន៍ វាមិនបានពង្រឹងស្ត្រីឲ្យចេះទ្រាំទ្រនឹងគ្រោះថ្នាក់ និងភាពមិនអនុគ្រោះរបស់សមរភូមិមុខទេ ។ ភាពរឹងមាំនេះអាចសម្រេចបានតែតាមរយៈការអប់រំមនោគមវិជ្ជាត្រឹមត្រូវប៉ុណ្ណោះ ។ ការបញ្ចូលមនោគមវិជ្ជាបែបនេះគ្មានទាល់តែសោះចំពោះស្ត្រីដែលបានផ្តល់បទសម្ភាសន៍ ។ ផ្ទុយពីបក្សកុម្មុយនិស្តចិននិងវៀតណាម ខ្មែរក្រហមមិនបានផ្តល់ឲ្យស្ត្រីនូវមូលហេតុរឹងមាំដើម្បីប្រយុទ្ធទេ ។ ផលប្រយោជន៍យូរអង្វែងសម្រាប់ស្ត្រីដូចជាសមភាពខាងនយោបាយ ការឈប់សម្រាក ពេលសម្រាលកូន ឬសិទ្ធិទទួលការអប់រំមិនបានរៀបរាប់សោះ នៅក្នុងកម្មវិធីនយោបាយរបស់ខ្មែរក្រហម ។

ដោយខ្វះខាតការឃោសនានិងការបញ្ចូលមនោគមវិជ្ជាឲ្យបានជ្រាលជ្រៅដូចនៅប្រទេសចិននិងវៀតណាម ការប្រើប្រាស់ស្ត្រីនៅក្នុងសង្គ្រាមរបស់ខ្មែរក្រហមជាការកេងប្រវ័ញ្ចទាំងស្រុង ។ បដិវត្តន៍ខ្មែរក្រហមប្រើប្រាស់ទ្រឹស្តីដើមរបស់ អែងដែល ទាំងស្រុង ដោយបង្ខំឲ្យស្ត្រីទទួលស្គាល់ថា ខ្លួនត្រូវបាន«រំដោះ»រួចហើយ នៅពេលដែលស្ត្រីត្រូវបានរុញបញ្ចូលទៅក្នុងកងទ័ពឬចលនាផលិតកម្ម ។ វាជាសញ្ញាបញ្ជាក់ទុកមុនអំពីការរំលោភបំពានរបស់ខ្មែរក្រហមទៅលើកម្លាំងពលកម្មរបស់ស្ត្រី នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដូចបានរៀបរាប់ដោយ ម៉ម កល្យាណី "របបកម្ពុជាប្រជាធិបតេយ្យបានប្រើប្រាស់គោលនយោបាយ ភេទដើម្បីបង្ហាញឲ្យឃើញអំពីការផ្តល់សិទ្ធិស្មើគ្នា សម្រាប់ស្ត្រីដើម្បីកេណ្ឌទ័ពស្ត្រី" ។ ក្រោយពីបានសម្ភាសន៍ស្ត្រីខ្មែរ ម៉ម កល្យាណីបានអះអាងថា ការចិញ្ចឹមបីបាច់កុមារ និងការងារផ្សេងទៀតនៅក្នុងសហករណ៍ពុំបានរំដោះស្ត្រីឬធ្វើឲ្យស្ត្រីមានសិទ្ធិស្មើគ្នាជាមួយបុរសទេ ប៉ុន្តែវាបានអនុញ្ញាតឲ្យរបបកម្ពុជាប្រជាធិបតេយ្យកាន់តែងាយស្រួលក្នុងការកេងប្រវ័ញ្ច កម្លាំងពលកម្មស្ត្រី ។ ស្ត្រីបានតវ៉ាចំពោះការបាត់បង់តួនាទីបែបប្រពៃណីរបស់ខ្លួនដែលជាការពេញចិត្តនិងអំនួត ហើយត្រូវបានជំនួសវិញដោយការតស៊ូដើម្បីបដិវត្តន៍មួយដែលស្ត្រីមិនមានជំនឿទៅលើ ។

ការមិនយកចិត្តទុកដាក់ទៅលើស្ត្រីរបស់បក្សកុម្មុយនិស្តកម្ពុជាបានរារាំងមិនឲ្យស្ត្រីក្លាយទៅលើជាជនបដិវត្តន៍ពិតប្រាកដដោយចំនួនច្រើន ។ ការដោះស្រាយបញ្ហាស្ត្រីមិនបានល្អត្រូវបានបង្ហាញឲ្យឃើញតាមរយៈការយល់ដឹងតិចតួច ដែលយើងមានអំពី "សមាគមស្ត្រីកម្ពុជាប្រជាធិបតេយ្យ" និងប្រធានសមាគម ខៀវ ប៉ុណ្ណារី ដែលជាភរិយារបស់ ប៉ុល ពត ។ នៅក្នុងសៀវភៅ "របប ប៉ុល ពត" លោក បេ៊ន ឃៀរនិន បានសរសេរថា គណៈប្រតិភូមកពីសហជីពស្ត្រីវៀតណាមមួយក្រុមបានធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា នៅឆ្នាំ១៩៧៧ ។ នេះជាការអញ្ជើញរបស់សមាគមស្ត្រីកម្ពុជាដែលបានទៅប្រទេសវៀតណាមនៅឆ្នាំ១៩៧៦ ។ "សមាគមស្ត្រីកម្ពុជាប្រជាធិបតេយ្យ" ត្រូវបានតំណាងឲ្យដោយ អៀង ធីរិទ្ធ ជាប្អូនស្រីរបស់ ខៀវ ប៉ុណ្ណារី និងជាភរិយារបស់រដ្ឋមន្ត្រីការបរទេសកម្ពុជាប្រជាធិបតេយ្យ អៀង សារី ។ គួរឲ្យឆ្ងល់ខ្លាំងណាស់ ខៀវ ប៉ុណ្ណារី មិនដែលលេចមុខជាសាធារណៈ ហើយថែមទាំងមិនដែលត្រូវបានប្រកាសថាជាប្រធានសមាគមស្ត្រីទៀតផង ។ ក្នុងពេលជាមួយគ្នានោះ អៀង ធីរិទ្ធ បានរៀបរាប់តិចតួចបំផុតអំពីសមាគមនេះ ។ មេដឹកនាំរបស់គណៈប្រតិភូវៀតណាមឆ្ងល់ថា "ខ្ញុំមានអារម្មណ៍ថា នៅកម្ពុជាដូចជាគ្មានសមាគមស្ត្រីពិតប្រាកដទេ ហើយបើមានមែននោះ ខ្មែរក្រហមកំពុងតែលុបបំបាត់សមាគមនេះចោលហើយ" ។ ឃៀរនិន បានបន្តថា ខៀវ ប៉ុណ្ណារី បានក្លាយទៅជាវិកលចរិតនៅឆ្នាំ១៩៧៥ ។ ប៉ែកឃ័រ បានសរសេរ

ថា ខៀវ ប៉ុណ្ណារី បានចាប់ផ្តើមធ្លាក់ខ្លួនឈឺនៅពេលដែលគាត់បានរស់នៅជាមួយ ប៉ុល ពត មុននិងក្នុងសម័យបដិវត្តន៍ ។ "ចំណែក ឯ អៀង ធីរិទ្ធ" ប៉ែកយ័រ សរសេរថា "នឹងក្លាយទៅជាស្ត្រីទីមួយរបស់បដិវត្តន៍" ។

នេះជាអកុសលនៃការវិវឌ្ឍន៍ទៅមុខសម្រាប់ស្ត្រីកម្ពុជា ពីព្រោះ អៀង ធីរិទ្ធ ក៏ដូចស្ត្រីផ្សេងទៀតដែលមានឋានន្តរស័ក្តិខ្ពស់នៅក្នុងបក្ស គឺខ្វះការយល់ដឹងអំពីជីវិតជាក់ស្តែងរបស់កសិករពិសេសគឺកសិករស្ត្រី ។ នៅក្នុងបទសម្ភាសន៍មួយជាមួយ ប៉ែកយ័រ នៅក្នុងឆ្នាំ១៩៨០ អៀង ធីរិទ្ធ បាននិយាយការពារគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ដែលបញ្ជាក់ពីការយល់ច្រឡំទាំងស្រុងរបស់គាត់អំពីអ្វីដែលមានសារសំខាន់ចំពោះស្ត្រីកសិករកម្ពុជា ។ ធីរិទ្ធ និយាយថា "ពីមុនស្ត្រីត្រូវតែធ្វើការត្រឡប់មកផ្ទះ ហើយដើររកត្រី អង្ករ រួចយកមកចម្អិន ហើយថែទាំកូនចៅថែមទៀត ។ នេះគឺបន្ទុកធ្ងន់ធ្ងរណាស់សម្រាប់ស្ត្រី ។ នៅក្នុងសហករណ៍ស្ត្រីត្រឡប់មកពីធ្វើការវិញអាចហូបបាយបាន" ។ ប៉ែកយ័រ បានចង្អុលបង្ហាញថា អ្វីដែល "ធ្ងន់ធ្ងរ"សម្រាប់ អៀង ធីរិទ្ធ គឺជាការសប្បាយរីករាយនឹងជីវិតប្រចាំថ្ងៃសម្រាប់ស្ត្រីទៅវិញទេ នោះគឺការចិញ្ចឹមបីបាច់កូនចៅនិងការបំពេញការងារផ្ទះ ។

មានចំណុចតិចតួចប៉ុណ្ណោះដែលបានដឹងឮអំពីសមាគមស្ត្រី ។ ស្ត្រីនៅក្នុងឃុំព្រែកស្តីបានសរសេរប្រវត្តិផ្ទាល់ខ្លួនដោយបង្ខំ នៅក្នុងគុកដែលភាគច្រើនបានរៀបរាប់ថាខ្លួនជាសមាជិករបស់ "កងនារី" ប៉ុន្តែគ្មានស្ត្រីណាម្នាក់ក្នុងចំណោមនេះយល់ច្បាស់អំពីអត្ថន័យពិតប្រាកដនៃឃ្លានេះទេ ហើយពុំបានចាំថាខ្លួនជាសមាជិករបស់សមាគមស្ត្រីណាមួយឡើយ ។ ម៉ៃ ឃើលខានី បានកត់សម្គាល់ថា នៅក្នុងសម័យសង្គ្រាមរណសិរ្សរំដោះជាតិកម្ពុជាបានបង្កើតអង្គការផ្សេងៗដើម្បីកេណ្ឌប្រជាកសិករ រួមទាំង "យុវជនជាតិនិយមកម្ពុជា"និង"ស្ត្រីជាតិនិយមកម្ពុជា" ។ តួនាទីមួយផ្នែករបស់អង្គភាពទាំងពីរនេះគឺបញ្ជូននារីទៅបម្រើបក្សនិងបដិវត្តន៍ ។ ប៉ុន្តែគ្មានភស្តុតាងណាមួយបញ្ជាក់អំពីគោលនយោបាយច្បាស់លាស់ចំពោះស្ត្រីរបស់អង្គភាពទាំងពីរនេះទេ ។ សម្រាប់ខ្មែរក្រហមការគ្រប់គ្រងស្ត្រីឲ្យមានប្រសិទ្ធភាព គឺមិនមែនជាអាទិភាពនោះទេ ។ ដូចកំហុសជាច្រើនផ្សេងទៀតខ្មែរក្រហមបានអើពើចំពោះជីវិតពិតរបស់មហាជនកម្ពុជា ។

ទស្សនៈរបស់ខ្មែរក្រហមចំពោះស្ត្រីមានចំណុចខ្វះខាតបួនយ៉ាង ។ ទីមួយ ខ្មែរក្រហមបានពឹងពាក់យ៉ាងខ្លាំងទៅលើការប្រើប្រាស់ការបង្ខិតបង្ខំដើម្បីទទួលបានការចូលបម្រើបដិវត្តន៍ ។ ជាលទ្ធផល ស្ត្រីភាគច្រើនបានចូលបម្រើបដិវត្តន៍ទាំងភិតភ័យហើយមិនមែនដោយសារការប្តូរផ្តាច់ពីក្នុងចិត្តនោះទេ ។ ទីពីរ ខ្មែរក្រហមបានបង្កឲ្យមានការបែកបាក់គ្រួសារ ប៉ុនប៉ងផ្តាច់ចំណងគ្រួសារដែលប្រជាជនស្រលាញ់ពេញចិត្ត ហើយព្យាយាមដណ្តើមយកអំណាចទៅលើកូនពីគ្រួសារ ។ ចំណុចនេះបង្កឲ្យមានការមិនពេញចិត្តពីស្ត្រីក្មេង ដែលចាត់ទុកការហាមប្រាមមិនឲ្យមកជួបឪពុកម្តាយជាភាពឃោរឃៅពុំអាចទ្រាំទ្របាន ។ ទីបី ខ្មែរក្រហមបានផ្តល់ដល់ស្ត្រីនូវការអប់រំមនោគមវិជ្ជា និងការហ្វឹកហ្វឺនមិនត្រឹមត្រូវ ។ ជួនកាលខ្មែរក្រហមមិនបានបង្រៀនអ្វីទាំងអស់ ។ ជាលទ្ធផលស្ត្រីពុំបានរៀបចំខ្លួនដើម្បីទ្រាំទ្រ ទុក្ខវេទនានៅក្នុងបដិវត្តន៍ហើយមិនមានមូលហេតុច្បាស់លាស់ណាមួយដើម្បីប្រយុទ្ធនោះទេ ។ ទីបួន ខ្មែរក្រហមត្រូវបរាជ័យទាំងស្រុងក្នុងការបង្កើតគោលនយោបាយស្ត្រីដ៏មានប្រសិទ្ធភាពមួយដែលអាចទាក់ទាញស្ត្រីហើយរៀបរាប់អំពីអ្វីដែលមានប្រយោជន៍ចំពោះស្ត្រីដែលត្រូវទាមទារឲ្យបាន ។ ខ្មែរក្រហមក៏បរាជ័យក្នុងការរៀបចំស្ត្រីឲ្យមានប្រសិទ្ធភាពដែរ ។ ផ្ទុយទៅវិញខ្មែរក្រហមបានពឹងផ្អែកទៅលើទ្រឹស្តីមិនជឿនលឿនរបស់ អង់ដែល ក្នុងការបង្កើតគោលនយោបាយស្ត្រីរបស់ខ្លួនបង្ខំ ស្ត្រីឲ្យចូលបម្រើកងទ័ព ឬចូលរួមសកម្មភាពផលិតកម្ម ហើយបានប្រកាសថាតាមរយៈការងារលើសលុបទាំងនេះ ស្ត្រីនឹងត្រូវរំដោះ ហើយមានសិទ្ធិស្មើគ្នានឹងបុរស ។ ចំណុចខ្វះខាតទាំងបួននេះបញ្ជាក់ថា ការគាំទ្រដែលខ្មែរក្រហមទទួលបានពីស្ត្រីគឺមិនគ្រប់គ្រាន់ ឬខ្សោយ ឬក៏គ្មានតែម្តង ។

### សេចក្តីសន្និដ្ឋាន

### "កម្មាភិបាលមួយចំនួនប្រហែលធ្វើខុសខ្លះ" ។
### អៀង សារី ថ្លែងនៅក្នុងឆ្នាំ១៩៧៩

កង្វះការគាំទ្រពីស្ត្រីចំពោះខ្មែរក្រហមគឺជាផ្នែកមួយនៃបរាជ័យជាទូទៅរបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងនាមជារដ្ឋ

មួយ និងក្នុងនាមជាចលនាមួយ ។ គោលនយោបាយទៅលើវិស័យកសិកម្មដ៏មានមហិច្ចតា ការសង្ស័យ និងការមិនទុកចិត្តគ្នាហួសហេតុរួមទាំងភាពឃោរឃៅជាទូទៅបានកំណត់រូបរាងឲ្យរបបខ្មែរក្រហម ។ ឯការរៀបចំគម្រោងត្រឹមត្រូវដែលជាការប្រឹងប្រែងដើម្បីបង្កើតទំនាក់ទំនងជាវិជ្ជមានជាមួយប្រជាកសិករនិងការដឹកនាំដែលអាចបត់បែនបាន សុទ្ធតែពុំបានកើតមាន ។ សំឡេងរបស់អង្គការជាសំឡេងតែមួយគត់ដែលត្រូវបានអនុញ្ញាតនៅក្នុងសម័យខ្មែរក្រហម ប៉ុន្តែអ្វីដែលអង្គការនិយាយមិនបានបញ្ជាក់អំពីឆន្ទៈរបស់ប្រជាកសិករទូទៅទេ ។

ខ្មែរក្រហមបរាជ័យក្នុងការបញ្ចុះបញ្ចូលស្ត្រីឲ្យចូលរួមបម្រើបដិវត្តន៍ដើម្បីបុព្វហេតុបដិវត្តន៍ ។ ខ្មែរក្រហមបានប្រើប្រាស់សេចក្តីសាទរពីដំបូងរបស់ស្ត្រី ដែលចូលបម្រើបដិវត្តន៍ដោយស្ម័គ្រចិត្ត ហើយបានរិះគន់អ្នកដែលមិនចូលបដិវត្តន៍ រួបបង្ខំអ្នកទាំងនេះឲ្យចាកចេញពីផ្ទះ ។ នេះជាទុក្ខវេទនាមិនអាចទ្រាំបានសម្រាប់ស្ត្រីភាគច្រើនដែលស្រលាញ់គ្រួសារជាងអ្វីៗទាំងអស់ ។ ស្ត្រីទាំងនេះបានបង្ហាញពីភក្តីភាពចំពោះគ្រួសារតាមរយៈការលួចរត់ត្រឡប់មកផ្ទះជាញឹកញាយដើម្បីជួបឪពុកម្តាយ ហើយមិនខ្វាយខ្វល់ចំពោះការទាមទារឲ្យមានភាពស្មោះត្រង់មិនរួញរាចំពោះបដិវត្តន៍របស់ខ្មែរក្រហមឡើយ ។

ខ្មែរក្រហមបានរិះគន់ភាពរឹងរូស "គ្រួសារនិយម"នេះ ប៉ុន្តែមិនបានផ្តល់ជម្រើសជាដំណោះស្រាយផ្សេងទេ ។ សម្រាប់ប្រជាកសិករ អង្គការជាអង្គភាពឬអំណាចមិនស្គាល់មុខមួយដែលឃោរឃៅហើយតែងតែនាំមកនូវទុក្ខវេទនានិងការផ្លាស់ប្តូរដែលមិនពេញចិត្ត ។ ខ្មែរក្រហមពុំមានលទ្ធភាពបង្ហាញអំពីឧត្តមគតិនយោបាយរបស់ខ្លួនដល់ស្ត្រីឡើយ ។ ជាទូទៅ ខ្មែរក្រហមមិនទាំងសាកល្បងបង្ហាញផង ពីព្រោះកម្មាភិបាលខ្វះបទពិសោធន៍បានជ្រើសយកអំពើឃោរឃៅ ជាជាងការឃោសនានយោបាយដើម្បីទទួលយកការគាំទ្រពីមហាជន ។ ដូច្នេះ ការបញ្ចូលមនោគមវិជ្ជាគឺនៅខ្សោយ ហើយជួនកាលគ្មានទាល់តែសោះ ។ ត្រង់ចំណុចនេះ ខ្មែរក្រហមបានអើពើចំពោះការដាស់តឿនរបស់ហ្វាណុង ដែលថា កសិករត្រូវតែទទួល "ការបំភ្លឺ ការអប់រំនិងការបញ្ចូលមនោគមវិជ្ជា" ។ ចំពោះនយោបាយ ហ្វាណុង បន្តថា មិនត្រូវប្រើជា"មធ្យោបាយធ្វើឲ្យងឿងឆ្ងល់នោះទេ ប៉ុន្តែជាមធ្យោបាយតែមួយគត់សម្រាប់ពង្រឹងការតស៊ូ និងត្រៀមឲ្យប្រជាជនទទួលរ៉ាប់រងការងារគ្រប់គ្រងប្រទេសឲ្យច្បាស់លាស់និងភ្លឺថ្លា" ។ ការអើពើរបស់ខ្មែរក្រហមចំពោះសាធារណជនជាការធ្វើឲ្យបរាជ័យដល់ខ្លួនឯង ហើយបញ្ជាក់អំពីការមិនធ្វើតាមទ្រឹស្តីដែលចែងអំពីសារសំខាន់នៃការអប់រំនយោបាយពិសេសចំពោះយុវជនដែលរៀបរាប់នៅក្នុងទស្សនាវដ្តីយុវជនរបស់បក្សៈ "ជាតិមួយដែលយុវជនមានសតិអារម្មណ៍បដិវត្តន៍និងគោលនយោបាយរឹងមាំ...នឹងឈ្នះទៅលើការឈ្លានពានរបស់ខ្មាំង" ។ ប៉ុន្តែ នៅក្នុងសង្គមជាក់ស្តែង"សតិអារម្មណ៍បដិវត្តន៍"មានភាពទន់ខ្សោយលាយឡំជាមួយនឹងទស្សនៈអភិរក្សនិយមរបស់កសិករ ។ ទុក្ខវេទនាដែលប្រជាកសិករទទួលរងនៅក្នុងសម័យខ្មែរក្រហម គ្រាន់តែបានពង្រឹងតម្លៃប្រពៃណីពិសេសគ្រួសារបែបប្រពៃណីប៉ុណ្ណោះ ។

ស្ត្រីច្បាស់ជាខ្វះខាត"សតិអារម្មណ៍បដិវត្តន៍" ពីព្រោះខ្មែរក្រហមមិនបានផ្តល់អ្វីទាំងអស់ទៅឲ្យស្ត្រី ក្នុងការបណ្តុះគំនិតឲ្យស្រលាញ់បដិវត្តន៍ ។ លើសពីនេះ ខ្មែរក្រហមនៅតែព្យាយាមគាំទ្រសិទ្ធិស្ត្រីទៀត ។ មាត្រាទី១៣នៃច្បាប់រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យបានចែងយ៉ាងច្បាស់ថា "បុរសនិងនារីស្មើភាពគ្នាពេញទីលើគ្រប់វិស័យទាំងអស់" ។ ប៉ុន្តែគ្មានការពន្យល់បន្ថែមទៅលើមាត្រានេះ ដែលបង្ហាញឲ្យឃើញពីការមិនចាប់អារម្មណ៍ទៅលើភាពពិស្តារនិងមិនចាប់អារម្មណ៍ចំពោះបញ្ហាស្ត្រីទូទៅ ។ នៅក្នុងសម្ភាសន៍ស្ត្រីបានបកស្រាយថា គាត់បានហាត់រៀនត្រឹមតែចាំឃ្លាថា "បុរសនិងនារីមានសិទ្ធិស្មើគ្នា" ។ ប៉ុន្តែឃ្លានេះមានន័យថា ស្ត្រីត្រូវធ្វើការធ្ងន់ដូចបុរស លីសែងគ្រាប់រំសេវនៅក្នុងសមរភូមិមុខដ៏គ្រោះថ្នាក់ដែលស្ត្រីមិនបានត្រៀមខ្លួនទុកជាមុន ។ ស្ត្រីខ្លះពេញចិត្តនឹងធ្វើការងារលំបាកដូចបុរសនៅក្នុងសមរភូមិ ។ ប៉ុន្តែ ខ្មែរក្រហមមិនបានពង្រឹងការយល់ឃើញល្អបែបនេះតាមរយៈការអប់រំនយោបាយនោះទេ ។ ទីបំផុត ការខ្លាចស្លាប់និងភាពឯកោនៅសមរភូមិដែលបង្កឡើងដោយការបំបែកបំបាក់គ្រួសារបានគ្របដណ្តប់ទៅលើការប្តូរផ្តាច់សម្រេចគោលដៅរបស់បដិវត្តន៍ដែលអាចកើតមាន ។

ស្ត្រីនៅក្នុងសម័យបដិវត្តន៍ចិន វៀតណាម និងកូរ៉េខាងជើង បានធ្វើការនៅក្នុងក្របខ័ណ្ឌមនោគមវិជ្ជាច្បាស់លាស់ ដែលផ្តល់ប្រយោជន៍ជាក់ស្តែងដល់ស្ត្រីជាថ្នូរសម្រាប់ការចូលរួមបម្រើបដិវត្តន៍ ។ សិទ្ធិបោះឆ្នោតរបស់ស្ត្រី សិទ្ធិលែងលះ និងកាន់កាប់ដីធ្លី បានក្លាយទៅជាចំណាប់អារម្មណ៍របស់មេដឹកនាំបក្សកុម្មុយ-និស្ត ។ ការទទួលខុសត្រូវរបស់ស្ត្រីបានកើនឡើងនៅក្នុងសម័យសង្គ្រាម ហើយស្ត្រីដើរតួនាទីថ្មីបានល្អ ដោយបានធ្វើវិភាគទានមានតម្លៃចំពោះចលនាតស៊ូនៅពេលដែលបុរសកំពុងប្រយុទ្ធនៅក្នុងសមរភូមិមុខ ។ នៅក្នុងពេលជាមួយគ្នាមេដឹកនាំកុម្មុយនិស្តរបស់ប្រទេសទាំងនេះបានស្ទាក់ស្ទើរមិនហ៊ានប្រឆាំងនឹងប្រពៃណីកសិករទាំងស្រុង រួមទាំងគ្រួសារផង: បិតាធិបតេយ្យគឺជាកម្លាំងដ៏រឹងមាំនៅក្នុងប្រទេសទាំងបី (ចិន កូរ៉េខាងជើង និងវៀតណាម) ។ មានការសាកល្បងមួយចំនួន ពិសេសនៅប្រទេសចិន និងកូរ៉េខាងជើងដើម្បីបញ្ចូលការងារនៅក្នុងផ្ទះមួយចំនួនជាការងារសហករណ៍ ប៉ុន្តែគ្រួសារដែលមានឪពុកម្តាយនិងកូន ជាសមាជិកនៅតែមានសារប្រយោជន៍ចំពោះរបបកុម្មុយនិស្តនៅអាស៊ីទាំងបី ។ ការរំដោះស្ត្រីត្រូវបានកត់សម្គាល់ថា ជាគោលដៅមួយ ប៉ុន្តែការសម្រេចគោលដៅនេះត្រូវធ្វើតាមរយៈសកម្មភាពបដិវត្តន៍ ។ គំនិតនេះបានកើតឡើងចេញពីការជឿជាក់របស់ ហ្វ្រេដរិក អែងដែល ដែលថាស្ត្រីអាចរំដោះបាននៅពេលដែលស្ត្រីចូលរួម


សិល្បការិនីខ្មែរក្រហម

ពេញលេញនៅក្នុងផលិតកម្មឧស្សាហកម្ម ។ ផ្ទុយទៅវិញ អ៊ែងដែល យល់ថា គ្រួសារដែលមានឪពុកម្តាយនិងកូនជាសមាជិក ជាការធ្វើឲ្យស្ត្រីក្លាយជាទាសករ ហើយបានប្រកាសឲ្យមានការលុបបំបាត់ចោលគ្រួសារប្រភេទនេះ ។ ចំពោះ អ៊ែងដែល ការងារក្នុងផ្ទះដូចជាការចិញ្ចឹមបីបាច់កូនចៅត្រូវក្លាយជាការងាររួមនៅក្នុងសហករណ៍ ។

នយោបាយរបស់ខ្មែរក្រហមមានលក្ខណៈស្រដៀងគ្នានឹងគំនិតប្លែករបស់ អ៊ែងដែល ។ ខ្មែរក្រហមបានព្យាយាមប្រែក្លាយប្រទេសកម្ពុជាទាំងមូលឲ្យទៅជាសហករណ៍ដោយលុបបំបាត់ចោលគ្រួសារទាំងស្រុង ។ គំនិតរបស់ អ៊ែងដែល ក៏ស្របគ្នាជាមួយនឹងតម្រូវការជាចាំបាច់ទៅលើកម្លាំងពលកម្មនិងកងទ័ព ។ បទពិសោធន៍របស់ស្ត្រីដែលបានផ្តល់បទសម្ភាសន៍សម្រាប់និក្ខេបបទនេះ ផ្តល់ជាឧទាហរណ៍ដំបូងមួយអំពីនយោបាយនេះ នៅពេលដែលស្ត្រីត្រូវបានដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរសម្រាប់ការទាក់ទងរបស់ស្ត្រីជាមួយគ្រួសារនិង«ភាពមិនស្មោះត្រង់» ចំពោះអង្គការនៅពេលដែលស្ត្រីបានរត់គេចចេញពីសមរភូមិ ។ ខ្មែរក្រហមចង់អនុវត្តកម្មវិធីកុម្មុយនិស្តដ៏បរិសុទ្ធមួយដែលមិនធ្លាប់មាន ។ តាមការពិតជនកុម្មុយនិស្តកម្ពុជាពេញចិត្តនឹងអួតសរសើរអំពីភាពមានតែមួយគត់នៃបដិវត្តន៍របស់ខ្លួន ។ ទ្រឹស្តីទៅលើគ្រួសាររបស់ អ៊ែងដែល បានផ្តល់ជាសេចក្តីព្រាងសម្រាប់កំណែទម្រង់ដ៏គំហុកដែលខ្មែរក្រហមសង្ឃឹមថានឹងក្លាយទៅជាគំរូសម្រាប់បដិវត្តន៍ផ្សេងទៀតនៅក្នុងពិភពលោក ។ ជ័យជម្នះនៅក្នុងប្រទេសចិន កូរ៉េខាងជើងនិងវៀតណាម អាចក្លាយជាឧទាហរណ៍ដ៏សំខាន់មួយសម្រាប់ខ្មែរក្រហម ។ ផ្ទុយទៅវិញ ខ្មែរក្រហម បែរជាមើលឃើញថាប្រទេសទាំងបីនេះត្រូវបរាជ័យក្នុងការអនុវត្តន៍ការផ្លាស់ប្តូរសង្គមដ៏គំហុកពិតប្រាកដដែល អ៊ែងដែល បានរៀបរាប់ទៅវិញ ។ ដូច្នេះខ្មែរក្រហមយល់ថាខ្លួនត្រូវធ្វើឲ្យសម្រេច ។



ការប៉ុនប៉ង «ធ្វើឲ្យប្លែកពីគេ» របស់ខ្មែរក្រហមនាំទៅការបរាជ័យគួរឲ្យសង្វេគ ។ មេដឹកនាំខ្មែរក្រហមមិនបានរៀបចំខ្លួនដើម្បីដឹកនាំប្រទេសឲ្យមានប្រសិទ្ធភាពឡើយ ហើយគោលនយោបាយចំពោះស្ត្រីដ៏ពិស្តារដែលមានសារសំខាន់ក៏មិនបានបង្កើតដែរ ។ កំណែទម្រង់សេដ្ឋកិច្ច កសិកម្ម និងសង្គម ដ៏ស្មុគស្មាញត្រូវបានគ្រោងអនុវត្តតាមរយៈ «សន្ទុះបដិវត្តន៍» មិនមែនតាមរយៈការគ្រោងទុកដោយប្រុងប្រយ័ត្នដែលឆ្លើយតបទៅនឹងកាលៈទេសៈជាក់ស្តែងនោះទេ ។ ដូចផលិតកម្មកសិកម្មដែលនឹងត្រូវបង្កើនតាមរយៈការធ្វើការងារធ្ងន់ធ្ងរ ស្ត្រីនឹងត្រូវរំដោះតាមរយៈការធ្វើការងារពលកម្មដ៏យ៉ាប់យ៉ឺន ។ ជាលទ្ធផល ឆេនដល័រ បានសរសេរថា «កម្ពុជានឹងក្លាយទៅជាគុកឥតជញ្ជាំង» ប៉ុន្តែស្ថានភាពនេះជាការបង្ហាញអំពីសមភាពភេទនៅកម្ពុជា ។ ភាពឃោរឃៅរបស់របប ប៉ុល ពត មិនប្រកាន់ភេទទេ ហើយប្រជាជនកម្ពុជាគ្រប់រូបបានរងទុក្ខវេទនាដោយសារអំពើហិង្សានិងការបរាជ័យខាងនយោបាយដ៏ធ្ងន់ធ្ងររបស់របបនេះ ។ **ហ្សាល់ ភាភារីយ៉ា**

# អំពើឃោរឃៅរបស់ខ្មែរក្រហមក្រោមច្បាប់កម្ពុជា

ការសិក្សារបស់យើងពេលនេះគឺផ្តោតសំខាន់ទៅលើ ស្ថានភាពនៃអំពើឃោរឃៅរបស់ខ្មែរក្រហមក្រោមច្បាប់កម្ពុជា ។ ទោះជាសកម្មភាពរបស់ខ្មែរក្រហមបានរំលោភទៅលើបទដ្ឋានច្បាប់អន្តរជាតិក៏ដោយ ក៏សកម្មភាពទាំងនេះឆ្លុះបញ្ចាំងអំពីការប្រមាថមកលើប្រព័ន្ធច្បាប់កម្ពុជានាពេលនោះដែរ ។ សហគមន៍អន្តរជាតិមានចំណាប់អារម្មណ៍គ្រប់គ្រាន់ទៅលើអ្វីដែលខ្មែរក្រហមបានប្រព្រឹត្តក្នុងគោលបំណងបដិសេធចោលនូវអំពើមួយចំនួនតាមរយៈច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ មុខសញ្ញាផ្ទាល់នៃសកម្មភាពរបស់ខ្មែរក្រហមគឺ ប្រជាជន សង្គម និងរដ្ឋកម្ពុជា ។ ក្នុងនាមជារដ្ឋដែលមានអំពើឃោរឃៅកើតឡើង ប្រទេសកម្ពុជាពិតជាមានយុត្តាធិការក្នុងការដាក់បញ្ញត្តិច្បាប់ព្រហ្មទណ្ឌដែលអាចក្រសោបនូវបទល្មើសទាំងនេះ ក៏ដូចជាយុត្តាធិការក្នុងការអនុវត្តន៍ច្បាប់នោះតាមរយៈការជំនុំជម្រះក្តីព្រហ្មទណ្ឌ ។ សំខាន់ដូចគ្នានេះដែរ បទឧក្រិដ្ឋក្រោមច្បាប់កម្ពុជាខ្វះខាតនូវធាតុផ្សំពិសេសៗនៃបទឧក្រិដ្ឋអន្តរជាតិ ហើយមានលក្ខណៈងាយស្រួលក្នុងការបង្ហាញភស្តុតាង ។

### ១) ការពិចារណាតាមវិទ្យាសាស្ត្រ

ការពិនិត្យរួមទៅលើច្បាប់កម្ពុជា តម្រូវឲ្យមានការអនុវត្តន៍ខុសគ្នាបន្តិចជាមួយនឹងការពិនិត្យរួមទៅលើច្បាប់កម្ពុជាក្នុងការកំណត់របស់ច្បាប់អន្តរជាតិចំពោះឧក្រិដ្ឋភាពនៃអំពើឃោរឃៅរបស់ខ្មែរក្រហម ។ ទីមួយៈ ភាពស្រដៀងគ្នាជាមូលដ្ឋានមួយចំនួននៅក្នុងបរិបទច្បាប់នេះ នឹងលេចឡើងដោយសារច្បាប់ព្រហ្មទណ្ឌអន្តរជាតិទាញចេញពីធាតុសំខាន់ជាច្រើនពីប្រព័ន្ធច្បាប់ពិភពលោក ។ ប្រព័ន្ធច្បាប់កម្ពុជាវិវឌ្ឍចេញពីប្រព័ន្ធច្បាប់មួយនៃប្រព័ន្ធច្បាប់ពិភពលោកនេះ ពោលគឺប្រព័ន្ធច្បាប់ស៊ីវិលបារាំង ។ ភាពមិនប្រាកដប្រជាមួយចំនួនក្នុងការកំណត់បរិបទនៃច្បាប់ទម្លាប់អន្តរជាតិ អាចមានបញ្ហាកាន់តែតិចនៅក្នុងករណីច្បាប់ក្នុងស្រុករបស់កម្ពុជាដែលក្រមព្រហ្មទណ្ឌកំណត់បទល្មើសច្បាស់លាស់ជាង ។

មានឧបសគ្គពីរដែលធ្វើឲ្យកិច្ចការនេះមិនធម្មតា ។ ទីមួយ ប្រភពនៃច្បាប់កម្ពុជាទាំងប្រភពបឋម និងប្រភពទីពីរៈ ពិតជាកម្រមានណាស់ ។ កម្ពុជាបានអភិវឌ្ឍនៅក្នុងអំឡុងឆ្នាំដែលមិនមានសន្តិភាពដាច់ស្រឡះនូវអង្គច្បាប់និងក្រឹត្យច្បាប់ផ្សេងទៀតក្នុងលក្ខណៈជាប្រទេសក្រីក្រ ។ ក្នុងករណីនេះ ទោះជាមានការសិក្សាស្រាវជ្រាវទូលំទូលាយប៉ុណ្ណាក៏ដោយ ក៏យើងមិនអាចរកឃើញនូវករណីយុត្តិសាស្ត្រណាមួយដែលបរិយាយល្អិតល្អន់អំពីក្រមច្បាប់ដែលមានសព្វថ្ងៃនេះដែរ ។ តាមពិតទៅវិធាននៃច្បាប់មិនទាន់បានចាក់ឫសរឹងមាំគ្រប់គ្រាន់នៅក្នុងប្រទេសកម្ពុជាឡើយ សម្រាប់អភិវឌ្ឍនូវទ្រឹស្តីច្បាប់ទំនើបៗ ។ ក្រមទាំងនោះមិនមានការបោះផ្សាយនៅក្នុងទម្រង់ដែលបង្ហាញអំពីវិសោធនកម្ម និងការកែប្រែផ្សេងទៀតឡើយ ចាប់តាំងពីបោះផ្សាយជាលើកដំបូងមក ។

ឧបករណ៍បឋមសម្រាប់ច្បាប់មុនសម័យខ្មែរក្រហមគឺក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (Code Pénal et Lois Pénales) ដែលបោះផ្សាយជាលេខពិសេស(Recueil Judiciaire) ដោយក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ។ យើងមិនទាន់ឃើញប្រភពណាដែលអាចយកជាការបាននិងមានលក្ខណៈទូលំទូលាយដែលធ្វើឲ្យមានភាពទំនើបដល់ច្បាប់នេះឡើយ ពេញអំឡុងឆ្នាំ១៩៧៥ ទោះបីជាតាមរយៈការពិនិត្យទូទៅទៅលើច្បាប់កម្ពុជាក្នុងរយៈពេល១៩ឆ្នាំ(គិតត្រឹមឆ្នាំ១៩៩៥) អាចឃើញថាមានវិសោធនកម្មមួយចំនួនចំពោះក្រមព្រហ្មទណ្ឌនោះ ។ ស្រដៀងគ្នានេះដែរ ប្រភពនានានៅក្នុងច្បាប់ព្រហ្មទណ្ឌក្រោយឆ្នាំ១៩៧៥ មិនមានគ្រប់គ្រាន់ទេ ។ តាមដែលយើងដឹងកម្ពុជាប្រជាធិបតេយ្យមិនបានបោះពុម្ពផ្សាយច្បាប់អ្វីឡើយ ។ របបសាធារណរដ្ឋប្រជា

មានិតកម្ពុជាបានចេញនូវក្រឹត្យច្បាប់នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០ ស្តីអំពី «អំពើក្បត់បដិវត្តន៍និងបទឧក្រិដ្ឋផ្សេងទៀត» ដែលផ្តន្ទាទោសដល់បទល្មើសជាច្រើន ដែលបង្កើតឡើងជាលក្ខណៈបុគ្គលប្រឆាំងនឹងបដិវត្តន៍ ។

នៅក្នុងសម័យអ៊ុនតាក់ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានផ្សព្វផ្សាយនូវសេចក្តីព្រាងក្រមព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។ រដ្ឋកម្ពុជា(ដែលស្ថិតនៅក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស) ក៏បានអនុម័តច្បាប់មួយស្តីអំពីនីតិវិធីព្រហ្មទណ្ឌនៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៣ ។ ចំពោះប្រភពទីពីរៈ យើងមិនឃើញមានឡើយនៅក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា ។

ទីពីរៈ ស្ថានភាពដាក់លាក់នៃលិខិតូបករណ៍នានាមិនទាន់រីកញែកឲ្យដាច់ស្រឡះនៅឡើយ ។ កម្ពុជាបានឆ្លងកាត់យ៉ាងហោចណាស់នូវរបបគ្រប់គ្រងចំនួន៦ផ្សេងៗគ្នាចាប់តាំងពីទទួលបានឯករាជ្យពីអាណានិគមនិយមបារាំង ។ របបទាំងនោះមានដូចជាព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋខ្មែរ កម្ពុជាប្រជាធិបតេយ្យ សាធារណប្រជាមានិតកម្ពុជាឬរដ្ឋកម្ពុជា ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ឬអ៊ុនតាក់ និងព្រះរាជាណាចក្រកម្ពុជាទីពីរ ។ ច្បាប់អនុម័តក្នុងរបបមុនៗនៅតែមានសុពលភាព ប៉ុន្តែត្រូវបាត់បង់តម្លៃនៅក្នុងករណីជាច្រើន ។ និយាយឲ្យល្អគឺថា នៅក្នុងប្រវត្តិសាស្ត្រកម្ពុជាដែលមានលក្ខណៈប្របូកប្របល់ចាប់តាំងពីកម្ពុជាទទួលបានឯករាជ្យមក បញ្ហាទាំងអស់នេះកម្របានដោះស្រាយដោយអ្នកដែលមានអំណាចណាស់ ។ មន្ត្រីនៅក្នុងក្រសួងយុត្តិធម៌កំពុងតែរៀបចំនូវក្រមច្បាប់ថ្មី ប៉ុន្តែក្នុងល្បឿនដ៏យឺតមួយដែលក្រមនេះអាចគ្រប់គ្រងទៅលើការកាត់សេចក្តីនាពេលអនាគត ហើយទម្រាំតែដាក់ជូនដល់រដ្ឋសភាអនុម័តទៀតវាស៊ីពេលមិនតិចឡើយ ។ ជាងនេះទៅទៀត លក្ខណៈជាក់ស្តែងនៃសន្ធិសញ្ញានៅក្នុងច្បាប់ក្នុងស្រុក ក៏មិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយ ជាពិសេសទាក់ទងនឹងអនុសញ្ញាស្តីអំពីការទប់ស្កាត់និងផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ដែលអាចបង្កើតបានដោយផ្ទាល់នូវការទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះបុគ្គលទាំងឡាយ ឬត្រូវតែអនុវត្តតាមច្បាប់ក្នុងស្រុក ។

យើងសូមវិភាគដូចតទៅ ។ ទីមួយៈ យើងជឿថា ដោយផ្អែកលើគោលការណ៍ដែលទទួលយកជាទូទៅ «គ្មានបទល្មើសគ្មានច្បាប់ចែង» ច្បាប់ព្រហ្មទណ្ឌកម្ពុជាមុនឆ្នាំ១៩៧៥ គឺជាប្រភពបឋមនៃច្បាប់ទាក់ទងនឹងការទទួលខុសត្រូវរបស់ខ្មែរក្រហមចំពោះអំពើដែលខ្លួនបានប្រព្រឹត្តឡើងនៅអំឡុងឆ្នាំ១៩៧៥ - ១៩៧៩ ។ ច្បាប់ព្រហ្មទណ្ឌកម្ពុជាបើផ្អែកលើច្បាប់បារាំង គឺទទួលស្គាល់នូវគោលការណ៍អប្រតិសកម្មដែលហាមដាច់ខាតមិនឲ្យមានការអនុវត្តន៍នូវទោសទណ្ឌចំពោះការប្រព្រឹត្តិបទល្មើសដែលមិនមានចែងនៅក្នុងក្រមនៅពេលមានការប្រព្រឹត្តអំពើនោះ ។

ច្បាប់កម្ពុជាអាចទទួលស្គាល់នូវលទ្ធភាពដែលច្បាប់ក្រោយអង្គហេតុមួយអាចចងក្រងជាច្បាប់នូវបទល្មើសដែលត្រូវបានទទួលស្គាល់ម្តងទៀតនៅពេលមានប្រព្រឹត្តបើទោះជាមិនចែងថានៅក្រោច្បាប់ច្បាស់លាស់ក៏ដោយ ។ ការបកស្រាយអំពីគោល-ការណ៍គ្មានបទល្មើសគ្មានច្បាប់ចែង កាន់តែមានបញ្ហានៅក្នុងវង្វង់ច្បាប់ក្នុងស្រុករបស់កម្ពុជា ។ ច្បាប់អន្តរជាតិបានទទួលស្គាល់នូវលទ្ធភាពនៃបទឧក្រិដ្ឋអន្តរជាតិដោយគ្មានច្បាប់ចែងច្បាស់ពីព្រោះច្បាប់អន្តរជាតិវិវឌ្ឍជាបឋមតាមរយៈទំនៀមទម្លាប់ ហើយរដ្ឋនានាមិនទាន់បានយល់ព្រមទៅលើក្រមព្រហ្មទណ្ឌអន្តរជាតិនៅឡើយទេ ។ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជា ក្រមព្រហ្មទណ្ឌនៅជាធរមានចាប់តាំងពីសម័យអាណានិគមមកម៉្លេះ ហើយយើងមានការស្ទាក់ស្ទើរក្នុងការបន្ថែមបទល្មើសដែលមិនមានចែងនៅក្នុងក្រមនោះ ។

ទីពីរៈ យើងសន្មតថាបទល្មើសធំៗដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅតែជាបទល្មើសក្នុងអំឡុងឆ្នាំជាប់ៗគ្នានៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ ប្រការនេះហាក់ដូចជាត្រូវនឹងករណីនេះ ដូចជានៅក្នុងព្រះរាជាណាចក្រទីមួយនិងសម័យសាធារណរដ្ឋខ្មែរ ។ ចំពោះសម័យខ្មែរក្រហមវិញ យើងមិនមានភ័ស្តុតាងណាដែលបង្ហាញថាកម្ពុជាប្រជាធិបតេយ្យលុបចោលឬប្រកាសយ៉ាងឱឡារិកនូវច្បាប់ព្រហ្មទណ្ឌដែលនៅជាធរមានឡើយនៅពេលដែលរបបនេះកាន់កាប់អំណាច ។ ទោះបីជាកម្ពុជាប្រជាធិបតេយ្យមានចេតនាច្បាស់លាស់ចង់ចាប់ផ្តើមបង្កើតនូវ«ឆ្នាំសូន្យ»នៅកម្ពុជាក៏ដោយ ប្រសិនបើគ្មានភ័ស្តុតាង

ច្បាស់លាស់ យើងមិនចង់សន្មតថា របបកម្ពុជាប្រជាធិបតេយ្យលុបបំបាត់នូវឧក្រិដ្ឋភាពនៃអំពើដាក់ស្តែងដែលត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋពីសំណាក់រដ្ឋស្ទើរតែទាំងអស់នោះឡើយ ។

ជាងនេះទៅទៀត ទោះបីជាមានការប្រកាសជាឱឡារិកក៏ដោយក៏មិនអាចរារាំងមិនឲ្យអំពើរបស់ខ្មែរក្រហមចៀសផុតពីឧក្រិដ្ឋភាពក្រោមច្បាប់កម្ពុជាមុននោះដែរ ។ ប្រការនេះហាក់ដូចជាពិត ប្រសិនបើខ្មែរក្រហមរិះរកមធ្យោបាយក្នុងការប្រើប្រាស់ការប្រកាសជាឱឡារិកនេះ ដើម្បីឲ្យខ្លួនមានហេតុផលក្នុងការរំលោភទៅលើការការពារជាមូលដ្ឋានបំផុតនៃសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ។ ឧទាហរណ៍ សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់បានកាត់សេចក្តីទាំងពួកណាហ្ស៊ីនិងឆ្នាំព្រំដែនអាល្លឺម៉ង់ខាងកើត ទោះជាមានការអះអាងរបស់ចុងចោទថារបបទាំងនោះដាក់បន្ទំធម្មានុរូបរបស់ខ្លួនដើម្បីបង្កើតច្បាប់ថ្មីទៀតក៏ដោយ ។ ផ្ទុយពីនេះ ការប៉ុនប៉ងរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការលុបបំបាត់ចោលនូវច្បាប់មុនសម្រាលទោសដល់សមាជិកអង្គការរបស់ខ្លួនដែលនៅថ្នាក់ក្រោម និងការទទួលខុសត្រូវបន្ទាប់បន្សំដែលអាចនឹងមិនដឹងអំពីលក្ខណៈនៃច្បាប់មុនឬធម្មានុរូបនៃការប្រព្រឹត្តិរបស់របបនោះ ។

ដោយផ្អែកលើច្បាប់ឆ្នាំ១៩៥៦ យើងត្រៀមខ្លួននឹងទទួលស្គាល់ថាតុលាការកម្ពុជាមិនទាន់បានអនុវត្តច្បាប់នេះនៅឡើយទេក្នុងរយៈពេលមួយគំណមកនេះ ។ ការប្រើប្រាស់ច្បាប់នេះអាចនឹងនាំដល់ការច្របូកច្របល់ដល់ចៅក្រម ព្រះរាជអាជ្ញា និង មេធាវីការពារក្តី ។ ប៉ុន្តែប្រការនេះនៅតែជាប្រភពច្បាប់ដ៏ជាក់ច្បាស់ ហើយសមត្ថកិច្ចចាំបាច់ត្រូវតែដឹងអំពីរឿងនេះ (ឬរៀនឡើងវិញ) ដើម្បីឲ្យមានការកាត់សេចក្តីត្រឹមត្រូវ ។

## ២) បទល្មើសសំខាន់ក្រោមច្បាប់កម្ពុជាមុនឆ្នាំ១៩៧៥

ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គ្រសោបនូវបទល្មើសបឋមដែលទទួលស្គាល់ដោយរដ្ឋភាគច្រើន ។ អនុលោមតាមការអនុវត្តដាក់ស្តែងនៅប្រទេសបារាំងក្រមនេះចាត់ថ្នាក់បទល្មើសទៅតាមទម្ងន់ទោសៈ (បទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ) ។ បទឧក្រិដ្ឋនិងបទមជ្ឈិម ត្រូវបានចាត់ថ្នាក់កាន់តែស៊ីជម្រៅថែមទៀតជាថ្នាក់ទី១ ថ្នាក់ទី២ ឬថ្នាក់ទី៣ ទៅតាមកម្រិតធ្ងន់ធ្ងរនៃការដាក់ទណ្ឌកម្ម ។ បទឧក្រិដ្ឋថ្នាក់ទី៣ត្រូវផ្តន្ទាទោសប្រហារជីវិតបទឧក្រិដ្ឋទី២ត្រូវផ្តន្ទាទោសធ្វើការដោយបង្ខំអស់មួយជីវិត ចំណែកឯបទឧក្រិដ្ឋថ្នាក់ទី១ ត្រូវផ្តន្ទាទោសឲ្យធ្វើការដោយបង្ខំក្នុងរយៈពេលកំណត់មួយ ។

បទមជ្ឈិមត្រូវផ្តន្ទាទោសដាក់ពន្ធនាគារឬដាក់ពិន័យ ។ បទលហុត្រូវផ្តន្ទាទោសដោយការឃាត់ខ្លួន ដាក់ពិន័យ ឬឃាត់ខ្លួនផងនិងដាក់ពិន័យផង ។ ក្រមព្រហ្មទណ្ឌក៏ផ្តល់នូវលក្ខខណ្ឌជាច្រើនដែលក្នុងនោះតុលាការអាចបន្ធូរឬបន្ថែមទោសទៅតាមស្ថានសម្រាលទោស និងស្ថានទម្ងន់ទោស ។ ស្ថានទម្ងន់ទោសរួមបញ្ចូលវិធីសាស្ត្រក្នុងការប្រព្រឹត្តិបទល្មើសស្ថានភាពរបស់ជនរងគ្រោះនិងលិខិតថ្កោលទោសរបស់អ្នកប្រព្រឹត្តិបទល្មើស ។

បទល្មើសបឋមនិងការផ្តន្ទាទោសអាចសង្ខេបជូនដូចខាងក្រោម÷

◆មនុស្សឃាតមាត្រា(៥០១-៥០៨)ៈ ជនណាធ្វើឲ្យមនុស្សស្លាប់ ជននោះមានពិរុទ្ធក្នុងបទមនុស្សឃាត ។ បើការស្លាប់នោះបណ្តាលមកពីអំពើឥតចេតនាទេ អំពើនោះមានឈ្មោះថាមនុស្សឃាតដោយអចេតនា ។ បើស្លាប់បណ្តាលមកពីអំពើប្រកបដោយចេតនា ចង់សម្លាប់ អំពើនោះឈ្មោះថា មនុស្សឃាតដោយចេតនា ។ មាត្រា៥០៥ ចែងថា ចៅក្រមអាចសន្និដ្ឋានថាឃាតករ មាន**មរណ**ចេតនាបានកាលបើឃាតករបានប្រើសាស្ត្រាវុធគួរដល់ស្លាប់ កាលណាបើឃាតកប្រហារយ៉ាងពេញទំហឹង កាលណាបើមានមុខរបួសមុតសាំលើខ្លួនអ្នកស្លាប់ កាលណាបើឃើញថាឃាតករបានរើសរកកន្លែងដំណំនៅលើខ្លួនអ្នកស្លាប់គួរដល់ស្លាប់មែន ។ ឃាតកម្មគឺជាបទឧក្រិដ្ឋថ្នាក់ទី២ ។ ការលួចធ្វើឃាតគឺជាបទឧក្រិដ្ឋថ្នាក់ទី៣ ។ មនុស្សឃាតដោយស្ម័គ្រចិត្តត្រូវផ្តន្ទាទោសទៅតាមថ្នាក់ផ្សេងៗគ្នាផ្អែកទៅតាមភាពធ្ងន់ធ្ងរនៃទោស ។

◆ អំពើទារុណកម្ម(មាត្រា៥០០)ៈ ជនណាធ្វើទារុណកម្មអ្នកដទៃដើម្បីឲ្យអ្នកនោះឈឺខ្លាំង ហើយឆ្លាយប្រាប់ពត៌មានផ្សេងៗដែលមានប្រយោជន៍ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬមជ្ឈិមកម្មណាមួយក្តី ដើម្បីសងសឹក ឬដោយអំពើចិត្តព្រៃរបស់ខ្លួនក្តី ជននោះត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីបី ។

◆ អំពើរំលោភ(មាត្រា៤៤៣-៤៦)ៈ មាត្រា៤៤៣ ឲ្យ

និយមន័យលើពាក្យរំលោភថា ជនណាបញ្ចូលឬប៉ុនប៉ងបញ្ចូលទាំងបង្ខំឬទាំងគំរាម នូវអង្គជាតិរបស់ខ្លួនទៅក្នុងអង្គជាតិស្ត្រីដែលប្រកែកមិនព្រមស្ម័គ្រផង ជននោះត្រូវចាត់ទុកមានពិរុទ្ធក្នុងបទកំហែងរួមបវេណីដល់ទីជម្រៅ ។ បើស្ត្រីរងគ្រោះមានអាយុតិចជាងដប់បីឆ្នាំ ពិរុទ្ធជនត្រូវមានទោសខក្រិដ្ឋថ្នាក់ទីមួយ ។

◆ ការបង្ករបួសស្នាមផ្សេងៗទៀត(មាត្រា៤៩៥-៤៩៩)៖ វិហិង្សាធ្វើដោយចេតនាលើរូបអ្នកដទៃ ត្រូវផ្ដន្ទាទោសកាលណាបើវិហិង្សានោះមិនបណ្ដាលឲ្យមានស្នាកស្នាមមិនបណ្ដាលឲ្យមានកម្មវិបាកដល់សុខភាពនៃអ្នករងគ្រោះទេ បើបទល្មើសនោះបានប្រព្រឹត្តដោយគ្មានប្រើអាវុធទេ ពិរុទ្ធជននោះត្រូវមានទោសមជ្ឈិមថ្នាក់ទីមួយ ។ បើបទល្មើសនោះបានប្រព្រឹត្តដោយមានប្រើអាវុធផង ពិរុទ្ធជនត្រូវមានទោសមជ្ឈិមថ្នាក់ទីពីរ ។ ជនណាគ្មានចេតនានឹងសម្លាប់គេទេ ប៉ុន្តែ បានធ្វើ ឬ មានបំណងធ្វើដោយចេតនាឲ្យអ្នកដទៃ មានគ្រោះថ្នាក់មិនដល់ស្លាប់ដោយពន្យុះសត្វក្ដី ដោយធ្វើកលខបាយដូចម្ដេចក្ដី ដោយប្រើវិធីយ៉ាងណាក្ដីជននោះត្រូវទុកដូចជាបានធ្វើវិហិង្សាដោយចេតនាប្រព្រឹត្តដោយមានប្រើអាវុធដែរ ។

◆ ការចាប់និងការឃុំខ្លួនក្រៅច្បាប់(មាត្រា៤៨២-៤៨៦)៖ ជនណាគ្មានបានទទួលបង្គាប់ពីអាជ្ញាធរជាធម្មានុរូបសោះ និងក្រៅពីករណីនៃបទល្មើសមជ្ឈិមឬបទខក្រិដ្ឋជាក់ស្ដែងទៀត ហើយចាប់ឃុំ និងឃាត់ទុកនូវបុគ្គលណាម្នាក់ក្នុងរយៈវេលាមិនលើសពីដប់ថ្ងៃទេ ជននោះត្រូវមានទោសមជ្ឈិមថ្នាក់ទីពីរ ។ ក្នុងករណីផ្ទុយទៅវិញគឺថា លើសពីដប់ថ្ងៃឡើងទៅជននោះត្រូវមានទោសមជ្ឈិមថ្នាក់ទីបី ។ ជនណាដែលបានចាប់ឃុំនិងឃាត់មនុស្សទុកហើយធ្វើវិហិង្សាលើរូបកាយក្ដី ធ្វើទុក្ខបុកម្នេញក្ដីបង្អត់អាហារក្ដី ជននោះត្រូវផ្ដន្ទាដល់អតិបរមានៃទោសដែលពោលខាងលើ ។ បន្ថែមពីលើនេះទៀត ចារីប្រព្រឹត្តបទល្មើសអាចត្រូវផ្ដន្ទាទោសពីបទរំលោភទៅលើសិទ្ធិស៊ីវិលរបស់បុគ្គលដូចជាសេរីភាពក្នុងការធ្វើដំណើរជាដើម ។ មាត្រា២៨៩-៥១ កំណត់ថាចៅក្រមណាចេញបង្គាប់ឲ្យឃុំមនុស្សដែលគ្មានត្រូវចោទពីបទខក្រិដ្ឋឬបទមជ្ឈិមសោះចៅក្រមនោះត្រូវមានទោសមជ្ឈិមថ្នាក់ទីពីរ ។

◆ បទល្មើសប្រឆាំងនឹងសាសនា (មាត្រា២០៩-១៨)៖ ការព្យាបាទដល់ជីវិតរបស់បព្វជិតក្នុងសាសនារបស់រដ្ឋនៅវេលាដែលលោកកំពុងធ្វើវត្តប្រតិបត្តិ ឬឱកាសដែលលោកធ្វើវត្តប្រតិបត្តិតាមច្បាប់សាសនា ត្រូវមានទោសខក្រិដ្ឋថ្នាក់ទីបី ។

◆ ការរំលោភលើអំណាចរដ្ឋាភិបាល (មាត្រា២៤០-៤៤)៖ អ្នករាជការ ឬអ្នកតំណាងអាជ្ញាធរសាធារណៈបំពេញមុខការដោយរំលោភអំណាច ឬបង្គាប់ឲ្យគេបំពេញមុខការដោយរំលោភអំណាចអ្នករាជការឬអ្នកតំណាងនោះត្រូវមានទោសមជ្ឈិមថ្នាក់ទីពីរ ។ អ្នករាជការ អ្នកតំណាងអាជ្ញាធរសាធារណៈអាក់ខានមិនបានទៅ ឬប្រកែកមិនទៅពិនិត្យ ឬទៅប្ដឹងអាជ្ញាធរខាងតុលាការពីបទល្មើសដែលខ្លួនបានពត៌មានហើយ អ្នករាជការអ្នកតំណាងនោះត្រូវមានទោសមជ្ឈិមថ្នាក់ទីពីរ ។

ក្រៅពីបទល្មើសរៀបរាប់ខាងលើនេះ ក្រមដែលចែងអំពីច្បាប់យោធាដែលបោះផ្សាយជាមួយនឹងក្រមព្រហ្មទណ្ឌដែរបានចែងអំពីបទល្មើសបន្ថែមពីលើនេះទៀតដែលប្រព្រឹត្តឡើងដោយបុគ្គលិកយោធា ។ បទល្មើសនិងការផ្ដន្ទាទោសត្រូវបានកំណត់ជាទូទៅស្រដៀងគ្នានឹងបទល្មើសនិងការផ្ដន្ទាទោសនៅក្នុងក្រមព្រហ្មទណ្ឌដែរ ។ ភាគច្រើននៃក្រមយោធានេះផ្ដោតសំខាន់ទៅលើបទល្មើសទាក់ទងនឹងយោធា ដូចជាការមិនព្រមធ្វើតាមបញ្ជា ការរត់ចោលជួរ និងអំពើក្បត់ជាតិ ប៉ុន្តែក្រមនេះចាត់ទុកការលួចប្លន់ជាបទខក្រិដ្ឋថ្នាក់ទីពីរ នៅពេលការលួចប្លន់នោះប្រព្រឹត្តដោយយោធាដែលប្រដាប់ដោយអាវុធ ប្រើកម្លាំងឬអំពើហិង្សាផ្សេងទៀត ។ ប្រសិនបើសមាជិកណានៅក្នុងក្រុមជាអ្នកញុះញង់ជននោះព្រមទាំងអ្នកដែលមានតំណែងខ្ពស់នៅក្នុងជួរយោធាគឺជាខក្រិដ្ឋជនថ្នាក់ទីពីរ ហើយអ្នកក្រៅពីនោះជាខក្រិដ្ឋជនថ្នាក់ទី១ ។

ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនបានចែងឲ្យបានច្បាស់អំពីបទខក្រិដ្ឋអន្តរជាតិដូចជាអំពើប្រល័យពូជសាសន៍ ខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬខក្រិដ្ឋសង្គ្រាម ប៉ុន្តែក្រមព្រហ្មទណ្ឌនេះផ្ដោតសំខាន់ត្រឹមទៅលើបទល្មើសធម្មតានៃច្បាប់ក្នុងស្រុកតែប៉ុណ្ណោះ ។ បញ្ហាថាតើ ច្បាប់កម្ពុជាអនុញ្ញាតឲ្យមានការកាត់សេចក្ដីដោយផ្ទាល់ទៅលើបុគ្គលពីបទប្រព្រឹត្តខក្រិដ្ឋកម្មអន្តរជាតិដោយគ្មានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា នៅតែមិនទាន់មានលក្ខណៈ

ដាច់ស្រឡះនៅឡើយទេ ។ ច្បាប់រដ្ឋធម្មនុញ្ញបារាំងហាក់ដូចជាអនុញ្ញាតឲ្យមានការកាត់សេចក្តីយ៉ាងហោចណាស់ក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលផ្អែកលើសន្ធិសញ្ញា ពីព្រោះសន្ធិសញ្ញាអាចយកមកអនុវត្តជាលក្ខណៈក្នុងស្រុកបានត្រឹមតែក្រោមច្បាប់ដែលបោះពុម្ពជាផ្លូវការប៉ុណ្ណោះ ។ ប្រសិនបើកម្ពុជាអនុវត្តតាមប្រទេសបារាំង កម្ពុជាអាចដាក់បញ្ចូលគ្នារវាងច្បាប់អន្តរជាតិជាមួយនឹងច្បាប់ក្នុងស្រុកតាមរយៈក្រឹត្យទោះជាមានការកើតឡើងនូវការអនុវត្តប្រតិសកម្មក៏ដោយ ។ (ប្រសិនបើកម្ពុជាបានចេញជាច្បាប់អនុសញ្ញាទប់ស្កាត់និងផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ ឬច្បាប់សន្ធិសញ្ញាព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតថាអាចអនុវត្តបានក្នុងស្រុកបញ្ហាប្រតិសកម្មនឹងមិនអាចកើតឡើងចំពោះបទល្មើសអន្តរជាតិ ប៉ុន្តែយើងមិនដឹងថា តើវាបានកើតឡើងឬនៅទេ) ។

### ៣) ការការពារពីបទចោទប្រកាន់ និង«ខ»ផ្សេងៗទៀតដែលអាចឲ្យរួចទោស

ក្រមព្រហ្មទណ្ឌផ្តល់នូវលក្ខខណ្ឌមួយចំនួនសម្រាប់ឲ្យរួចទោស ។ ទីមួយៈ មនុស្សវិកលចរិតនិងមនុស្សខ្សោយសតិទាំងអស់នេះមិនមានការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌចំពោះអំពើល្មើសដែលខ្លួនបានប្រព្រឹត្តទេ ប៉ុន្តែក្នុងបទស៊ីវិល ជនទាំងនេះ នៅតែមានការទទួលខុសត្រូវដដែល ។ ទីពីរ ពិរុទ្ធជនមានអាយុតិចជាង ១៨ឆ្នាំ ក្នុងខណៈប្រព្រឹត្តបទល្មើសនោះ ត្រូវប្រមាណថាមិនទាន់ដឹងខុសត្រូវ មិនត្រូវទទួលខុសត្រូវទេ ។ ជននេះត្រូវរួចផុតពីការចោទប្រកាន់ផុតពីទោសពៃរ៍ទាំងអស់ ប៉ុន្តែ តុលាការត្រូវសម្រេចថាឲ្យជននោះនៅក្រោមការឧបត្ថម្ភ ការសង្គ្រោះ ការត្រួតត្រាការអប់រំ ឬការកែខ្លួនណាមួយក្នុងថិរវេលាដែលមានកំណត់ ។ ទីបីៈ ជនជាប់ចោទអាចជជែកការពារខ្លួនដោយហេតុផលប្រធានសក្តិបាន ។ កាលបើមានភ័ស្តុតាងថាមានកម្លាំងអ្វីមួយបានបង្ខំជនណាម្នាក់ឲ្យប្រព្រឹត្តបទល្មើសអ្វីមួយ ហើយជននោះកាលមិនអាចទប់ទល់នឹងកម្លាំងនោះបានក៏ប្រព្រឹត្តបទល្មើសនោះទៅ ។ ជនប្រព្រឹត្តិបទល្មើសនេះមិនត្រូវឲ្យទទួលខុសចំពោះអំពើដែលខ្លួនប្រព្រឹត្តឡើយ ។ ទីបួនៈ ចាត់ទុកជាអំពើល្មើសក្នុងបទព្រហ្មទណ្ឌទេ? កាលណាបើអំពើទាំងឡាយនោះធ្វើតាមបង្គាប់របស់ច្បាប់ ហើយអ្នកបញ្ជាឲ្យធ្វើក៏ជាអាជ្ញាធរធម្មានុរូបដែរ ។ ក្នុងករណីដែលសេចក្តីបង្គាប់ជាអនីត្យានុកូល ហើយអ្នកបញ្ជាជាអាជ្ញាធរធម្មានុរូប ចៅក្រមត្រូវថ្លឹងមើលតាមការគួរនូវសភាពនៃការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌរបស់ភ្នាក់ងារអ្នកសម្រេចការណ៍នោះ ។ ទីប្រាំៈ កិច្ចការពារខ្លួន ។ កាលណាបើការចាំបាច់តម្រូវឲ្យកាប់សម្លាប់ឬវាយជនណាម្នាក់ដើម្បីការពារខ្លួនឯង ឬអ្នកដទៃដោយធម្មានុរូបអំពើកាប់សម្លាប់ ឬវាយនេះមិនចូលជាឧក្រិដ្ឋកម្ម ឬទោសកម្មទេ ។ កិច្ចការពារខ្លួនឯងឬការពារអ្នកដទៃ នឹងទុកជាធម្មានុរូបបានលុះតែមានការរំលោភពីភាគម្ខាងមកមុន គឺថាគេវាយកាប់ដោយអយុត្តិធម៌ជាមុន ។ ចំណុចចុងក្រោយក្រមព្រហ្មទណ្ឌនេះ ចែងច្បាស់អំពីអាជ្ញាយុកាលនៃបទល្មើស ។ បទល្មើសឧក្រិដ្ឋមានអាជ្ញាយុកាល១០ឆ្នាំ បទមជ្ឈិមមានអាជ្ញាយុកាល ៥ឆ្នាំ និង បទលហុ១២ខែ ។ អាជ្ញាយុកាលនៃបទល្មើសចាប់រាប់ពីថ្ងៃប្រព្រឹត្តបទល្មើស ហើយត្រូវផ្អាកនៅពេលអាជ្ញាធរខាងតុលាការផ្តើមស៊ើបសួរ ។

### ៤) ការអនុវត្តន៍ជាក់ស្តែងសម្រាប់ប្រទេសកម្ពុជា

ដោយយករឿងទាំងអស់មកគិតឃើញថា យើងផ្តល់នូវការសន្និដ្ឋានតាមព្រឹត្តិន័យទាក់ទងនឹងកំហុសរបស់មន្ត្រីខ្មែរក្រហមក្រោមច្បាប់កម្ពុជា ។ ការសម្រេចប្រកបដោយអាជ្ញាព្រឹត្តនឹងតម្រូវឲ្យមានការវិភាគឲ្យបានប្រុងប្រយ័ត្នទៅលើអង្គច្បាប់ព្រហ្មទណ្ឌកម្ពុជា និងការពិចារណាទៅលើកត្តាសំខាន់ៗនិងជាករណីយុត្តិសាស្ត្រដែលមិនអាចទាញចេញពីក្រមព្រហ្មទណ្ឌបាន ។

ចំពោះបទល្មើសសំខាន់ៗវាហាក់ដូចជាថា អំពើឃោរឃៅដែលប្រព្រឹត្តដោយខ្មែរក្រហមត្រូវនឹងនិយមន័យទូទៅនៃបទឧក្រិដ្ឋនានានៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។ បទឧក្រិដ្ឋទាំងនេះរួមមានឃាតកម្ម ទារុណកម្ម ការរំលោភ ការបង្ខាំងខុសច្បាប់ការបង្ករបួសស្នាមផ្សេងៗ ការវាយប្រហារមកលើសាសនានិងការរំលោភផ្សេងៗទៀតពីសំណាក់អាជ្ញាធររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ ដោយសារឧក្រិដ្ឋកម្មទាំងនេះស្ថិតនៅក្រោមច្បាប់កម្ពុជា ព្រះរាជអាជ្ញាមិនចាំបាច់ស្វែងរកធាតុផ្សំផ្សេងទៀតដែលបង្កើតបានជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មដែល

មានលក្ខណៈអន្តរជាតិផ្សេងៗទៀតទេ ។ ជាពិសេស ចេតនាក្នុងការកម្ទេចក្រុមមួយជាលក្ខណៈប្រព័ន្ធទ្រង់ទ្រាយធំបំណងប្រឆាំងនឹងក្រុមមួយទៀត ដោយសារការសេពគប់និងសម្ព័ន្ធភាពជម្លោះប្រដាប់អាវុធមិនមានលក្ខណៈស៊ីសង្វាក់គ្នាទេ ។

បើពិនិត្យទៅលើក្រមព្រហ្មទណ្ឌកម្ពុជាគ្មានអ្វីគួរឲ្យឆ្ងល់ទេថា វាបង្ហាញនូវបទល្មើសដទៃទៀត ក្នុងនោះរួមមានបទល្មើសទាក់ទងនឹងទ្រព្យសម្បត្តិ និងការរំលោភលើសិទ្ធិស៊ីវិលនិងសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ ។

ប៉ុន្តែការការពារខ្លួនពីការចោទប្រកាន់បណ្តាលឲ្យមានការពិចារណាសំខាន់ៗជាច្រើន ។ ទីមួយៈ ជនប្រព្រឹត្តបទល្មើសអាចរួចផុតពីការទទួលខុសត្រូវ ជាពិសេសដោយយោងទៅលើការគ្រប់គ្រងតាមលក្ខណៈផ្តាច់ការ និងបរិយាកាសប្រកបដោយភេរវកម្មដែលរុំជុំជិតប្រទេសកម្ពុជាពេញមួយសម័យនោះ ។ ហេតុដូចនេះ ការរកឲ្យឃើញកំហុសរបស់ក្មេងជំទង់ដែលមិនដឹងខុសត្រូវហាក់ដូចជាពិបាកធ្វើណាស់ ។ ទីពីរ ស្ថានភាពការពារខ្លួនដោយសំអាងប្រធានសត្តិនឹងតម្រូវឲ្យមានការពិនិត្យពិច័យល្អិតល្អន់ បើទោះជាក្រមនោះហាក់ដូចជាបង្ហាញថាជនប្រព្រឹត្តបទល្មើសត្រូវមានភ័ស្តុតាងបង្ហាញថាកាលនោះខ្លួនប្រឈមមុខនឹងការស្លាប់បើខ្លួនមិនសម្លាប់មនុស្សក៏ដោយ ។ ប្រការនេះអាចកម្រិតចំនួនមនុស្សឲ្យនៅត្រឹមចំនួនតិចចំពោះអ្នកដែលចង់ពឹងផ្អែកលើការការពារខ្លួនតាមវិធីនេះ ។ ស្រដៀងគ្នានេះដែរ យើងចោទជាសំណួរថាតើការប្តឹងការពារខ្លួនអាចអនុវត្តនៅក្នុងស្ថានការណ៍ច្រើនប៉ុនណា បើជនរងគ្រោះដែលគ្មានអ្នកណាជួយភាគច្រើនជាជនរងគ្រោះខ្មែរក្រហមនោះ? ទីបីៈ ការការពារដែលផ្អែកលើវិសាលភាពនៃការអនុវត្តន៍តាមបញ្ជាក្រោមច្បាប់កម្ពុជា នឹងចាំបាច់ត្រូវតែកំណត់ឲ្យបានច្បាស់ ។ តើបញ្ជារបស់ខ្មែរក្រហមមានលក្ខណៈស្របច្បាប់ចំពោះគោលបំណងនៃការផ្តល់ការការពារខ្លួនបែបនេះដែរឬទេ? ប្រសិនបើគ្មាន តើការអនុវត្តន៍បញ្ជាដែលអធម្មានុរូប ត្រូវទទួលខុសត្រូវត្រឹមកម្រិតណា? តុលាការនឹងពិនិត្យមើលទៅលើករណីយុត្តិសាស្ត្រដែលគាត់តែងចេញជារូបរាងឡើងនៅក្រោយសង្គ្រាមលោកលើកទីពីរនិងស្ថានការណ៍ផ្សេងៗទៀត ដើម្បីឆ្លើយនឹងសំណួរនេះឲ្យបាន ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ទោះជាចម្លើយចេញមកយ៉ាងម៉េចក៏ដោយ វាគ្មានអ្វីគួរឲ្យមន្ទិលសង្ស័យទេថា អ្នកដែលស្ថិតនៅក្នុងជួរថ្នាក់ដឹកនាំជាតិ ឬអ្នកផ្សេងទៀតដែលមានឆន្ទានុសិទ្ធិគ្រប់គ្រាន់ក្នុងការចេញបញ្ជា មិនអាចសំអាងលើការការពារក្នុងករណីនេះបានឡើយ ។

ចំណុចចុងក្រោយនិងសំខាន់បំផុតគឺបញ្ហាដែនអាជ្ញាយុកាល ។ យើងអាចបកស្រាយថា មិនអាចមានការកាត់សេចក្តីលើមេដឹកនាំខ្មែរក្រហមដែលបានប្រព្រឹត្តអំពើឃោរឃៅនៅអំឡុងឆ្នាំ១៩៧៥-១៩៧៩ នៅក្រោយឆ្នាំ១៩៨៩ បានទេ ពោលគឺមានរយៈពេល១០ឆ្នាំក្រោយពីមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយខ្មែរក្រហមចាកចេញពីទីក្រុងភ្នំពេញ ។ តាមពិតបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្តឡើងនៅមុនឆ្នាំ១៩៧៩ គួរតែត្រូវបានផ្តើមស៊ើបអង្កេតឬចោទប្រកាន់មុនឆ្នាំ១៩៨៩ ទើបបាន ។

ប៉ុន្តែការបកស្រាយ ក៏ដូចជាជម្រើសមួយទៀតគឺអាចមានសម្រាប់ព្រះរាជអាជ្ញានិងតុលាការ ។ ទីមួយៈ តុលាការអាចសម្រេចថា អវត្តមាននៃប្រព័ន្ធតុលាការកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៥ បានធ្វើឲ្យផុតរលត់ដែនអាជ្ញាយុកាលចាប់តាំងពីពេលនោះមកម្ល៉េះ ។ តាមទ្រឹស្តីនេះ អាជ្ញាយុកាលមិនមានទៀតឡើយរហូតដល់មានការបង្កើតឡើងសាជាថ្មីនូវអយ្យការនិងប្រព័ន្ធតុលាការត្រឹមត្រូវ ។ យោងតាមគោលការណ៍ “ឋានៈនិងតួនាទីមិនអាចលុបលាងកំហុសបាន” (*The maxim nemo ex suo delicto meliorem suam conditionem facere potest*) បញ្ជាក់ថា ខ្មែរក្រហមមិនគួរទទួលបានទទួលផលប្រយោជន៍ចេញពីការបំផ្លិចបំផ្លាញប្រព័ន្ធតុលាការខ្លួនឯងនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ឡើយ ។

ទស្សីករណ៍នេះក៏មានតម្លៃដែរ ដោយសារថា ដោយមានការសន្និដ្ឋានមិនច្បាស់លាស់នៅពីក្រោយក្រមព្រហ្មទណ្ឌកម្ពុជា (ឬក្រមក្នុងស្រុកផ្សេងៗទៀត) ប្រព័ន្ធតុលាការដែលកំពុងតែដំណើរការក្នុងរដ្ឋាភិបាលបច្ចុប្បន្នដែលគ្រប់គ្រងលើទឹកដីរបស់ខ្លួនមិនកើតមានឡើយចាប់តាំងពីឆ្នាំ១៩៧៩មក ។ មកដល់ពេលនេះ ប្រព័ន្ធតុលាការនៅតែមានលក្ខណៈមិនទំនើប ព្រមទាំងមិនមានការរៀបរយត្រឹមត្រូវឡើយ ដែលមានជនសង្ស័យនៅពីក្រៅ

ការគ្រប់គ្រងរបស់អាជ្ញាធរកណ្តាល ។ បើទោះជាតុលាការបដិសេធមិនព្រមពន្យារដែនអាជ្ញាយុកាលដោយសារហេតុផលនេះក្តី ក៏សភាជាតិអាចអនុម័តច្បាប់ថ្មីទាក់ទងនឹងបញ្ហានេះ ។ កម្ពុជាអាចផ្អែកលើច្បាប់បារាំងដែលមានលក្ខណៈដូចគ្នា ។ ច្បាប់នោះបានពន្យារអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាទៅលើការកាត់សេចក្តីដោយសារតែភាពកង្វះប្រសិទ្ធភាពនៃប្រព័ន្ធតុលាការនៅអំឡុងសង្គ្រាមលោកលើកទី២ ។ ទីពីរៈ តុលាការអាចសម្រេចថា ការជំនុំជម្រះក្តីកំបាំងមុខនៅឆ្នាំ១៩៧៩ ទៅលើមេដឹកនាំខ្មែរក្រហមពីសំណាក់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើឲ្យផុតរលត់អាជ្ញាយុកាលបទល្មើសបាត់ទៅហើយ ហើយទាំងរដ្ឋាភិបាលនោះ និងរដ្ឋាភិបាលបន្តបន្ទាប់ក្រោយមកទៀតបាននិងកំពុងតែស៊ើបអង្កេតបទល្មើសដែលប្រព្រឹត្តដោយខ្មែរក្រហមនាពេលនោះ ។ តាមមាត្រា១១២ និង១១៤ នៃក្រមព្រហ្មទណ្ឌចែងថា រយៈពេលនៃអាជ្ញាយុកាលបទល្មើសទាំងឡាយត្រូវឈប់គិតពីត្រឹមថ្ងៃដែលអាជ្ញាធរខាងតុលាការផ្តើមស៊ើបសួរឬផ្តើមចោទប្រកាន់ ។ រយៈពេលនៃអាជ្ញាយុកាលដែលឈប់គិតព្រោះតុលាការបានដំណើងពីបណ្តឹងនោះ ត្រូវលើកយកមកគិតមករាប់សាជាថ្មីឡើងវិញ កាលណាបើតុលាការចប់កិច្ចស៊ើបអង្កេតជំនុំជម្រះអស់ហើយ ។ ទឡ្ហីករណ៍នេះមានចន្លោះប្រហោងពីរចំណុចគឺៈ ការជំនុំជម្រះក្តីឆ្នាំ១៩៧៩ មិនច្បាស់ថាយុត្តិសាស្ត្រទេ ហើយយើងមិនដឹងថា ចាប់តាំងពីពេលរៀបចំតុលាការនោះ អាជ្ញាធរកម្ពុជាបានធ្វើការស៊ើបអង្កេតលើអំពើឃោរឃៅរបស់ខ្មែរក្រហមដោយសុទ្ធចិត្តឬយ៉ាងណាទេ ។ ទីបីៈ និងដែលអាចមានជោគជ័យ គឺរាជរដ្ឋាភិបាលកម្ពុជាអាចអនុម័តច្បាប់ថ្មីមួយដើម្បីពង្រីងនិងលុបចោលនូវអាជ្ញាយុកាលនៃបទល្មើសនៅក្នុងករណីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងនោះមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែរ ។ យុទ្ធសាស្ត្រនេះមានយុត្តិសាស្ត្រគ្រប់គ្រាន់ដែលអនុវត្តជាក់ស្តែងដោយរដ្ឋាភិបាលនៅបណ្តាប្រទេសអឺរ៉ុបខាងលិច ជាពិសេសសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ នៅពេលនោះអាជ្ញាយុកាលនៃបទល្មើសចាប់ផ្តើមរលត់ចំពោះបទល្មើសដែលប្រព្រឹត្តឡើងដោយពួកណាហ្ស៊ី ។ ការលុបចោលនូវអាជ្ញាយុកាលនៃបទល្មើសទំនងជាត្រូវបានយល់ស្របដោយអនុសញ្ញាឆ្នាំ១៩៦៨ ស្តីអំពីការមិនអនុវត្តអាជ្ញាយុកាលនៃបទល្មើសចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងដោយអនុសញ្ញាក្រុមប្រឹក្សាអឺរ៉ុបឆ្នាំ១៩៧៤ ស្តីអំពីបញ្ហាដដែល ។ ទោះបីជារដ្ឋមួយចំនួនតូចដែលអនុវត្តទៅតាមអនុសញ្ញាទាំងនេះឲ្យយោបល់ថា ការលុបចោលនូវច្បាប់អាជ្ញាយុកាលនោះមិនទាន់ត្រូវបានតម្រូវថាជាបញ្ហាទំនៀមទម្លាប់ក៏ដោយ ប៉ុន្តែតាមការអនុវត្តន៍ជាក់ស្តែងរបស់រដ្ឋពិតជាគាំទ្រការលើកឡើងថា ការលុបចោលរបស់ខ្លួនយ៉ាងហោចណាស់ត្រូវតែទទួលការអនុញ្ញាត ហើយមិនផ្ទុយនឹងច្បាប់ ។

ទាក់ទងនឹងបញ្ហាច្បាប់ក្នុងស្រុក រដ្ឋទាំងឡាយមានជំហរផ្សេងៗគ្នាទៅលើបញ្ហាថាតើការពង្រីកឬលុបបំបាត់ចោលនូវច្បាប់អាជ្ញាយុកាលចំពោះបទល្មើសដែលប្រព្រឹត្តឡើងនៅក្នុងអតីតកាល (រួមទាំងអាជ្ញាយុកាលនៃបទល្មើសដែលបានហួសពេលកំណត់ទៅហើយ) ជាការរំលោភលើគោលការណ៍ច្បាប់ក្នុងស្រុកស្តីអំពី"អប្រតិសកម្ម" ។ តុលាការប្រទេសបារាំងសម្រេចថា ច្បាប់បារាំងឆ្នាំ១៩៦៤ដែលលុបចោលនូវអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិអាចអនុវត្តជាលក្ខណៈប្រតិសកម្មបានដើម្បីកាត់សេចក្តីបាប៊ី បើទោះជាច្បាប់អាជ្ញាយុកាលចំពោះបទល្មើសឃាតកម្មបានផុតកំណត់មុនពេលដែលអនុម័តច្បាប់ឆ្នាំ១៩៦៤នោះហើយក្តី ។ ជំហរនេះអាចទទួលបានការគាំទ្រពីសំណាក់តុលាការកម្ពុជាដែរ ។

**ចេសុន ប្រាហាម**

# ស្តាប់ប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣:៣០-៣:៤៥នាទី តាមរយៈវិទ្យុ១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា ។

**លី សុផល និង ផាត រចនា**

# អន្តរទំនាក់ទំនងរវាងយុត្តិធម៌និងការផ្សះផ្សាជាតិៈ បទពិសោធរបស់អាហ្វ្រិកខាងត្បូងស្តីអំពី យុត្តិធម៌សម័យអន្តរកាលសម្រាប់របបអាប៉ាថេត

***សេចក្តីផ្តើមៈ***

នាយករដ្ឋមន្ត្រីនៃប្រទេសស៊ុយអែដ ហ្គោរ៉ាន ជីសុន បានអញ្ជើញរដ្ឋាភិបាលចំនួនជាង៤ប្រទេសឲ្យចូលរួមនៅក្នុងវេទិកាអន្តរជាតិមួយនៅទីក្រុងស្តុកខូម ស្តីអំពី "ការពិត យុត្តិធម៌ និងការផ្សះផ្សា" ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៣ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០២ ។ សន្និសីទនេះបានពិភាក្សាថាតើការពិតនិងយុត្តិធម៌មានទំនាក់ទំនងជាមួយការផ្សះផ្សាយ៉ាងដូចម្តេច ។ កិច្ចប្រជុំបានផ្តល់ឲ្យរដ្ឋាភិបាល សហគមន៍ អ្នកស្រាវជាវ និងក្រុមវិជ្ជាជីវៈដែលមានវត្តមាន នូវឱកាសផ្លាស់ប្តូរទស្សនៈនិងបទពិសោធស្តីអំពីការផ្សះផ្សា ។ សំណួរមួយក្នុងចំណោមសំណួរសំខាន់ៗបំផុតគឺ តើការផ្សះផ្សាកើតមាននៅពេលណា? តើអាចសម្រេចបានយ៉ាងដូចម្តេចនិងដោយមធ្យោបាយបែបណា?

ក្នុងសុន្ទរកថាបើកសន្និសីទនេះ នាយករដ្ឋមន្ត្រីស៊ុយអែដបានគូសបញ្ជាក់ថា "ការផ្សះផ្សា" គឺជាដំណើរការមួយដែលលំបាកស្មុគស្មាញនិងមានរយៈពេលវែង ។ ការផ្សះផ្សាតម្រូវឲ្យមាន"យុត្តិធម៌សម័យអន្តរកាល" ដែលអាចធ្វើជាគ្រឹះសម្រាប់អភិវឌ្ឍលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ។ ការផ្សះផ្សាទាមទារពីយើង អ្នកនយោបាយ អ្នកស្រាវជ្រាវ និងអ្នកផ្សេងទៀត នូវសេចក្តីក្លាហាន ការយល់ដឹង និងឆន្ទៈ ដើម្បីរួមចំណែកទទួលខុសត្រូវ ។ ដូច្នេះយើងត្រូវប្រឹងឲ្យអស់ពីសមត្ថភាព និងប្រសិទ្ធភាពក្នុងការបញ្ចប់និងការពារជម្លោះ ។ យើងត្រូវលើកយកដំណើរការផ្សះផ្សាធ្វើជារបៀបវារៈខាងនយោបាយ ។

មួយទសវត្សរ៍មុន យើងឃើញមានការអំពាវនាវសុំឲ្យមានការទទួលខុសត្រូវមិនមែនគ្រាន់តែពីសំណាក់រដ្ឋ ប៉ុន្តែពីសំណាក់បុគ្គលម្នាក់ៗគ្រប់កម្រិត ដែលដើរតាមការដឹកនាំផ្តាច់ការ និងការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ គ្មាននរណាម្នាក់អាចគេចផុតពីសំណាញ់យុត្តិធម៌បានឡើយ ។ គណៈកម្មការស្វែងរកការពិតនានានិងតុលាការអន្តរជាតិត្រូវបានបង្កើតឡើង ។ ប៉ុន្តែយើងមិនបានដឹងច្បាស់ថា តើការផ្សះផ្សាប្រព្រឹត្តទៅយ៉ាងដូចម្តេចនៅក្នុងដំណើរការនយោបាយ សង្គម និងចិត្តសាស្ត្រ ដែលសាំញ៉ាំដូចជាវិធីដែលនាំឲ្យមានការផ្តួចផ្តើមឲ្យមានផ្សះផ្សា ដែលនាំឲ្យសង្គមទាំងមូលចូលរួមក្នុងការផ្សះផ្សាជាតិ និងដែលនាំឲ្យជនរងគ្រោះនិងជនដៃដល់រស់នៅជាមួយគ្នាបន្ទាប់ពីមានជម្លោះដ៏គឹងគែងរួចមក ។

ក្នុងស្ថានការណ៍ក្រោយជម្លោះ ការរំលោភបំពាន និងការរំលោភសិទ្ធិមនុស្ស មានការសង្ឃឹមថាអ្នកដែលបានប្រព្រឹត្តខុសឱបក្រសោបគំនិតផ្សះផ្សា ។ ការផ្សះផ្សាគឺលើសពីការដោះស្រាយជម្លោះធម្មតា ដែលក្នុងនោះតំណាងនៃភាគីជម្លោះចេញមុខចរចារកដំណោះស្រាយដែលអាចទទួលយកបានទាំងសងខាង ។

ការផ្សះផ្សាទាក់ទិនទៅនឹងសីលធម៌និងភាពជាមនុស្ស ហើយប៉ះពាល់គ្រប់ផ្នែកនៃសង្គមៈ តើការពិតប៉ុនណាអាចឲ្យសង្គមមួយដោះស្រាយនិងទទួលស្គាល់អ្វីដែលបានកើតឡើងពីអតីតកាល? តើការទាមទាររកយុត្តិធម៌អាចធ្វើបានដល់កម្រិតណាដោយមិនប៉ះពាល់ដល់ការផ្សះផ្សានាពេលអនាគត? បុគ្គលម្នាក់ៗប្រឈមមុខនឹងជម្រើសជាច្រើន ពោលគឺ តើបុគ្គលនោះត្រូវសងសឹក បំភ្លេច ឬក៏អត់ឱន ដើម្បីទទួលស្គាល់នូវអ្វីដែលបានកើតឡើងពីអតីតកាល ។ មានសំណួរជាច្រើនដែលត្រូវចោទសួរ ។ គ្មានវិធីណាមួយដែលងាយស្រួលឡើយ ។ គ្មានមធ្យោបាយតែ

មួយនោះទេ ។ អ្នកដែលមានបទពិសោធធ្វើការនៅក្នុងគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សានៅអាហ្វ្រិកខាងត្បូងដឹងពីបញ្ហានេះ ។

ទាក់ទងនឹងការពិត យុត្តិធម៌ និងការផ្សះផ្សា បទពិសោធន៍របស់អាហ្វ្រិកខាងត្បូងមានសារប្រយោជន៍សម្រាប់លើកជាសំណួរនាំមុខមួយចំនួនអំពីចរិតនៃអ្វីដែលអាចជាទស្សនវិស័យសមស្រប ។ និយាយដោយសង្ខេបប្រជាធិបតេយ្យនៃអាហ្វ្រិកខាងត្បូងបានប្រសូត្រឡើងក្នុងឆ្នាំ១៩៩៤ ក្រោយពីមានការរើសអើងពូជសាសន៍អស់រយៈពេលជាងពាក់កណ្តាលសតវត្សរ៍ដែលលើកឡើងនៅក្នុងគោលការណ៍នៃច្បាប់រដ្ឋធម្មនុញ្ញ ។ វាជាដំណាក់កាលមួយនៃការគាបសង្កត់យ៉ាងព្រៃផ្សៃប៉ះពាល់ដល់ក្រុមនានា ការវាយរំលោភបំពានលើប្រទេសជិតខាង ហើយថែមទាំងឈានចូលក្នុងកិច្ចការសង្គ្រាមគីមីនិងវិទ្យាសាស្ត្របង្កើតកូនឲ្យបានល្អ ។ សភាថ្មីបានសម្រេចចិត្តប្រឈមមុខនឹងអតីតកាលដ៏កខ្វក់នេះតាមរយៈការបង្កើតនូវគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាដែលជាអង្គភាពមួយស្ថាបនាឡើងដោយច្បាប់មួយអនុម័តនៅពាក់កណ្តាលឆ្នាំ១៩៩៥ ។ គោលដៅនៃច្បាប់នេះគឺដើម្បីបង្កើនការយល់ដឹងអំពីអតីតកាលដ៏ជូរចត់របស់ប្រទេសអាហ្វ្រិកខាងត្បូងរាប់ចាប់ពីទសវត្សរ៍ឆ្នាំ១៩៦០មក ។

ប្រទេសអាហ្វ្រិកខាងត្បូងសព្វថ្ងៃប្រសើរជាងកាលពីអតីតកាលខ្លាំងណាស់ ។ ប្រទេសអាហ្វ្រិកខាងត្បូងត្រូវប្រឈមមុខនឹងប្រជាជនរបស់ខ្លួនតាមរយៈការតទល់ដោះស្រាយនូវស្ថានភាពមួយដែល«អតីតកាលមិនមែនជាអតីតកាល» ។ ការបោះឆ្នោតបែបប្រជាធិបតេយ្យលើកដំបូងបានធ្វើឡើងក្នុងឆ្នាំ១៩៩៤ ។ ដំណោះស្រាយបានពីការចរចាឆ្ពោះទៅរកសង្គមមួយប្រកបដោយលទ្ធិប្រជាធិបតេយ្យបានត្រួសត្រាយផ្លូវ ហើយមានតួនាទីជាមូលដ្ឋានសម្រាប់គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សា ។ វាក៏បានដាក់នូវដែនកំណត់នៃការកាត់ទោសអតីតជនដែលនៅក្រោមប្រព័ន្ធនយោបាយថ្មី ។ ទាំងការគាបសង្កត់និងការប្រឆាំង បានបង្កឲ្យមានការគាំងដំណើរមួយនៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ។ អ្នកដែលកំពុងកាន់អំណាចមិនអាចបំបាត់អ្នកប្រឆាំង ឯអ្នកដែលកំពុងតស៊ូមិនអាចធ្វើឲ្យប្រព័ន្ធគ្រប់គ្រងចុះញ៉ម ។ ដូច្នេះជម្រើសតែមួយគត់ដែលកើតចេញពីទុគ្រោះនេះ គឺត្រូវសម្រេចនូវស្ថានភាពឈ្នះៗតាមរយៈការចរចានិងការសម្របសម្រួល ។ ការផ្តល់ឲ្យនិងការទទួលយកដែលតម្រូវឲ្យមាននោះ មានទំនាក់ទំនងវែងឆ្ងាយជាមួយគណៈកម្មាការស្វែងរកការពិតនិងការផ្សះផ្សា ។

«ខ»ចុងបញ្ចប់សរសេរឡើងនៅឯចលនាតស៊ូចុងក្រោយដើម្បីត្រួសត្រាយផ្លូវសម្រាប់រដ្ឋធម្មនុញ្ញអន្តរកាលដែលបានអនុម័តដោយភាគីទាំងអស់រយៈពេល៨ឆ្នាំមុន បានផ្តល់ឲ្យមានការលើកលែងទោសក្នុងរឿងក្តីដែលទាក់ទងនឹងនយោបាយ ។ ការកំណត់ករណីណាដែលត្រូវលើកលែងទោស បានក្លាយទៅជាប្រធានបទនៃការពិភាក្សាដ៏ក្តៅគគុក ។ ការដឹកនាំប្រទេសជាតិទៅមុខឆ្ពោះទៅរកទាំងយុត្តិធម៌និងសន្តិភាពបានបដិសេធចំពោះទ្រឹស្តីដាច់ខាតក្នុងការទទួលខុសត្រូវជាខ្សែសង្វាក់ ។

ទាក់ទិននឹងយុត្តិធម៌និងការផ្សះផ្សាជាតិនៅប្រទេសអាហ្វ្រិកខាងត្បូង ខ្ញុំនឹកឃើញនូវស្ថានប័នពីរសំខាន់ៗ គឺមជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌សម័យអន្តរកាល និងវិទ្យាស្ថានដើម្បីយុត្តិធម៌និងការផ្សះផ្សា ។ ស្ថាប័នទាំងពីរនេះបាននិងកំពុងគាំទ្រកម្មវិធីយុត្តិធម៌សម័យអន្តរកាលនៅទីក្រុង ខេបថោន នៃប្រទេសអាហ្វ្រិកខាងត្បូងតាំងពីឆ្នាំ២០០២ ។ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០២ ខ្ញុំត្រូវបានជ្រើសរើសសម្រាប់កម្មវិធីអាហាររូបករណ៍ធ្វើការស្រាវជ្រាវយុត្តិធម៌អន្តរកាលនៃប្រទេសអាហ្វ្រិកនិងប្រទេសនៅអាស៊ី-អាគ្នេយ៍ ដើម្បីសិក្សានិងធ្វើការនៅប្រទេសអាហ្វ្រិកខាងត្បូងសម្រាប់រយៈពេល៦ខែ ចាប់ពីពាក់កណ្តាលខែមករាដល់ខែកក្កដា ឆ្នាំ២០០៣ ។ វិទ្យាស្ថានដើម្បីយុត្តិធម៌និងការផ្សះផ្សាដែលមានមូលដ្ឋាននៅទីក្រុង ខេបថោន នៃប្រទេសអាហ្វ្រិកខាងត្បូងនិងមជ្ឈមណ្ឌលអន្តរជាតិ ដើម្បីយុត្តិធម៌សម័យអន្តរកាលដែលមានទីតាំងនៅទីក្រុងញូវយកនៃសហរដ្ឋអាមេរិកបានធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូជាច្រើន ។ វិទ្យាស្ថានសិក្សាជាន់ខ្ពស់និងអង្គការក្រៅរដ្ឋាភិបាលជាច្រើននៅទីក្រុងខេបថោនបានសម្របសម្រួលកម្មវិធីនេះ ។

បុគ្គលិកសិក្សាទាំង២៨រូបត្រូវបានជ្រើសរើសពីតំបន់នានានៃពិភពលោក និងពីប្រទេសមួយចំនួនដូចជា អាហ្គានីស្ថាន

ភូមា ប៉ូរុនឌី កម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ទីម័រខាងកើត ហ្គាណា ឥណ្ឌូណេស៊ី ម៉ូហ្សាំប៊ិក សេរ៉ាឡេអូន អាហ្វ្រិកខាងត្បូងនិងប្រទេសហ្ស៊ីមបាវេ ។ បុគ្គលសិក្សាទាំងអស់នោះបានសិក្សាសំដៅឲ្យបានសញ្ញាប័ត្រទាក់ទងនឹងសិទ្ធិមនុស្ស និងយុត្តធម៌សម័យអន្តរកាល ដែលផ្តល់ឲ្យដោយមជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌សម័យអន្តរកាល និងវិទ្យាស្ថានដើម្បីយុត្តិធម៌និងការផ្សះផ្សា ។ បុគ្គលិកសិក្សាក៏បានចូលរួមសិក្សាយ៉ាងទៀងទាត់នៅសាកលវិទ្យាល័យខេបថោនដែរ ។ លើសពីនេះទៀត បុគ្គលិកសិក្សាត្រូវបានអនុញ្ញាតឲ្យចុះធ្វើកម្មសិក្សានៅតាមអង្គការក្រៅរដ្ឋាភិបាលថែមទៀត ។

វាក៏បានធ្វើឲ្យខ្ញុំនឹកឃើញដល់បុគ្គលដែលគួរឲ្យគោរពចំនួន ២រូបគឺៈ បណ្ឌិត អាឡិច បូរ៉េន ប្រធានមជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌សម័យអន្តរកាលនិងជាអតីតអនុប្រធានគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សានៅប្រទេសអាហ្វ្រិកខាងត្បូង បណ្ឌិត ឆាល វីឡាវិស៊ីនស្យូ នាយកប្រតិបត្តិនៃវិទ្យាស្ថានដើម្បីយុត្តិធម៌និងការផ្សះផ្សា និងជាអតីតនាយកផ្នែកស្រាវជ្រាវនៃគណៈកម្មការស្វែងរកការពិត និងការផ្សះផ្សា ហើយនិងសហការីរបស់បណ្ឌិតទាំងពីរ ដែលបានធ្វើឲ្យកម្មវិធីនេះកាន់តែរីកចម្រើន ។ មជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌សម័យអន្តរកាលដែលធ្វើការជាដៃគូជាមួយវិទ្យាស្ថានដើម្បីយុត្តិធម៌និងការផ្សះផ្សាបាននិងកំពុងចាត់ចែងកម្មវិធីយុត្តិធម៌សម័យអន្តរកាល ដែលជាកម្មវិធីសិក្សាស្រាវជ្រាវមួយមានទីតាំងនៅទីក្រុងខេបថោននៃប្រទេសអាហ្វ្រិកខាងត្បូងតាំងពីឆ្នាំ២០០២មកម្ល៉េះ រហូតមកដល់ពេលថ្មីៗនេះ កម្មវិធីយុត្តិធម៌អន្តរជាតិមានជាង៤០បុគ្គលិកសិក្សា ហើយកម្មវិធីនេះនឹងចាប់ផ្តើមវគ្គថ្មីនៅដើមឆ្នាំ២០០៤ ។

ដូច្នេះនៅក្នុងសំណេរនេះ ជាដំបូងខ្ញុំចង់រៀបរាប់ដោយសង្ខេបនូវបទពិសោធន៍របស់គណៈកម្មការស្វែងការពិតនិងការផ្សះផ្សានៅប្រទេសអាហ្វ្រិកខាងត្បូង ។ បន្ទាប់មកខ្ញុំចង់ពិភាក្សាអំពីអ្វីទៅជាទំនាក់ទំនងរវាងយុត្តិធម៌និងការផ្សះផ្សានៅក្នុងប្រទេសនេះ ។ ជាចុងក្រោយខ្ញុំក៏ចង់ពិភាក្សាអំពីបទពិសោធនៅក្នុងយុត្តិធម៌សម័យអន្តរកាលនៃប្រទេសអាហ្វ្រិកខាងត្បូងដែលខ្ញុំធ្លាប់ដកពិសោធន៍នៅទីនោះដែរ ។

មូលហេតុដែលខ្ញុំជ្រើសប្រធានបទនេះគឺដោយសារថា វាមានបញ្ហាសារសំខាន់ពីរស្មើគ្នា និងមិនអាចញែកចេញពីគ្នាបាន គឺ យុត្តិធម៌ និង ការផ្សះផ្សា ។ យុត្តិធម៌គ្មានការផ្សះផ្សា និងការផ្សះផ្សាគ្មានយុត្តិធម៌មិនអាចសម្រេចបាននោះទេ ។ តើប្រទេសអាហ្វ្រិកខាងត្បូងបានស្ថាបនា "ប្រជាជាតិឥន្ទធនូ" (ប្រទេសដែលលាយជាតិសាសន៍ច្រើន) ដើម្បីការផ្សះផ្សាបានកម្រិតណាហើយ?

សំណេរនេះមិនមែនចង់បង្ហាញនូវដំណោះស្រាយណាមួយឡើយ ប៉ុន្តែសង្ឃឹមថានឹងរួមចំណែកឲ្យមានការយល់ដឹងស៊ីជម្រៅអំពីដំណើរការរយៈពេលវែងក្នុងការប្រឹងប្រែងដើម្បីយុត្តិធម៌ពិតប្រាកដ និងអំពីដំណើរការនាពេលអនាគតក្នុងការផ្សះផ្សានៅអាស៊ី-អាគ្នេយ៍ទាំងមូល ពិសេសគឺប្រទេសកម្ពុជាដែលកំពុងធ្វើជាម្ចាស់សិក្ខាសាលាលើកទី៧ស្តីអំពី "ការផ្សះផ្សានៅអាស៊ីអាគ្នេយ៍" ។

### សាវតាររបស់"គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សា" នៅប្រទេសអាហ្វ្រិកខាងត្បូង

គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាត្រូវបានបង្កើតឡើងក្រោមរដ្ឋាភិបាលប្រជាធិបតេយ្យលើកទី១នៃប្រទេសអាហ្វ្រិកខាងត្បូងក្រោយការបោះឆ្នោតនៅឆ្នាំ១៩៩៤ ។ គណៈកម្មការនេះមានតួនាទីរៀបចំកត់ត្រាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរដែលបានប្រព្រឹត្តឡើងក្នុងពេលនៃ"ជម្លោះកងអតីតកាល" ធ្វើអនុសាសន៍អំពីការផ្តល់សំណងប៉ះប៉ូវចំពោះជនរងគ្រោះ និងការផ្តល់នូវការលើកលែងទោសទាក់ទងនឹង"អំពើដែលជាប់ពាក់ព័ន្ធជាមួយនឹងគោលដៅនយោបាយ" ទៅឲ្យបុគ្គលទាំងឡាយដែលបានលាតត្រដាងទាំងស្រុងនូវអ្វីដែលខ្លួនបានប្រព្រឹត្ត ។

គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាបានបោះពុម្ពផ្សាយរបាយការណ៍មួយដែលមាន៥ លេខក្នុងឆ្នាំ១៩៩៨ ដែលរួមបញ្ចូលការរកឃើញយ៉ាងល្អិតល្អន់និងអនុសាសន៍នានា ហើយកំណត់អត្តសញ្ញាណជនរងគ្រោះពីការរំលោភបំពានសិទ្ធិមនុស្សជាង២០០០០នាក់ ។ ទោះបីជាមានវិវិឌ្ឍខាងការផ្តល់អនុសាសន៍មិនមែនរូបិយវត្ថុក៏ដោយ ក៏សំណើទាមទារសំណងខាងហិរញ្ញវត្ថុនៅតែមានលេចធ្លោយ៉ាងខ្លាំង ។ ការកាត់ទោសមួយ

ចំនួនលើអតីតកម្លាំងបុគ្គលិកសន្តិសុខពីបទឧក្រិដ្ឋកម្មនៃរបប អាប៉ាថេតត្រូវបានធ្វើឡើង ។ ប៉ុន្តែមានការបរាជ័យជាដុំកំភួនក្នុងការការកាត់ទោសខ្លះក្នុងចំណោមការកាត់ទោសទាំងនោះ ។

របាយការណ៍ពីរលេខបន្ថែមទៀតដែលក្នុងចំណោមរឿងរ៉ាវផ្សេងទៀតបានផ្តល់នូវតារាងជនរងគ្រោះមួយដែលរឹតតែមានលក្ខណៈពេញលេញ ត្រូវបានបញ្ចប់នៅឆ្នាំ២០០២ ប៉ុន្តែរឿងក្តីតុលាការមួយដែលប្តឹងដោយ“គណបក្សសេរីភាពអ៊ីនកាថា” ប្រឆាំងនឹងគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាបានពន្យារពេលការបោះពុម្ពផ្សាយស្ទើរតែពេញមួយឆ្នាំ ។ គណបក្សសេរីភាពអ៊ីនកាថាបានទាំស្វែងរកវិសោធនកម្មមួយចំនួនចំពោះការរកឃើញរបស់គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាដែលវាមានការទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣ រឿងក្តីតុលាការត្រូវបានដោះស្រាយដោយមានកិច្ចព្រមព្រៀងរបស់គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាចំពោះការផ្លាស់ប្តូរបន្ទាប់បន្សំក្នុងរបាយការណ៍ ប៉ុន្តែបន្សល់ទុកការរកឃើញសំខាន់ឲ្យនៅគាំងដំណើរដោយបំបាត់ចោលនូវឧបសគ្គចុងក្រោយចំពោះការបោះពុម្ពផ្សាយនិងចំពោះការអនុវត្តន៍នៃកម្មវិធីមួយក្នុងការជួសជុលសំណងខូចខាតនានា ។

“ច្បាប់លើកកម្ពស់សាមគ្គីនិងការផ្សះផ្សាជាតិ” មានគោលបំណងបំបិទចោលនូវសៀវភៅស្តីអំពីអាប៉ាថេតនិងផ្តល់នូវៈ

ទី១...ការស៊ើបអង្កេតនិងការស្ថាបនានូវរូបភាពឲ្យបានពេញលេញតាមដែលអាចធ្វើទៅបាននូវចរិត មូលហេតុ និងវិសាលភាពនៃការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ១៩៦០ រហូតដល់កាលបរិច្ឆេទបញ្ចប់កំណត់នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញនៅក្នុងប្លុកខាងក្រោសាធារណរដ្ឋ ។ ទី២ ការផ្តល់ការលើកលែងទោសចំពោះបុគ្គលដែលបើកចំហយ៉ាងពេញទំហឹងនូវហេតុការណ៍ពាក់ព័ន្ធនឹងគោលដៅនយោបាយដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃជម្លោះក្នុងអតីតកាល ។ ទី៣ ការផ្តល់ឲ្យជនរងគ្រោះនូវឱកាសបកស្រាយការរំលោភបំពានដែលខ្លួនបានទទួលរង ។ ទី៤ ការចាត់វិធានការសំដៅផ្តល់សំណងលើការខូចខាត ការស្តារនីតិសម្បទានិងការស្ថាបនាឡើងវិញនូវសេចក្តីថ្លៃថ្នូររបស់មនុស្សដល់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស ។ ទី៥ ការរាយការណ៍ចំពោះជាតិ អំពីការរំលោភបំពាននិងជនរងគ្រោះ ។ ទី៦ ការបង្កើតអនុសាសន៍សំដៅទប់ស្កាត់អំពើរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ ទី៧ ការស្ថាបនាគណៈកម្មការស្វែងរកការពិត និងការផ្សះផ្សា គណៈកម្មាធិការរំលោភសិទ្ធិមនុស្ស គណៈកម្មាធិការលើកលែងទោស និងគណៈកម្មាធិការជួសជុលសំណងនិងស្តារនីតិសម្បទា ។ ទី៨ ការផ្តល់អំណាចប្រគល់តួនាទីនិងការដាក់កាតព្វកិច្ចទៅឲ្យគណៈកម្មការនិងគណៈកម្មាធិការនានា ។

មានចំណុចសំខាន់ៗជាច្រើននៅក្នុងច្បាប់នេះៈ ១) អំពើហិង្សាដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងខែតុលាឆ្នាំ១៩៦០ ដល់ខែឧសភា ឆ្នាំ១៩៩៤ (ថ្ងៃឡើងកាន់អំណាចរបស់ប្រធានាធិបតី ណែលសុន ម៉ាន់ដេឡា) ត្រូវបានរៀបរាប់ ។ ២)ជនរងគ្រោះត្រូវបានផ្តល់ឱកាសឲ្យបរិយាយអំពីការរងគ្រោះរបស់ខ្លួន ។ ៣) ជនដៃដល់ត្រូវតែមានវត្ថុបំណងនយោបាយនាពេលដែលធ្វើជាសមាជិកអង្គភាពនយោបាយ ឬចលនារំដោះ ឬជានិយោជករបស់រដ្ឋឬជាសមាជិករបស់អង្គភាពសន្តិសុខ ។ ៤) សេចក្តីថ្លៃថ្នូរជាមនុស្ស និងជាជនស៊ីវិលនឹងត្រូវធ្វើឲ្យមានដូចដើមវិញ និង ៥)សំខាន់បំផុតគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាបានលើកឡើងអំពីវិធានការដើម្បីទប់ស្កាត់ការរំលោភសិទ្ធិមនុស្សក្នុងពេលអនាគត ។

របាយការណ៍របស់គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាត្រូវបានចែកផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨ ។ របាយការណ៍ប្រាំលេខនេះបានលាតត្រដាងអំពើឃោរឃៅផ្តល់ការស្តារលទ្ធភាពពលកម្មជនរងគ្រោះ ហើយបានក្លាយទៅជាមូលដ្ឋានសម្រាប់ការលើកលែងទោសឲ្យជនដៃដល់ ។ របាយការណ៍អំពីរបប អាប៉ាថេត នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូងបានធ្វើឲ្យជនរងគ្រោះមានអារម្មណ៍ធូរស្រាល ដែលនាំឲ្យមានការបញ្ចប់ទំព័រព្រៃផ្សៃនៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសអាហ្វ្រិកខាងត្បូង ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារសាក្សីចេះតែលេចមុខជាបន្តបន្ទាប់ ប្រវត្តិសាស្ត្រនៃរបប អាប៉ាថេត នឹងត្រូវកែសម្រួលឡើងវិញនៅពេលអនាគត ។ ចំណុចទាំងអស់នៅក្នុងច្បាប់នេះ

ប្រែប្រួលទៅតាមទំនាក់ទំនងរវាងតួនាទីទាំងបីៈ ការលាតត្រដាងទាំងស្រុងនូវការពិត ការលើកលែងទោសចំពោះជនដែលរៀបរាប់ការពិតទាំងស្រុងនិងការប៉ះប៉ូវនិងការស្តារលទ្ធភាពរបស់ជនរងគ្រោះឬសមាជិកគ្រួសារជនរងគ្រោះ ។ ប្រសិនបើគ្មានអន្តរាគមន៍ជាទូទៅ ការផ្សះផ្សាត្រូវចំណាយពេលជាច្រើនឆ្នាំ ឬច្រើនជំនាន់ទើបអាចសម្រេចបាន ។ ដើម្បីធ្វើឲ្យប្រទេសអាហ្វ្រិកខាងត្បូងនៅតែមានឧត្តមភាពនៅក្នុងតំបន់ ដំណើរការនេះត្រូវតែចាប់ផ្តើមឲ្យបានឆាប់និងប្រលបដោយប្រសិទ្ធភាព ។

ព្រះចៅអធិការ ដឹសមុន ទូទូ គឺជាអតីតប្រធានគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សា ។ សមាជិកទាំង១៧ របស់គណៈកម្មការនេះត្រូវបានជ្រើសចេញពីគ្រប់មជ្ឈដ្ឋានសង្គមអាហ្វ្រិកខាងត្បូងហើយដឹកនាំគណៈកម្មាធិការបីគឺៈ គណៈកម្មាធិការលើកលែងទោស គណៈកម្មាធិការការរំលោភសិទ្ធិមនុស្សនិងគណៈកម្មាធិការសំណងនិងស្តារលទ្ធភាពការងារ ។

តាមរយៈអ្នកនិពន្ធដ៏មានទេពកោសល្យរបស់ប្រទេសអាហ្វ្រិកខាងត្បូងឈ្មោះ ចូនី ស្ទេនបឺក ប្រវត្តិសាស្ត្រសង្គមនៃរបបអាប៉ាថេតរបស់អាហ្វ្រិកខាងត្បូងបច្ចុប្បន្នគឺជាដំណើររឿងនៃ «ភាពរំជើបរំជួលដែលមនុស្សត្រូវបានបណ្តេញឲ្យទៅរស់នៅពាសវាលពាសកាលនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង និងត្រូវបង្ខំឲ្យរស់នៅក្នុងទីលំនៅមិនសមរម្យ ពោរពេញទៅដោយអំពើឃោរឃៅ និងការរំលោភបំពាន» ។

## យុត្តិធម៌និងការផ្សះផ្សានៅប្រទេសអាហ្វ្រិកខាងត្បូង

### យុត្តិធម៌

បរិស្ថាននៃយុត្តិធម៌នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូងផ្តល់នូវការពិនិត្យពិស្តារមួយទៅលើនយោបាយរបស់ប្រទេសអាហ្វ្រិកខាងត្បូងនៅក្រោយសម័យរដ្ឋាភិបាលអាប៉ាថេត រយៈពេលដប់ឆ្នាំ ។ វាផ្តល់នូវទស្សនៈសំខាន់ទីមួយអំពីទ្រឹស្តីនិងការអនុវត្តន៍បរិស្ថាននៃយុត្តិធម៌នៅអាហ្វ្រិកខាងត្បូង ។ លើសពីនេះ វាបានផ្តល់នូវការវិភាគជាគោលមួយនៃចលនាបរិស្ថានយុត្តិធម៌សព្វថ្ងៃក៏ដូចជាការត្រួតពិនិត្យទៅលើទិសដៅដែលវាអាចឆ្ពោះទៅកាន់នៅពេលអនាគត ។ ចាប់ផ្តើមឡើងពីប្រវត្តិនៃចលនាបរិស្ថានយុត្តិធម៌នៅក្នុងប្រទេស វាស្វែងរកសំណួរគ្រប់ជ័ណ្ឌនិងដាក់ស្តែងមួយចំនួន ។ តើយុត្តិធម៌បរិដ្ឋានមានទំនាក់ទំនងជាមួយការមិនយកចិត្តទុកដាក់និងភាពក្រីក្រនៅអាហ្វ្រិកខាងត្បូងយ៉ាងដូចម្តេចខ្លះ? តើបរិស្ថានយុត្តិធម៌និងបរិស្ថាននៃគំនិតមានទំនាក់ទំនងជាមួយគ្នាយ៉ាងដូចម្តេចខ្លះ? តើប្រព័ន្ធច្បាប់ជាឧបករណ៍ដ៏ត្រឹមត្រូវសម្រាប់ដោះស្រាយឲ្យមានភាពស្មើគ្នាផ្នែកបរិស្ថានឬទេ? តើជាតិសាសន៍វណ្ណៈសង្គម និងភេទ មានទំនាក់ទំនងគ្នាយ៉ាងដូចម្តេចនៅក្នុងបរិបទបរិស្ថានអាហ្វ្រិកខាងត្បូង?

បរិស្ថាននៃយុត្តិធម៌នៅប្រទេសអាហ្វ្រិកខាងត្បូងជាការស្រាវជ្រាវកាន់តែរឹងមាំទៅលើភាពមិនយុត្តិធម៌ផ្នែកបរិស្ថាននៅក្នុងប្រទេស និងលាយឡំគ្នាជាមួយរឿងរ៉ាវជីវិតពិតនៃការតស៊ូដោយកម្មករនិងសហគមន៍ដើម្បីការផ្លាស់ប្តូរបរិស្ថាន ។ វាជាធនធានមិនអាចកាត់ថ្លៃបានមួយសម្រាប់ប្រជាជនអាហ្វ្រិកខាងត្បូងនិងសហគមន៍អន្តរជាតិ ដែលចាប់អារម្មណ៍នឹងការកើនឡើងនិងកាន់តែកើនឡើងជាលក្ខណៈសកលនៃចលនាបរិស្ថានយុត្តិធម៌ ។

យុទ្ធសាស្ត្រនយោបាយសម័យអន្តរកាលនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូងបានក្លាយទៅជាចំណុចចាប់អារម្មណ៍មួយរបស់អន្តរជាតិ ដោយសារគណៈកម្មការស្វែងរកការពិត និងការផ្សះផ្សាបានក្លាយទៅជាចំណុច(យោងមូលដ្ឋាន) នៃការជជែកពិភាក្សាទូទៅថាតើសង្គមដែលរងការបែកបាក់ធ្ងន់ធ្ងរអាចកែប្រែការរំលោភបំពានឲ្យទៅជាយុត្តិធម៌សម័យអន្តរកាលការកសាងលទ្ធិប្រជាធិតេយ្យ និងការការពារសិទ្ធិមនុស្សតាមរបៀបណា?

### ការផ្សះផ្សា

មេដឹកនាំនៃរបបដឹកនាំផ្តាច់ការយោធាដែលរំលោភបំពានប្រជាជននៅអាមេរិកកណ្តាលនិងអាមេរិកឡាទីនពន្យល់ថា ការផ្សះផ្សាជា «ការអត់ឱននិងបំភ្លេចចោល» ។ ការបង្ខំឲ្យបំភ្លេចចោលអតីតកាលដែលចាត់ទុកជាការផ្សះផ្សា គួរតែត្រូវបដិសេធដោយជនគ្រប់រូបដែលទទួចចង់បានសន្តិភាពយូរអង្វែង ។

ការផ្សះផ្សាពិតប្រាកដតម្រូវឲ្យមានការត្រួតពិនិត្យដ៏ស្មោះត្រង់ទៅលើយុត្តិធម៌ ដើម្បីបង្ហាញនិងកត់សម្គាល់ឧក្រិដ្ឋកម្មពីអតីតកាល ។ ជាជាងការបំបិទមាត់និងមិនយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ការផ្សះផ្សាទាមទារឲ្យសម្រែករបស់ជនរងគ្រោះត្រូវគេស្តាប់ឮ ហើយការឈឺចាប់របស់ជនរងគ្រោះត្រូវ

ទទួលស្គាល់ ។

យុត្តិធម៌និងការទទួលខុសត្រូវគឺជាធាតុមូលដ្ឋាននៃការផ្សះផ្សាពិតប្រាកដ ។ ការតបស្នងប៉ះប៉ូវគួរតែត្រូវបានផ្តល់ទៅឲ្យជនរងគ្រោះមិនមែនគ្រាន់តែដើម្បីសងសម្រាប់ការខាតបង់របស់ជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែដើម្បីផ្ញើជាសារមួយមានអត្ថន័យថាការរំលោភបំពានមិនអាចទទួលយកបានតទៅទៀតទេ ។

តាមរយៈការទទួលយកនូវការដាក់ទណ្ឌកម្មនិងការបញ្ជាក់នូវការសោកស្តាយ ផ្លូវវិក បានត្រួសត្រាយផ្លូវឲ្យមានការផ្សះផ្សាពិតប្រាកដនៅក្នុងតំបន់ ។ ការផ្សះផ្សាតម្រូវឲ្យមាន "ការផ្លាស់ប្តូរឆ្នាំចាស់" ។ នៅក្នុងសង្គមដែលមេដឹកនាំពុករលួយបានបង្កើតឲ្យមានស្ថាប័នពុករលួយជាច្រើន សន្តិភាពយូរអង្វែងមួយនឹងមិនកកើតទេ លុះត្រាតែនគរបាល យោធា តុលាការ និងស្ថាប័នផ្សេងទៀតនៃរដ្ឋាភិបាលឆ្លងកាត់កំណែទម្រង់ជាមូលដ្ឋានសិន ។

ជនដែលបន្តក្តោបក្តាប់អភ័យឯកសិទ្ធិលើសលប់ក្រោយពេលមានជម្លោះ តែងតែមិនយល់ថា ការផ្សះផ្សាបង្រួបបង្រួមជាតិមិនអាចឋិតថេរបាននៅក្នុងករណីមានវិសមភាពនៃសិទ្ធិជាបន្តបន្ទាប់ ។ គ្មានអ្វីដែលអាចអត់ឱនឲ្យមេដឹកនាំដែលមិនខ្វាយខ្វល់ចំពោះលទ្ធផលនៃទង្វើរបស់ខ្លួនទេ ។ នយោបាយគ្មានឧត្តមគតិនិងមិនបម្រើសង្គមរបស់ប្រធានាធិបតី រ៉ូបឺត មូហ្គាប៊ី នៅក្នុងប្រទេសហ្ស៊ីមបាវេ នឹងត្រូវទទួលស្គាល់ពីមជ្ឈដ្ឋានផ្សេងៗតិចជាងនេះ ប្រសិនបើបន្ទាប់ពីទទួលបានឯករាជ្យ ជនជាតិស្បែកសប្រកាន់យកទ្រឹស្តីទំនើបជាងបច្ចុប្បន្នចំពោះការបែងចែកទ្រព្យសម្បត្តិដីស្មើភាពគ្នាមួយ ។

ក្នុងករណីនេះ គួរឲ្យអស្ចារ្យណាស់ដែលប្រទេសអាហ្វ្រិកខាងត្បូងបានធ្វើដំណើរឆ្ពោះទៅមុខយ៉ាងឆ្ងាយក្នុងការកសាង "ប្រជាជាតិឥន្ទធនូ" មួយដែលប្តូរផ្តាច់ចំពោះការផ្សះផ្សាបង្រួបបង្រួមជាតិ ។ ប៉ុន្តែ ប្រទេសហ្ស៊ីមបាវេគួរតែក្លាយទៅជាមេរៀនមួយសម្រាប់ជនជាតិស្បែកសដែលនៅតែបន្តគ្រប់គ្រងទ្រព្យសម្បត្តិភាគច្រើនរបស់ប្រទេសអាហ្វ្រិកខាងត្បូង ។ ការផ្សះផ្សាពិតប្រាកដតម្រូវឲ្យមានការលះបង់ខ្ពស់ដែលរួមទាំងការព្យាយាមលុបបំបាត់ចោលនូវភាពមិនស្មើសិទ្ធិគ្នាដែលចេះតែបន្តកើតមាននៅពេលដែលការប្រយុទ្ធគ្នាត្រូវបានបញ្ចប់ ។

ការផ្សះផ្សាយូរអង្វែងតម្រូវឲ្យមានកំណែទម្រង់ច្បាប់នយោបាយ និងសេដ្ឋកិច្ច ជាទ្រង់ទ្រាយធំ ។ ប៉ុន្តែធ្វើដូច្នេះបានអាស្រ័យទៅលើសកម្មភាពរបស់មេដឹកនាំដែលមានតួនាទីសំខាន់នៅក្នុងជម្លោះ ។ មេដឹកនាំដែលមានចក្ខុវិស័យខ្ពស់ដូចជា ណែលសុន ម៉ាន់ដេឡា និង អ៊ុងសាន ស៊ូជី បានបញ្ជាក់នូវសន្តានចិត្តល្អទោះជាមេដឹកនាំទាំងពីររូបនេះមានឱកាសទាមទារនូវការសងសឹកវិញក៏ដោយ ។ ប៉ុន្តែការកើនឡើងនៃភាពស្និទ្ធស្នាលគ្នានឹងមិននាំទៅរកការផ្សះផ្សាទេ លុះត្រាតែសប្បុរសធម៌នេះត្រូវបានតបស្នងវិញដោយការព្យាយាមព្យាបាលរបួសចាស់នៃជម្លោះដោយជនដែលបានប្រព្រឹត្ត ។

## យុត្តិធម៌សម័យអន្តរកាលនៅអាហ្វ្រិកខាងត្បូង

ដូចដែលនាយករដ្ឋមន្ត្រីស៊ុីស លោក ហ្គោរ៉ែន ជីសុន បានរៀបរាប់ខាងលើ ការផ្សះផ្សារាប់បញ្ចូលទាំងការទាមទារឲ្យមាន"យុត្តិធម៌សម័យអន្តរកាល"ដែលអាចជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស ។ ហេតុដូច្នេះតើ "យុត្តិធម៌សម័យអន្តរកាល"មានអត្ថន័យដូចម្តេច? តើ"យុត្តិធម៌សម័យអន្តរកាល"មានតួនាទីយ៉ាងដូចម្តេចសម្រាប់ប្រទេសអាហ្វ្រិកខាងត្បូងនៅក្នុងសង្គមបែកបាក់មួយ?

នៅក្នុងសង្គមអន្តរកាល "យុត្តិធម៌សម័យអន្តរកាល" ត្រូវបានពន្យល់ខុសគ្នាពីបុគ្គលមួយទៅបុគ្គលមួយទៀត ។ ឧទាហរណ៍ ១) ជាគំរូមួយដែលផ្តោតការយកចិត្តទុកដាក់ទៅលើប្រទេសដែលបានលេចមុខចេញពីការរំលោភបំពានសិទ្ធិមនុស្សនៅក្រោមរបបដឹកនាំផ្តាច់ការមួយ និងរបៀបដែលប្រទេសទាំងនេះស្វែងរកយុត្តិធម៌ ។ ២) ជាស្ថានការណ៍មួយដែលអាស្រ័យទៅលើល្បាយមិនសព្វសាច់រវាងការយល់ឃើញដ៏ឈឺចាប់និងក្តីសង្ឃឹមមិនងាយទទួលបាន ។ ៣) ជាលទ្ធិប្រជាធិបតេយ្យថ្មីងាយបែកបាក់ និងមិនពេញលេញដែលបានឬកំពុងប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីដោះស្រាយភាពអយុត្តិធម៌ពីអតីតកាល ។

ការជជែកវែកញែកបែបក្រុបខ័ណ្ឌ ឬដែលមានបំណងធ្វើតាមទ្រឹស្តី ក្លាយទៅជាការជជែកដោយគ្មានទ្រឹស្តីប្រសិនបើត្រូវដាក់បញ្ចូលទៅក្នុងភាពគ្មានអ្វីទាំងអស់ ។ សូមលើកជាឧទាហរណ៍

អំពីការពិភាក្សាគឺសរសេរដោយសាស្ត្រាចារ្យ ដោយអានអូរិន លីឌីរ ដែលមានការចាប់អារម្មណ៍ទៅលើយុត្តិធម៌សម័យអន្តរកាល និង កាលូស និណូ ដែលជាមន្ត្រីជួរការសំខាន់ម្នាក់នៅក្នុងរដ្ឋាភិបាលរបស់លោក រ៉ាអ៊ូល អាល់ហ្វុនស៊ីន នៅក្នុងប្រទេសអាហ្សង់ទីន នៅពេលដែលរដ្ឋាភិបាលនេះបានប្រឹងប្រយុទ្ធទល់នឹងកេរដំណែលនៃរបបយោធាក្នុងអាណត្តិមុន ។ នៅក្នុងអត្ថបទដ៏មានអានុភាពមួយដែលបានបោះពុម្ពនៅក្នុងឆ្នាំ១៩៩១ អូរិន លីឌីរ បានគាំទ្រចំពោះការកាត់ទោសឧក្រិដ្ឋជន ដោយលើកហេតុផលថា ការកាត់ទោសបែបនោះគឺតម្រូវឲ្យមានដោយច្បាប់អន្តរជាតិ ហើយ“ពីព្រោះតែការកាត់ទោសធានាឲ្យបាននូវអាទិភាពនៃសិទ្ធិនិងតម្លៃ រដ្ឋាភិបាលគួរទទួលយកនូវការប្រថុយប្រថានពីការកាត់ទោស រួមទាំងការមិនពេញចិត្តពីអង្គភាពយោធាផង” ។

នៅពីក្រោយអត្ថបទសិក្សានៃ“យុត្តិធម៌សម័យអន្តរកាល” និងនៅពីក្រោយការជជែកពិភាក្សារវាង អូរិន លីឌីរ និង និណូ ដែលសាស្ត្រាចារ្យ កាន់ដឺរ អាស្នាល់ បានសង្ខេបទាក់ទងនឹងបញ្ហាពីរគឺនយោបាយមិនប្រាកដនិយម និងនយោបាយប្រាកដនិយម ។ ចេញហួសពីចំណុចនៃការពិភាក្សាវែកញែកជាក់ស្តែងដែលបែងចែកពួកគេគឺជាសារប្រយោជន៍ចម្បងនៃការពិភាក្សាវែកញែក ។ អូរិន លីឌីរជឿជាក់ថា“រាល់ការពិពណ៌នា”អំពីកាតព្វកិច្ចច្បាប់អន្តរជាតិរបស់ជនប្រឆាំងនឹងរដ្ឋាភិបាលអាជ្ញាយុកាលរបស់របបគាបសង្កត់បាត់បង់បន្តិចថែមទៀត ដែលធ្វើឲ្យមានការពេញចិត្តនិងការមិនដឹងខ្លួន ។ “ករណីកិច្ចច្បាប់មួយបង្កើតដើម្បីកាត់ទោសការរំលោភបំពានសិទ្ធិមនុស្សប្រព្រឹត្តឡើងនៅក្រោមរបបមុន គឺជាឧបករណ៍ដ៏រេចរឹលពេកសម្រាប់ជួយរដ្ឋាភិបាលក្រោយដែលត្រូវតែតទល់នឹងភាពស្មុគស្មាញក្នុងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យសាជាថ្មី” ។

ទាក់ទិនទៅនឹងភាពស្មុគស្មាញនៃសម័យអន្តរកាលរបស់ប្រទេសអាហ្វ្រិកខាងត្បូង ប្រវត្តិនៃរបបអាប៉ាថេតមានដំណាក់កាលជាច្រើនដែលយើងដឹងច្បាស់ ដែលបន្តជាមូលដ្ឋានគ្រឹះចាំបាច់សម្រាប់រាល់ការពិភាក្សាអំពីយុត្តិធម៌សម័យអន្តរកាលនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ។ ទីមួយជ័យជម្នះនៅក្នុងការបោះឆ្នោតឆ្នាំ១៩៤៨ដ៏ចង្អៀតរបស់“គណបក្សជាតិ”បានចាប់ផ្តើមដំណាក់កាលថ្មីមួយនៃការពង្រឹងនិងការប្រាប់ជាសញ្ញា នៅពេលដែលមតិភាគច្រើននៃការបោះឆ្នោត ដែលមានតែជនជាតិស្បែកសអាចចូលរួមរបស់រដ្ឋាភិបាល អាប៉ាថេត ត្រូវបានទទួលតាមរយៈការបញ្ចូលគ្នានៃច្បាប់រដ្ឋធម្មនុញ្ញលម្អៀងនិងការទាមទារដោយជនស្បែកសអំពីការបោះឆ្នោតរបស់គណបក្សជាតិ ។ បន្ទាប់មកទៀត ការតវ៉ារបស់ពលរដ្ឋចំពោះការដឹកនាំរបស់រដ្ឋា-ភិបាលអាប៉ាថេត នៅក្នុងទសវត្សឆ្នាំ១៩៥០ ត្រូវបានទប់ស្កាត់តាមរយៈការហាមឃាត់មិនឲ្យមានចលនារំដោះ រួមទាំងបិទអង្គការ “សមាជជាតិអាហ្វ្រិក” នៅក្នុងឆ្នាំ១៩៦០ផង ។ ក្នុងដំណាក់កាលនេះសកម្មភាពសម្ងាត់ មើលពីក្រៅហាក់មានភាពស្ងប់ស្ងៀម ។ ក្បាលម៉ាស៊ីនសន្តិសុខរបស់ អាប៉ាថេត បានមានប្រៀបជាង ។ មកដល់ដើមទសវត្សរ៍ឆ្នាំ១៩៧០ របបអាប៉ាថេតដ៏មានអំនួតបានចាប់ផ្តើមវាយប្រហារដោយយុត្តិសាស្ត្រ នៅក្នុងទ្វីបអាហ្វ្រិកនិងនៅទ្វីបផ្សេងទៀត ។ ដំណាក់កាលដែលមើលទៅមានភាពនឹងនរនេះត្រូវបានបង្អាក់ដោយការបះបោររបស់និស្សិតនៅក្នុងឆ្នាំ១៩៧៦ នៅសូវេតូ ដែលជាព្រឹត្តិការណ៍មួយចាប់អន្ទ្រេនប្រទេសអាហ្វ្រិកខាងត្បូងឲ្យញាប់ញ័រជាងនៅប្រទេសបារាំងកាលពីឆ្នាំ១៩៦៨ទៅទៀត ។ ចេញពីដំណាក់កាលនេះ ទោះជាមានកងកម្លាំងគាបសង្កត់របស់អង្គភាពសន្តិសុខនៃរបបអាប៉ាថេតក៏ដោយ ក៏មានការតវ៉ាមួយបានកើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ហើយ“ចលនាប្រជាធិបតេយ្យរួបរួម” បានប្រកាសគោលដៅជាពាក្យស្លោកមួយដែលមានអត្ថន័យថា “ដើម្បីធ្វើឲ្យប្រទេសអាហ្វ្រិកខាងត្បូងមិនអាចគ្រប់គ្រងបាន” ។

លីអូណែល អាប្រាហាំ តវ៉ាអំពីអ្វីដែលគាត់មើលឃើញថាជាការគាំទ្រជាសកលចំពោះនយោបាយជាងគាំទ្រការពិតនៅក្នុងទម្រង់ជាការអត់ឱនទោសដែលត្រូវ “ផ្តល់ឲ្យជនដែលបម្រើមូលហេតុនយោបាយដោយជនដែលជំរុញដោយមូលហេតុនយោបាយ” ។ នេះជាការព្រួយបារម្ភមួយដែលដំណើរការយុត្តិធម៌សម័យអន្តរកាលដ៏មានប្រសិទ្ធភាពមួយត្រូវតែដោះ-ស្រាយឲ្យបានថាៈ គណៈកម្មការស្វែងរកការពិតគឺមិនត្រូវបានបង្កើតឡើងដោយការឃុបឃិតជាមួយសត្រូវដើម្បីផ្តល់ឲ្យជនដៃ

ដល់នូវការអត់ឱនទោសដើម្បីបញ្ចប់រឿងនោះទេ ។

ប្រធានាធិបតីរបស់ប្រទេសអាហ្វ្រិកខាងត្បូង លោក ថាបូ បេគី ពេញចិត្តនឹងយកសម្តីរបស់ លាំងស្តុន ហ៊្យូ កវី ជនជាតិអាមេរិកស្បែកខ្មៅមកនិយាយ ដែលបានរំឭកយើងអំពីអ្វីដែលកើតឡើងចំពោះសុបិនដែលមិនបានសម្រេចៈ វាផ្ទុះឡើង ។ ដូច្នេះ ប្រទេសអាហ្វ្រិកខាងត្បូងត្រូវតែដោះស្រាយនូវភាពមិនស្មើសិទ្ធិគ្នា ដែលបន្សល់ពីរបបមុនហើយដែលមិនអាចសម្រេចភារកិច្ចនេះនៅក្នុងបរិយាកាសប្រឈមមុខគ្នាបានឡើយ ។ ប៉ុន្តែភ្លាមៗនោះដែរ ការល្បងកម្លាំងនេះបានដាក់គំនិតបង្កើតតុលាការព្រហ្មទណ្ឌនៅក្នុងពន្លឺថ្មីមួយ ។ តុលាការព្រហ្មទណ្ឌនឹងមិននាំមកវិញនូវការបាត់បង់សិទ្ធិដល់អ្នកដែលត្រូវរំលោភពីអតីតកាលនោះទេ ។ ទោះបីជាតុលាការនេះអាចកំញើញបុធ្វើឲ្យញញើតដល់ឧក្រិដ្ឋជនផ្សេងទៀតនៅក្នុងកងកម្លាំងប្រដាប់អាវុធដែលចង់ប្រកាសខ្លួនថាជាអ្នកដឹកនាំថ្មី តាមរយៈការធ្វើរដ្ឋប្រហារក៏ដោយក៏តុលាការនេះ មិនអាចដោះស្រាយស្ថានភាពដែលក្នុងនោះសុបិនត្រូវបានរារាំងមិនឲ្យក្លាយទៅជាការពិតដែលការផ្ទុះមួយអាចកើតឡើងដែរ ។ នេះជាមូលហេតុដែលគណៈកម្មការស្វែងរកការពិតបានពិភាក្សាវែកញែកតាំងពីដំបូងបង្អស់នៅក្នុងសម័យអន្តរកាល ។ សាស្ត្រាចារ្យ កាន់ដឺរ អាស្មាល់ ជាលក្ខណៈបុគ្គលបានផ្សារភ្ជាប់គំនិតនៃគណៈកម្មការស្វែងរកការពិតជាមួយសំណងនិងយុត្តិធម៌សង្គម ។ ប្រធានបទមួយដែលសាស្ត្រាចារ្យរូបនេះនិងសហនិពន្ធរបស់លោកបានយកទៅបកស្រាយនៅក្នុងសៀវភៅស្តីអំពីយុត្តិធម៌សម័យអន្តរកាលនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ។ សហនិពន្ធទាំងពីររូបនេះបានទាញហេតុផលថា យុត្តិធម៌សម័យអន្តរកាលមិនមែនគ្រាន់តែជារឿងកាត់ទោសឧក្រិដ្ឋជនប៉ុណ្ណោះនោះទេ វាត្រូវតែជាផ្នែកមួយនៃដំណើរការជាលក្ខណៈប្រព័ន្ធមួយនៃ÷ ១) ការទទួលស្គាល់ចំពោះភាពមិនស្របច្បាប់របស់របបអាប៉ាថេត ២) ការទទួលស្គាល់អំពីតម្រូវការសម្រាប់សកម្មភាពកែតម្រូវមួយដើម្បីព្យាបាលអតីតកាលនៃសង្គមសេដ្ឋកិច្ចពោរពេញទៅដោយការប្រកាន់ពូជសាសន៍របស់របបអាប៉ាថេត ៣) ការបង្កើតឡើងនូវសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ដែលមានន័យថាជាការធ្វើកំណែទម្រង់ប្រព័ន្ធព្រហ្មទណ្ឌនិងយុត្តិធម៌ ឲ្យចេញឆ្ងាយពីការបណ្តែតបណ្តោយឲ្យចំណុចទាំងនេះជាអ្នកកំណត់ច្បាប់នៅក្នុងសម័យអន្តរកាល ៤) ការដាក់សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិទៅក្នុងច្បាប់ដែលមានន័យថាជាការបែងចែកទ្រព្យសាជាថ្មី ៥) ការទទួលស្គាល់ដោយមោះមុតនូវការទទួលខុសត្រូវរួមគ្នាដោយជនដែលមានអភ័យឯកសិទ្ធិនៅក្នុងរបបអាប៉ាថេត ដែលភាគច្រើននៃអ្នកទាំងនេះបានគាំទ្រការបោះឆ្នោតដែលមានតែជនស្បែកសប៉ុណ្ណោះមានសិទ្ធិចូលរួមអស់រយៈពេលជាងបួនទសវត្សរ៍ និង៦) ការទទួលស្គាល់ចំពោះការទាមទាររបស់សហគមន៍ជាតិនិងអន្តរជាតិ ដោយរួមទាំងបទដ្ឋាននៃច្បាប់អន្តរជាតិដែរ ។ យុត្តិធម៌សម័យអន្តរកាលមានច្រើនទម្រង់ ។ យើងមិនអាចគិតថាដំណើរការនៃការកាត់ទោសឧក្រិដ្ឋជនធ្វើឲ្យបាត់បង់អស់នូវមធ្យោបាយសម្រេចយុត្តិធម៌បានទេ ។

សាស្ត្រាចារ្យ ឆាល វីឡា វីសិនស្យូ អតីតប្រធានផ្នែកស្រាវជ្រាវរបស់គណៈកម្មការស្វែងរកការពិតរបស់ប្រទេសអាហ្វ្រិកខាងត្បូង បានកត់សម្គាល់យ៉ាងហោចណាស់៥ទម្រង់ផ្សេងៗគ្នាដែលយុត្តិធម៌អាចកើតមាន រួមទាំង "យុត្តិធម៌ជាការអះអាងអំពីសេចក្តីថ្លៃថ្នូររបស់មនុស្ស" ។ ទាំងនោះគឺៈ ១) យុត្តិធម៌ហាមប្រាមដែលផ្តល់ឧទាហរណ៍អំពីអ្វីដែលបានកើតឡើងពីអតីតកាល និងការដាក់ទោស ២) យុត្តិធម៌សំណងដែលតម្រូវឲ្យអ្នកស្នងអំណាចពីរបបចាស់ចូលរួមនៅក្នុងវិធានការបដិទានបច្ចុប្បន្ន ៣) យុត្តិធម៌កសាងដែលមានបំណងព្យាបាលសតិអារម្មណ៍មិនប្រក្រតីរបស់ជនរងគ្រោះនិងជនដៃដល់ ៤) យុត្តិធម៌ជាមធ្យោបាយនៃការអះអាងអំពីភាពថ្លៃថ្នូររបស់មនុស្សដែលទទួលស្គាល់នូវភាពស្មើសិទ្ធិគ្នារបស់មនុស្សម្នាក់ៗ ពិសេសនៅកន្លែងដែលអំពើឃោរឃៅសម័យមុនបានកើតឡើងចំពោះក្រុមមនុស្ស និង៥) យុត្តិធម៌ជាការប្រកាសអំពីភាពឥតទោសរបស់ជនដែលត្រូវចោទប្រកាន់ជាភេរវករឬចារបុរស ។

ប្រសិនបើយើងប្រកាន់យកទស្សនៈរិះគន់សមល្មមអំពីទម្រង់ផ្សេងៗនៃយុត្តិធម៌ យើងនឹងចាប់ផ្តើមឃើញថា គណៈកម្មការស្វែងរកការពិត ប្រសិនបើអនុវត្តឲ្យបានត្រឹមត្រូវជាទម្រង់មួយនៃការទាមទាររកយុត្តិធម៌ជាជាងការលះបង់របស់វា ដូចដែលសាស្ត្រាចារ្យ អាន់ដ្រេ ឌូ តយ របស់សាកលវិទ្យាល័យ

ខេប ថៅន បានអះអាង ។ លើសពីនេះ អង្គការសិទ្ធិមនុស្សមួយចំនួនបានទទួលស្គាល់ថា ធម្មជាតិនៃការទទួលខុសត្រូវជាទស្សនៈមួយ(ដែលស្របតាមតែខុសពីយុត្តិធម៌) គឺបត់បែនដែរ ។ ឧទាហរណ៍ វប្បធម៌នៃការរួចទោសអាចចៀសវាងបាន ហើយការទទួលខុសត្រូវ ត្រូវបានទទួលតាមរយៈការលាតត្រដាងជាសាធារណៈនូវអំពើឃោរឃៅ ។ ដោយសារស្ថានការណ៍នៅក្នុងសម័យអន្តរកាលមានភាពសាំញ៉ាំ ការធ្វើឲ្យសាមញ្ញដែលទាមទារដោយពួកអភិរក្សក្រុមព្រហ្មទណ្ឌចាស់ មិនមានប្រយោជន៍នៅក្នុងសម័យអន្តរកាលនៅប្រទេសអាហ្វ្រិកខាងត្បូងក៏ដូចជានៅក្នុងប្រទេសផ្សេងទៀតដែរ ។

តាមរយៈសាស្ត្រាចារ្យ អាន់ដ្រេ ឌូ តយ "ទស្សនៈរបស់គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាចំពោះយុត្តិធម៌នៅក្នុងសម័យអន្តរកាលមិនត្រូវការឲ្យបកស្រាយថាជាការសម្រុះសម្រួលផ្នែកសីលធម៌ ការលះបង់យុត្តិធម៌ដើម្បីទទួលយកការពិត និងការផ្សះផ្សានោះទេ" ។ លើសពីនេះ តាមរយៈ ហ្គ្រេប៊ីល"វាជាការឆ្គាំឆ្គងប្រសិនបើយើងឲ្យតម្លៃយុត្តិធម៌តាមបែបតុលាការនូរឹមបឺក និងអ្វីដែលប្រហាក់ប្រហែលនឹងយុត្តិធម៌តាមបែបគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សា" ។ ប៉ុន្តែវាមិនមែនពិបាករកនោះទេនូវទស្សនៈបែងចែកដាច់ណាត់រវាងជនរងគ្រោះនិងជនដៃដល់នៅក្នុងការគិតរបស់អ្នកដែលបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ។ អតីតអនុប្រធាន"គណៈកម្មការប្រទេសអាហ្វ្រិកខាងត្បូង" លោកអាឡិច បូរ៉ែន បានបកស្រាយថា "ភាពតានតឹងដ៏ធំនៅក្នុងយុត្តិសម័យអន្តរកាលកើតឡើងរវាងនយោបាយនៃការសម្រុះសម្រួលនិងទស្សនៈយុត្តិធម៌បែបថ្មី" ។

ដូចលោកប្រធានាធិបតី ណែលសុន ម៉ាន់ដេឡា បានកត់សម្គាល់នៅក្នុងអារម្ភកថារបស់លោកនៅក្នុងសៀវភៅរបស់ នៀល គ្រីត មានចំណងជើងថា "យុត្តិធម៌សម័យអន្តរកាល"ថា "សម័យអន្តរកាលនាំមកជាមួយនូវភារកិច្ចធំធេង…វាបញ្ជាក់អំពីក្តីសង្ឃឹមថ្មី លាយជាមួយជម្រើសពិបាកទទួលយកដែលប្រទេសជាច្រើនត្រូវតែជ្រើសយកនៅលើវិថីឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យនិងការរីកចម្រើនសេដ្ឋកិច្ច" ។

ទស្សនៈស៊ីជម្រៅបែបនេះកាន់តែក្លាយជាចំណុចចាប់អារម្មណ៍ក្នុងការពិភាក្សាវែកញែកអំពីវិធីដែលប្រទេសជាច្រើនអាចដោះស្រាយចំពោះអតីតកាលជិះជាន់តាមវិធីដែលល្អបំផុត ។ វាជាការគួរឲ្យអាណិត ដែលជាទូទៅអត្ថបទសិក្សានៅក្នុងផ្នែកនេះខ្វះខាតការយល់ដឹងលម្អិតអំពីលក្ខន្តិកៈច្បាប់នៅពេលក្រោយ ។ ប៉ុន្តែមានសញ្ញាដែលពោរពេញទៅដោយក្តីសង្ឃឹមជាច្រើន ។ សៀវភៅរបស់សាស្ត្រាចារ្យ រុធី តេតែល ដែលមានចំណងជើងថា"យុត្តិធម៌សម័យអន្តរកាល" ដែលបោះពុម្ពដោយសកលវិទ្យាល័យអក់ស៊ហ្វត ជាការព្យាយាមទីមួយហើយដែលសាស្ត្រាចារ្យកាន់ដឹរ អាស្មាល់ ផ្សារភ្ជាប់ភារកិច្ចជាក់ស្តែងនឹងទ្រឹស្តីនៃស្ថានការណ៍នៅក្នុងសម័យអន្តរកាលទៅនឹងការពិភាក្សាវែកញែកយូរអង្វែង ។ សាស្ត្រាចារ្យ តេតែល ប្រឈមមុខទៅនឹងការពិតដែលថាច្បាប់មានលក្ខណៈនិងតួនាទីប្លែកមួយនៅក្នុងស្ថានការណ៍នៃបំលាស់ប្តូរនយោបាយដ៏គំហុក ដែលបទបញ្ញត្តិច្បាប់ត្រូវតែមានអត្ថន័យមួយប្លែកនៅក្នុងកាលៈទេសៈបែបនោះ ។ គាត់បានទាញហេតុផលយ៉ាងត្រឹមត្រូវថា យើងមិនអាចយកច្បាប់ដែលប្រើប្រាស់នៅក្នុងសង្គមដែលមានភាពនឹងនទៅហើយមកប្រើប្រាស់ដោយគ្មានការពិចារណានៅក្នុងបរិបទខុសគ្នា និងពោរពេញទៅដោយភាពតានតឹងនៃយុត្តិធម៌សម័យអន្តរកាលបានទេ ។ ជំនួសវិញគាត់បានកត់សម្គាល់អំពីអ្វីដែលគាត់ដាក់ឈ្មោះថា "ទស្សនាទានច្បាប់សម័យអន្តរកាល" ពឹងផ្អែកទៅលើការសង្កេតឃើញដែលថា "បទបញ្ញត្តិច្បាប់សម័យអន្តរកាលជាបណ្តុំនៃតម្លៃសង្គមខុសៗគ្នានៅក្នុងសម័យអន្តរកាល" ។

គាត់បានកត់សម្គាល់ថា នៅក្នុងន័យនេះកេរដំណែលរបស់តុលាការនូរឹមបឺក ដែលជាការបង្ហាញជាសាធារណៈនូវការកាត់ទោសជនដៃដល់ គឺជា"ឧទាហរណ៍ប្លែកពីធម្មតា" ត្រូវបានកោតសរសើរក្នុងន័យនៃការល្មើសច្បាប់ជាជាងការគោរពតាមនិងបង្ខំឲ្យប្រតិបត្តិសិទ្ធិមនុស្សនៅពេលក្រោយ ។ តុលាការនូរឹមបឺកបានជំរុញឲ្យយើងរួមបញ្ចូលយុត្តិធម៌ជាមួយនឹងការកាត់ទោសតាមបែបព្រហ្មទណ្ឌ ប៉ុន្តែការអនុវត្តជាក់ស្តែងនូវយុត្តិធម៌សម័យអន្តរកាល មានភាពប្លែកពីរដ្ឋមួយទៅមួយ ។ ទោះជាទ្រឹស្តីទស្សនាទានច្បាប់របស់សាស្ត្រាចារ្យ តេតែល មានគុណសម្បត្តិយ៉ាងដូចម្តេចក៏ដោយ ក៏សៀវភៅរបស់គាត់គឺជាសញ្ញាដ៏មានក្តី

សង្ខេបថា ជម្រៅនៃទ្រឹស្តីនៃការសិក្សាអំពីយុត្តិធម៌សម័យអន្តរកាលនៅទីបំផុតកំពុងតែកើនឡើងហើយ ។ សាស្ត្រាចារ្យ កាន់ដឹរ អាស្មាល់ គិតថា នៅទីបំផុតយើងកំពុងតែធ្វើដំណើរចាកចេញពីការបែងចែកដាច់ណាត់រវាងល្អនិងអាក្រក់ហើយ ។

លើសពីនេះ គាត់គិតថានៅក្នុងករណីខ្លះ តេតែល មិនបានកំណត់ឲ្យបានច្បាស់លាស់នូវការទាញហេតុផលស៊ីជម្រៅរបស់មេធាវីផ្នែកច្បាប់នោះទេ ជាហេតុនាំគាត់កំណត់រូបភាពនៃវិធានច្បាប់មួយដែលមិនសូវបត់បែននៅក្នុងមជ្ឈដ្ឋាន“ធម្មតា” ឬមិននៅក្នុងសម័យអន្តរកាល ។ ជាក់ស្តែងគាត់បានលើកឡើងថាការផ្លាស់ប្តូររូបរាងរបស់យុត្តិធម៌ក្នុងសម័យអន្តរកាល នាំមកនូវទម្លាប់មិនសមរម្យមួយនៃ“ការកាត់សេចក្តីដើម្បីផលប្រយោជន៍នយោបាយ”ដែលអ្នកទ្រឹស្តីបែបរិះគន់គាំទ្រទៅវិញ ។ សាស្ត្រាចារ្យ តេតែល ផ្តល់យោបលថា នៅក្នុងស្ថានការណ៍មិនអន្តរកាលការទាញហេតុផលរបស់អ្នកទ្រឹស្តីបែបរិះគន់ អំពីសារជាតិនៃច្បាប់ដែលបម្រើផលប្រយោជន៍នយោបាយច្រើនពេក គឺមិនសូវទទួលបានលទ្ធផលប៉ុន្មានទេ ។ សាស្ត្រាចារ្យ កាន់ដឹរ អាស្មាល់ខ្លួនឯងចាត់ទុកថាច្បាប់ជាទម្រង់មួយនៃនយោបាយមិនសូវបត់បែនដើម្បីឲ្យគាត់អាចមានភាពយុត្តិធម៌ចំពោះអ្នកទ្រឹស្តីបែបរិះគន់ក្នុងបរិបទយុត្តិធម៌មិនអន្តរកាលនៅក្នុងសម័យធម្មតា ។ ការបែកចេញពីគំនិតស៊ីជម្រៅដ៏មានប្រយោជន៍អំពីការសិក្សាផ្នែកច្បាប់បែបរិះគន់បានក្លាយទៅជាបញ្ហាដ៏ជាក់លាក់មួយ នៅក្នុងសេចក្តីបញ្ចប់នៃសៀវភៅរបស់គាត់សាស្ត្រាចារ្យ តេតែល បានទាញហេតុផលថា “វិភាគទានមួយបែបថ្មីរបស់ច្បាប់សម័យអន្តរកាលចំពោះ “បំលាស់ប្តូរនយោបាយ”គឺថា វាត្រូវទប់ស្កាត់ដោយក្របខ័ណ្ឌនយោបាយនិងនៅក្រៅក្របខណ្ឌនយោបាយ” ។ គំនិតដែលថាច្បាប់ទោះនៅក្នុងមជ្ឈដ្ឋានធម្មតាឬអន្តរកាលរួមចំណែកនៅក្នុង“ការនៅក្រៅក្របខ័ណ្ឌ”នយោបាយក្តី ត្រូវតែផ្តល់ឲ្យយើងនូវការផ្អាកមួយរយៈបន្ទាប់ពីឆ្លងកាត់អស់រយៈពេលមួយសតវត្សរ៍នៃភាពប្រាកដនិយមផ្នែកច្បាប់ ។

តាមការពិត គណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាអាចដោះស្រាយចំពោះភាពអយុត្តិធម៌ទូទៅនិងទាំងមូល ។ ជាក់ស្តែង គណៈកម្មការនេះបានអនុវត្តការកាត់ទោសអំពីផ្នែកដែលខុសនៅក្នុងសង្គមស៊ីវិល ដូចជាការងារពេទ្យ ការងារច្បាប់ ការងារអាជីវកម្ម និងប្រព័ន្ធតុលាការ ។ ប៉ុន្តែម្តងម្កាលគណៈកម្មការនេះហាក់ដូចជាស្ទាក់ស្ទើរមិនហ៊ានផ្សងព្រេងឲ្យហួសពីបទឧក្រិដ្ឋស៊ីវិលនិងនយោបាយដែលមានស្រាប់ (ពិសេសទាក់ទងទៅនឹងការស៊ើបអង្កេតទៅលើសហគមន៍អាជីវកម្ម) ហើយការផ្សព្វផ្សាយតាមប្រព័ន្ធសារព័ត៌មានរបស់គណៈកម្មការនេះបានផ្តោតការយកចិត្តទុកដាក់មិនសមាមាត្រទៅលើទង្វើព្រៃផ្សៃរបស់ជនដែលទទួលបានការអត់ឱនទោសផ្នែកច្បាប់ ។ នេះគឺជាកំហុសរបស់អ្នកបម្រើការក្នុងគណៈកម្មការនិងយន្តការទំនាក់ទំនងសាធារណៈរបស់គណៈកម្មការនេះ (ជាជាងច្បាប់រៀបរាប់ខាងលើ) ដែលអនុម័តដោយសភា ។ នេះមិនដើម្បីផ្តល់ជាយោបល់ថាច្បាប់មិនមានចន្លោះប្រហោងនោះទេ ។ ដោយសារមានតែអ្នកដែលមានការភិតភ័យចំពោះការកាត់ទោសក្នុងតុលាការព្រហ្មទណ្ឌនៅក្រោមច្បាប់របស់របបអាប៉ាថេតចាស់ទាមទារការលើកលែងទោស ដែលជាលទ្ធផលប្រចាំថ្ងៃរបស់របបអាប៉ាថេតដែលមិនមែនជាការល្មើសច្បាប់នៅក្រោមច្បាប់ចាស់មិនឋិតនៅក្នុងក្របខ័ណ្ឌលើកលែងទោសទេ ទោះជាទង្វើនេះធ្លាក់នៅក្នុងដែននៃច្បាប់ក៏ដោយ ។ វាអាចផ្តល់ហេតុផលថាជំហានទីមួយនៅក្នុងដំណើរការទាមទារយុត្តិធម៌នៅក្នុងសម័យអន្តរកាលគួរតែជាការឲ្យសច្ចាប័នទៅអនុសញ្ញាឆ្នាំ១៩៧៣ស្តីអំពី “ការទប់ស្កាត់អំពើឧក្រិដ្ឋកម្មនៅក្នុងរបបអាប៉ាថេត” ដែលប្រកាសឲ្យចូលជាធរមានដើម្បីកាត់ទោសចំពោះការរើសអើងពូជសាសន៍នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងស្រុករបស់ខ្លួន ។

ការណ៍នេះបានទទួលស្គាល់ថា ច្បាប់អន្តរជាតិជាបង្អែកផ្នែកច្បាប់សម្រាប់ការកាត់ទោសបទឧក្រិដ្ឋព្រហ្មទណ្ឌនាពេលក្រោយ ទោះជានៅក្នុងករណីអវត្តមាននៃការហាមប្រាមតាមបែបព្រហ្មទណ្ឌពាក់ព័ន្ធនៅក្រោមច្បាប់ព្រហ្មទណ្ឌរបស់របបមុនក៏ដោយ ។ ដូច្នេះសំណួរគឺមិនមែនការខ្វះខាតមូលដ្ឋានច្បាប់សម្រាប់ការកាត់ទោសទេ ប៉ុន្តែថាតើការកាត់ទោសនៅក្នុងខណៈនេះអាចនឹងជំរុញឲ្យមានការផ្តល់យុត្តិធម៌នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូងឬទេ?

នៅពេលដែលសញ្ញាណហាក់ប្រាកដប្រជានៃយុត្តិធម៌

សម័យអន្តរកាលកំពុងតែរីកចម្រើនយ៉ាងឆាប់រហ័សនៅក្នុងប្រព័ន្ធនយោបាយជាតិ សញ្ញាណដែលអូសទាញដោយការដាក់ទណ្ឌកម្មដើម្បីយុត្តិធម៌ ហាក់ឋិតនៅជាគោលគំនិតនៅក្នុងមជ្ឈដ្ឋានអន្តរជាតិ ។ រូទី តេតែល ពន្យល់ថា ទោះជាមានសញ្ញាបញ្ជាក់អំពីការកកើតថ្មី ដូចជាការរំកិលទៅរកការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ក៏«យុត្តិកម្មប្រវត្តិសាស្ត្រដើម្បីរាប់បញ្ចូលយុត្តិធម៌អ្នកស្នងទៅក្នុងក្របខ័ណ្ឌអន្តរជាតិត្រូវរសាយដែរ ។ ក្តីសង្ឃឹមក្រោយសង្គ្រាមសម្រាប់បង្កើតច្បាប់ព្រហ្មទណ្ឌអន្តរជាតិបច្ចុប្បន្ននៅតែមិនទាន់ត្រូវបានបំពេញ ។ សេចក្តីសាទរពីដំបូងសម្រាប់ការរីកចម្រើននៃច្បាប់អន្តរជាតិ ឥឡូវនេះត្រូវបាត់បង់ដោយកង្វះប្រសិទ្ធភាពរបស់យន្តការអន្តរជាតិក្នុងការឆ្លើយតបទៅនឹងអំពើឃោរឃៅ» ។

ការពិភាក្សាវែកញែកអំពីថាតើការរត់ពន្ធគ្រឿងញៀនអន្តរជាតិគួរត្រូវបញ្ចូលឬអត់ មិនចាំបាច់យកមកពិភាក្សានៅអាហ្វ្រិកខាងត្បូងទេ ពីព្រោះថាគណៈកម្មការស្វែងរកការពិតមិនមែនបង្កើតឡើងដើម្បីដោះស្រាយបទឧក្រិដ្ឋបែបនោះឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ទស្សនវិស័យចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ និងចំពោះកិច្ចការដែលតុលាការនេះអាចធ្វើ គឺជាមធ្យោបាយដ៏មានប្រយោជន៍មួយដើម្បីលើកឡើងថាតើយុត្តិធម៌សម័យអន្តរកាល ច្បាប់អន្តរជាតិ និងយុត្តិធម៌អន្តរជាតិមានអត្ថន័យដូចម្តេចចំពោះអាហ្វ្រិកខាងត្បូង ។ ទី១) អាហ្វ្រិកខាងត្បូងគួរតែឋិតនៅក្នុងពិភពនៃការពិភាក្សាវែកញែកហើយមិនធ្វើតាមទំនើងចិត្តដែលអំណាចអនុញ្ញាតឲ្យធ្វើនោះទេ ។ ស្ថាប័នអន្តរជាតិត្រូវក្លាយជាវេទិកាសម្រាប់ការពិភាក្សាពិតប្រាកដ មិនមែនការយល់ព្រមដោយបង្ខំពីអ្នកកាន់អំណាចនិងការលួចបន្លំសន្លឹកឆ្នោតនោះទេ ។ នេះជាយន្តការដែលរដ្ឋាភិបាលលោក ឌី ខ្លឹត បានព្យាយាមហើយបរាជ័យក្នុងការបញ្ចូលទៅក្នុងនយោបាយជាតិរបស់ប្រទេសអាហ្វ្រិកខាងត្បូង ។

ប្រសិនបើអាហ្វ្រិកខាងត្បូងមិនបានចាប់អារម្មណ៍នឹងចំណុចនេះ អំពីផលប៉ះពាល់របស់ស្ថាប័នអន្តរជាតិទៅលើវិធីដែលពិភពលោកពិចារណាថាតើអំពើអយុត្តិធម៌ណាត្រូវយកមកកាត់សេចក្តីនោះទេ ដំណើរការនៅក្នុងសម័យអន្តរកាលនឹងត្រូវបានផ្សារភ្ជាប់ទៅនឹងបទដ្ឋានអន្តរជាតិហើយមិនមែនជាការបង្កើតរបស់យើង ។ ចំណុចនេះអាចត្រូវបានពន្យល់ភ្ជាប់ជាមួយដំណើរការរបស់គណៈកម្មការស្វែងរកការពិតក្នុងស្រុករបស់ប្រទេសអាហ្វ្រិកខាងត្បូង ។ ដូចដែលសាស្ត្រាចារ្យ កាន់ដឺរ អាស្មាល់ បានផ្តល់យោបល់មកទល់បច្ចុប្បន្នការពិភាក្សាជាអន្តរជាតិអំពីយុត្តិធម៌សម័យអន្តរកាលមានភាពសាមញ្ញក្នុងផ្នែកទ្រឹស្តី ។ នោះគឺជាការប្រើប្រាស់ជម្លោះនៅក្នុងប្រទេសផ្សេងទៀត(គួរឲ្យកត់សម្គាល់គឺ«សង្គ្រាមកខ្វក់»នៅអាមេរិកឡាទីន) ដើម្បីសន្និដ្ឋានថា ដោយសារមានការរំលោភបំពានភាគីទាំងសងខាងនៅក្នុងជម្លោះទាំងនេះច្បាស់ជាមានភាពស្រដៀងជាមួយប្រទេសណាមួយហើយ ។

**(នៅមានត)**

**ថ្លង សុភារិទ្ធ**

# ពាក្យស្លោកខ្មែរក្រហម

- កម្មាភិបាលល្អ និងគណៈកម្មាធិការល្អ គឺស្ទុះស្ទាញដោះស្រាយ និងលើកស្ទួយជីវភាពមហាជនបានល្អ គ្រប់ផ្នែក និង គ្រប់ពេលវេលា ដោយគោលជំហរទទួលខុសត្រូវ និងច្នៃប្រឌិតគំនិតផ្តើមខ្ពស់។
- វាយសម្រុកថែបំប៉ន ជីវភាពប្រជាជនឱ្យបានល្អ និងកើនចម្រើនឡើងឆាប់រហ័សជានិច្ច ទៅព្រមនិងបំពាក់បំប៉នជាមូលដ្ឋានខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង។
- ក្តាប់ជាប់ និងអនុវត្តឱ្យល្អ ផែនការបង្កើនចំនួនប្រជាជន និងឱ្យបានច្រើនជាអតិបរិមាពី១៥–២០លាននាក់ក្នុង១០–១៥ឆ្នាំខាងមុខនេះ។
- សមរភូមិមុខ ជាតំណាងដ៏ឆ្នើមនៃមោទនភាពបដិវត្តន៍របស់ប្រជាជាតិនិងប្រជាជនកម្ពុជាទាំងមូល។
- ឈរជាប់ខាតនិងគ្រប់កាលៈទេសៈ លើជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន កាន់កាប់វាសនាខ្លួនដោយខ្លួនឯង។

(សៀវភៅកំណត់ហេតុលេខ ០៧៦)

# ខ្ញុំមិនដែលស្គាល់ភាពអត់ឃ្លានដូចម្ដាយខ្ញុំទេ

ជារៀងរាល់ឆ្នាំនៅថ្ងៃបុណ្យកាន់បិណ្ឌចូលមកដល់ ក្រុមគ្រួសាររបស់ខ្ញុំបាននាំគ្នារៀបចំចង្ហាន់ជាច្រើនមានដូចជាបាយសម្ល បង្អែមផ្លែឈើ នំនែកនិងទៀនធូបយកទៅវត្តដើម្បីប្រគេនដល់ព្រះសង្ឃដែលគង់នៅតាមទីវត្តអារាម ។ ម៉ាក់តែងតែប្រាប់ខ្ញុំជារឿយៗថា ការយកម្ហូបអាហារទៅវត្តដើម្បីឧទ្ទិសកុសលទៅដល់ជីដូនជីតា ហើយនិងសាច់ញាតិបងប្អូនរបស់គាត់ ដែលបានស្លាប់បាត់បង់ជីវិតនាសម័យ ប៉ុល ពត ជាពិសេសឧទ្ទិសជូនទៅដល់លោកឪពុកនិងបងប្រុសរបស់ម៉ាក់ ។ ម៉ាក់បាននិយាយដដែលៗថាការសម្លាប់ដ៏ព្រៃផ្សៃមកលើគ្រួសាររបស់ម៉ាក់ដិតជាប់ក្នុងអារម្មណ៍របស់គាត់ជានិច្ច ដែលមិនអាចបំភ្លេចបាន ។ ម៉ាក់បានរៀបរាប់ប្រាប់ខ្ញុំនូវរឿងរ៉ាវអតីតកាលដូរចត់និងពីភាពលំបាកវេទនាដែលនារីដូចរូបគាត់បានជួបប្រទះកាលពីសម័យខ្មែរក្រហម ។

ម៉ាក់របស់ខ្ញុំជាកូនទីបីក្នុងចំណោមបងប្អូន៦នាក់ ។ ស្រុកកំណើតរបស់ម៉ាក់ នៅឃុំកំពង់ចក ស្រុករំដួល ខេត្តស្វាយរៀង ។ ឪពុកម្ដាយរបស់ម៉ាក់ជាមន្ត្រីរាជការ ។ មុនឆ្នាំ១៩៧០ ជីតាខ្ញុំធ្វើគ្រូបង្រៀននៅឃុំកំពង់ចក ស្រុករំដួល ខេត្តស្វាយរៀង ។ ក្រោយឆ្នាំ១៩៧០ ជីតាខ្ញុំបានមកធ្វើទាហាននៅភ្នំពេញ ខណៈនោះក្រុមគ្រួសារម៉ាក់ក៏បានមករស់នៅភ្នំពេញទាំងអស់គ្នា ។ ក្រុមគ្រួសាររបស់ម៉ាក់មានជីវភាពរស់នៅធូរធាររមធ្យម ។

ម៉ាក់បានប្រាប់ខ្ញុំថានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញឲ្យទៅនៅតាមទីជនបទស្រុកស្រែចម្ការ ។ ក្រុមគ្រួសាររបស់ម៉ាក់ ក៏ត្រូវជម្លៀសចេញពីផ្ទះនៅម៉ោងប្រហែល២រសៀលដោយធ្វើដំណើរទៅតាមផ្លូវជាតិលេខ១ ។ ជីតារបស់ខ្ញុំស្ពាយអីវ៉ាន់ដៃម្ខាង និងដៃម្ខាងទៀតដឹកដៃពូរបស់ខ្ញុំដែលមានអាយុ៥ឬ៦ឆ្នាំ ។ ចំណែកជីដូនខ្ញុំនិងម៉ាក់វែកជង់ទូលជង ។ ធ្វើដំណើរទៅមុខបានឆ្ងាយបន្តិចជីតារបស់ខ្ញុំត្រូវខ្មែរក្រហមចាប់ដោយចោទថាគាត់ជាទាហាន លន់ណុល ។ ជីដូនខ្ញុំ ម៉ាក់ និងបងប្អូនរបស់ម៉ាក់ បានបន្តដំណើរទៅមុខទៀត ។ ការធ្វើដំណើរដ៏វែងឆ្ងាយនិងការរង់ចាំដ៏អស់សង្ឃឹមបានបណ្ដាលឲ្យម៉ាក់ធ្លាក់ខ្លួនឈឺ ។ ក្រោយមកម៉ាក់បានដឹងតាមរយៈអ្នកធ្វើដំណើរជម្លៀសជាមួយគ្នាប្រាប់ថាជីតារបស់ខ្ញុំត្រូវខ្មែរក្រហមសម្លាប់ហើយ ។

បន្ទាប់ពីធ្វើដំណើរអស់រយៈពេលប្រមាណមួយខែក្រុមគ្រួសាររបស់ម៉ាក់បានមកដល់ស្រុករំដួល ឃុំកំពង់ចក ខេត្តស្វាយរៀង ដែលជាស្រុកកំណើត ។ ប្រជាជននៅទីនោះមិនសូវពេញចិត្តនឹងគ្រួសាររបស់ម៉ាក់ទេ ព្រោះម៉ាក់ត្រូវបានខ្មែរក្រហមចាត់ទុកថាជាប្រជាជនថ្មី ។ ម៉ាក់ត្រូវធ្វើការងារដូចជា ដឹកប្រឡាយ កាប់ដីនិងភ្ជួរស្រែ ។ ម៉ាក់មិនដែលបានហូបគ្រប់គ្រាន់ទេហូបតែបបររាវ



សារិន វីរៈ និងក្រុមគ្រួសារថតនៅឆ្នាំ១៩៩២

កក្កុកសម្រាកក៏មិនដែលបានគ្រប់គ្រាន់ដែរ ។ សមាជិកក្រុមគ្រួសាររបស់ម៉ាក់ត្រូវបំបែកចេញពីគ្នាទាំងអស់ ។

ម៉ាក់រស់នៅទីនោះបានរយៈពេលជិតពីរឆ្នាំ ខ្មែរក្រហមក៏ជម្លៀសគាត់ទៅខេត្តពោធិ៍សាត់ ។ ម៉ាក់បាននិយាយថា ពេលនោះខ្មែរក្រហមចង់យកគ្រួសារទាំងអស់ទៅសម្លាប់មិនដឹងជាមានមូលហេតុអ្វីទេ ។ បងប្រុសរបស់ម៉ាក់ឈ្មោះ ចាន់ ដុល្លា ត្រូវអង្គការហៅឲ្យទៅធ្វើការសហករណ៍ ហើយបានបាត់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ ។ ម៉ាក់និយាយបន្តថា រយៈពេលមួយឆ្នាំបន្ទាប់ពីការស្លាប់របស់បងប្រុសម៉ាក់ កម្មាភិបាលខ្មែរក្រហមម្នាក់បានប្រាប់ម៉ាក់និងយាយឲ្យរៀបចំខ្លួនទៅប្រមូលផលនៅសហករណ៍ជាមួយអ្នកភូមិពីរឬបីនាក់ទៀតនៅថ្ងៃស្អែក ។ ម៉ាក់និងយាយដឹងក្នុងចិត្តជាស្រេចថាពិតជាត្រូវខ្មែរក្រហមយកទៅសម្លាប់ ។ ម៉ាក់រន្ធត់ចិត្តយ៉ាងខ្លាំងនឹងសេចក្តីស្លាប់ដែលនឹងមកដល់ក្នុងពេលឆាប់ៗ ។ សំណាងល្អម៉ាក់និងយាយបានរួចជីវិតដោយសាររបបខ្មែរក្រហមត្រូវបានវាយបណ្តេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

ក្នុងខែមីនា ឆ្នាំ១៩៧៩ ជីដូន ម៉ាក់ និងប្អូនៗរបស់បានធ្វើដំណើរមកទីក្រុងភ្នំពេញវិញ ។ គាត់បានមកស្នាក់នៅផ្ទះចាស់ដដែលគឺនៅម្តុំបឹងទំពុន ។ ក្រុមគ្រួសាររបស់ម៉ាក់ចាប់ផ្តើមកសាងជីវិតថ្មីពីបាតដៃទទេ ដោយដួញដូរនិងដោះដូរស្បៀងអាហារនិងគ្រឿងឧបភោគដូចជាស្រូវអង្ករដូរជាមួយអំបិលប្រហុកជាដើម ។ រហូតមកដល់ឆ្នាំ១៩៨០ ទើបយាយរបស់ខ្ញុំមានដើមទុនគ្រប់គ្រាន់សម្រាប់ទិញតូបលក់ក្រណាត់នៅក្នុងផ្សារទួលទំពូង ហើយម៉ាក់ត្រូវទទួលបន្ទុកថែរក្សាប្អូនៗ មិនតែប៉ុណ្ណោះថែមទាំងជួយលក់ដូរជាមួយយាយរបស់ខ្ញុំថែមទៀត ។

ឆ្នាំ១៩៨០ ម៉ាក់បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងប៉ារបស់ខ្ញុំ ។ ម៉ាក់បានឆ្លងកាត់ឧបសគ្គជាច្រើន បើប្រៀបធៀបមករូបខ្ញុំដែលជាកូននៅសម័យនេះគឺខុសគ្នាឆ្ងាយណាស់ ។ រូបខ្ញុំកើតមកស្គាល់តែភាពសុខស្រួល មិនដែលស្គាល់ភាពអត់ឃ្លានធ្វើពលកម្មហួសកម្លាំងទេ ជាពិសេសនោះគឺបានរស់នៅជួបជុំគ្រួសារដឹកកក់ក្តៅមួយ ។ ម៉ាក់តែងតែបួងសួងជានិច្ចកាលកុំឲ្យមានរបបខ្មែរក្រហមកើតឡើងសាជាថ្មីម្តងទៀត ព្រោះគាត់មិនចង់ឲ្យកូនៗរបស់គាត់ជួបប្រទះនឹងទុក្ខវេទនាដូចជារូបគាត់ឡើយ ។

**សារិន ធីរ:**

# ដំណឹងសួររកកូនប្រុស

ខ្ញុំបាទឈ្មោះ អ៊ីង អៀង អាយុ៧៣ឆ្នាំ និងប្រពន្ធឈ្មោះ ហុង ង៉ែត អាយុ៦៧ឆ្នាំ ។ មានភូមិកំណើតនៅភូមិថ្កុល ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល សព្វថ្ងៃរស់នៅក្នុងភូមិឃុំដដែល ។ ខ្ញុំបាទមានកូនទាំងអស់៦នាក់ ក្នុងនោះកូនស្រី៤ប្រុស២នាក់ ឈ្មោះ គីម សុ(ស្រី) , គីម យន(ប្រុស) , គីម ហ៊ាង(ប្រុស) , មុំ (ស្រី) , គីម(ស្រី) , គីម ទាវ (ស្រី) ។

ខ្ញុំបាទសូមសួររកកូនប្រុសឈ្មោះ គីម ហ៊ាង កើតឆ្នាំឆ្លូវ បើគិតមកដល់បច្ចុប្បន្នមានអាយុប្រហែល៤៣ឆ្នាំហើយ ។ គីម ហ៊ាង ធ្លាប់បានរៀននៅសាលា កង ម៉ម ត្រឹមថ្នាក់ទី១១ ក្នុងឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល បានចេញពីផ្ទះទៅធ្វើបដិវត្តន៍នៅក្នុងឆ្នាំ១៩៧៤ កាលនោះគាត់មានអាយុប្រហែល១៤ឆ្នាំ ។

នៅឆ្នាំ១៩៧៧-១៩៧៨ ឈ្មោះ ឆែម និង ជ័រ ដែលជាអ្នកភូមិជាមួយគ្នានិងធ្លាប់ធ្វើជាកងទ័ពខ្មែរក្រហមបានជួប គីម ហ៊ាង ដែលកំពុងធ្វើការនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ។ កាលនោះ គីម គីម ហ៊ាង មានឈ្មោះហៅក្រៅថា ចិនក្រហម ។ បន្ទាប់ពីនោះមក ខ្ញុំមិនបានទទួលដំណឹងពីឈ្មោះ គីម ហ៊ាង ទៀតទេ ។

បើកូនប្រុសបានទទួលដំណឹង ឬអស់លោកណាបានស្គាល់ឈ្មោះ គីម ហ៊ាង នេះ សូមមេត្តាមកទាក់ទងខ្ញុំបាទ នៅក្នុងភូមិឃុំខាងលើ ឬមកមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទលេខ(៨៥៥) ២៣ ២១១ ៨៧៥ ទូរសារលេខ (៨៥៥) ២៣ ២១០ ៣៥៨ *Email: dccam@online.com.kh.* ដោយក្តីអនុគ្រោះ ។




ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់តម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication, *Searching for the Truth*. To contribute, please phone (855) 23 211 875 or Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the Truth*. Number 48, December 2003.**
**Funded by Norway, Sweden, Switzerland, the Netherlands, Canada and USA.**